# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

## បឋមភាគ

## ៤

រាជធានីភ្នំពេញ

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥៤៧

# អដ្ឋសាលិនី

## បឋមភាគ

## ៤

ព. ស.

**២៥៥៧**

រក្សាសិទ្ធិ

# អដ្ឋសាលិនី

## អដ្ឋកថាព្រះអភិធម្មបិដក

## (ឈ្មោះ ធម្មសង្គណី)

### បឋមភាគ ៤


រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែរៀបរៀងដោយខ្ញុំព្រះករុណាខ្ញុំបាទ សុន្ទរ៍-សារមៀន



ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥៥៧ គ. ស. ២០១៣

# សេចក្តីបញ្ជាក់

គម្ពីរ **អដ្ឋកថាព្រះអភិធម្ម** ជាពាក្យអធិប្បាយសេចក្តីក្នុងព្រះអភិ-ធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគ គឺ

**១.បឋមភាគ** ឈ្មោះ **អដ្ឋសាលិនី** អធិប្បាយគម្ពីរ ***ធម្មសង្គណី***

**២.ទុតិយភាគ** ឈ្មោះ **សម្មោហវិនោទនី** អធិប្បាយគម្ពីរ ***វិភង្គ***

**៣.តតិយភាគ** ឈ្មោះ **បរមត្ថទីបនី** អធិប្បាយគម្ពីរ ***បញ្ចបករណ៍***

តាំងពី ***ធាតុកថា*** រហូតដល់ចប់គម្ពីរ ***បដ្ឋាន*** ទាំងអស់ ។

បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ។ ឯសៀវភៅដែលលោកអ្នកកំពុងអាននេះ ជាគម្ពីរអដ្ឋ-កថា ***អភិធម្មបិដក បឋមភាគ ៤*** កើតឡើងដោយស្នាព្រះហស្តនៃ ***ព្រះពុទ្ធឃោសាចារ្យ*** ជាជនជាតិឥណ្ឌា បានរចនានៅឯប្រទេសសិរីលង្កា ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធជាង ៩០០ឆ្នាំ ។ ឯរូបខ្ញុំផ្ទាល់វិញ គ្រាន់តែជាអ្នកផ្តើមប្រែសម្រួលរៀបរៀង ជាបណ្តោះអាសន្ន សម្រាប់អ្នកដែលត្រូវការសិក្សារៀនសូត្រតែប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ខ្ញុំ***សូមបញ្ជាក់*** និងសូមទោសជាមុន ចំពោះអ្នកអាន និងអ្នកសិក្សាជាទីគោរពថា ខ្ញុំពុំមានសមត្ថភាពនៃការចេះដឹងគ្រប់គ្រាន់ ដូចសេចក្តីនៃធម៌ដែលមាននៅ

ក្នុងសៀវភៅនេះទេ ថែមទាំងសមត្ថភាពនៃការប្រែសម្រួល និងរៀបរៀង នេះទៀត មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ ការខុសឆ្គាំឆ្គង ទាំងនុ៎ះ មានដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ តែខ្ញុំយល់ ឃើញថា **មានប្រសើរជាងគ្មាន** ព្រោះគម្ពីរដែលរងនូវព្រះអភិធម្មបិដក បែបនេះ មិនធ្លាប់ដែលមានមកក្នុងប្រទេសយើងទេ ដូច្នេះ យើងក៏ អាចឧទាហរណ៍បានថា ៖

* សម័យណា ដែលមានភាពអន្ធការ សូម្បីតែពន្លឺអំពិលអំពែក ក៏ អាចភ្លឺបានដែរ ។

* សម័យណា គ្មានដើមឈើ គេក៏អាចយកដើមល្ហុង ធ្វើជាដើម ឈើបានដែរ ។ ល ។ (ស្រីហិតោបទេស) ។

ព្រោះហេតុដូច្នេះ ខ្ញុំសូមផ្ញើនូវគម្ពីរនេះ ដល់លោកអ្នកសិក្សា និង វិញ្ញូជនទាំងឡាយ ជួយកែសម្រួល សម្រាប់សិក្សាតរៀងទៅ ។ ដើម្បី សម្រួលដល់ការបូកសរុបមតិកែតម្រូវ ក្នុងអត្ថបទនេះ សូមមេត្តា ជ្រាបដូចតទៅ ៖

១-សូមសរសេរឈ្មោះ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំ ដែលកែ សម្រេចនៅលើក្រដាសដែលផ្ញើមក ។

២-ចុះលេខទំព័រ បន្ទាត់ ក្នុងតារាងលេខ ១ និងលេខ ២ ។ ចំពោះសេចក្តី ពាក្យ ឃ្លា ឬអក្ខរាវិរុទ្ធត្រង់ណា ដែលយល់ថា មិនទាន់ត្រឹមត្រូវ សូមសរសេរចុះក្នុងតារាងលេខ ៣ ។ ចំណែកពាក្យដែលយល់ថា គួរកែមកជាយ៉ាងណាវិញនោះ សូមសរសេរចុះក្នុងតារាងលេខ ៤ ។

៣-ប្រសិនបើ ការកែតម្រូវនោះ មានឯកសារបញ្ជាក់ សូមចុះឈ្មោះឯកសារនោះ ក្នុងតារាងលេខ ៥ ។

៤-នៅក្នុងតារាងលេខ ៦ សម្រាប់បញ្ជាក់បន្ថែម ចំពោះករណីពិសេសណា ដែលប្រាថ្នាចង់បញ្ជាក់បន្ថែម ។

៥-សូមផ្ញើកំណែមកខ្ញុំតាមរយៈគណៈកម្មការដែលមានអាសយដ្ឋានដូចនៅក្នុងអត្ថបទនេះស្រាប់ ។

* ប្រសិនបើ នៅក្នុងអត្ថបទនេះ មានការខុសទំព័រលេខរៀង អក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៣

ខ្ញុំព្រះករុណា ខ្ញុំបាទ **សុន្ទរ៍ សាមៀន**

សូមអរព្រះគុណ និងអរគុណ

# តារាងកែតម្រូវ

## នាមឈ្មោះអ្នកជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួល

-ព្រះមហា **រស់ សុភា** (ព្រះបាឡាត់នៃសម្តេចអគ្គមហាសង្ឃរាជ)

-ព្រះមហាសុវណ្ណបជ្ជោតោ **ភង ណាំ** (ចៅអធិការវត្តសំពៅមាស)

-ភិក្ខុវជិរប្បញ្ញោ **គូ សុភាព** (គណៈកម្មការបច្ចេកទេស នៃពុទ្ធិក-បណ្ឌិតសភា ក្នុងសាកលវិទ្យាល័យបញ្ញាសាស្ត្រនៃកម្ពុជា) ។

-សមណនិស្សិតខន្តិជាតិកោ **វ៉ៃ ភិរក្ស**

-ភិក្ខុសាមណេរជាពហុស្សុតក្នុង **វត្តនិរោធារាម**

-លោក **ស្ងួនឱសថ** (ក្រុមទ្រទ្រង់ព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ)

-ឧបាសក **វ៉ៃ គឹមហាវ** (គណកម្មការវត្តសុវណ្ណមាលីទន្លេបិទ)

-ឧបាសក **សំរ៉ុង ចំណោ** -ឧបាសក **វឿង សិរីសុគន្ធ**

-អ្នកគ្រូ **ធី សុធី** -ឧបាសក **ថូ៉ច សុខុម**

-លោកធម្មរក្ខិតោ **គង់ ស៊ីវន**។

## អ្នកមានឧបការៈក្នុងការងារធម្មទាននេះ

-លោកបញ្ញាបទីបោ**ព្រឿង ប៊ុនធឿន** -ភិក្ខុខន្តិជាតិកោ**វ៉ៃ ភិរក្ស**

-ឧបាសិកា **លី ស៊ីវម៉ូ** ជាដើម -ឧបាសិកា **ថុន ស៊ូគី** ជាដើម

-ភិក្ខុសាមណេរ **វត្តគិរីរម្យចាស់** ជាដើម ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសទ្ធានចិត្តដ៏ល្អរបស់គុណម្ចាស់ ញាតិញោមជាពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួល ព្រមទាំងចំណាយរូបិយវត្ថុជាដើម ដើម្បីជំរុញឲ្យអត្ថបទនៃគម្ពីរនេះ ចេញជារូបរាងឡើង ។

បន្ទាប់ពីបឋមភាគ ៤ នេះទៅ ខ្ញុំនឹងដំណើរការបោះពុម្ពនូវសៀវភៅធម៌ផ្សេងៗ ជាបន្តទៀត ។

អាស្រ័យហេតុនេះ សូមព្រះគុណម្ចាស់ ញាតិញោមទាំងក្នុង និងក្រៅប្រទេស មេត្តាជួយឧបត្ថម្ភ ដើម្បីបូជាធម៌ តាមកម្លាំងសទ្ធា ។

ម្យ៉ាងទៀត បើព្រះគុណម្ចាស់ ញាតិញោមត្រូវការចូលប្រាក់ ដើម្បីថតចម្លងជាធម្មទាន ឬយកផ្សាយផ្ទាល់ខ្លួន ឬក៏យកទៅតម្កល់តាមវត្តនានា សូមមេត្តាទាក់ទងតាមរយៈទូរសព្ទដូចខាងក្រោមនេះ ៖

០៩២ ៩០ ៨២ ៦៥

០៩៧ ២៣ ៣០ ២១៥

០១៦ ៤៦ ៥២ ៣៤

# ឧទ្ទិសកថា

ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង និងក្រៅប្រទេស, **អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន** រាជរដ្ឋាភិបាលដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស និងក្រៅប្រទេស មានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូមទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗ រូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។

**ដោយអំណាចនៃមហាកុសលជាធម្មទាននេះ សូមឱ្យ ៖**

*-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ*

*-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា*

*-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ*

*-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ៕*

**តារាងកែតម្រូវ**

ថ្ងៃទី ....... ខែ ..... ឆ្នាំ ...

**បឋមភាគ ៤**

ឈ្មោះ ..........................

សម្រាប់បោះពុម្ពបន្ត

អាសយដ្ឋាន ..................

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ឯកសារយោង | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |

# អដ្ឋសាលិនី អដ្ឋកថាព្រះអភិធម្មបិដក

# ឈ្មោះ ធម្មសង្គណី

# បឋមភាគ ៤

**មាតិកាធម៌** **ទំព័រ**

## អដ្ឋកថារូបវិភត្តិ


សម្តែងអំពីឯកនិទ្ទេស ..... ..... ..... ..... ..... ..... .... ១

សម្តែងអំពីវិធសព្ទ ..... ..... ..... ..... ..... ..... .... ... ៥

សម្តែងអំពីសង្គហសព្ទ ..... ..... ..... ..... ..... ..... ..... ៦


## អដ្ឋកថាទុកនិទ្ទេស


សម្តែងអំពីការចែកបទឱបាទា ..... ..... ..... ..... .... ... ៨

សម្តែងអំពីចក្ខាយតនៈ ..... ..... ..... ..... ..... ..... ... ៩

សម្តែងអំពីចក្ខាយតននិទ្ទេស ..... ..... ..... ..... .... ... ១៧

សម្តែងអំពីពាក្យថាសោតៈជាដើម ..... ..... ..... ..... ... ១៩

សម្តែងអំពីវាទៈរបស់អាចារ្យពួកខ្លះ ..... ..... ..... ..... ២៥

ភ្នែកប្រៀបដូចពស់ ..... ..... ..... ..... ..... .... .... ២៩

ត្រចៀកប្រៀបដូចក្រពើ ..... ..... ..... ..... ..... ..... .. ៣០
ច្រមុះប្រៀបដូចបក្សី ..... ..... ..... ..... ..... ..... ៣១
អណ្តាតប្រៀបដូចសុនខ (ឆ្កែ) ស្រុក ..... ..... ..... ....... ៣២
កាយប្រៀបដូចសុនខព្រៃ ..... ..... ..... ..... .... ..... ៣២
អដ្ឋកថារូបាយតននិទ្ទេស ..... ..... ..... ..... ..... ...... ៣៦
សម្តែងអំពីលក្ខណាទិចតុក្កៈរបស់រូប ..... ..... ..... ...... ៤០
អដ្ឋកថាសទ្ទាយតននិទ្ទេស ..... ..... ..... ..... ..... ..... ៤១
សម្តែងអំពីលក្ខណាទិចតុក្កៈរបស់សំឡេង ..... ..... ..... ..... ៤៣
អដ្ឋកថាគន្ធាយតននិទ្ទេស ..... ..... ..... ..... ..... .... ៤៣
សម្តែងអំពីលក្ខណាទិចតុក្កៈរបស់ក្លិន ..... ..... ..... ...... ៤៤
អដ្ឋកថារសាយតននិទ្ទេស ..... ..... ..... ..... .... ..... ៤៥
សម្តែងអំពីលក្ខណាទិចតុក្កៈរបស់រស ..... ..... .... .... .. ៤៦
អដ្ឋកថាឥត្ថិន្ទ្រិយនិទ្ទេស ..... ..... ..... ..... ..... ..... ៤៧
អដ្ឋកថាបុរិសិន្ទ្រិយនិទ្ទេស ..... ..... ..... ..... .... ..... ៤៩
សម្តែងអំពីឧភតោព្យញ្ជនកៈ ..... ..... ..... ..... ..... ... ៥១
អដ្ឋកថាជីវិតិន្ទ្រិយនិទ្ទេស ..... ..... ..... ..... ..... ..... ៥៣
អដ្ឋកថាកាយវិញ្ញត្តិនិទ្ទេស ..... ..... ..... ..... ..... .... ៥៤
អដ្ឋកថាវចីវិញ្ញត្តិនិទ្ទេស ..... ..... ..... ..... ..... ..... ៥៧

អដ្ឋកថាអាកាសធាតុនិទ្ទេស ..... ..... ..... ..... .... ... ៦០

អដ្ឋកថាឧបចយៈ និង សន្តតិនិទ្ទេស ..... ..... ..... ..... ៦៤

អដ្ឋកថាជរតានិទ្ទេស ..... ..... ..... ..... ..... ..... .. ៦៧

សម្តែងអំពីជរា ២ យ៉ាង ..... ..... ..... ..... ..... .... ៦៩

អដ្ឋកថាអនិច្ចតានិទ្ទេស ..... ..... ..... ..... ..... ..... ៧០

សម្តែងអំពីជាតិ ជរា មរណៈ ដូចបច្ចាមិត្រ ៣ នាក់ ..... ..... ៧២

អដ្ឋកថាកពឡិង្ការាហារនិទ្ទេស ..... ..... ..... ..... ..... ៧៣

សម្តែងអំពីអាហារគ្រោតគ្រាត និង ល្អិត ..... ..... ...... ៧៧

អដ្ឋកថានោឧបាទានិទ្ទេស ..... ..... ..... ..... ..... ... ៧៩

អដ្ឋកថាផោដ្ឋព្វាយតននិទ្ទេស ..... ..... ..... ..... ..... ៧៩

អដ្ឋកថាអាបោធាតុនិទ្ទេស ..... ..... ..... ..... ..... ... ៨៦

អដ្ឋកថាឧបាទិន្នាទិនិទ្ទេស ..... ..... ..... ..... ..... .... ៩០

អដ្ឋកថាចិត្តសមុដ្ឋាននិទ្ទេស ..... ..... ..... ..... ..... .. ៩២

អដ្ឋកថាចតុក្កនិទ្ទេស ..... ..... ..... ..... ..... ... .... ៩៣

អដ្ឋកថាបញ្ចកនិទ្ទេស ..... ..... ..... ..... ..... ..... .. ៩៤

អដ្ឋកថាឆក្កាទិនិទ្ទេស ..... ..... ..... ..... ..... ...... ៩៦

សម្តែងអំពីបកិណ្ណកកថា ..... ..... ..... ..... ..... .... ៩៨

សម្តែងអំពីសមុដ្ឋានរបស់រូប ..... ..... ..... ..... .... ..... ៩៩

# អធិប្បាយនិក្ខេបកណ្ឌ


សម្តែងអំពីកុសលត្តិកនិទ្ទេសទី ១ ..... ..... ..... ..... ... ១១០

សម្តែងអំពីអព្យាកតធម្មនិទ្ទេស ..... ..... ..... ..... .... ១១៤

សម្តែងអំពីវេទនាត្តិកនិទ្ទេសទី ២ ..... ..... ..... ..... ... ១១៥

សម្តែងអំពីវិបាកត្តិកនិទ្ទេសទី ៣ ..... ..... ..... ..... .... ១១៦

សម្តែងអំពីឧបាទិន្នត្តិកនិទ្ទេសទី ៤ ..... ..... ..... ..... .. ១១៦

សម្តែងអំពីវិតក្កនិទ្ទេសទី ៦ ជាដើម ..... ..... ..... ..... ១១៧

សម្តែងអំពីទស្សនត្តិកនិទ្ទេសទី ៨ ..... ..... .... ....... ១១៨

រឿងការមិនឃើញព្រះអរិយៈ ..... ..... ..... ..... ...... ១២៣

សម្តែងអំពីវិន័យ ២ យ៉ាង ..... ..... ..... ..... ...... .. ១២៤

សម្តែងអំពីសេចក្តីសង្ស័យ ..... ..... ..... ..... ..... ... ១៣១

សម្តែងអំពីទស្សនហេតុត្តិកនិទ្ទេសទី ៩ ..... ..... ..... ... ១៣៨

សម្តែងអំពីបរិត្តារម្មណត្តិកនិទ្ទេសទី ១៣ ..... ..... ..... ... ១៣៩

សម្តែងអំពីមិច្ឆត្តត្តិកនិទ្ទេសទី ១៥ ..... ..... ..... ....... ១៤០

សម្តែងអំពីមគ្គារម្មណត្តិកនិទ្ទេសទី ១៦ ..... ..... ..... .... ១៤១

សម្តែងអំពីឧប្បន្នត្តិកនិទ្ទេសទី ១៧ ..... ..... ..... ...... ១៤២

សម្តែងអំពីអតីតត្តិកនិទ្ទេសទី ១៨ ..... ..... ..... ........ ១៤៥

សម្តែងអំពីអជ្ឈត្តត្តិកនិទ្ទេសទី ២០ ..... ...... ..... ..... ១៤៦

សម្តែងអំពីហេតុគោច្ឆកៈ ..... ..... ..... ..... ..... ... ១៤៧
សម្តែងអំពីលោភនិទ្ទេស ..... ..... ..... ..... ..... ..... ១៤៩
សម្តែងអំពីទោសនិទ្ទេស ..... ..... ..... ..... ..... ... ១៦០
សម្តែងអំពីសង្ខតទុកនិទ្ទេស ..... ..... ..... ..... ..... .. ១៦២
សម្តែងអំពីវិញ្ញាយ្យទុកនិទ្ទេស ..... ..... ..... ..... ..... ១៦៣
សម្តែងអំពីអាសវទុកនិទ្ទេស ..... ..... ..... ..... ...... ១៦៥

## អធិប្បាយសញ្ញោជនឆក្កៈ

សម្តែងអំពីមាននិទ្ទេស .... ..... ..... ..... ..... ..... ១៧១
សម្តែងអំពីឥស្សានិទ្ទេស ..... ..... ..... ..... ..... ... ១៧៣
សម្តែងអំពីលក្ខណៈឥស្សា ២ យ៉ាង ..... ..... ..... ..... ១៧៥
សម្តែងអំពីមច្ឆរិយនិទ្ទេស ..... ..... ..... ..... ..... .... ១៧៦
សម្តែងអំពីគណ្ឋគោច្ឆក្កនិទ្ទេស ..... ..... ..... ..... .... ១៨៣

## អធិប្បាយនីវរណគោច្ឆកៈ

សម្តែងអំពីថីនមិទ្ធនិទ្ទេស .... ..... ..... ..... ..... ..... ១៨៤
សម្តែងអំពីមិទ្ធៈមិនមែនអកុសល ..... ..... ..... ..... ... ១៨៧
សម្តែងអំពីកុក្កុច្ចនិទ្ទេស .... ..... ..... ..... ..... ..... ១៩៩
សម្តែងអំពីធម៌ជានីវរណៈ និង សម្បយុត្តធម៌ ..... ..... .... ២០២

សម្តែងអំពីឧបាទានគោច្ឆកនិទ្ទេស ..... ..... ..... ...... ២០៣
សម្តែងអំពីកាមុបាទាននិទ្ទេស ..... ..... ..... ..... ..... ២០៥
សម្តែងអំពីទិដ្ឋុបាទាននិទ្ទេស ..... ..... ..... ..... ..... ២០៥
សម្តែងអំពីកិលេសគោច្ឆកៈ .... ..... ..... ..... ...... ២០៨
សម្តែងអំពីកាមាវចរនិទ្ទេសក្នុងបិដ្ឋិទុកៈ ...... ...... ...... ២១០
សម្តែងអំពីរូបាវចរធម្មនិទ្ទេស ...... ...... ..... ..... ..... ២១២
សម្តែងអំពីសរណទុកនិទ្ទេស (ទី ១៨) ..... ..... ..... .... ២១៣
សម្តែងអំពីវិជ្ជូបមទុកនិទ្ទេស ..... ..... ..... ..... ..... ៣១៣
សម្តែងអំពីពាលទុកនិទ្ទេស ..... ..... ..... ..... ...... ២១៦
សម្តែងអំពីតបនីយទុកនិទ្ទេស ..... ..... ..... ..... ..... ២១៦
សម្តែងអំពីអធិវចនទុកនិទ្ទេស ..... ..... ..... ...... .... ២១៧
សម្តែងអំពីនាមរូបទុកនិទ្ទេស ..... ..... ..... ..... ...... ២២២
សម្តែងអំពីឋានាឋានទុកនិទ្ទេស ..... ..... ..... ....... ២៣០
សម្តែងអំពីនិទ្ទេសនៃអាជ្ជវៈ និង មទ្ទវៈ ..... ..... ..... .... ២៣១
សម្តែងអំពីខន្តិទុកនិទ្ទេស ..... ..... ..... ..... ..... ..... ២៣១
សំដែងអំពីសោរច្ចទុកនិទ្ទេស ..... ..... ..... ..... ..... ២៣២
សម្តែងអំពីសាខល្យទុកនិទ្ទេស ..... ..... ..... ..... ..... ២៣៣
សម្តែងអំពីបដិសណ្ឋារទុកនិទ្ទេស ..... ..... ..... ..... .. ២៣៦

សម្ដែងអំពីឥន្ទ្រិយេសុ អគុត្តទ្វារតាទុកនិទ្ទេស ..... ..... ..... ២៤១
សម្ដែងអំពីភោជនេ អមត្តញ្ញុតានិទ្ទេស ..... ..... ..... .... ២៤៤
សម្ដែងអំពីឥន្ទ្រិយេសុ គុត្តទ្វារតាទុកនិទ្ទេស ..... ..... ...... ២៤៥
សម្ដែងអំពីភោជនេ មត្តញ្ញុតានិទ្ទេស ..... ..... ..... .... ២៤៧
ព្រាហ្មណ៍ល្មោភស៊ី ៥ នាក់ ..... ..... ..... ..... ...... ២៥១
អង្គ ១២ របស់ភិក្ខុអ្នកឆាន់អាហារ ..... ..... ..... ..... ២៥៣
ព្រះមហាសីវត្ថេរចាត់អង្គទុក ៨ ..... ..... ..... ..... .... ២៥៤
សម្ដែងអំពីមុដ្ឋស្សច្ចទុកៈ ..... ..... ..... ..... ..... .... ២៥៥
សម្ដែងអំពីភាវនាពលទុកៈ ..... ..... ..... ..... ..... ... ២៥៦
សម្ដែងអំពីទិដ្ឋិវិសុទ្ធិទុកនិទ្ទេស ..... ..... ..... ..... .... ២៥៧
សម្ដែងអំពីសង្វេគទុកនិទ្ទេស ..... ..... ..... ..... ..... ២៥៩
សម្ដែងអំពីអសន្តុដ្ឋតាកុសលធម្មទុកនិទ្ទេស ..... ..... ..... ២៥៩
សម្ដែងអំពីវិជ្ជាទុកនិទ្ទេស ..... ..... ..... ..... ..... .... ២៦២

## អដ្ឋកថាកណ្ឌវណ្ណនា

អធិប្បាយសេចក្ដីនៃពួកតិកៈ ..... ..... ..... ..... ..... ២៦៦
សម្ដែងអំពីបរិត្តារម្មណត្តិកៈ ..... ..... ..... ..... ..... .... ២៦៨

សម្ដែងអំពីធម៌មានអារម្មណ៍ជាមហគ្គតៈជាដើម ..... ..... .. ២៧០
សម្ដែងអំពីចតុត្ថជ្ឈាន ១២ យ៉ាង ..... ..... ..... ..... ... ២៧២
សម្ដែងអំពីមគ្គារម្មណត្តិកៈ ..... ..... ..... ..... ..... ... ២៧៩
សម្ដែងអំពីអតីតារម្មណត្តិកៈ ..... ..... ..... ..... ........ ២៨១
សម្ដែងអំពីចិត្តុប្បាទកាមាវចរកុសល ៨ ..... ..... ..... .... ២៨៤
សម្ដែងអំពីចិត្តុប្បាទជារូបាវចរចតុត្ថជ្ឈាន ..... ..... ..... .. ២៨៦
សម្ដែងអំពីបច្ចុប្បន្នកាល ៣ យ៉ាង ..... ..... ..... ..... ... ២៨៨
សម្ដែងអំពីអជ្ឈត្តត្តិកៈជាដើម ..... ..... ..... ..... ...... ២៩៤
សម្ដែងអំពីការចែកអារម្មណ៍របស់ចិត្តុប្បាទ ..... ..... ..... ២៩៧
សម្ដែងអំពីហេតុគោច្ឆកនិទ្ទេស ..... ..... ..... ..... .... ៣០៤
សម្ដែងអំពីនីវរណគោច្ឆកទុកៈ ..... ..... ..... ..... ..... ៣០៦
សម្ដែងអំពីកិលេសគោច្ឆកទុកៈ ..... ..... ..... ..... .... ៣០៨

**និគមកថា**

# អក្សរសង្ខេប

## ដែលប្រើក្នុងគម្ពីរអដ្ឋកថាព្រះអភិធម្ម បឋមភាគ ៤ នេះគឺ

| | |
|---|---|
| អភិ. | ព្រះអភិធម្មបិដក |
| អំ. ឯកក. | អង្គុត្តរនិកាយ ឯកកនិបាត |
| អំ. ចតុក្ក. | អង្គុត្តរនិកាយ ចតុក្កនិបាត |
| អំ. ឆក្ក. | អង្គុត្តរនិកាយ ឆក្កនិបាត |
| អំ. តិក. | អង្គុត្តរនិកាយ តិកនិបាត |
| ខុ. ឥតិ. | ខុទ្ទកនិកាយ ឥតិវុត្តកៈ |
| ខុ. ខុ. | ខុទ្ទកនិកាយ ខុទ្ទកបាឋៈ ឬខុទ្ទកនិកាយ ខុទ្ទកនិបាត |
| ខុ. ចូឡ. | ខុទ្ទកនិកាយ ចូឡបណ្ណាសកៈ ឬខុទ្ទកនិកាយ ចូឡនិទ្ទេស |
| ខុ. ជា. | ខុទ្ទកនិកាយ ជាតក |
| ខុ. ធ. | ខុទ្ទកនិកាយ ធម្មបទ |
| ខុ. បដិ. | ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ |
| ខុ. មហា. | ខុទ្ទកនិកាយ មហាវគ្គ |
| ទី. ម. | ទីឃនិកាយ មហាវគ្គ ឬទីឃនិកាយ មជ្ឈិមបណ្ណាសកៈ |
| ទី. សី. | ទីឃនិកាយ សីលក្ខន្ធវគ្គ |
| ប. សូ. | បបញ្ចសូទនី |
| ម. ឧ. | មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ |
| ម. ទី. | មនោរថទីបនី |
| មនោ. បូ. | មនោរថបូរណី |

| | |
|---|---|
| ម. ម. | មជ្ឈិមនិកាយ មហាវគ្គ |
| ម. មូ. | មជ្ឈិមនិកាយ មូលបណ្ណាសកៈ |
| វិនយ. | វិនយបិដក |
| វិសុទ្ធិ. | វិសុទ្ធិមគ្គបករណ៍ |
| សំ. ឧ. | សំយុត្តនិកាយ ឧបរិបណ្ណាសកៈ |
| សំ. ខ. | សំយុត្តនិកាយ ខន្ធវារវគ្គ |
| សំ. និ. | សំយុត្តនិកាយ ឬសំយុត្តនិកាយ សគាថវគ្គ |
| សារ. បកា. | សារត្ថប្បកាសិនី |
| សំ. ម. | សំយុត្តនិកាយ មហាវគ្គ ឬសំយុត្តនិកាយ មហាវារវគ្គ |
| សំ. មូ. | សំយុត្តនិកាយ មូលបណ្ណាសកៈ |
| សម្មោ. វិ. | សម្មោហវិនោទនី |
| សារ. សិ. | សារត្ថប្បកាសិនី |
| សុ. វិ. | សុមង្គលវិលាសិនី |
| សំ. ស. | សំយុត្តនិកាយ សឡាយតនវគ្គ |
| សំ. សឡា. | សំយុត្តនិកាយ សឡាយតនវគ្គ |
| សំ. សី. | សំយុត្តនិកាយ សីលក្ខន្ធវគ្គ ។ |

# អដ្ឋសាលិនី

# អដ្ឋកថាធម្មសង្គណី

## បឋមភាគ ៤

ព. ស. ២៥៥៣

# អដ្ឋសាលិនី អដ្ឋកថាព្រះអភិធម្មបិដក

# ឈ្មោះ ធម្មសង្គណី

## បឋមភាគ ៤

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៚**

## អដ្ឋកថារូបវិភត្តិ

### សម្តែងអំពីឯកនិទ្ទេស

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់មានបំណង នឹងចែកសេចក្តីនៃរូបវិភត្តិ (មាតិកា) នោះ ទើបទ្រង់ផ្តើមត្រាស់ពាក្យមានជាអាទិ៍ថា **“សព្វំ រូបំ ន ហេតុមេវ** = រូបទាំងអស់មិនមែនជាហេតុឡើយ” ។

**សួរថា** ក៏ក្នុងឯកនិទ្ទេសនេះ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់មិនបានធ្វើពាក្យសួរថា “រូបទាំងអស់នោះ មិនមែនជាហេតុ តើយ៉ាងណា ?” ។

ឆ្លើយថា ព្រោះមិនមានសេចក្តីផ្សេងគ្នា ។

ពិតមែន ក្នុងឯកនិទ្ទេសនេះក្នុងខដែលផ្សេងគ្នាយ៉ាងនេះថា រូបទាំងអស់មិនមែនជាហេតុខ្លះ, ជាហេតុខ្លះ ដូចរូបទុកៈជាដើម ដែលជាឧបាទាយរូបខ្លះ ជាអនុបាទាយរូបខ្លះ, ព្រោះហេតុដូច្នោះ ទើបព្រះអង្គទ្រង់មិនបានចែកពាក្យសួរទុក ។

បណ្តាពាក្យទាំងនោះ ពាក្យថា “សព្វំ = ទាំងអស់” បានដល់ ទាំងអស់ គឺ

មិនមានសល់; ពាក្យថា “**រូបំ** = រូប” ទ្រង់ពង្រីកសេចក្ដីដល់សាមញ្ញលក្ខណៈ ដែលសម្ដែងដល់សភាពនៃរូបត្រូវប្រែប្រួល ដោយវិរោធិបច្ច័យ (បច្ច័យជាសត្រូវនឹងគ្នា) មានភាពត្រជាក់ជាដើម ។

ពាក្យថា “**ន ហេតុមេវ** = មិនមែនហេតុមែនពិត” នេះ ទ្រង់ពង្រីកហេតុសេចក្ដីដល់ការបដិសេធហេតុទូទៅ ។ ក្នុងខថា “**រូបមិនមែនហេតុ**” នោះ ហេតុមាន ៤ យ៉ាង គឺ

**១-ហេតុហេតុ** ហេតុដែលជាមូល

**២-បច្ចយហេតុ** ហេតុដែលជាបច្ច័យ

**៣-ឧត្តមហេតុ** ហេតុដែលជាប្រធាន

**៤-សាធារណហេតុ** ហេតុទូទៅដល់សព្វសត្វ ។

បណ្ដាហេតុទាំង ៤ នោះ ហេតុនេះគឺ “**កុសលហេតុ ៣** បានដល់ អលោភៈ អទោសៈ និងអមោហៈ, អកុសលហេតុ ៣ និងអព្យាកតហេតុ ៣” [១] ឈ្មោះថា **ហេតុហេតុ** ។ ហេតុដែលត្រាស់ទុកក្នុងបាលីថា “ម្នាលភិក្ខុទាំងឡាយ មហាភូតរូប ៤ ពួកនេះជាហេតុ, មហាភូតរូប ៤ ពួកនេះ ជាបច្ច័យដើម្បីការបញ្ញត្តិរូបក្ខន្ធ” [២] នេះឈ្មោះថា **បច្ចយហេតុ** ។ ហេតុដែលត្រាស់ទុកថា កុសលធម៌ និងអកុសលធម៌

---

[១] អភិ.។

[២] ម. ឧ. / សំ. ឧ.។

ជាហេតុខ្ពស់បំផុត ក្នុងឋានៈនៃការឱ្យវិបាករបស់ខ្លួន, ឥដ្ឋារម្មណ៍ជាហេតុខ្ពស់បំផុតក្នុងឋានៈនៃកុសលវិបាក, អនិដ្ឋារម្មណ៍ជាហេតុខ្ពស់បំផុតក្នុងឋានៈនៃអកុសលវិបាក ដូចដែលត្រាស់ទុកថា "តថាគតរមែងដឹងច្បាស់តាមសេចក្តីពិតនូវផលនៃកម្មសមាទានដែលជា **អតីតៈ អនាគត និងបច្ចុប្បន្ន ដោយឋានៈ ដោយហេតុ**"[៣] ដូច្នេះឈ្មោះថា **ឧត្តមហេតុ**; ហេតុដែលត្រាស់ទុកថា "ខដែលថាអវិជ្ជានេះប៉ុណ្ណោះ ជាហេតុ អវិជ្ជានេះជាបច្ច័យដល់សង្ខារទាំងឡាយ, អវិជ្ជាជាហេតុទូទៅ សូម្បីដល់សង្ខារទាំងឡាយ, រមែងផ្សាយទៅកាន់ភាវៈជាបច្ច័យ" ដូចដែលត្រាស់ថា បឋវីរស អាបោរស ជាបច្ច័យដល់មធុរសខ្លះ ដល់អមធុរសខ្លះ យ៉ាងណា, អវិជ្ជាក៏ជាសាធារណប្បច្ច័យដល់សង្ខារដែលជាកុសលខ្លះ ជាអកុសលខ្លះ ក៏ដូច្នោះដែរ ឈ្មោះថា **សាធារណហេតុ** ។

ក៏ក្នុងទីនេះ ទ្រង់មានបំណងយក **ហេតុហេតុ** (ហេតុដែលជាមូល); ព្រះមានព្រះភាគទ្រង់កំណត់បដិសេធដល់ភាវៈនៃរូប ជាហេតុមានមកហើយក្នុងមាតិកាថា "**ហេតូ ធម្មា ន ហេតូ ធម្មា**"[៤] ដោយប្រការដូច្នេះ ទើបត្រាស់ថា "**រូបទាំងអស់ មិនមែនជាហេតុទេ**"; បណ្ឌិតគប្បីជ្រាបការពង្រីកសេចក្តីដល់ការបដិ-

---

[៣] ម. មូ. / ខុ. បដិ. / អភិ. ។

[៤] អភិ. ៧៨ ។

សេធ និងការមិនបដិសេធក្នុងបទទាំងអស់ដោយន័យនេះចុះ; ចំណែកវចនត្ថៈ គឺពាក្យកំណត់សេចក្ដីនៃបទទាំងពួង ខ្ញុំពោលទុកក្នុងការពណ៌នាបទមាតិកានុ៎ះឯង ។

ក៏ក្នុងពាក្យថា **“សប្បច្ចយមេវ** = ប្រព្រឹត្តទៅជាមួយបច្ច័យមែនពិត” នោះ បានដល់ មានកម្មជាសមុដ្ឋាន មានកម្មជាបច្ច័យដូចគ្នា; គប្បីជ្រាបសេចក្ដីនៃរូបនោះឯង ដោយអំណាចនៃបច្ច័យ ៤ តាមដែលពោលទុកយ៉ាងនេះថា “រូបដែលមានអាហារជាសមុដ្ឋានជាដើម មានអាហារជាដើម ជាបច្ច័យមែនពិត” ។ ពាក្យថា **“រូបមេវ** = ជារូបធម៌មែនពិត” បានដល់ ទ្រង់បដិសេធអរូបថាជារូប តាមដែលត្រាស់ទុកក្នុងមាតិកាថា “ **រូបិនោ ធម្មា អរូបិនោ ធម្មា** = ធម៌ដែលជារូប ធម៌ដែលមិនមែនជារូប”[៥] ។

ក្នុងពាក្យថា **“ឧប្បន្នំ ឆហិ វិញ្ញាណេហិ** = ជាបច្ចុប្បន្នធម៌ដែលវិញ្ញាណ ៦ គប្បីដឹង” គឺរូបនោះឯងកើតឡើងចំពោះមុខដែលវិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើមគប្បីដឹងបាន, តែការកំណត់ លោកសង្គ្រោះសំដៅយកចក្ខុវិញ្ញាណជាដើម; ពិតមែន ចក្ខុវិញ្ញាណជាដើមនោះ រមែងមិនដឹងអតីតៈ និងអនាគត, ចំណែកមនោវិញ្ញាណរមែងដឹងអតីតៈខ្លះ អនាគតខ្លះ ។ មនោវិញ្ញាណនោះ ប្រព្រឹត្តទៅហើយក៏ ឈ្មោះថា ធ្លាក់ទៅហើយក្នុងក្រសែដូចគ្នា ព្រោះធ្លាក់ចុះក្នុងក្រសែនៃវិញ្ញាណ ៥ ។

ម្យ៉ាងទៀត រូបធម៌ទាំងនោះ ឈ្មោះថា មិនទៀងមែនពិត ដោយអត្ថថា មាន

[៥] អភិ. ៧៨ ។

ហើយ ត្រឡប់ជាមិនមានវិញ; ឈ្មោះថា ដែលជរាគ្របសង្កត់ហើយយ៉ាងនោះ ព្រោះជាធម៌ដែលជរាគប្បីគ្របសង្កត់បាន ។ ម្យ៉ាងទៀត ព្រោះជរារមែងប្រាកដក្នុងរូបកាយ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា "ជាធម្មជាតិដែលត្រូវជរាគ្របសង្កត់ ដោយពិត" ដូច្នេះខ្លះ ៕

## **សម្តែងអំពីវិធសព្ទ**

ក៏វិធសព្ទក្នុងព្រះបាលីថា "**ឯវំ ឯកវិធេន រូបសង្គហោ** = សង្គ្រោះរូបមានប្រភេទមួយយ៉ាងនេះ" នេះ ប្រើក្នុងសេចក្តីសំដៅដល់ **មានះ សណ្ឋាន និង កោដ្ឋាសៈ** ។

ពិតមែន **មានះ** ឈ្មោះថា **វិធា** ដូចក្នុងប្រយោគមានជាអាទិ៍ថា "**សេយ្យោ-ហមស្មីតិ វិធា, សទិសោហមស្មីតិ វិធា** មានះថា យើងល្អជាងគេ, មានះថា យើងស្មើនឹងគេ"[៦] ដូច្នេះ; **សណ្ឋាន** ឈ្មោះថា **វិធា** ដូចក្នុងប្រយោគ មានជាអាទិ៍ថា "**កថំ វិធំ សីលវន្តំ វទន្តិ, កថំ វិធំ បញ្ញវន្តំ វទន្តិ** = បណ្ឌិតទាំងឡាយហៅមនុស្សមានសណ្ឋានយ៉ាងណាថា មានសីល, ហៅមនុស្សមានសណ្ឋានយ៉ាងណាថា មានបញ្ញា"[៧] ព្រោះបទថា "**កថំ វិធំ**" មានសេចក្តីដូចបទថា "**កថំ សណ្ឋិតំ**";

---

[៦] អភិ. ។

[៧] សំ. ស. / អភិ. ។

**កោដ្ឋាសៈ** ឈ្មោះថា **ខិធា** ដូចក្នុងប្រយោគមានជាអាទិ៍ថា “**ឯកខិរេធន ញ្ញាណ-ឆគ្គុ, ទុខិរេធន ញ្ញាណាឆគ្គុ**= ញ្ញាណវត្ថុប្រភេទ ១, ញ្ញាណវត្ថុប្រភេទ ២” [៨] ដូច្នេះ សូម្បីក្នុងអធិការនេះ ក៏ទ្រង់បំណងយកកោដ្ឋាសៈដែរ ៕

## សម្ដែងអំពីសង្គហសព្ទ

សូម្បីក្នុង**សង្គហ**សព្ទ ក៏មាន ៤ យ៉ាង ដោយអំណាចនៃជាតិសង្គហៈ, សញ្ជាតិសង្គហៈ, កិរិយាសង្គហៈ និងគណនសង្គហៈ ។

ក្នុងសង្គហៈទាំង ៤ នោះ សង្គហៈ គឺការសង្គ្រោះនេះថា “សូមក្សត្រទាំង-ពួងចូរមក, សូមព្រាហ្មណ៍ទាំងពួងចូរមក, សូមវេស្សៈទាំងពួងចូរមក, សូមសូទ្រៈទាំងពួងចូរមក” និងពាក្យថា “ម្នាលវិសាខៈ ធម៌ពួកនេះគឺ **សម្មាវាចា, សម្មា-កម្មន្តៈ, សម្មាអាជីវៈ** សង្គ្រោះចូលក្នុងសីលក្ខន្ធ” [៩] ឈ្មោះថា **ជាតិសង្គហៈ** ។

សង្គហៈ គឺការសង្គ្រោះនេះថា ពិតមែន ការសង្គ្រោះទាំងអស់នេះ បានដល់ការសង្គ្រោះជាពួកតែមួយជាមួយគ្នា ដូចក្នុងពាក្យដែលត្រាស់ថា “អ្នកមានជាតិជាមួយគ្នាចូរមក; ពួកអ្នកស្រុកកោសលទាំងអស់ចូរមក, ពួកអ្នកស្រុកមគធៈទាំងអស់ចូរមក, ពួកជាងឈើទាំងអស់ចូរមក” និងពាក្យថា “ម្នាលវិសាខៈ ធម៌ពួកនេះ គឺ

---

[៨] ម. ឧ. / សំ. ខ. ។

[៩] ម. មូ. ។

**សម្មាវាយាមៈ, សម្មាសតិ, សម្មាសមាធិ** សង្គ្រោះចូលក្នុងសមាធិខន្ធ” ដូច្នេះ ឈ្មោះថា **សញ្ញាតិសង្គហៈ** ។

សង្គហៈ គឺការសង្គ្រោះ ពិតមែន ក្នុងការសង្គ្រោះនេះ វត្ថុទាំងអស់ដល់ការសង្គ្រោះតែមួយជាមួយគ្នា ដោយឋានៈនៃសញ្ជាតិ គឺដោយទីនៅអាស្រ័យ ដូចក្នុងទីដែលលោកពោលថា “អ្នកកើតក្នុងទីជាមួយគ្នា របស់ទាក់ទងគ្នា ដោយជាតិក្នុងទីទាំងពួងចូរមក, នាយហត្ថាចារ្យទាំងពួងចូរមក, នាយអស្សាចារ្យទាំងពួងចូរមក, នាយរថទាំងពួងចូរមក” និងពាក្យថា “ម្នាលវិសាខៈ ធម៌ពួកនេះ គឺ **សម្មាទិដ្ឋិ, សម្មាសង្កប្បៈ** សង្គ្រោះចូលក្នុងបញ្ញាខន្ធ” [១០] ដូច្នេះ ឈ្មោះថា **កិរិយាសង្គហៈ**។ ព្រោះវត្ថុទាំងពួងនេះ ដល់ការសង្គ្រោះជាពួកជាមួយគ្នាដោយហេតុគឺការធ្វើរបស់ខ្លួន។

សង្គហៈ គឺការសង្គ្រោះ ដែលពោលទុកថា “ចក្ខាយតនៈដល់ការរាប់សង្គ្រោះចូលក្នុងខន្ធណា ? ចក្ខាយតនៈដល់ការរាប់សង្គ្រោះចូលក្នុងរូបក្ខន្ធ; បើចក្ខាយតនៈដល់ការរាប់សង្គ្រោះចូលក្នុងរូបក្ខន្ធសោត, ព្រោះហេតុនោះ លោកក៏ត្រូវពោលថា ‘ចក្ខាយតនៈរាប់បញ្ចូលក្នុងរូបក្ខន្ធ” [១១] ដូច្នេះ ឈ្មោះថា **គណនសង្គហៈ** ។ ក្នុងទីនេះ លោកមានបំណងយក **គណនសង្គហៈ**, ព្រោះការរាប់សង្គ្រោះនេះ លោកអធិ-

---

[១០] ម. មូ.។

[១១] អភិ.។

ប្បាយថា បានដល់ ការរាប់រូបដោយចំណែកមួយ ។ ក្នុងបទទាំងពួង ក៏មានន័យដូចគ្នានេះដែរ ៕

# អដ្ឋកថាឧទ្ទេសកនិទ្ទេស

## សម្តែងអំពីការចែកបទឧបាទា

ឥឡូវនេះ កាលទ្រង់សម្តែងចែកបទ ពាក្យសួរដែលទុកជាប្រធានបទដំបូង ព្រោះសភាពផ្សេងគ្នា ក្នុងការសង្គ្រោះរូបមានប្រភេទ ២ ជាដើម យ៉ាងនេះថា "**អត្ថិ រូបំ ឧបាទា, អត្ថិ រូបំ នោ ឧបាទា** = រូបជាឧបាទាក៏មាន, រូបដែលជាអនុបាទាក៏មាន" ដូច្នេះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា "**កតមន្តំ រូបំ ឧបាទា** = រូបជាអនុបាទានោះ តើដូចម្តេច" ។ ក្នុងព្រះបាលីនោះ រូបដែលឈ្មោះថា **ឧបាទា** ព្រោះអត្ថថា អាស្រ័យ = **ឧបាទិយតីតិ ឧបាទា**, អធិប្បាយថា ឧបាទាយរូបនេះ កាន់យកមហាភូតរូបយ៉ាងមាំហើយ មិនបញ្ចេញ (លែង) ទុក គឺរមែងអាស្រ័យមហាភូតរូបនោះហើយប្រព្រឹត្តទៅ ៕

## សម្តែងអំពីចក្ខាយតនៈ

ឥឡូវនេះ កាលបើនឹងសម្តែងរូបនោះដោយប្រភេទផ្សេងៗ ទើបត្រាស់

ពាក្យមានជាអាទិ៍ថា **“ចក្ខាយតនំ** = ចក្ខាយតនៈ” ។ លុះព្រះមានព្រះភាគទ្រង់លើកឧបាទាយរូប ២៣ យ៉ាង ឡើងសម្តែងដោយសង្ខេបហើយ កាលនឹងសម្តែងឧបាទាយរូបនោះនុ៎ះឯងដោយពិស្តារទៀត ទើបត្រាស់ថា **“កតមន្តំ រូបំ ចក្ខាយតនំ** = រូបដែលហៅថា ចក្ខាយតនៈនោះ តើដូចម្តេច ?” ជាដើម ។

ក្នុងពាក្យថា **ចក្ខាយតនៈ** នោះ ចក្ខុមាន ២ យ៉ាង គឺ **មំសចក្ខុ** និង **បញ្ញាចក្ខុ** ។

**ក្នុងមំសចក្ខុ** និង **បញ្ញាចក្ខុ**នោះ បញ្ញាចក្ខុមាន ៥ យ៉ាង គឺ

១-**ពុទ្ធចក្ខុ** ចក្ខុរបស់ព្រះពុទ្ធ

២-**សមន្តចក្ខុ** បានដល់សព្វញ្ញុតញ្ញាណ

៣-**ញាណចក្ខុ** កែវភ្នែកឃើញធម៌

៤-**ទិព្វចក្ខុ** ភ្នែកទិព្វ

៥-**ធម្មចក្ខុ** មគ្គខាងក្រោម ៣ ។

បណ្តាបញ្ញាចក្ខុទាំង ៥ នោះ ចក្ខុដែលត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ តថាគតបានត្រួតមើលលោកដោយពុទ្ធចក្ខុ ក៏បានឃើញពួកសត្វ អ្នកមានកិលេសដូចធូលីក្នុងកែវភ្នែកតិច ។ ល ។ អ្នកនឹងគប្បីប្រៀនប្រដៅឱ្យដឹងបានដោយលំបាកក៏មាន” [១២] នេះឈ្មោះថា **ពុទ្ធចក្ខុ** ។ ចក្ខុដែលត្រាស់ទុកថា “សព្វញ្ញុតញ្ញាណ

---

[១២] ម. មូ.។

ហៅថា សមន្តចក្ខុ”[១៣] នេះហៅថា **សមន្តចក្ខុ** ។ ចក្ខុដែលត្រាស់ទុកថា “ចក្ខុកើតឡើងហើយ, ញាណកើតឡើងហើយ”[១៤] នេះឈ្មោះថា **ញាណចក្ខុ** ។ ចក្ខុដែលត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញដោយទិព្វចក្ខុដ៏បរិសុទ្ធ”[១៥] នេះ ឈ្មោះថា **ទិព្វចក្ខុ** ។ ញាណ គឺមគ្គ ៣ ខាងក្រោមដែលត្រាស់ទុកថា “ធម្មចក្ខុប្រាសចាកធូលី ប្រាសចាកមន្ទិល រមែងកើតឡើងលើអាសនៈដែលអង្គុយនោះឯង”[១៦] នេះ ឈ្មោះថា **ធម្មចក្ខុ** ។ សូម្បីមំសចក្ខុក៏មាន ២ យ៉ាង គឺ

**១-សសម្ភារចក្ខុ** គ្រាប់ភ្នែកដែលមានចំណែកប្រកប

**២-បសាទចក្ខុ** បសាទ (ប្រស្រី) ភ្នែក ។

បណ្តាមំសចក្ខុទាំងពីរនោះ ដុំសាច់នេះតាំងនៅចំពោះក្នុងរន្ធភ្នែក ខាងក្រោមកំណត់ដោយឆ្អឹងរន្ធភ្នែក ខាងលើកំណត់ដោយឆ្អឹងថ្ងាស ខាងទាំងពីរកំណត់ដោយប្រឡង់ភ្នែក ខាងក្នុងកំណត់ដោយខួរក្នុងឆ្អឹង ខាងក្រៅកំណត់ដោយរោមភ្នែក, ពោលដោយសង្ខេប ចក្ខុនេះមានចំណែកប្រកប (សសម្ភារៈ) ១៤ គឺ **ធាតុ ៤, វណ្ណៈ, គន្ធៈ, រសៈ, ឱជៈ សម្ភវៈ** (កំណើត), **សណ្ឋាន, ជីវិត, ភាវៈ, កាយបសាទ**

---

[១៣] ខុ. ចូឡនិទ្ទេស ។

[១៤] ធម្មចក្កប្បវត្តនសូត្រ ។

[១៥] ម. មូ. ។

[១៦] ម. មូ. ។

**ចក្ខុបសាទ**" ពោលដោយពិស្តារ មានសសម្ភារៈ គឺចំណែកប្រកបដល់ ៤៤ យ៉ាង ដោយអំណាចនៃរូប ៤៤ ពួកនេះ គឺ រូបទាំង ១០ នេះ បានដល់ **ធាតុ ៤**, **វណ្ណៈ**, **គន្ធៈ**, **រសៈ**, **ឱជៈ**, **សណ្ឋាន** និង **សម្ភវៈ** ដែលអាស្រ័យធាតុ ៤ ហើយកើតឡើង អំពីសមុដ្ឋាន ៤ ទើបរួមជារូប ៤០, រូប ៤ កើតដោយកម្មជាសមុដ្ឋានតែម្យ៉ាង គឺ **ជីវិត**, **ភាវៈ**, **កាយបសាទ** និង **ចក្ខុបសាទ** ។

សត្វលោក (ពាលបុថុជ្ជន) ចាំ (សម្គាល់) ដុំសាច់បានថា "ជាភ្នែកពណ៌ស, ភ្នែកធំ, ភ្នែកបរិសុទ្ធ, ភ្នែកស្រលៀង" រមែងមិនចាំថាជាចក្ខុ, រមែងចាំនូវវត្ថុដោយសេចក្ដីថាជាចក្ខុ, ភ្នែកនោះជាដុំសាច់តាំងនៅចំពោះក្នុងរន្ធភ្នែកដែលសរសៃចងទុកខួរក្នុងឆ្អឹងខាងក្នុងជាពណ៌សក៏មាន, ជាពណ៌ខ្មៅក៏មាន, ជាពណ៌ក្រហម ក៏មាន, ជាបឋវីក៏មាន, ជាអាបោក៏មាន, ជាតេជោក៏មាន និងជាវាយោក៏មាន ។ ភ្នែកណាមានពណ៌ស ព្រោះច្រើនដោយស្លេស្ម៍, មានពណ៌ខ្មៅ ព្រោះច្រើនដោយទឹកប្រមាត់, មានពណ៌ក្រហម ព្រោះច្រើនដោយលោហិត, មានភាពរឹងកំព្រឹស ព្រោះច្រើនដោយបឋវី, មានទឹកភ្នែកហូរចេញ ព្រោះច្រើនដោយអាបោ, មានភាពស្ងួតក្រៀម ព្រោះច្រើនដោយតេជោ, មានការធ្មេចបើកៗ ព្រោះច្រើនដោយវាយោ; នេះឈ្មោះថា **សសម្ភារចក្ខុ** ។

ចំណែកបសាទរូបណាអាស្រ័យមហាភូតរូបទាំង ៤ នេះ នៅក្នុង**សសម្ភារ-ចក្ខុ**នេះ ជាប់ចំពោះក្នុង**សសម្ភារចក្ខុ**នេះ, រូបនេះឈ្មោះថា **ចក្ខុបសាទ**; ចក្ខុ-

បសាទពួកនេះ តាំងនៅជ្រៀតចូលរហូតដល់ក្រដាសភ្នែក ៧ ជាន់ ដូចប្រេងដែលជ្រាបចូលទៅក្នុងសំឡីគ ៧ ជាន់, ក្នុងរង្វង់ភ្នែក ដែលឃើញរូបដូចនឹងកន្លែងជាទីកើតនៃសិរីសណ្ឋានរបស់បុគ្គលទាំងឡាយ អ្នកឈរនៅត្រង់មុខចំកណ្ដាលនៃរង្វង់ភ្នែកពណ៌ខ្មៅព័ទ្ធព័ទ្ធដោយប្រឡង់ភ្នែក ពណ៌សនៃសសម្ភារចក្ខុនោះ មានឧបការៈ ដែលធាតុទាំង ៤ ឧបការៈដោយកិច្ចការឱ្យទ្រទ្រង់ទុក ឱ្យនៅសើម ឱ្យអប់ឧណ្ហ ឱ្យរំកិលរួចទៅមកបាន (សកម្មភាព) ប្រៀបដូចមេទំ ៤ នាក់ ធ្វើនាទីជាអ្នកចិញ្ចឹមថែរក្សា ឱ្យទ្រង់ផ្ចូត ឱ្យការប្រដាប់តាក់តែងព្រះអង្គ និងឱ្យនូវកិច្ចបក់ផ្លិតដូច្នោះ ដែលឧតុ ចិត្ត និងអាហារឧបត្ថម្ភហើយ ដែលអាយុ គឺជីវិតិន្ទ្រិយតាមអនុបាល ចោមរោមដោយគោចររូបមាន *វណ្ណៈ គន្ធៈ* និង *រសៈ*ជាដើម កាលបើពោលដោយប្រមាណនៃចក្ខុបសាទនេះ មានប្រមាណប៉ុនក្បាលចៃ ឱ្យសម្រេចការប្រព្រឹត្តទៅនៃវត្ថុ [១៧] និងទ្វាររបស់ចិត្តទាំងឡាយមានចក្ខុវិញ្ញាណជាដើម [១៨] តាំងនៅតាមការគួរ [១៩] សមដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្តពោលទុកថា ៖

**“យេន ចក្ខុបសាទេន រូបានិ សមនុបស្សតិ**
**បរិត្តំ សុខុមំ ឯតំ កាសិរសមូបមំ**

---

[១៧] វត្ថុសំដៅដល់ទីជាទីអាស្រ័យរបស់ចក្ខុវិញ្ញាណ ។

[១៨] គឺមានវិញ្ញាណ និងចក្ខុវិញ្ញាណជាដើម មានតទារម្មណ៍ជាទីបំផុត ។

[១៩] យោជនាថា តាមគួរដល់វត្ថុ និងទ្វារ ។

សត្វរមែងឃើញរូបទាំងឡាយដោយចក្ខុបសាទណា ចក្ខុបសាទនោះ តូច ល្អិត មានប្រមាណប៉ុនក្បាលចៃ”[២០] ។

ចក្ខុផង អាយតនៈនោះផង ព្រោះហេតុនោះ ទើបឈ្មោះថា ចក្ខាយតនៈ; សូម្បីក្នុងខថា **“យំ ចក្ខុ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ** = ចក្ខុណាជាបសាទរូបអាស្រ័យមហាភូតរូប ៤” នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថថា ការប្រកប (ទុតិយាវិភត្តិ), អធិប្បាយថា បសាទរូបអាស្រ័យមហាភូតរូប ៤ ហើយប្រព្រឹត្តទៅ។ ដោយបទនេះ លោកកាន់យកចក្ខុបសាទប៉ុណ្ណោះ, បដិសេធចក្ខុដ៏សេស ។

ចំណែកពាក្យណា ដែលត្រាស់ទុកក្នុង**ឥន្ទ្រិយគោចរសូត្រ**ថា “បសាទរូបអាស្រ័យមហាភូតរូបមួយ បានដល់ បឋវីសង្គ្រោះមិនបានដោយភូតរូប ៣ គឺ **អាបោ តេជោ និងវាយោ**” ដូច្នេះ, ក្នុង**ចតុបរិវត្តសូត្រ**ពោលទុកថា “បសាទរូបអាស្រ័យមហាភូតរូប ២ គឺ **បឋវីធាតុ និង អាបោធាតុ** មិនសង្គ្រោះដោយមហាភូតរូប ២ គឺ **តេជោធាតុ និង វាយោធាតុ**” , ពាក្យនោះត្រាស់ទុកដោយបរិយាយ; ដ្បិតថា សុត្តន្តិកកថានេះ ជាបរិយាយទេសនា; ក៏ទេសនាក្នុងសុត្តន្តិកកថានេះ ត្រាស់បរិយាយនេះទុកថា “បសាទរូបណា អាស្រ័យមហាភូតរូបទាំង ៤, បសាទរូបនោះ ក៏ជាបសាទរូប ក្នុងមហាភូតរូបពួកនោះតែមួយយ៉ាងៗ ខ្លះ តែពីរយ៉ាងៗ ខ្លះនោះឯង ។

តែព្រះអភិធម្ម ឈ្មោះថា **និប្បរិយាយទេសនា**, ព្រោះហេតុដូច្នោះ ក្នុង

---

[២០] វិសុទ្ធិ. ៣ (ខន្ធនិទ្ទេស) ។

ព្រះអភិធម្មនេះ ទើបត្រាស់ថា “បសាទរូបអាស្រ័យមហាភូតរូប ៤” ។

សរីរៈក្តី ខន្ធបញ្ចកៈក្តី ត្រាស់ហៅថា **អត្តភាព** ព្រោះសេចក្តីដែលសភាវៈនេះ មនុស្សពាលកំណត់ប្រកាន់ថា **“នេះជាអត្តភាពរបស់យើង”** , ធម៌ដែលរាប់បញ្ចូលក្នុងអត្តភាពនោះ ធម៌ដែលអាស្រ័យអត្តភាពនោះ ហៅថា **រាប់បញ្ចូលក្នុងអត្តភាព**; ដែលឈ្មោះថា ជាសភាពដែលឃើញមិនបាន (អនិទស្សនៈ) ព្រោះអត្ថថា មិនអាចដើម្បីនឹងឃើញបានដោយចក្ខុវិញ្ញាណ ។ ដែលឈ្មោះថា **ប៉ះខ្ទប់បាន** ព្រោះអត្ថថា ការប៉ះពាល់ ការខ្ទាំងខ្ទប់ រមែងកើតក្នុងបសាទនេះ ។

ក្នុងពាក្យទាំងឡាយមានពាក្យថា **“ដោយចក្ខុណា ”** ជាដើម មានសេចក្តីដោយសង្ខេបដូចតទៅនេះ ៖

សត្វនេះឃើញរូប មានប្រការដូចពោលហើយក្នុងអតីតៈ, ឬកំពុងឃើញក្នុងបច្ចុប្បន្ន, ឬថានឹងឃើញក្នុងអនាគត ដោយចក្ខុណា ដែលជាហេតុ; បើចក្ខុរបស់សត្វនោះនៅមិនគប្បីបែកធ្លាយទៅ, ពេលនោះ គេក៏គប្បីឃើញរូបដែលមកកាន់គន្លងបានដោយចក្ខុនោះ, ឬឃើញហើយនូវរូបអតីតៈ ដោយចក្ខុអតីតៈ, រមែងឃើញ រូបបច្ចុប្បន្ន ដោយចក្ខុជាបច្ចុប្បន្ន, ឬនឹងឃើញរូបអនាគត ដោយចក្ខុដែលជាអនាគត ។

ក្នុងអធិការនេះមានព្រះបាលីកំណត់ទុកថា **“សចេ តំ រូបំ ចក្ខុស្ស អាបាថំ អាគច្ឆេយ្យ, ចក្ខុនា តំ រូបំ បស្សេយ្យ** = បើរូបនោះគប្បីមកកាន់គន្លងនៃចក្ខុសោត, សត្វនោះ ក៏គប្បីឃើញរូបនោះបានដោយចក្ខុ” ។

រូបនេះហៅថា **ចក្ខុខ្លះ** ដោយអត្ថថា ជាអ្នកបង្ហាញក្នុងការឃើញ = **ទស្សនបរិណាយកដ្ឋេន**, នេះហៅថា **ចក្ខាយតនៈខ្លះ** ដោយអត្ថថា ជាកន្លែង និងជាទីប្រជុំនៃធម៌មានផស្សៈជាដើម = **សញ្ជាតិសមោសរណដ្ឋេន** ។ នេះហៅថា **ចក្ខុធាតុខ្លះ** ដោយអត្ថថា ជារបស់សោះសូន្យ និងមិនមែនសត្វ = **សុញ្ញតសភាវ-និស្សត្តដ្ឋេន** ។ នេះហៅថា **ចក្ខុន្ទ្រិយខ្លះ** ព្រោះអត្ថថា រមែងគ្រងភាពជាធំ ក្នុងលក្ខណៈនៃការឃើញ = **ទស្សនលក្ខណេ ឥន្ទដ្ឋំ ការេតិ** ។ នេះហៅថា **លោកខ្លះ** ដោយអត្ថថា ត្រូវគ្រាំគ្រាទ្រុឌទ្រោម = **លុជ្ជនបលុជ្ជនដ្ឋេន** ។ នេះហៅថា **ទ្វារខ្លះ** ដោយអត្ថថា ជាផ្លូវចូលទៅ = **វលញ្ជនដ្ឋេន** ។ នេះហៅថា **សមុទ្រខ្លះ** ដោយអត្ថថា ឱ្យពេញបានដោយលំបាក = **ទុប្បូរណីយដ្ឋេន** ។ នេះហៅថា **បណ្ឌរៈខ្លះ** ដោយអត្ថថា បរិសុទ្ធ = **បរិសុទ្ធដ្ឋេន** ។ នេះហៅថា **ខេត្ត** (ក្សេត្រ) ខ្លះ ដោយអត្ថថា ជាទីកើតចំពោះនៃធម៌មានផស្សៈជាដើម = **ផស្សាទីនំ អភិជាយនដ្ឋេន** ។ នេះហៅថា **វត្ថុខ្លះ** ដោយអត្ថថា ជាទីអាស្រ័យនៃធម៌ មានផស្សៈជាដើមមនោះនុ៎ះឯង = **តេសំយេវ បតិដ្ឋដ្ឋេន** ។ នេះហៅថា **នេត្រខ្លះ** ព្រោះអត្ថថា រមែងសម្តែងផ្លូវដែលស្មើ និងមិនស្មើ (ហើយ) នាំអត្តភាពទៅ = **សមំ វិសមំ ទស្សេន្តំ អត្តភាវំ នេតិ** ។ នេះហៅថា **នយនាខ្លះ** ដោយអត្ថថា សម្តែងផ្លូវដែលស្មើ និងមិនស្មើ (ហើយ)នាំអត្តភាពនោះទៅដែរ = **តេនេវ អដ្ឋេន** ។ នេះហៅថា **ច្រាំងនេះ** (អាយ) ខ្លះ **ច្រាំងនោះ** (នាយ) ខ្លះ ដោយអត្ថថា រាប់បញ្ចូលដោយ

កាយរបស់ខ្លួន = **សក្កាយ បរិយាបន្នរត្តន** ។ ឯរូបនេះ ហៅថា **សុញ្ញគាម** ( ស្រុកស្ងាត់) ខ្លះ ដោយអត្ថថា ជាសាធារណៈដល់សត្វដ៏ច្រើន = **ពហុសាធារណរត្តន** និងដោយអត្ថថា មិនមានម្ចាស់ = **អសាមិករត្តន** ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ បណ្ឌិតគប្បីប្រកបឈ្មោះ ១៤ យ៉ាង មានពាក្យថា "**ចក្ខុបេតំ** = នេះហៅថា ចក្ខុខ្លះ" ជាដើម ដោយបទ ៤ * មានបទថា "**បស្សិ វា** = ឃើញហើយឬ" ជាដើម ហើយគប្បីជ្រាបថា ព្រះភគវាទ្រង់ត្រាស់ន័យជាគ្រឿងកំណត់ចក្ខាយតនៈទុក ៤ បទដូច្នេះ ។ គប្បីជ្រាបយ៉ាងណា ?

គប្បីជ្រាបថា ក៏ក្នុងព្រះបាលីនេះ មានន័យដូច្នេះថា ៖

សត្វនេះឃើញហើយ ឬកំពុងឃើញ ឬក៏នឹងឃើញ ឬថាគប្បីឃើញនូវរូបជាវត្ថុដែលឃើញបាន និងប៉ះខ្ទប់បានដោយចក្ខុណា ជាវត្ថុដែលឃើញមិនបាន, តែប៉ះខ្ទប់បាន រូបនេះហៅថា **ចក្ខុខ្លះ** ។ ល ។ នេះហៅថា **សុញ្ញគាម** = ស្រុកស្ងាត់ខ្លះ, រូបនេះឯង ហៅថា ចក្ខាយតនៈដូច្នេះខ្លះ ។ សូម្បីន័យដ៏សេស ក៏គប្បីជ្រាបយ៉ាងនេះចុះ ៕

---

* បទ ៤ គឺ **បស្សិ វា, បស្សតិ វា, បស្សិស្សតិ វា, បស្សេ វា** = ឃើញហើយ, ឬកំពុងឃើញ, ឬក៏នឹងឃើញ, ឬថា គប្បីឃើញ ។

## សម្តែងអំពីចក្ខាយតននិទ្ទេស

ឥឡូវនេះ ព្រោះក្នុងវេលាដែលចេញផ្លេកបន្ទោរជាដើម សូម្បីបុគ្គលមិនត្រូវការមើលរូប ក៏រមែងខ្ទប់ចក្ខុបសាទបាន, ព្រោះហេតុដូច្នោះ ព្រះអង្គទ្រង់បំណងនឹងប្រកាសអាការៈនោះ ទើបទ្រង់ផ្តើមនិទ្ទេសវារៈ ( វារៈដែលពោលដោយការពង្រីកសេចក្តី ) ទីពីរ ដូចតទៅ ៖

ក្នុងព្រះបាលីនោះ បទថា **"យម្ហិ"** បានដល់ ក្នុងចក្ខុណា ដែលជាហេតុ ។ ពាក្យថា **"រូបំ** = រូប" នោះជាបឋមាវិភត្តិ ។ បណ្តាបទទាំងនោះ បទថា **"បដិ-ហញ្ញិ វា** = ប៉ះខ្ទប់ហើយ" ជាអត្ថនៃអតីតៈ ។ បទថា **"បដិហញ្ញិ វា** = រមែងប៉ះខ្ទប់" ជាអត្ថនៃបច្ចុប្បន្ន ។ បទថា **"បដិហញ្ញិស្សតិ វា** = នឹងប៉ះខ្ទប់" ជាអត្ថនៃអនាគត ។ បទថា **"បដិហញ្ញេ វា** = គប្បីប៉ះខ្ទប់" ជាអត្ថនៃការកំណត់ ។

ពិតណាស់ រូបជាអតីតៈ ឈ្មោះថា ប៉ះខ្ទប់ហើយ សូម្បីក្នុងចក្ខុដែលជាអតីតៈ, រូបដែលជាបច្ចុប្បន្ន ក៏ឈ្មោះថា រមែងប៉ះខ្ទប់ក្នុងចក្ខុដែលជាបច្ចុប្បន្ន, រូបដែលជាអនាគត ក៏ឈ្មោះថា នឹងប៉ះខ្ទប់ក្នុងចក្ខុដែលជាអនាគត ។ ក្នុងព្រះបាលីនេះ មានសេចក្តីកំណត់ទុកថា "បើរូបនោះគប្បីមកកាន់គន្លងចក្ខុសោត, រូបនោះគប្បីប៉ះខ្ទប់ក្នុងចក្ខុ" ដូច្នេះ ។ តែកាលបើពោលដោយសេចក្តីហើយ បើរូបកាយកំពុងប៉ះខ្ទប់នូវបសាទប៉ុណ្ណោះ ទើបឈ្មោះថា រមែងប៉ះខ្ទប់ ។ សូម្បីក្នុងអធិការនេះ គប្បីជ្រាបន័យនៃការកំណត់ទាំង ៤ ដោយន័យដែលពោលទុកមុននោះចុះ ។

ឥឡូវនេះ ព្រះភគវាដើម្បីទ្រង់ប្រកាសអាការៈ ដែលបុគ្គលបំណងនឹងក្រឡេកមើល ដោយសេចក្ដីប្រាថ្នារបស់ខ្លួនទើបបង្អោនក្រឡេកមើលដោយចក្ខុតម្រង់ទៅរករូប, ចក្ខុទើបប៉ះខ្ទប់រូបនោះ, ទើបផ្ដើមត្រាស់និទ្ទេសវារៈទី ៣ ដូចតទៅ ។ ពោលដោយនិទ្ទេសវារៈទី ៣ នោះ ជាក់ច្បាស់ហើយមែនពិត, តែក្នុងអធិការនេះ ចក្ខុទទួលអារម្មណ៍ហើយប៉ុណ្ណោះ ទើបឈ្មោះថា រមែងប៉ះខ្ទប់ក្នុងរូប, បណ្ឌិតគប្បីជ្រាបន័យនៃការកំណត់ ៤ យ៉ាង សូម្បីក្នុងនិទ្ទេសវារៈទី ៣ នេះដោយន័យមុននុ៎ះចុះ ។

ខាងមុខពីនេះទៅទ្រង់សម្ដែងវារៈ ១០ គឺ ធម៌ ៥ ដោយអំណាចនៃការសម្ដែងការកើតផស្សបញ្ចកៈ និងធម៌ ៥ ដោយអំណាចនៃការសម្ដែងការកើតឡើង ដោយមានអារម្មណ៍ទាក់ទងគ្នាដល់ធម៌ពួក ៥ មានផស្សៈជាដើមនោះឯង ។

បណ្ដាបទទាំងនោះ បទថា **“ចក្ខុំ និស្សាយ** = អាស្រ័យចក្ខុ” បានដល់អាស្រ័យចក្ខុ គឺធ្វើចក្ខុឱ្យជាបច្ច័យ ។ បទថា **“រូបំ អារព្ភ** = ប្រារព្ធរូប” បានដល់មកដល់ គឺប៉ងសំដៅអាស្រ័យនូវរូបារម្មណ៍ ។ ដោយព្រះបាលីនេះ ទ្រង់សម្ដែងសភាពនៃរូបជាបច្ច័យដោយសេចក្ដីជាបុរេជាតប្បច្ច័យនៃធម៌ មានផស្សៈជាដើម ដែលអាស្រ័យចក្ខុបសាទ និងដោយអារម្មណាធិបតិប្បច្ច័យ អារម្មណូបនិស្សយ-ប្បច្ច័យ នៃធម៌ទាំងឡាយដែលរាប់បញ្ចូលក្នុងជវនវីថិក្នុងចក្ខុទ្វារ ។ ក្នុង ៥ វារៈក្រៅពីនេះ ទ្រង់សម្ដែងសភាពនៃរូបជាបច្ច័យដោយត្រឹមតែអារម្មណប្បច្ច័យយ៉ាង

នេះថា រូបជាអារម្មណ៍របស់ធម៌ដែលតែងតែមាន ព្រោះហេតុនោះ ធម៌ (ចក្ខុ-វិញ្ញាណ) នេះ ទើបឈ្មោះថា មានរូបជាអារម្មណ៍ ។ គប្បីជ្រាបន័យដែលទ្រង់កំណត់មួយន័យៗ ៤ វារៈ ក្នុងវារៈទាំង ១០ សូម្បីពួកនេះ ដូចក្នុង ៣ វារៈដំបូង។

ចក្ខុដែលទ្រង់លើកឡើងសម្ដែងដើម្បីសួរថា “រូបដែលឈ្មោះថា ចក្ខាយ-តនៈ តើដូចម្ដេច ?” ដើម្បីសម្ដែងពាក្យថា “**ឥទន្តំ** = រូបនេះឯង” ដោយប្រការផ្សេងៗ ទើបសម្ដែងនិទ្ទេសវារៈ ១៣ គឺន័យមុន ៣ វារៈ, ន័យនេះ ១០ វារៈ ។ ក៏ក្នុងវារៈ ១៣ ពួកនេះតែមួយវារៈៗ គប្បីជ្រាបថា ទ្រង់សម្ដែងប្រដាប់ដោយន័យទុក ៥២ ន័យ ព្រោះការកំណត់វារៈមួយៗ ៤ ន័យដូច្នេះ ។

សូម្បីក្នុងនិទ្ទេសវារៈនៃសោតាយតនៈជាដើម ខាងមុខពីចក្ខុនិទ្ទេសនេះ ក៏ន័យនេះដែរ, តែក្នុងសោតាយតននិទ្ទេសជាដើមនេះ គប្បីជ្រាបតែពាក្យដែលផ្សេងគ្នាយ៉ាងនេះ ៖

## សម្ដែងអំពីពាក្យថាសោតៈជាដើម

ធម៌ដែលឈ្មោះថា សោតៈ ព្រោះអត្ថថា បានឮ = **សុណាតីតិ សោតំ** ។ សោតៈនោះ តាំងនៅក្នុងប្រទេសមានសណ្ឋានដូចរង្វង់មូល មានរោមក្រហម ល្អិតដុះនៅខាងក្នុងប្រហោងនៃសសម្ភារសោតៈ (ត្រចៀកព្រមដោយគ្រឿងប្រកប) ដែលធាតុទាំងឡាយ មានប្រការដូចពោលហើយ បានទទួលឧបការៈ ដែលឧតុ ចិត្ត និងអាហារជួយឧបត្ថម្ភ ដែលអាយុ គឺជីវិតរូបជួយអនុបាល ដែលគោចររូប

មានវណ្ណៈជាដើម ចោមរោមហើយឱ្យសម្រេចភាវៈជាវត្ថុ និងទ្វារដល់សោត-វិញ្ញាណជាដើម តាមសមគួរ ។

ធម៌ដែលឈ្មោះថា **ឃានៈ** ព្រោះអត្ថថា រមែងហិតក្លិន = **ឃាយតីតិ ឃានំ** ។ ឃានៈដែលជាបសាទរូបនោះ តាំងនៅក្នុងប្រទេស មានសណ្ឋានដូចក្រចកជើងពពែ ខាងក្នុងប្រហោងសសម្ភារឃានៈ ( ប្រហោងច្រមុះព្រមដោយសសម្ភារៈចំណែកប្រកប) បានទទួលឧបការៈឧបត្ថម្ភអនុបាល និងការចោមរោម តាមដែលបានពោលហើយ ឱ្យសម្រេចសេចក្ដីជាវត្ថុ និងទ្វារដល់ឃានវិញ្ញាណជាដើម តាមសមគួរ ។

ធម៌ដែលឈ្មោះថា **ជិវ្ហា** ដោយអត្ថថា លិទ្ធរស = **សឆាយនត្ថេន**, ជិវ្ហាដែលជាបសាទរូបនោះ តាំងនៅក្នុងប្រទេសមានសណ្ឋាន ដូចចុងស្រទាប់ផ្កាឧប្បលខាងលើនៃទីកណ្ដាលសសម្ភារជិវ្ហា ( អណ្ដាតព្រមដោយចំណែកប្រកប) បាន **ឧប-ការៈ ឧបត្ថម្ភ អនុបាល** និងការចោមរោមតាមដែលពោលហើយ ឱ្យសម្រេចជាវត្ថុ និងទ្វារនៃជិវ្ហាវិញ្ញាណជាដើមតាមសមគួរ ។

តែក្នុងកាយនេះ ឈ្មោះថា **ឧបាទិន្នករូប** មានប្រការត្រឹមណា, **កាយា-យតនៈ**ក៏តាំងនៅក្នុងកាយទាំងអស់ ដូចជ័រក្នុងស្រទាប់កប្បាស បាន **ឧបការៈ ឧបត្ថម្ភ អនុបាល** និងការចោមរោមតាមប្រការដែលពោលហើយ ក៏ឱ្យសម្រេចភាវៈជាវត្ថុ និងទ្វារដល់កាយវិញ្ញាណជាដើមតាមសមគួរ ។ នេះជាសេចក្ដីផ្សេងគ្នា

ក្នុងឧបាទាយរូបនោះ ។ សេចក្តីផ្សេងគ្នានៃព្រះបាលី និងអដ្ឋកថាដ៏សេស គប្បីជ្រាបដោយន័យ ដែលពោលទុកក្នុងចក្ខុនិទ្ទេសនុ៎ះចុះ ។ ក៏ក្នុងទីនេះ បទថា សោតៈជាដើម មកក្នុងទីនៃបទចក្ខុ, បទថា **សំឡេង** ជាដើម មកក្នុងទីនៃបទរបស់រូប, បទថា **បានឮ** ជាដើម មកក្នុងទីនៃបទទាំងឡាយ មានការឃើញហើយជាដើម; ក៏ ២ បទនេះ គឺនេះឈ្មោះថា **នេត្រខ្លះ**, នេះឈ្មោះថា **នយនាខ្លះ** មិនមាន, ព្រោះហេតុដូច្នោះ ទើបវត្ត និងទ្វារម្យ៉ាងៗ មាន ១២ ឈ្មោះ ។ ពាក្យដ៏សេសដូចនឹងពាក្យដែលពោលទុកក្នុងបទទាំងពួងនោះដែរ ។

ក្នុងអធិការនៃកាយាយតនៈនោះ ប្រសិនបើមានអ្នកចោទថា "ឈ្មោះថា **ឧបាទិន្នករូបនេះ** មាននៅក្នុងកាយនេះត្រឹមណា, កាយាយតនៈ ក៏មាននៅក្នុងកាយទាំងអស់ ដូចជ័រក្នុងប៉ុយកប្បាស, ប្រសិនបើដូច្នោះ ក៏រមែងដល់ការច្រឡំគ្នាដោយលក្ខណៈ (ក្នុងកលាបៈដទៃ) ។ ឆ្លើយថា មិនប្រាកដថា ច្រឡំគ្នា (ក្នុងកលាបៈដទៃ) ទេ ។ ព្រោះហេតុអ្វី ? ព្រោះសេចក្តីមិនមានក្នុងកលាបៈដទៃរបស់គ្នានឹងគ្នា ។ សួរថា បើយ៉ាងនោះ កាយាយតនៈក៏មិនមានក្នុងកាយទាំងពួងឬ ? ឆ្លើយថា ដោយបរមត្ថក្នុងឧបាទិន្នករូបទាំងអស់ លោកមិនបានចែកកាយទុកដោយឡែក; តែហេតុនៃសេចក្តីផ្សេងគ្នារបស់ឧបាទិន្នករូបនោះ នរណាៗ មិនអាចដើម្បីវែកញែក ហើយបញ្ញត្តិបានឡើយ, ព្រោះហេតុដូច្នោះ ទើបបានពោលទុកយ៉ាងនេះ ។

ដូចយ៉ាងថា រូប និងរសជាដើម លោកពោលថាជារបស់ជ្រួតជ្រាបនៅជាមួយគ្នានឹងគ្នា ព្រោះសេចក្តីដែលរូប និងរសជាដើមនរណា។មិនអាចញែកពីគ្នាបានដូចផង់ខ្សាច់ល្អិតទេ, តែដោយបរមត្ថ រសក៏មិនមាននៅក្នុងរូប, បើនឹងគប្បីមានសោត រសក៏គប្បីប្រាកដដោយសព្ទថា រូបដែរ យ៉ាងណាមិញ, សូម្បីកាយាយតនៈក៏យ៉ាងនោះដែរ ពោលដោយបរមត្ថមិនមាននៅក្នុងកាយ (ឧបាទិន្នករូប) ទាំងអស់ និងមិនមានក្នុងកាយទាំងអស់ ក៏មិនមែន ព្រោះមិនមាននរណាអាចដើម្បីនឹងបែងចែកបានឡើយ ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបថាសេចក្តីច្រឡូកច្រឡំគ្នា ដោយលក្ខណៈ ក្នុងទីនេះទើបមិនប្រាកដ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីមិនច្រឡំគ្នារបស់បសាទរូបទាំងនេះ ដោយការកំណត់លក្ខណៈជាដើម ។ ពិតណាស់ បណ្តាបសាទរូបទាំងនេះ ៖

**រូបាភិឃាតារហភូតប្បសាទលក្ខណំ ទដ្ឋុកាមតានិទានកម្មសមុដ្ឋានភូតប្បសាទលក្ខណំ វា ចក្ខុ** = ចក្ខុមានសេចក្តីថ្លារបស់ភូតរូបដែលគួរដល់ការប៉ះខ្ទប់រូបជាដើម ជាលក្ខណៈ ឬមានសេចក្តីថ្លារបស់ភូតរូប មានកម្មជាសមុដ្ឋានដែលជាហេតុរបស់បុគ្គលអ្នកត្រូវការនឹងមើលជាលក្ខណៈ ។

**រូបេសុ អាវិញ្ឆនរសំ** មានការទាញរូបទាំងឡាយមកជាកិច្ច

**ចក្ខុវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** មានការទ្រទ្រង់នូវចក្ខុវិញ្ញាណជាបច្ចុប្បដ្ឋាន ។

**ទដ្ឋុកាមតានិទានកម្មជភូតបទដ្ឋានំ** មានភូតរូបដែលកើតពីកម្ម ជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងមើលជាបទដ្ឋាន ។

**សទ្ទាភិឃាតារហភូតប្បសាទលក្ខណំ សោតុកាមតានិទានកម្ម-សមុដ្ឋានភូតប្បសាទលក្ខណំ វា សោតំ** ត្រចៀកមានសេចក្ដីថ្លានៃភូតរូប ដែលគួរដល់ការប៉ះខ្ទប់សំឡេង ជាលក្ខណៈ ឬមានសេចក្ដីថ្លារបស់ភូតរូបដែលមានកម្មជាសមុដ្ឋាន ដែលជាហេតុរបស់បុគ្គល អ្នកប្រាថ្នាដើម្បីនឹងស្ដាប់ជាលក្ខណៈ ។

**សទ្ទេសុ អាវិញ្ឆនរសំ** មានការទាញសំឡេងទាំងឡាយមកជាកិច្ច

**សោតវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** មានការទ្រទ្រង់នូវសោត-វិញ្ញាណ ជាបច្ចុប្បដ្ឋាន ។

**សោតុកាមតានិទានកម្មជភូតបទដ្ឋានំ** មានភូតរូបដែលកើតពីកម្ម ជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងស្ដាប់ជាបទដ្ឋាន ។

**គន្ធាភិឃាតារហភូតប្បសាទលក្ខណំ ឃាយិតុកាមតានិទានកម្មជ-សមុដ្ឋានភូតប្បសាទលក្ខណំ វា ឃានំ** ច្រមុះមានសេចក្ដីថ្លារបស់ភូតរូប ដែលគួរដល់ការប៉ះខ្ទប់ក្លិនជាលក្ខណៈ ឬមានសេចក្ដីថ្លារបស់ភូតរូបដែលកើតពីកម្ម ជាសមុដ្ឋាន ជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងធុំ (ក្លិន) ជាលក្ខណៈ ។

**គន្ធេសុ អាវិញ្ឆនរសំ** មានការស្រូបក្លិនទាំងឡាយមកជាកិច្ច

**ឃានវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** មានការទ្រទ្រង់នូវឃាន-វិញ្ញាណ ជាបច្ចុប្បដ្ឋាន ។

**ឃាយិតុកាមតានិទានកម្មជភូតបទដ្ឋានំ** មានភូតរូបដែលកើតពីកម្ម ជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងធុំក្លិនជាបទដ្ឋាន ។

**រសាភិឃាតារហភូតប្បសាទលក្ខណា សាយិតុកាមតា និទានកម្មជ-សមុដ្ឋានភូតប្បសាទលក្ខណា ជិវ្ហា** អណ្ដាតមានសេចក្ដីថ្លារបស់ភូតរូបដែលគួរដល់ការប៉ះខ្ទប់រសជាលក្ខណៈ ឬមានសេចក្ដីថ្លារបស់ភូតរូប ដែលកើតពីកម្មជាសមុដ្ឋាន ជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងលិទ្ធរសជាលក្ខណៈ ។

**រសេសុ អាវិញ្ឆនរសា** មានការទាញរសទាំងឡាយមកជាកិច្ច ។

**ជិវ្ហាវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានា** មានការទ្រទ្រង់នូវជិវ្ហាវិញ្ញាណជាបច្ចុប្បដ្ឋាន ។

**សាយិតុកាមតានិទានកម្មជភូតបទដ្ឋានា** មានភូតរូបកើតពីកម្មជាហេតុរបស់បុគ្គល អ្នកប្រាថ្នាដើម្បីនឹងលិទ្ធរសជាបទដ្ឋាន ។

**ផោដ្ឋព្វាភិឃាតារហភូតប្បសាទលក្ខណោ ផុសិតុកាមតានិទានកម្មជ-សមុដ្ឋានភូតប្បសាទលក្ខណោ វា កាយោ** កាយមានសេចក្ដីថ្លារបស់ភូតរូបដែលគួរដល់ការប៉ះខ្ទប់ផោដ្ឋព្វៈជាលក្ខណៈ ឬមានសេចក្ដីថ្លារបស់ភូតរូបដែលកើតពីកម្មជាសមុដ្ឋាន ជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងពាល់ត្រូវជាលក្ខណៈ ។

**ផោដ្ឋព្វសុ អាទិញ្ឆនរសោ** មានការទាញផោដព្វៈទាំងឡាយមកជាកិច្ច **កាយវិញ្ញាណស្ស អាធារភាវបច្ចុបដ្ឋានោ** មានការទ្រទ្រង់នូវកាយ-វិញ្ញាណជាបច្ចុប្បដ្ឋាន ។

**ផុសិតុកាមតានិទានកម្មជភូតបទដ្ឋានោ** មានភូតរូបកើតពីកម្មជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងប៉ះខ្ទប់ជាបទដ្ឋាន ៕

## សម្ដែងអំពីវាទៈរបស់អាចារ្យពួកខ្លះ

ក៏អាចារ្យពួកខ្លះពោលថា "បសាទរបស់ភូតរូបទាំងឡាយ ដែលមានតេជោ-ធាតុច្រើនជាចក្ខុ, បសាទទាំងឡាយរបស់ភូតរូបទាំងឡាយ ដែលមាន**វាយោធាតុ បឋវីធាតុ** និង **អាបោធាតុច្រើន ជាសោតៈ ជាឃានៈ** និង **ជាជិវ្ហា**, បសាទរបស់ភូតរូបទាំងអស់(៤)ជាកាយ" ។

អាចារ្យបរវាទីមួយពួកទៀតពោលថា "បសាទរបស់ភូតរូប ដែលក្រៃលែងដោយតេជោធាតុជាចក្ខុ, បសាទទាំងឡាយរបស់ភូតរូប ដែលក្រៃលែងដោយវាយោ-ធាតុក្នុងប្រហោងត្រចៀកក្រៃលែងដោយអាបោធាតុដ៏ក្រៃលែងដោយ**បឋវីធាតុក៏ជាសោតៈ ជាឃានៈ ជាជិវ្ហា និងជាកាយ**" ។ អាចារ្យទាំងឡាយគប្បីពោលជំទាស់អាចារ្យបរវាទីទាំងនោះថា "សូមលោកចូរនាំព្រះសូត្រមកអាង" ។ ជាការពិត

ណាស់ លោកអាចារ្យបរវាទីទាំងនោះ នឹងមិនឃើញព្រះសូត្រឡើយ ។ តែអាចារ្យពួកខ្លះ ក៏នៅតែពោលដោយហេតុក្នុងបសាទរូបពួកនោះថា "ព្រោះសេចក្ដីដែលភូតរូប មានតែជោធាតុជាដើម គប្បីឧបការៈដោយរូបទាំងឡាយដែលមានគុណ " ។ គប្បីជំទាស់កេចិអាចារ្យទាំងនោះថា "ក៏នរណាទៅពោលយ៉ាងនេះថា រូបជាដើម ជាគុណរបស់ភូតរូបមានតេជោធាតុជាដើម, ព្រោះក្នុងអវិនិព្ភោគរូប (រូបដែលញែកពីគ្នាមិនបាន ៨ យ៉ាង) ទាំងឡាយ នរណាៗ រមែងមិនបានដើម្បីនឹងពោលថា "ក្នុងភូតរូបទាំងនោះ រូបនេះជាគុណរបស់រូបនេះៗ" ដូច្នេះឡើយ ។

បើបរវាទីនឹងគប្បីដេញដោលសកវាទីថា "ពួកលោករមែងប្រាថ្នាកិច្ចទាំងឡាយមានការទ្រទ្រង់បឋវីធាតុជាដើមទុក ព្រោះសេចក្ដីដែលភូតរូបនោះៗ ក្នុងសម្ភារៈនោះៗ ជារបស់ក្រៃលែងយ៉ាងណា, ខដែលពួកលោកគប្បីប្រាថ្នាថា រូបទាំងឡាយជាគុណរបស់ភូតរូបទាំងនោះ ព្រោះសម្ដែងសេចក្ដីដែលរូបជាដើមក្នុងសម្ភារៈដ៏ក្រៃលែងដោយតេជោធាតុជាដើមជារបស់មានច្រើន ក៏ដូច្នោះដែរ" ។

**សកវាទីគប្បីជំទាស់បរវាទីនោះថា** "ពួកយើងប្រាថ្នា, ប្រសិនបើថា ក្លិនក្នុងចំណែកបឋវីធាតុគប្បីមានច្រើនជាងក្លិនរបស់ទឹកបន្លែជ្រក់ ដែលអាបោធាតុច្រើន និងពណ៌របស់ទឹកត្រជាក់ ក៏គប្បីមានពណ៌ច្រើនជាង សូម្បីពណ៌របស់ទឹកក្ដៅដែលមានតេជោធាតុច្រើន" ដូច្នេះ តែពាក្យដែលពោលហើយទាំង ២ នេះ មិនមានទេ, ព្រោះហេតុដូច្នោះ សូមពួកលោកគប្បីលះការកំណត់ផ្សេងគ្នានៃចក្ខុជាដើម ដែល

ជាទីអាស្រ័យនោះចុះ, រូប និងរសជាដើម សូម្បីមិនប្លែកគ្នារបស់ភូតរូបទាំងឡាយ, តែក៏មិនប្លែកគ្នា យ៉ាងណា, ខដែលលោកនឹងគប្បីកាន់យកថា កាលបើមានការប្លែកគ្នា ក៏មិនគប្បីកាន់យកបសាទមានចក្ខុជាដើមយ៉ាងនោះទេ ។

**សួរថា** ក៏ហេតុដែលមិនទូទៅដល់គ្នានឹងគ្នានោះ បានដល់អ្វី ?

ឆ្លើយថា បានដល់ កម្មប៉ុណ្ណោះជាហេតុផ្សេងគ្នារបស់បសាទរូបទាំងនោះ, ព្រោះហេតុដូច្នោះ សេចក្ដីផ្សេងគ្នានៃបសាទរូបពួកនោះ ព្រោះសេចក្ដីផ្សេងគ្នានៃកម្ម, មិនមែនសេចក្ដីផ្សេងគ្នារបស់ភូតរូបទេ ។ ព្រោះថា កាលបើភាវៈនៃភូតរូបមាន បសាទរូបនោះឯងនឹងមិនកើតឡើងឡើយ; បុរាណាចារ្យទាំងឡាយ ពោលទុកថា ក៏បសាទរូបរបស់មហាភូតរូបទាំងឡាយដូចគ្នា មិនមែនរបស់មហាភូតរូបមិនដូចគ្នាទេ ។

ក៏បណ្ដាបសាទរូបទាំងនេះ ដែលមានសេចក្ដីផ្សេងគ្នា ព្រោះសេចក្ដីផ្សេងគ្នានៃកម្ម ចក្ខុ និងសោតៈ **ជាអសម្បត្តវិសយគ្គាហកៈ** = ទទួលអារម្មណ៍ដែលមកមិនដល់, ព្រោះឧប្បត្តិហេតុរបស់វិញ្ញាណក្នុងអារម្មណ៍ ដែលមានទីអាស្រ័យ មិនជាប់នឹងមហាភូតរូបដែលជាទីអាស្រ័យរបស់ខ្លួន; ឃានៈ ជិវ្ហា និងកាយជា **សម្បត្ត-វិសយគ្គាហកៈ** = ទទួលអារម្មណ៍ដែលមកដល់ខ្លួន, ព្រោះភាវៈនៃឧប្បត្តិហេតុរបស់វិញ្ញាណក្នុងអារម្មណ៍ ដែលជាប់នឹងមហាភូតរូបជាទីអាស្រ័យរបស់ខ្លួន ដោយអំណាចនៃវត្ថុជាទីអាស្រ័យ និងដោយខ្លួនឯងនោះដែរ ។

តែក្នុងអដ្ឋកថាពោលថា "អារម្មណ៍ឈ្មោះថា **សម្បត្តៈ** ដែលមកដល់ខ្លួន ព្រោះភាវៈនៃអារម្មណ៍មកកាន់គន្លងនៃចក្ខុ និងសោតៈមែនពិត, ពិតណាស់ ពណ៌ (វណ្ណៈ) របស់មណ្ឌលនៃព្រះចន្ទ និងព្រះអាទិត្យតាំងនៅឆ្ងាយដល់ ៤២.០០០ យោជន៍ ក៏នៅប៉ះខ្ទប់ចក្ខុបសាទបាន; ពណ៌នោះសូម្បីប្រាកដតាំងនៅក្នុងទីឆ្ងាយ ក៏ឈ្មោះថា **សម្បត្តៈ**ដែរ, ចក្ខុឈ្មោះថា មានអារម្មណ៍ដែលមកដល់ (សម្បត្តៈ) ព្រោះភាវៈនៃពណ៌នោះជាអារម្មណ៍តែម្យ៉ាង ។ កាយវិការរបស់បុគ្គលទាំងឡាយ ដែលកាប់ដើមឈើក្នុងទីឆ្ងាយក្តី របស់ជាងជ្រលក់អ្នកគក់សំពត់ក្តី រមែងប្រាកដ សូម្បីតែពីចម្ងាយ, តែសំឡេងមកដោយការជាប់ត។ គ្នានៃធាតុប៉ះខ្ទប់សោតៈហើយ ក៏សន្សឹម។ អស់ទៅ" ។

ក្នុងអដ្ឋកថានោះ អារម្មណ៍ឈ្មោះថា **សម្បត្តៈ** (ដែលមកដល់ខ្លួន) ព្រោះភាវៈនៃអារម្មណ៍នោះមកកាន់គន្លង ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា ពណ៌របស់មណ្ឌលព្រះចន្ទ ក៏មិនមកដល់ចក្ខុ រមែងប្រាកដតាំងនៅក្នុងទីឆ្ងាយនោះឯង; ប្រសិនបើ សូម្បីសំឡេងគប្បីសន្សឹម។ មកសោត, នៅក្នុងទីឆ្ងាយ ក៏គប្បីបានឮយឺត។, ព្រោះមកដោយការប៉ះខ្ទប់ត។ គ្នា កាលបើប៉ះខ្ទប់សោតៈ ក៏មិនប្រាកដ ឈ្មោះថាសំឡេងនោះ នៅក្នុងទិសឈ្មោះឯណោះ; ព្រោះហេតុដូច្នោះ ចក្ខុ និងសោតៈទើបមានអារម្មណ៍ជា **អសម្បត្តៈ** (មកមិនដល់) មែនពិត ៕

## នៃ្តកប្រៀបដូចពស់

បសាទរូបនេះប្រៀបដូចសត្វពស់ជាដើម ដូចយ៉ាងថា ឡើងឈ្មោះថា ពស់ រមែងមិនពេញចិត្តក្នុងទីសើម និងរៀបស្មើក្នុងទីខាងក្រៅ, ទើបចូលទៅក្នុងដើមឈើ ស្លឹកស្មៅក្រាស់ និងដំបូកនោះឯង រមែងពេញចិត្តក្នុងវេលាដេក, រមែងដល់ភាពជាសត្វមានចិត្តស្ងប់យ៉ាងណា, សូម្បីចក្ខុនេះ ក៏យ៉ាងនោះដែរ គឺមានសេចក្ដីពេញចិត្តក្នុងកន្លែងដែលមិនរាបស្មើ រមែងមិនពេញចិត្ត មិនប្រាថ្នាសូម្បីនឹងក្រឡេកមើលក្នុងទីមានជញ្ជាំងមាសជាដើមដែលរៀបរយ, តែពេញចិត្តក្នុងទីមានក្បូរក្បាច់ចំរុះពណ៌ ដោយរូបផ្កាឈើលតាវល្លិជាដើមមែនពិត, ព្រោះក្នុងទីដូច្នោះ កាលបើភ្នែកនៅមិនទាន់ល្មម មនុស្សទាំងឡាយក៏នៅហាមាត់ចង់មើល ៕

## ត្រចៀកប្រៀបដូចក្រពើ

**សូម្បីក្រពើសោត** កាលបើទៅខាងក្រៅមិនឃើញវត្ថុ ដែលខ្លួននឹងគប្បីចាប់យក, ក៏ធ្មេចភ្នែកទៅ; តែក្នុងកាលជ្រមុជចុះកាន់ទឹកប្រមាណមួយរយព្យាម ចូលទៅកាន់រូងដេកហើយ, ក្នុងកាលនោះ ចិត្តរបស់វាក៏ដល់ភាពស្ងប់ លក់យ៉ាងសប្បាយយ៉ាងណា, សូម្បី**សោតៈ**នេះ ក៏យ៉ាងនោះដែរ ពេញចិត្តក្នុងទីមានរូងដែលអាស្រ័យអាកាស ពេញចិត្តក្នុងរូងប្រហោងត្រចៀកប៉ុណ្ណោះ, អាកាសប្រហោងត្រចៀកប៉ុណ្ណោះ ជាបច្ច័យក្នុងការបានឮសំឡេងនោះ; សូម្បីអជដាកាសក៏សមគួរដែរ;

ព្រោះថា កាលបើធ្វើការស្វាធ្យាយក្នុងល្អាង (លេណដ្ឋាន) សំឡេងមិនចោះទម្លុះល្អាងចេញទៅខាងក្រៅទេ, តែក៏ចេញទៅតាមប្រហោងទ្វារ បង្អួចប៉ះខ្ទប់ត។ គ្នាទៅនៃធាតុហើយ ទើបប៉ះខ្ទប់សោតបសាទ ។ ក្នុងលំដាប់នៃការប៉ះខ្ទប់ជនអ្នកអង្គុយនៅលើខ្នងល្អាង (ផ្ទាំងថ្ម) រមែងដឹងថា "បុគ្គលឈ្មោះឯណោះ រមែងស្វាធ្យាយ" ដូច្នេះ ។ កាលបើមានពាក្យពោលយ៉ាងនេះ ឈ្មោះថា អារម្មណ៍របស់សោតៈ ក៏ជាសម្បត្តៈ (គឺមកដល់ខ្លួនបាន) ។

**សួរថា** ក៏សោតៈនេះ មានអារម្មណ៍ជាសម្បត្តៈឬ ?

ឆ្លើយថា មែនហើយ មានអារម្មណ៍ជាសម្បត្តៈ ។

**សួរថា** បើដូច្នោះ ស្គរជាដើមឮក្នុងទីឆ្ងាយ ក៏មិនគប្បីដឹងថា "សំឡេងក្នុងទីឆ្ងាយ" ដូច្នេះមែនឬ ?

ឆ្លើយថា មិនគប្បីដឹង ក៏មិនមែន, ព្រោះកាលបើសំឡេងប៉ះខ្ទប់សោតបសាទ រមែងមានការដឹងដោយប្រការនោះ។ ថា "សំឡេងឆ្ងាយ, សំឡេងជិត, សំឡេងត្រើយឯណោះ, សំឡេងត្រើយឯណេះ" , ខនេះជារឿងធម្មតា ។

ក៏ធម្មតានេះ តើយ៉ាងណា, ក៏ធម្មតាប្រហោងត្រចៀកមាននៅក្នុងទីណា។ ការឮមានតែពីក្នុងទីនោះ។, ដូចការឃើញព្រះចន្ទ និងព្រះអាទិត្យជាដើម ព្រោះហេតុដូច្នោះ សោតបសាទនេះ ទើបមានអារម្មណ៍ជាអសម្បត្តៈដោយពិត ៕

## ច្រមុះប្រៀបដូចបក្សី

សូម្បីបក្សីក៏មិនរីករាយលើដើមឈើ ឬផែនដី; តែក្នុងវេលាណា វាហើរកន្លងផុតការចោលដុំដីមួយរយៈ (លេឌ្ឌុបាត) ហើរឡើងទៅកាន់អាកាសស្រឡះ, ក្នុងវេលានោះវាក៏នឹងមានចិត្តស្ងប់យ៉ាងណា, សូម្បីឃានៈ ក៏យ៉ាងនោះដែរ មានសេចក្ដីពេញចិត្តក្នុងអាកាស មានក្លិនតាមខ្យល់ជាអារម្មណ៍; ដូចយ៉ាងគោ កាលបើភ្លៀងធ្លាក់ថ្មីៗ ក៏ហិតក្លិនផែនដី ហើយងើយមុខរកអាកាសស្រូបខ្យល់; ឯវេលាដែលបុគ្គលសូម្បីយកម្រាមដៃចាប់ដុំដីដែលមានក្លិន ហើយហិតក្លិនបែរមុខមករកខាងខ្យល់ ក៏មិនដឹងក្លិននោះដែរ ៕

## អណ្ដាតប្រៀបដូចសុនខ (ឆ្កែ) ស្រុក

សូម្បីសុនខស្រុក កាលបើត្រាច់ទៅខាងក្រៅ រមែងមិនឃើញទីក្សេមចាកភ័យ, រមែងត្រូវគេប្រទូសរ៉ាយដោយត្រូវគេចោលដោយដុំដីជាដើម, ចូលទៅកាន់ខាងក្នុងស្រុកហើយ ក៏កាយផេះត្រង់ភ្នក់ភ្លើង ដេកជាសុខយ៉ាងណា, សូម្បីជិវ្ហា ក៏យ៉ាងនោះដែរ មានអធ្យាស្រ័យក្នុងស្រុក មានរសអាស្រ័យអាបោធាតុជាអារម្មណ៍; ពិតយ៉ាងនោះមែន ភិក្ខុសូម្បីនឹងធ្វើសមណធម៌រហូត ៣ យាមនៃរាត្រីហើយ កាន់បាត្រ និងចីវរពីព្រឹកព្រហាមចូលទៅកាន់ស្រុក, ព្រោះថា កាលបើរបស់ទំពាស៊ីស្ងួតមិនសើមដោយទឹកមាត់ នរណាៗ ក៏មិនអាចដឹងរសបាន ៕

## កាយប្រៀបដូចសុនខព្រៃ

សូម្បីសុនខព្រៃ កាលបើត្រាច់ទៅខាងក្រៅ ក៏មិនប្រសប់សេចក្ដីរីករាយ, តែបើវាទំពាស៊ីសាច់មនុស្ស ក្នុងព្រៃខ្មោចហើយដេកនោះឯង វាទើបមានសេចក្ដីសុខ យ៉ាងណា, សូម្បីកាយក៏យ៉ាងនោះដែរ មានអធ្យាស្រ័យ (ទម្លាប់) ក្នុងឧបាទិន្នករូប (រូបមានចិត្តគ្រប់គ្រង) មានផោដ្ឋព្វៈអាស្រ័យបឋវីធាតុជាអារម្មណ៍ ។ ពិតយ៉ាងនោះមែន ជនទាំងឡាយកាលបើមិនបានឧបាទិន្នកៈដទៃ យកបាតដៃរបស់ខ្លួននោះឯង រងសិរសៈដេក; បឋវីធាតុនៃកាយរបស់បុគ្គលនោះ សូម្បីនៅខាងក្នុង និងខាងក្រៅ ក៏ជាបច្ច័យក្នុងការទទួលអារម្មណ៍ ។ ពិតមែនហើយ ទីដេកសូម្បីក្រាលទុកយ៉ាងល្អ នៅមិនទាន់អង្គុយ ឬដេក ក៏មិនដឹងសេចក្ដីរឹង និងទន់បាន ឬផ្លែឈើដែលគេដាក់ទុកលើបាតដៃ នៅមិនទាន់ច្របាច់ក៏មិនអាចដឹងសេចក្ដីរឹង និងទន់បាន ។ បឋវីធាតុដែលនៅខាងក្នុង ឬខាងក្រៅ ទើបជាបច្ច័យដោយការដឹងការប៉ះខ្ទប់ របស់បសាទនេះ ។ គប្បីជ្រាបសេចក្ដីមិនលាយឡំគ្នានៃបសាទរូបនោះ ដោយការកំណត់ធម៌មានលក្ខណៈយ៉ាងនេះឯង ។

ពិតណាស់ លក្ខណៈ, រស, បច្ចុប្បដ្ឋាន, បទដ្ឋាន, អារម្មណ៍, អធ្យាស្រ័យ និងវត្ថុទីនៅអាស្រ័យរបស់ចក្ខុបសាទជាដើមម្យ៉ាង, របស់សោតបសាទជាដើមម្យ៉ាង ព្រោះហេតុដូច្នោះ ចក្ខាយតនៈជាដើម ទើបមិនច្រឡំគ្នាឡើយ ។

ម្យ៉ាងទៀត គប្បីជ្រាបសូម្បីឧបមាក្នុងសេចក្ដីដែលបសាទរូបពួកនោះ មិនច្រឡំ

គ្នាដូចតទៅនេះ ៖

ដូចយ៉ាងថា ស្រមោលនៃទង់ទាំងឡាយ ៥ ពណ៌ដែលគេបានលើកឡើង ជាប់ជាមួយគ្នា ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា ស្រមោលរបស់ទង់ ក៏មិនលាយឡំគ្នានឹងគ្នាយ៉ាងណា; ម្យ៉ាងទៀត កាលបើគេយកចំណែក ៥ ពណ៌មូលធ្វើជាប្រឆេះប្រទីប (ចង្កៀង) អុចឱ្យភ្លឺហើយ អណ្តាតភ្លើងមើលទៅដូចជាមួយគ្នា ក៏ពិតមែន, ប៉ុន្តែអណ្តាតភ្លើងនៃរស្មីរបស់ចំណែកនោះៗ ក៏ជាចំណែកដោយឡែកៗពីគ្នា មិនច្រឡូកច្រឡំគ្នាយ៉ាងណា, អាយតនៈទាំង ៥ នេះ សូម្បីរួមគ្នានៅក្នុងអត្តភាពជាមួយគ្នា, តែក៏មិនច្រឡូកច្រឡំគ្នានឹងគ្នាយ៉ាងនោះដែរ; មិនមែនតែអាយតនៈទាំង ៥ ប៉ុណ្ណោះទេ សូម្បីរូបដ៏សេសក៏មិនច្រឡូកច្រឡំគ្នាដែរ ។

ពិតណាស់ នៅក្នុងសរីរៈនេះ មានកាយ ៣ កំណាត់គឺ

- **ហេដ្ឋិមកាយោ** កាយកំណាត់ខាងក្រោម ១
- **មជ្ឈិមកាយោ** កាយកំណាត់ត្រង់កណ្តាល ១
- **ឧបរិមកាយោ** កាយកំណាត់ខាងលើ ១ ។

បណ្តាកាយទាំង ៣ កំណាត់នោះ កាយចំណែកខាងក្រោម ចាប់តាំងពីផ្ចិតចុះទៅ ឈ្មោះថា **កាយកំណាត់ខាងក្រោម**; ក្នុងកាយកំណាត់ខាងក្រោមនោះ មាន

រូប ៤៤ រូប គឺកាយទសកៈ ១០ [២១], ភាវទសកៈ ១០, មានអាហារជាសមុដ្ឋាន ៨, មានឧតុជាសមុដ្ឋាន ៨, មានចិត្តជាសមុដ្ឋាន ៨ [២២], កាយខាងលើតាំងពីផ្ចិតឡើងទៅដល់បំពង់ក ឈ្មោះថា **កាយកំណាត់ត្រង់កណ្តាល**; ក្នុងកាយកំណាត់ត្រង់កណ្តាលនោះ មានរូប ៥៤ រូប គឺ កាយទសកៈ ១០, ភាវទសកៈ ១០, វត្ថុទសកៈ ១០ រូបទាំង ៣ មានរូបដែលមានអាហារជាសមុដ្ឋានជាដើម ម្យ៉ាងៗ ៨ ។ កាយខាងលើតាំងពីបំពង់កឡើងទៅ ឈ្មោះថា **កាយកំណាត់ខាងលើ** ។ ក្នុងកាយកំណាត់ខាងលើនោះ មានរូប ៨៤ គឺ ចក្ខុទសកៈ ១០, សោតទសកៈ ១០, ឃានទសកៈ ១០, ជិវ្ហាទសកៈ ១០, កាយទសកៈ ១០, ភាវទសកៈ ១០ និងរូប ៣ មានរូបដែលមានអាហារជាសមុដ្ឋានជាដើម ម្យ៉ាងៗ មាន ៨ ។

បណ្តារូបទាំងនោះ រូបដែលឈ្មោះថា ចក្ខុទសកៈ ដោយអំណាចនៃនិប្ផន្នរូប ១០ ជារូបដែលញែកចេញពីគ្នាតែគ្រប់ចំណែកមិនបាននេះ គឺមហាភូតរូប ៤ ជា

---

[២១] ទសកៈ ១០ គឺ មហាភូតរូប ៤, វណ្ណៈ ១, គន្ធៈ ១, រសៈ ១, ឱជា ១, ជីវិតរូប ១ និងកាយបសាទ ១ ។

[២២] អាហារសមុដ្ឋានជាដើមម្យ៉ាងៗ មាន ៨ បានដល់ អវិនិព្ភោគរូប ៨ មានបឋវីជាខាងដើម មានឱជា ជាទីបំផុត ។

បច្ច័យដល់ចក្ខុបសាទ, វណ្ណៈ, គន្ធៈ, រសៈ, ឱជា, ជីវិតិន្ទ្រិយ និងចក្ខុបសាទ ។ សូម្បីរូបដ៏សេស ក៏គប្បីជ្រាបដោយន័យនេះដែរ ។ បណ្ដាកាយទាំង ៣ កំណាត់នោះ រូបក្នុងកាយកំណាត់ខាងក្រោម មិនលាយជាមួយនឹងកាយកំណាត់ត្រង់កណ្ដាល និងរូបកាយកំណាត់ខាងលើ, សូម្បីរូបក្នុងកាយដ៏សេស ២ ទៀត ក៏មិនលាយជាមួយនឹងរូបកាយក្រៅនេះដែរ ។ ដូចយ៉ាងថា ស្រមោលភ្នំ និងស្រមោលដើមឈើ ក្នុងវេលាល្ងាចដូចជាប់ជាមួយគ្នា ក៏ពិតមែនហើយ, ប៉ុន្តែមិនបានលាយជាមួយគ្នា យ៉ាងណា; សូម្បីក្នុងកាយទាំងនេះ គឺ រូប ៤៤ ក្ដី, រូប ៥៤ ក្ដី, រូប ៨៤ ក្ដី, ក៏យ៉ាងនោះដែរ គឺហាក់ដូចជាជាប់ជាមួយគ្នា, តែក៏មិនលាយឡំនូវគ្នានឹងគ្នាបានឡើយ ៕

## អដ្ឋកថារូបាយតននិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **រូបាយតនៈ** ដូចតទៅ ៖

ពណ៌ (វណ្ណៈ) នោះឯង ហៅថា **វណ្ណនិភា**, ន័យម្យ៉ាងទៀត ដែលឈ្មោះថា **និភា** ព្រោះអត្ថថា រមែងបញ្ចេញពន្លឺ, អធិប្បាយថា រមែងប្រាកដដល់ចក្ខុ-វិញ្ញាណ, ពន្លឺ គឺពណ៌ ឈ្មោះថា **វណ្ណនិភា** ។ រូបដែលឈ្មោះថា សនិទស្សនៈ (វត្ថុដែលឃើញបាន) ដោយប្រព្រឹត្តទៅព្រមជាមួយការឃើញ, អធិប្បាយថា គប្បីឃើញដោយចក្ខុវិញ្ញាណ ។ រូបដែលឈ្មោះថា សប្បដិឃៈ (ប៉ះខ្ទប់បាន) ដោយការប្រព្រឹត្តទៅព្រមជាមួយវត្ថុដែលប៉ះត្រូវ ញុំាងសេចក្ដីទង្គុកទង្គិចឱ្យកើត ។

បណ្ដាពណ៌ទាំងឡាយ មានពណ៌ខៀវស្រងាត់ជាដើម ពណ៌ខៀវ ដូចផ្កាត្រកៀត; ពណ៌លឿង ដូចផ្កាកណិការ; ពណ៌ក្រហម ដូចផ្កាច្បា; ពណ៌ស ដូចផ្កាយព្រឹក; ពណ៌ខ្មៅ ដូចត្បូងដុត; ពណ៌ហង្សបាទ ក្រហមព្រឿងដូចផ្កាភង្គី និងផ្កាសិន្ទុវារៈ; ក៏មាសត្រាស់ហៅថា "**ហរិ**" ដូចក្នុងពាក្យនេះថា "**ហរិត្ត ច, សាមខណ្ណា, កាមំ សុមុខ បក្កម** = ម្នាលសុមុខៈ អ្នកមានសម្បុរស្អាតដូចមាស លោកចូរគេចចេញតាមប្រាថ្នាចុះ"[២៣] ដូច្នេះ, ទោះជាយ៉ាងនោះ មាសនោះទ្រង់កាន់យកដោយសព្ទថា **ជាតរូប** ខាងមុខពីក្នុងនិទ្ទេសនេះទៅ ឈ្មោះថា **ហរិ** បានដល់ ពណ៌ស្រគាំ ព្រោះមិនបានទ្រង់កាន់យកវត្ថុទាំង ៧ ពួកនេះសម្ដែងដោយសភាវៈនោះទេ ។

បទថា "**ហរិខណ្ណំ** = ពណ៌ខៀវដូចស្លឹកឈើ" គឺដូចស្បូវភ្លាំងស្រស់ ។

បទថា "**អម្ពុរក្ខុខណ្ណំ** = ពណ៌ស្វាយ" គឺពណ៌ដូចពន្លកស្វាយ ។

វត្ថុទាំងពីរទ្រង់កាន់យកសម្ដែងទុកដោយសភាវៈ ។ វត្ថុ ១២ មានវែង និងខ្លីជាដើម ទ្រង់កាន់យកសម្ដែងដោយវោហារ; ឯវោហារនៃបទទាំងឡាយនោះ មានបទវែង និងខ្លីជាដើមនេះ សម្រេចហើយដោយឧបនិធាបញ្ញត្តិ (បញ្ញត្តិដោយប្រៀបធៀប) និងសម្រេចហើយដោយការតាំងទុក ។

ពិតមែន ពាក្យថា **វែង**ជាដើម ជាបទសម្រេចដោយការបញ្ញត្តិ ប្រៀបធៀបនូវគ្នានឹងគ្នា ។ ពាក្យថា **មូល** ជាដើម សម្រេចដោយការតាំងចុះ ។ ក្នុងបទ

---

[២៣] ខុ. ជា. ។

ពីរយ៉ាងនោះ ព្រោះប្រៀបធៀបរូបដែលខ្លីវែងជាងនោះ ទើបឈ្មោះថា វែង, ព្រោះប្រៀបធៀបជាមួយរូបដែលខ្លីជាងនោះ ឈ្មោះថា ខ្លី; ប្រៀបធៀបរូបដែលធំតូចជាងនោះ ឈ្មោះថា **អណុ** = ល្អិត, ប្រៀបធៀបជាមួយរូបដែលតូចជាងនោះ ឈ្មោះថា ធំ ។ រូបដែលមានសណ្ឋានដូចកង់រទេះ ឈ្មោះថា មូល; រូបមានសណ្ឋានដូចពងមាន់ ឈ្មោះថា **បរិមណ្ឌល**; រូបប្រកបដោយជ្រុងទាំងបួន ឈ្មោះថា **ចតុរស្សៈ** = ជ្រុង ៤; សូម្បីរូប ៦ ជ្រុងជាដើម ក៏នំយនេះដែរ ។ បទថា "**និន្នំ** = ទំនាប" បានដល់ រូបដែលទាប ។ បទថា "**ថលំ** = ដីទួល" បានដល់ រូបដែលពូនឡើង ។

បណ្ដារូបវែងជាដើមនោះ ព្រោះបុគ្គលសូម្បីប៉ះត្រូវរូបវែងជាដើម អាចដើម្បីដឹងបាន, តែពណ៌ខៀវជាដើមបុគ្គលប៉ះត្រូវហើយ មិនអាចជ្រាបបាន ព្រោះហេតុដូច្នោះ រូបាយតនៈដែលវែង ទើបមិនបានត្រាស់ទុកដោយត្រង់, រូបដែលខ្លីជាដើម ក៏មិនត្រាស់ទុកដូចគ្នា; តែក្នុងទីនេះ ត្រាស់ថា "វែង ខ្លី" ដូច្នេះ ព្រោះអាស្រ័យរូបនោះៗ ទើបតាំងនៅដោយប្រការនោះៗ គប្បីជ្រាបថា រូបាយតនៈ ក្នុងរូបាយតននិទ្ទេសនេះ ត្រាស់ទុកដោយវោហារនោះៗ ដូច្នេះ ។

បទថា "**ឆាយា អាតបោ** = ស្រមោល ថ្ងៃ" នេះ ទ្រង់កំណត់នូវគ្នានឹងគ្នា; ពន្លឺភ្លឺ និងងងឹត ក៏កំណត់ទុកនូវគ្នានឹងគ្នា ។ បទ ៤ មានបទថា "**អព្ភមហិកា**" ជាដើម សម្ដែងទុកដោយវត្ថុប៉ុណ្ណោះ ។ បណ្ដាបទទាំង ៤ នេះ បទថា "**អព្ភា** = មេឃ" បានដល់ ពពក; បទថា "**មហិកា**" បានដល់ ទឹកសន្សើម; ពណ៌នៃរូប

ទាំងឡាយមានមេឃជាដើម ទ្រង់សម្ដែងទុកដោយបទទាំង ៤ នេះ ។ ដោយបទថា **ចន្ទមណ្ឌលស្ស ខណ្ឌនិកា** ជាដើម ទ្រង់សម្ដែងពណ៌ គឺរស្មីនៃវត្ថុទាំងនោះ ។

ក្នុងវត្ថុមានព្រះចន្ទជាដើមនោះ គប្បីជ្រាបសេចក្ដីផ្សេងគ្នានៃវត្ថុទាំងឡាយ មានដួងព្រះចន្ទជាដើមយ៉ាងនេះ ៖

វិមានរបស់ចន្ទទេវបុត្រ បណ្ដោយ និងទទឹង ៤៩ យោជន៍ សម្រេចដោយកែវមណីបិទបាំងដោយប្រាក់ ឈ្មោះថា **ដួងព្រះចន្ទ** ។ វិមានរបស់សុរិយទេវបុត្រ បណ្ដោយ និងទទឹង ៥០ យោជន៍គត់ សម្រេចដោយមាស បិទបាំងទុកដោយកែវផលិក ឈ្មោះថា **ដួងព្រះអាទិត្យ** ។ វិមានរបស់ទេវបុត្រនោះៗ បណ្ដោយ និងទទឹង ៧ យោជន៍, ៨ យោជន៍, ១០ យោជន៍, ១២ យោជន៍, សម្រេចដោយរតនៈ ៧ ប្រការ ឈ្មោះថា **ដួងតារា** ។

បណ្ដាទេវបុត្រទាំងនោះ ព្រះចន្ទនៅខាងក្រោម, ព្រះអាទិត្យនៅខាងលើ, ចន្លោះព្រះចន្ទ និងព្រះអាទិត្យទាំង ២ មានចម្ងាយមួយយោជន៍; ដោយចំណែកបំផុតខាងក្រោមរបស់ព្រះចន្ទ និងដោយចំណែកបំផុតខាងលើរបស់ព្រះអាទិត្យមានចម្ងាយមួយរយយោជន៍; ដួងនក្ខត្តឫក្ស (ផ្កាយ) ទាំងឡាយរមែងគោចរទៅត្រង់ខាងទាំង ២ ។ ក៏បណ្ដាវត្ថុទាំង ៣ នោះ ព្រះចន្ទគោចរទៅយឺតៗ, ព្រះអាទិត្យគោចរទៅរហ័ស, ដួងផ្កាយទាំងឡាយទៅរហ័សជាងគេទាំងអស់ ។ គ្រាខ្លះគោចរទៅខាងមុខដួងព្រះចន្ទ និងដួងព្រះអាទិត្យ, គ្រាខ្លះ ក៏គោចរទៅខាងក្រោយ ។

បទថា **"អាទាសមណ្ឌលំ** = វង្វង់កញ្ចក់" បានដល់ សម្រេចដោយសិរីទ្ធិ។ ពាក្យថា "កែវមណី" គឺកែវពិទូរ្យដែលសល់មានប្រភេទមិនមែនតិច មានកែវមណីជោតិរសជាដើម ។ ពាក្យថា **"ស័ង្ខ"** បានដល់ ស័ង្ខដែលកើតឡើងឯង (ធម្មជាតិ); កែវមុក្តាក៏កើតឡើងឯង សូម្បីកែវពិទូរ្យដែលសល់ក៏ដូចគ្នា ។

បទថា **"វេឡុរិយោ** = កែវពិទូរ្យ" គឺកែវមណីដែលមានពណ៌ដូចឫស្សី ។ វណ្ណៈរបស់ព្រះសាស្តា ហៅថា ជាតរូប (មាស); ពិតមែន ព្រះសាស្តាមានវណ្ណៈដូចមាស, សូម្បីវណ្ណៈរបស់មាស ក៏ហៅថា វណ្ណៈព្រះសាស្តា ។ កហាបណៈ គឺ **លោហមាសកៈ** (មាសកៈធ្វើដោយលោហៈ) **ទារុមាសកៈ** (មាសកៈធ្វើដោយឈើ) **ជតុមាសកៈ** (មាសកៈធ្វើដោយជ័រ) ហៅថា **រជតៈ** (ប្រាក់)។ អធិប្បាយថា ម្យ៉ាងទៀត មាសកៈណាដល់នូវការចាយវាយបាន, សូម្បីមាសកៈទាំងអស់នោះ ក៏លោកកាន់យកក្នុងបទថា **រជតំ** នេះដែរ[៤១] ។

ដោយបទថា **"យំ វា បនញ្ញម្បិ** = ឬសូម្បីរូបដទៃណា" នេះ វៀររូបដែលត្រាស់ទុកក្នុងបាលី ទ្រង់កាន់យករូបដ៏សេស ដែលផ្សេងដោយពណ៌កន្ទេលផែង ពណ៌សំពត់ចាស់ និងពណ៌ផ្ទៃមេឃជាដើម, ព្រោះពណ៌ទាំងអស់នោះ រួមនៅក្នុងរូបដែលជា**យេវាបនកធម៌**ទាំងឡាយ ។ សូម្បីរូបនេះឯង ផ្សេងគ្នាដោយប្រភេទមានពណ៌ខៀវជាដើម, តែរូបទាំងអស់នោះ ក៏មិនបានផ្សេងគ្នាដោយលក្ខណៈ

---

[២៤] វិនយ. ៣ ។

ជាដើមដែរ ៕

## សម្តែងអំពីលក្ខណាទិចតុក្កៈរបស់រូប

ពិតមែនហើយ សូម្បីរូបទាំងអស់នេះ ៖

**ចក្ខុបដិហននលក្ខណំ** មានការប៉ះខ្ទប់ចក្ខុជាលក្ខណៈ

**ចក្ខុវិញ្ញាណស្ស វិសយភាវរសំ** មានភាពជាអារម្មណ៍របស់ចក្ខុវិញ្ញាណជារស ។

**តស្សេវ គោចរបច្ចុប្បដ្ឋានំ** មានសេចក្តីជាអារម្មណ៍របស់ចក្ខុវិញ្ញាណនោះឯង ជាបច្ចុប្បដ្ឋាន ។

**ចតុមហាភូតរូបបទដ្ឋានំ** មានមហាភូតរូប ៤ ជាបទដ្ឋាន[២៤] ។

ក៏ឧបាទាយរូបទាំងអស់ដូចជារូបនេះដែរ; ខ្ញុំនឹងពោលរូបដែលប្លែកផ្សេងគ្នា, រូបដ៏សេស ក្នុងនិទ្ទេសនេះ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងចក្ខាយតននិទ្ទេសនោះចុះ ។

ពិតមែន ក្នុងចក្ខាយតននិទ្ទេសនោះ និទ្ទេសមានចក្ខុជាប្រធានតែម្យ៉ាង, តែរូបាយតននិទ្ទេសនេះមានរូបជាប្រធាន ។ ក្នុងចក្ខាយតននិទ្ទេសនោះ មានឈ្មោះ ១០ យ៉ាង មានពាក្យថា “**ចក្ខុះមេ្បតំ** = រូបនេះជាចក្ខុខ្លះ” ជាដើម, ឯក្នុងរូបាយតននិទ្ទេសនេះមានឈ្មោះ ៣ យ៉ាង មានពាក្យថា “**រូបះមេ្បតំ** = នេះហៅថា រូប

---

វិសុទ្ធិ. ៣/ (ខន្ធនិទ្ទេស)។

ខ្លះ, រូបាយតនៈខ្លះ, រូបធាតុខ្លះ” ជាដើម, រូបដ៏សេសដូចជាមួយគ្នានោះឯង; សូម្បីក្នុងរូបាយតននិទ្ទេសនេះ ក៏ត្រាស់វារៈទាំងឡាយទុក ដូចត្រាស់វារៈ ១៣ ដើម្បីកំណត់ចក្ខុប្រដាប់ដោយន័យ ៤ វារៈដូចគ្នាដែរ ៕

## អដ្ឋកថាសទ្ទាយតននិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **សទ្ទាយតនៈ** ដូចតទៅ ៖

បទថា “**ភេរិសទ្ទោ** = សំឡេងស្គរ” បានដល់ សំឡេងស្គរធំ និងសំឡេងស្គរដែលគេវាយ ។ សូម្បីសំឡេងស្គរសម្ភោរ សំឡេងសង្ខ សំឡេងបណវៈ (ស្គរជ័យ)* ក៏ជាសំឡេង មានសំឡេងស្គរសម្ភោរជាដើមជាបច្ច័យ ។ សំឡេងដែលហៅថា ភ្លេងចម្រៀង ឈ្មោះថា សំឡេងច្រៀង ។ សំឡេងតន្ត្រីជាប់ទាក់ទងដោយពិណជាដើមសល់ពីសំឡេងដែលពោលហើយ ឈ្មោះថា **វាទិតសទ្ទោ** = សំឡេងប្រគុំ ។

បទថា “**សម្មសទ្ទោ** = សំឡេងវាយធ្វើភ្លេង” បានដល់ សំឡេងខាត់សំរិទ្ធិ និងសំឡេងនៃឈើត្នោត ។ បទថា “**បាណិសទ្ទោ** = សំឡេងបាតដៃ” បានដល់ សំឡេងទះដោយបាតដៃ ។ បទថា “**សត្តានំ និគ្ឃោសសទ្ទោ** = សំឡេងស្រែករបស់សត្វ” បានដល់ សំឡេងដែលបញ្ចេញដោយមានបទ និងព្យញ្ជនៈមិនប្រាកដរបស់សត្វច្រើនដែលប្រជុំគ្នា ។ បទថា “**ធាតូនំ សន្និបាតសទ្ទោ** = សំឡេង

---

* ស្គរដែលគេវាយក្នុងពេលសម្លាប់មនុស្ស ឬក្នុងពេលឈ្នះសង្គ្រាម ។

ប៉ះខ្ទប់គ្នារបស់ធាតុទាំងឡាយ” បានដល់ សំឡេងត្រកិតត្រកួតនូវគ្នានឹងគ្នានៃដើមឈើទាំងឡាយ និងសំឡេងវាយចួងជាដើម ។ សំឡេងរបស់ខ្យល់ផាត់ ឈ្មោះថា សំឡេងខ្យល់ ។ សំឡេងរបស់ទឹកកំពុងហូរ ឬទឹកប៉ះខ្ទប់គ្នា ឈ្មោះថា សំឡេងទឹក ។ សំឡេងសន្ទនាជាដើមរបស់ពួកមនុស្ស ឈ្មោះថា **សំឡេងមនុស្ស** ។ វៀរសំឡេងមនុស្សនោះចេញ សូម្បីសំឡេងដ៏សេសទាំងអស់ ឈ្មោះថា សំឡេងអមនុស្ស ។ ដោយបទទាំងពីរ ក៏សំឡេងមនុស្ស និងសំឡេងអមនុស្សនេះ សំឡេងទាំងអស់ជាការកាន់យកហើយ ។ សូម្បីកាលបើដូច្នេះ សំឡេងដែលមិនត្រាស់ទុកក្នុងព្រះបាលីដែលប្រព្រឹត្តទៅក្នុងវេលាពុះដើមឫស្សី និងហែកក្រណាត់សំពត់ចាស់ជាដើម គប្បីជ្រាបថា រួមចូលក្នុងខថា **យេវាបនកសទ្ទ**; សូម្បីសំឡេងផ្សេងគ្នាដោយប្រភេទមានសំឡេងស្គរជាដើមយ៉ាងនេះ, តែមិនបានផ្សេងគ្នាដោយលក្ខណៈជាដើមឡើយ ៕

## សម្តែងអំពីលក្ខណាទិចតុក្កៈរបស់សំឡេង

**សទ្ទោ ចេសោ សោតបដិហននលក្ខណោ សទ្ទោ** ក៏សំឡេងទាំងអស់ មានការប៉ះខ្ទប់ជាមួយសោតៈជាលក្ខណៈ ។

**សោតវិញ្ញាណស្ស វិសយភាវរសោ** មានភាពជាអារម្មណ៍របស់សោតវិញ្ញាណជាកិច្ច ។

**តស្សេវ គោចរបច្ចុបដ្ឋានោ** មានភាពជាគោចរ (អារម្មណ៍) របស់សោតវិញ្ញាណនោះឯងជាបច្ចុប្បដ្ឋាន ។

ពាក្យដ៏សេសគប្បីជ្រាបដោយន័យ ដែលពោលទុកក្នុងចក្ខាយតននិទ្ទេស នោះឯង; សូម្បីក្នុងសទ្ទាយតននិទ្ទេសនេះ ក៏ត្រាស់វារៈ ១៣ វារៈ ប្រដាប់ដោយន័យបួន១; សេចក្តីនៃបទនោះ អាចដឹងបានដោយន័យដែលពោលទុកហើយនុ៎ះឯង ព្រោះហេតុដូច្នោះ ទើបមិនបានឱ្យពិស្តារឡើយ ៕

## អដ្ឋកថាគន្ធាយតននិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **គន្ធាយតនៈ** ដូចតទៅ ៖

បទថា **“មូលគន្ធោ** = ក្លិនឫសឈើ” បានដល់ ក្លិនដែលកើតឡើងអាស្រ័យឫសឈើយ៉ាងណាមួយ ។ សូម្បីក្នុងក្លិនឈើជាដើម ក៏ន័យនេះដែរ ។ ក្លិនបន្លែជ្រក់ជាដើម ដែលនៅមិនសម្រេចហើយ ឬសម្រេចមិនល្អ ឈ្មោះថា **អាមគន្ធោ** = ក្លិនឆ្អាប ។ ក្លិនស្រកាត្រី ក្លិនសាច់ស្អុយ ក្លិនទឹកដោះថ្លាខូចជាដើម ឈ្មោះថា **វិសគន្ធោ** = ក្លិនស្អុយ ។

បទថា **“សុគន្ធោ** = ក្លិនក្រអូប” បានដល់ ក្លិនដែលគួរប្រាថ្នា ។ បទថា **“ទុគ្គន្ធោ** = ក្លិនស្អុយ” បានដល់ ក្លិនមិនគួរប្រាថ្នា ។ ដោយបទទាំង ២ គឺក្លិនក្រអូប និងក្លិនស្អុយនេះ រមែងជាការពោលសូម្បីដល់ក្លិនទាំងអស់ដែលទ្រង់កាន់យកហើយ ។ កាលបើដូច្នេះ សូម្បីក្លិនទាំងអស់ដែលមិនត្រាស់ទុកក្នុងព្រះបាលីមានក្លិនដើមភង្គី និងក្លិនសំពត់ចាស់ជាដើម គប្បីជ្រាបថារួមនៅត្រង់ **យេវាបនក**-

គន្ធៈ ។ សូម្បីក្លិននេះនឹងផ្សេងគ្នាដោយក្លិនមានឫសជាដើមយ៉ាងនេះ ពោលដោយលក្ខណាទិចតុក្កៈហើយ ក៏មិនផ្សេងគ្នាឡើយ ៕

## សម្តែងអំពីលក្ខណាទិចតុក្កៈរបស់ក្លិន

**សព្វោបិ ចេសោ ឃានបដិហននលក្ខណោ គន្ធោ** ក៏សូម្បីក្លិនទាំងអស់ មានការប៉ះខ្ទប់ឃានៈជាលក្ខណៈ ។

**ឃានវិញ្ញាណស្ស វិសយភាវរសោ** មានភាពជាអារម្មណ៍របស់ឃានវិញ្ញាណជារស ។

**តស្សេវ គោចរបច្ចុបដ្ឋានោ** មានភាពជាគោចររបស់ឃានវិញ្ញាណនោះឯង ជាបច្ចុប្បដ្ឋាន ។

ពាក្យដ៏សេសគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងចក្ខាយតននិទ្ទេសនោះឯង; សូម្បីក្នុងគន្ធាយតននិទ្ទេសនេះ ក៏ត្រាស់វារៈ ១៣ ប្រដាប់ដោយន័យ ៥២ ដែរ; ពោលដោយអត្ថវារៈទាំងនោះ ជាក់ច្បាស់ហើយមែនពិត ៕

## អដ្ឋកថារសាយតននិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **រសាយតនៈ** ដូចតទៅ ៖

បទថា “**មូលរសោ** = រសឫសឈើ” បានដល់ រសដែលអាស្រ័យ

ឫសឈើយ៉ាងណាមួយហើយកើតឡើង ។ សូម្បីក្នុងរសឈើជាដើម ក៏នំយនេះដែរ ។ បទថា “**អម្ពិលំ** = ជូរ” បានដល់ ទឹកដោះរាវជូរជាដើម ។ បទថា “**មធុរំ** = ផ្អែម” បានដល់ រសមានទឹកដោះថ្លានៃគោជាដើមម្យ៉ាង ។ ចំណែក ទឹកឃ្មុំផ្សំជាមួយរសចត់រក្សាទុកយូរទៅ ក៏ក្លាយជារសចត់មែនពិត, ទឹកអំពៅ ផ្សំជាមួយរសល្វីង រក្សា ទុកយូរទៅ ក៏ក្លាយជារសល្វីងមែនពិត; តែសប្បិ (ទឹក ដោះថ្លា) រក្សាទុកយូរ សូម្បីលះពណ៌ និងក្លិន ក៏នៅតែមិនលះរស ព្រោះ ហេតុដូច្នោះ ទឹកដោះថ្លានោះនុ៎ះឯង ទើបឈ្មោះថា ផ្អែមដោយចំណែកម្យ៉ាង ។

បទថា “**តិត្តកំ** = ល្វីង” បានដល់ ស្លឹកស្ដៅជាដើម ។ បទថា “**កដុកំ** = ហឹរ” បានដល់ រសខ្ញី និងម្រេចជាដើម ។ បទថា “**លោណិកំ** = អំបិល” បាន ដល់ អំបិលធម្មជាតិជាដើម ។ បទថា “**ខារិកំ** = ខារ” បានដល់ រសត្រប់ខារ និង ពន្លកឈើជាដើម ។ បទថា “**លម្ពិលំ** = ជូរលាយផ្អែម” បានដល់ ពុទ្រា កន្ទួតព្រៃ និងខ្វិតជាដើម ។ បទថា “**កសាវំ** = ចត់” បានដល់ ស្រម៉ជាដើម ។

សូម្បីរសទាំងអស់នេះ ត្រាស់ទុកដោយអំណាចនៃវត្ថុ; តែក្នុងនិទ្ទេសនេះ គប្បីជ្រាបថា រសត្រាស់ទុកដោយឈ្មោះ មានឈ្មោះថា ជូរជាដើមអំពីវត្ថុនោះៗ ។

បទថា “**សាទុ** = ឆ្ងាញ់” បានដល់ រសដែលគួរប្រាថ្នា ។ បទថា “**អសាទុ** = មិនឆ្ងាញ់” បានដល់ រសដែលមិនគួរប្រាថ្នា ។ ដោយបទទាំង ២ គឺរសដែលគួរ ប្រាថ្នា និងរសដែលមិនគួរប្រាថ្នានេះ សូម្បីរសទាំងអស់ជាការដែលទ្រង់កំណត់យក

ហើយ; លុះកាលបើមានសេចក្ដីយ៉ាងនោះ រសទាំងអស់ដែលមិនត្រាស់ទុកក្នុងព្រះបាលី មានរសដុំដី រសជញ្ជាំងផ្ទះ និងរសសំពត់ចាស់ជាដើម គប្បីជ្រាបថា រួមចូលក្នុង**យេវាបនករស** ។ សូម្បីរសនេះផ្សេងគ្នាដោយឫសឈើជាដើមយ៉ាងនេះ, តែពោលដោយលក្ខណៈជាដើម ក៏មិនប្លែកគ្នាឡើយ ៕

## សម្ដែងអំពីលក្ខណាទិចតុក្កៈរបស់រស

**សព្វោ បេសោ ជិវ្ហាបដិហននលក្ខណោ រសោ** រសមានការប៉ះខ្ទប់អណ្ដាត ជាលក្ខណៈ ។

**ជិវ្ហាវិញ្ញាណស្ស វិសយភាវរសោ** មានភាពជាអារម្មណ៍របស់ជិវ្ហា-វិញ្ញាណជារស ។

**តស្សេវ គោចរបច្ចុបដ្ឋានោ** មានភាពជាគោចររបស់ជិវ្ហានោះឯង ជា បច្ចុប្បដ្ឋាន ។

ពាក្យដែលសល់គប្បីជ្រាបដោយន័យ ដែលពោលទុកក្នុងចក្ខាយតន-និទ្ទេសនោះឯង; សូម្បីក្នុងនិទ្ទេសនេះ ក៏ត្រាស់វារៈ ១៣ ប្រដាប់ដោយន័យ ៥២ ដូចគ្នានោះដែរ ៕

## អដ្ឋកថាឥត្ថិន្ទ្រិយនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ឥត្ថិន្ទ្រិយ** ដូចតទៅ ៖

បទថា **“យំ”** ជាតតិយាវិភត្តិ, ក្នុងខនេះអធិប្បាយថា ទ្រង់ទ្រាយទាំង-ឡាយមានទ្រង់ទ្រាយស្ត្រីជាដើម រមែងមានដល់ស្ត្រីដោយហេតុណា ។ បណ្ដាបទទាំងនោះ បទថា **“លិង្គំ”** បានដល់ ទ្រង់ទ្រាយ (សណ្ឋាន) ។ ពិតមែន ទ្រង់ទ្រាយនៃអវយវៈមានដៃ, ជើង, ក និងពោះ (ឧទរ) ជាដើមរបស់ស្ត្រី មិនដូចរបស់បុរសទេ; ព្រោះកាយកំណាត់ខាងក្រោមរបស់ស្ត្រីទាំងឡាយរឹងប៉ឹង, កាយកំណាត់ខាងលើមិនរឹងប៉ឹង, ដៃជើងតូច, មាត់តូច ។

បទថា **“និមិត្តំ** = គ្រឿងសម្គាល់” បានដល់ ជាហេតុដឹងបានច្បាស់; ពិតមែន សាច់ជើងរបស់ស្ត្រីទាំងឡាយរឹងប៉ឹង, មុខមិនមានពុកមាត់ពុកចង្កា, សូម្បីចងសំពត់រឹតសក់ ក៏មិនដូចរបស់ពួកបុរស ។ បទថា **“កុត្តំ”** បានដល់ កិរិយា គឺការធ្វើ; ព្រោះថា ពួកស្ត្រីទាំងឡាយក្នុងវេលានៅក្មេង រមែងលេងចង្អេរ និងអង្រែតូចៗ, រមែងលេងតុក្កតា, យកដីស្អិត និងផ្ទៃមកវេញជាអម្បោះ ។

បទថា **“អាកប្បោ** = អាការៈ” បានដល់ អាការៈ គឺការដើរជាដើម; ព្រោះថា ស្ត្រីទាំងឡាយកាលបើដើរមិនលឿន, កាលបើឈរ, ដេក, អង្គុយ, ទំពាស៊ីបរិភោគ ក៏ឈរ, ដេក, អង្គុយ, ទំពាស៊ី, បរិភោគ មិនរហ័ស; កាលបើបរិភោគ ក៏បរិភោគយ៉ាងយឺត; ពិតមែន ជនទាំងឡាយឃើញមនុស្ស សូម្បីជាបុរសយឺតយ៉ាវ

ក៏និយាយថា "មនុស្សប្រុសនេះដើរ, ឈរ, អង្គុយ, ដេក, ទំពាស៊ី, បរិភោគ ដូចជាស្រី" ដូច្នេះ ។

បទថា "**ឥត្ថិត្តំ ឥត្ថិភាវោ** = ភាវៈស្ត្រី ភាវៈរបស់ស្ត្រី" សូម្បីទាំង ២ នេះ មានសេចក្តីសម្គាល់តែម្យ៉ាងដូចគ្នា, គឺជាសភាវៈរបស់ស្រី; ក៏សភាវៈរបស់ស្រីនេះ កើតពីកម្ម តាំងឡើងព្រមជាមួយចិត្តក្នុងបដិសន្ធិកាល; ចំណែកទ្រង់ទ្រាយស្ត្រីជាដើម មិនតាំងឡើងក្នុងបដិសន្ធិកាលដូចឥត្ថិន្ទ្រិយទេ, តែក៏អាស្រ័យឥត្ថិន្ទ្រិយតាំងឡើងក្នុងបវត្តិកាល ។ ដូចយ៉ាងថា កាលពីជៈ (គ្រាប់ពូជ) មានដើមឈើអាស្រ័យពីជៈ ព្រោះពីជៈជាបច្ច័យ ទើបចម្រើនធំធាត់ សម្បូរណ៍ដោយមែក និងចំពាមតាំងនៅពេញចន្លោះទទេ យ៉ាងណា, លុះកាលឥត្ថិន្ទ្រិយ គឺភាពជាស្ត្រីមានពិតអវយវៈមានទ្រង់ទ្រាយនៃស្ត្រីជាដើម ក៏មានដូច្នោះដែរ ។ ក៏ឥត្ថិន្ទ្រិយប្រៀបដូចពូជ, ទ្រង់ទ្រាយជាស្ត្រីជាដើម អាស្រ័យឥត្ថិន្ទ្រិយ រមែងតាំងឡើងក្នុងបវត្តិកាល ប្រៀបដូចដើមឈើ អាស្រ័យពូជចម្រើនធំធាត់ ហើយតាំងនៅពេញចន្លោះទទេ ដូច្នោះ ។

បណ្តាឥត្ថិន្ទ្រិយទាំងឡាយនោះ ឥត្ថិន្ទ្រិយមិនគប្បីដឹងដោយចក្ខុវិញ្ញាណទេ, គប្បីដឹងដោយមនោវិញ្ញាណប៉ុណ្ណោះ ។ ទ្រង់ទ្រាយរបស់ស្ត្រីជាដើម ដឹងបានតាមចក្ខុវិញ្ញាណខ្លះ តាមមនោវិញ្ញាណខ្លះ។

បទថា "**ឥទន្តំ រូបំ ឥត្ថិន្ទ្រិយំ** = រូបនេះឯង ហៅថា ឥត្ថិន្ទ្រិយ"

សេចក្ដីថា រូបនេះឯងមិនដូចជាចក្ខុន្ទ្រិយជាដើមសូម្បីជារបស់បុរសទេ; តែកាលពោលដោយនិយម ( ការកំណត់) ឥត្ថិន្ទ្រិយរបស់ស្ត្រីហ្នឹងឯង ឈ្មោះថា ឥត្ថិន្ទ្រិយ៕

## អដ្ឋកថាបុរិសិន្ទ្រិយនិទ្ទេស

សូម្បីក្នុងបុរិសិន្ទ្រិយ ក៏នំយនេះដែរ; តែទ្រង់ទ្រាយរបស់បុរសជាដើម គប្បីដឹងដោយសេចក្ដីផ្ទុយគ្នា ជាមួយទ្រង់ទ្រាយរបស់ស្ត្រីជាដើម; ព្រោះសណ្ឋាននៃអវយវៈមានដៃ, ជើង, ក និងពោះជាដើមរបស់បុរស មិនដូចរបស់ស្ត្រី, ព្រោះថាកាយកំណាត់ខាងលើរបស់បុរសមាំមួន, កាយកំណាត់ខាងក្រោមមិនមាំមួន; ដៃជើងក៏ធំ, មាត់ក៏ធំ, សាច់ជើងមិនធំ, ដុះពុកមាត់ ពុកចង្កា, ការប្រើសំពត់ចងសក់ក៏មិនដូចរបស់ស្ត្រីទាំងឡាយ, ក្នុងវេលានៅក្មេង រមែងលេងរថ និងនង្គ័លជាដើម, រមែងធ្វើពំនូកខ្សាច់ ដោយខ្សាច់ជាដើម រមែងជីកនូវក្រឡុក, សូម្បីការដើរជាដើមក៏រមែងអង់អាច ជនទាំងឡាយឃើញស្ត្រី អ្នកធ្វើការដើរជាដើមអង់អាច រមែងនិយាយពាក្យជាដើមថា “សូម្បីមនុស្សនេះរមែងដើរដូចបុរស” ។ ពាក្យដ៏សេសដូចជាពាក្យដែលពោលទុកក្នុងឥត្ថិន្ទ្រិយនោះដែរ ៕

## សម្តែងអំពីលក្ខណាទិចតុក្កៈ

បណ្តាឥន្ទ្រិយទាំង ២ នោះ ៖

**ឥត្ថីភាវលក្ខណំ ឥត្ថិន្ទ្រិយំ** ឥត្ថិន្ទ្រិយមានឥត្ថីភាវៈជាលក្ខណៈ

**ឥត្ថីតិ បកាសនរសំ** មានការប្រកាសនូវភេទស្រី ជារស

**ឥត្ថីលិង្គនិមិត្តកុត្តាកប្បានំ ករណភាវបច្ចុប្បដ្ឋានំ** មានភាវៈនៃការធ្វើនូវសណ្ឋាន និមិត្ត ការលេង និងកិរិយាអាការៈរបស់ស្ត្រី ជាបច្ចុប្បដ្ឋាន ។

**បុរិសភាវលក្ខណំ បុរិសិន្ទ្រិយំ** បុរិសិន្ទ្រិយមានបុរិសភាវៈជាលក្ខណៈ

**បុរិសោតិ បកាសនរសំ** មានការប្រកាសនូវភេទប្រុស ជារស

**បុរិសលិង្គនិមិត្តកុត្តាកប្បានំ ករណភាវបច្ចុប្បដ្ឋានំ** មានភាវៈនៃការធ្វើនូវសណ្ឋាន និមិត្ត ការលេង និងកិរិយាអាការៈរបស់បុរសជាបច្ចុប្បដ្ឋាន ។

សូម្បីភាវរូបទាំងពីររបស់បុគ្គលអ្នកកើតក្នុងបឋមកប្បនេះ រមែងតាំងឡើងក្នុងបវត្តិកាល, ខាងក្រោយមក ភាវរូបទាំងពីរនេះ ក៏តាំងឡើងក្នុងបដិសន្ធិកាល; សូម្បីតាំងឡើងក្នុងបដិសន្ធិកាលក៏រមែងញាប់ញ័រ រមែងផ្លាស់បានក្នុងបវត្តិកាល ។

ដូចយ៉ាងព្រះតម្រាស់ដែលត្រាស់ទុកក្នុងព្រះបាលីវិនីតវត្ថុ នៃបឋមបារាជិកថា “ក៏សម័យនោះឯង ភេទស្រីប្រាកដដល់ភិក្ខុមួយរូប, ភេទប្រុសប្រាកដដល់ភិក្ខុនីមួយរូប”[២៥] ។

---

[២៥] វិនយ. ១។

ក៏បណ្តាភេទទាំង ២ នេះ ភេទប្រុសជាឧត្តមភេទ, ភេទស្រី ជាហីនភេទ, ព្រោះហេតុដូច្នោះ ភេទប្រុសរមែងអន្តរធានទៅ ព្រោះអកុសលមានកម្លាំង, ភេទស្រី រមែងតាំងឡើងដោយកុសលដែលទុព្វល (កម្លាំងខ្សោយ); តែភេទស្រីកាលអន្តរធាន រមែងអន្តរធានទៅដោយអកុសលដែលទុព្វល, ភេទប្រុសរមែងតាំងឡើងដោយកុសលដែលមានកម្លាំង ។ គប្បីជ្រាបសូម្បីភាវរូបទាំងពីរយ៉ាងនេះ រមែងអន្តរធានទៅដោយអកុសល, រមែងតាំងឡើងដោយកុសល មានប្រការដូច្នេះ ៕

## សម្តែងអំពីឧភតោព្យញ្ជនកៈ

**សួរថា** បុគ្គលជាឧភតោព្យញ្ជនកៈ មានឥន្ទ្រិយ ១ ឬមានឥន្ទ្រិយ ២ ?

ឆ្លើយថា មានឥន្ទ្រិយ ១; ក៏ឥន្ទ្រិយរបស់ស្រីអ្នកជាឧភតោព្យញ្ជនកៈនោះនឹងជាឥត្ថិន្ទ្រិយរបស់បុរសអ្នកជាឧភតោព្យញ្ជនកៈ ជាបុរិសិន្ទ្រិយ ។

**សួរថា** កាលបើដូច្នោះ ព្យញ្ជនៈ (គ្រឿងសម្គាល់) ទី ២ នឹងមិនប្រាកដ, ព្រោះត្រាស់ទុកថា ឥន្ទ្រិយសម្តែងគ្រឿងចំណាំភេទ និងឥន្ទ្រិយរបស់បុគ្គល អ្នកជាឧភតោព្យញ្ជនកៈនោះក៏មិនមាន ។

ឆ្លើយថា ឥន្ទ្រិយរបស់បុគ្គលនោះ ជាគ្រឿងសម្តែងភេទក៏មិនមែន ។

**សួរថា** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះមិនមាននៅគ្រប់ពេលវេលាទេ ។

ព្រោះថា កាលណា ចិត្តត្រេកអររបស់ឥត្ថីឧភតោព្យញ្ជនកៈកើតក្នុងស្រី, ក៏ក្នុងកាលនោះ គ្រឿងសម្គាល់ភេទប្រុសរមែងប្រាកដ, គ្រឿងសម្គាល់ភេទស្រីរមែងបិទបាំងលាក់ទុក; បុរិសឧភតោព្យញ្ជនកៈក្រៅនេះ ក៏មានគ្រឿងសម្គាល់ភេទស្រីក្រៅនេះដូចគ្នា; ប្រសិនបើឥន្ទ្រិយរបស់ឧភតោព្យញ្ជនកៈពួកនេះ គប្បីមានគ្រឿងចំណាំទាំងពីរសោត, គ្រឿងចំណាំភេទទាំងពីរ ក៏គប្បីតាំងនៅសូម្បីក្នុងកាលគ្រប់កាល, តែថា មិនបានតាំងនៅទេ; ព្រោះហេតុដូច្នោះ ឥន្ទ្រិយនោះ គប្បីជ្រាបពាក្យនេះថា ឥន្ទ្រិយរបស់ឧភតោព្យញ្ជនកៈនោះ ជាហេតុនៃគ្រឿងចំណាំភេទមិនបាន; តែក្នុងទីនេះ ហេតុ គឺចិត្តសម្បយុត្តដោយរាគៈមានកម្មជាមិត្ត ក៏ព្រោះឥន្ទ្រិយរបស់ឧភតោព្យញ្ជនកៈនោះ មានត្រឹមតែមួយប៉ុណ្ណោះ, ព្រោះហេតុដូច្នោះ ឥត្ថីឧភតោ-ព្យញ្ជនកៈសូម្បីខ្លួនឯងក៏តាំងគភ៌បាន, រមែងធ្វើឱ្យបុគ្គលដទៃតាំងគភ៌ក៏បាន ។ ចំណែកបុរិសឧភតោព្យញ្ជនកៈរមែងធ្វើបុគ្គលដទៃឱ្យតាំងគភ៌បាន, តែខ្លួនឯងរមែងតាំងគភ៌មិនបានឡើយ ៕

## អដ្ឋកថាជីវិតិន្ទ្រិយនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃជីវិតិន្ទ្រិយ ពាក្យណាដែលខ្ញុំគួរពោលក្នុងជីវិតិន្ទ្រិយនិទ្ទេសនេះ, ពាក្យនោះខ្ញុំពោលទុកក្នុងអរូបជីវិតិន្ទ្រិយ ក្នុងគ្រាក្រោយមែនពិត; ក៏ក្នុងអរូបជីវិតិន្ទ្រិយនោះ ត្រាស់ទុកថា “អរូបធម៌ណា របស់អរូបធម៌

ទាំងនោះ” ដូច្នេះ, តែក្នុងជីវិតិន្ទ្រិយនិទ្ទេសនេះត្រាស់ថា “រូបធម៌ណារបស់រូបធម៌ពួកនោះ” ព្រោះភាពជារូបជីវិតិន្ទ្រិយ, នេះជាសេចក្ដីផ្សេងគ្នា; តែលក្ខណៈជាដើមរបស់រូបជីវិតិន្ទ្រិយនោះ គប្បីជ្រាបយ៉ាងនេះថា ៖

**សហជាតរូបានុបាលនលក្ខណំ ជីវិតិន្ទ្រិយំ** ជីវិតិន្ទ្រិយមានការតាមរក្សារូបដែលកើតព្រមគ្នាជាលក្ខណៈ ។

**តេសំ បវត្តនរសំ** មានការប្រព្រឹត្តទៅរបស់រូបធម៌ទាំងនោះជារស ។

**តេសំយេវ ឋបនបច្ចុប្បដ្ឋានំ** មានការតាំងទុកនូវរូបធម៌ទាំងនោះនុ៎ះឯង ជាបច្ចុប្បដ្ឋាន ។

**យាបយិតព្វភូតបទដ្ឋានំ** មានភូតរូបដែលញ៉ាំងរូបធម៌ឱ្យប្រព្រឹត្តទៅជាបទដ្ឋាន[២៦] ៕

## អដ្ឋកថាកាយវិញ្ញត្តិនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **កាយវិញ្ញត្តិ** ដូចតទៅ ៖

ក្នុងខថា កាយវិញ្ញត្តិនេះឯង, សភាវៈដែលឈ្មោះថា **វិញ្ញត្តិ** ព្រោះអត្ថថាភាវៈនៃមនុស្សទាំងឡាយក្ដី ឬសត្វតិរច្ឆានទាំងឡាយក្ដី ឱ្យដឹងភាវៈរបស់ខ្លួនដោយ

---

[២៦] វិសុទ្ធិ. ៣ (**ខន្ធនិទ្ទេស**) ។

កាយ សូម្បីសត្វតិរច្ឆាន ក៏ដឹងបំណងរបស់មនុស្សបាន សូម្បីមនុស្ស ក៏ដឹងបំណងរបស់សត្វបាន ដោយសភាវធម៌ដែលកាន់យកនេះ តាមទំនងនៃការកាន់យកកាយ ។

ន័យម្យ៉ាងទៀត ដែលឈ្មោះថា **វិញ្ញត្តិ** ព្រោះអត្ថថា ខ្លួនឯងរមែងឱ្យអ្នកដទៃដឹងបាន តាមទំនងនៃការកំណត់កាយ ។ វិញ្ញត្តិ គឺកាយ បានដល់ ការកម្រើកកាយដែលត្រាស់ទុកក្នុងពាក្យមានជាអាទិ៍ថា **"កាយេន សំវរោ សាធុ** = ការសង្រួមកាយជាការល្អ"[២៧] ដូច្នេះ ឈ្មោះថា **កាយវិញ្ញត្តិ** ។

ម្យ៉ាងវិញទៀត ដែលឈ្មោះថា **កាយវិញ្ញត្តិ** ព្រោះអត្ថថា រមែងសម្តែងឱ្យដឹងដោយកាយ ព្រោះជាហេតុឱ្យដឹងសេចក្តីប្រាថ្នា ដោយការកម្រើកកាយផ្សេងៗ និងព្រោះខ្លួនឯងក៏នឹងគប្បីដឹង ដោយប្រការដូច្នេះ ។

ក្នុងពាក្យមានជាអាទិ៍ថា **"កុសលចិត្តស្ស វា** = របស់បុគ្គលអ្នកមានចិត្តជាកុសល" អធិប្បាយថា ចិត្តរបស់បុគ្គលអ្នកមានចិត្តជាកុសល ដោយចិត្ត ៩ គឺ កាមាវចរកុសលចិត្ត ៨ ដួង, អភិញ្ញាចិត្ត ១ ដួង ឬអ្នកមានចិត្តជាអកុសល ដោយអកុសល ១២ ដួង ឬក៏មានចិត្តដែលជាអព្យាកតៈ ដោយកិរិយាចិត្ត ១១ ដួង គឺ មហាកិរិយាចិត្ត ៨ ដួង, បរិត្តកិរិយាចិត្ត ២ ដួង អភិញ្ញាដែលជារូបាវចរកិរិយាចិត្ត ១ ដួង; ចិត្តដទៃៗ ពីនេះ រមែងមិនញុំាងវិញ្ញត្តិឱ្យកើតបាន, ក៏ព្រះសេក្ខៈ, ព្រះអសេក្ខៈ និងបុថុជ្ជនក៏មានវិញ្ញត្តិ ដោយចិត្តមានប្រមាណប៉ុណ្ណេះឯង ព្រោះហេតុដូច្នោះ ទើប

---
[២៧] ខុ. ធ. ។

ព្រះអង្គទ្រង់សម្តែងវិញ្ញត្តិថាជាហេតុ ដោយបទទាំង ៣ ដោយអំណាចនៃធម៌មានកុសលជាដើមនេះ (កុសល អកុសល និងកិរិយា) ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងវិញ្ញត្តិដោយផល ដោយបទទាំង ៦ * ទើបត្រាស់ថា "**អភិក្កមន្តស្ស វា** = ឈានទៅមុខ" ជាដើម ។ ពិតមែន ការឈានទៅជាដើម ឈ្មោះថា ផលរបស់វិញ្ញត្តិ ព្រោះប្រព្រឹត្តទៅដោយអំណាចវិញ្ញត្តិ ។ បណ្តាបទទាំងឡាយមានការឈានទៅជាដើមនោះឯង បទថា "**អភិក្កមន្តស្ស** = ឈានទៅ" បានដល់ នាំកាយទៅខាងមុខ; បទថា "**បដិក្កមន្តស្ស** = ត្រឡប់ថយក្រោយ" បានដល់ នាំកាយត្រឡប់មកខាងក្រោយ; បទថា "**អាលោកេន្តស្ស** = ក្រឡេកមើល" បានដល់ ក្រឡេកមើលត្រង់ៗ។ បទថា "**វិលោកេន្តស្ស**" បានដល់ ក្រឡេកមើលខាងនេះ ក្រឡេកមើលខាងនោះ ។ បទថា "**សម្មិញ្ជន្តស្ស** = បត់ចូល" បានដល់ ទាញបត់សន្លាក់ទាំងឡាយ ។ បទថា "**បសារេន្តស្ស** = សណ្តូកចេញ" បានដល់ សណ្តូកសន្លាក់ទាំងឡាយចេញ ។

ឥឡូវនេះ ដើម្បីសម្តែងវិញ្ញត្តិដោយសភាវៈ ដោយបទទាំង ៦ ទើបត្រាស់ថា "**កាយស្ស ថម្ភនា** = ការតឹងរបស់កាយ" ជាដើម ។ បណ្តាបទទាំងនោះ បទថា "**កាយស្ស** = របស់កាយ" បានដល់ របស់សរីរៈ ។ សភាវៈដែលឈ្មោះថា ការតឹង (ថម្ភនា) ព្រោះអត្ថថា ធ្វើកាយឱ្យរឹងហើយ ឱ្យរឹងប៉ឹង ។ សភាវៈដែលតឹង

---

* ស្គរដែលគេវាយក្នុងពេលសម្លាប់មនុស្ស ឬក្នុងពេលឈ្នះសង្គ្រាម ។

នោះឯង ត្រាស់ហៅថា កិរិយាតឹងដោយល្អ (សន្ថម្ភនា) ព្រោះបន្ថែមដោយឧបសគ្គៈ;ម្យ៉ាងទៀត ការតឹងមានកម្លាំងច្រើន ឈ្មោះថា (សន្ថម្ភនា) ។ ការតឹងដោយល្អឈ្មោះថា **សន្ថម្ភិតត្តំ** ។

ឈ្មោះថា វិញ្ញត្តិ (ការសម្តែងឱ្យដឹងពីបំណង) ដោយអំណាចនៃការឱ្យដឹងឱ្យយល់ ។ កិរិយាដែលឱ្យយល់ពីបំណង ឈ្មោះថា **វិញ្ញាបនា** ។ ការសម្តែងឱ្យដឹងពីបំណង ឈ្មោះថា **វិញ្ញាបិតត្តំ** ។ ពាក្យដ៏សេសណា ដែលគប្បីពោលទុកក្នុងទីនេះ ពាក្យនោះ ខ្ញុំពោលទុកក្នុងទ្វារកថាខាងក្រោយហើយ ៕

## អដ្ឋកថាវចីវិញ្ញត្តិនិទ្ទេស

ក្នុងវចីវិញ្ញត្តិក៏ដូចគ្នា; តែសេចក្តីរបស់បទថា "វចីវិញ្ញត្តិ" និងបទនៃនិទ្ទេសទាំងឡាយ ដែលខ្ញុំនៅមិនបានពោលទុកក្នុងទ្វារកថានោះ គប្បីជ្រាបយ៉ាងនេះថា ៖

ក៏ឈ្មោះថា **វិញ្ញត្តិ** ព្រោះអត្ថថា មនុស្សក្តី, សត្វតិរច្ឆានក្តី ដែលនឹងឱ្យដឹងសភាវៈរបស់ខ្លួនដោយវាចា; សូម្បីសត្វតិរច្ឆាន ក៏ដឹងភាវៈរបស់មនុស្សបាន ឬមនុស្សក៏ដឹងភាវៈរបស់សត្វបានដោយសភាវៈនេះ ដោយកំណត់យកតាមទំនងនៃការកំណត់ពាក្យនិយាយ ។ ម្យ៉ាងទៀត ដែលឈ្មោះថា **វិញ្ញត្តិ** ព្រោះអត្ថថា រមែងដឹងបំណងដោយទំនងនៃការកំណត់និយាយពាក្យបានដោយខ្លួនឯង ។ វិញ្ញត្តិ គឺវចី បានដល់ ការកម្រើកញ័រដែលត្រាស់ទុកក្នុងព្រះបាលីមានជាអាទិ៍ថា **"សាធុ**

**ខាចាយ សំខរោ** = ការសង្រួមផ្លូវវាចាជាការល្អ”[២៨] ឈ្មោះថា វចីវិញ្ញត្តិ ។

នំយម្យ៉ាងទៀត ដែលឈ្មោះថា វចីវិញ្ញត្តិ ព្រោះអត្ថថា ការសម្ដែងបំណង ឱ្យដឹងផ្លូវវាចា ព្រោះជាហេតុឱ្យយល់សេចក្ដីប្រាថ្នាបាន ដោយសំឡេងរបស់វាចា និងព្រោះខ្លួនឯង ក៏នឹងគប្បីដឹងបានដោយប្រការដូច្នោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យជាដើមថា **“ខាចា គិរា** = ការនិយាយ ការបញ្ចេញវាចា” តទៅ ៖

ក៏ឈ្មោះថា **ខាចា** (ការនិយាយ) ព្រោះអត្ថថា ជាសភាវៈដែលគេពោល ។

ឈ្មោះថា **គិរា** (ការបញ្ចេញវាចា) ព្រោះអត្ថថា ដែលបុគ្គលបញ្ចេញ ។ ឈ្មោះថា **ខាក្យភេទោ** (ការពោល) ព្រោះអត្ថថា ការចរចា ។ ម្យ៉ាងទៀត ឈ្មោះថា **ព្យប្បថោ** (ការបញ្ចេញវាចា) ព្រោះអត្ថថា ពាក្យនិយាយនោះផង ជាផ្លូវរបស់បុគ្គលអ្នកប្រាថ្នានឹងដឹងសេចក្ដី និងញ៉ាំងអ្នកដទៃឱ្យដឹងផង ។ ឈ្មោះថា **ឧទិរណំ** (ការពោល) ព្រោះអត្ថថា រមែងថ្លែងចេញ ។ ឈ្មោះថា ឃោសៈ (ការបោយហៅ) ព្រោះអត្ថថា ដែលគេរមែងឃោសនា ។ ឈ្មោះថា **កម្ម** ព្រោះអត្ថថា ដែលគេរមែងធ្វើ ។ កម្ម គឺការឃោសនា ឈ្មោះថា ឃោសកម្ម, អធិប្បាយថា គេធ្វើការឃោសនាដោយប្រការផ្សេងៗ ដើម្បីឱ្យដឹងការបញ្ចេញវាចា ឈ្មោះថា វចី-ភេទ; តែវចីភេទ (ការបញ្ចេញវាចា) នោះ មិនមែនជាការទម្លាយ ជាវាចាដែល

[២៨] ខុ. ធ. ។

ប្លែកផ្សេងគ្នាប៉ុណ្ណោះ ទើបត្រាស់ថា **“វាចា វចី ភេទោ** = វាចាការសម្ដែងបំណងឱ្យដឹងតាមវាចា” ។ សទ្ទវាចានោះឯង ព្រះអង្គទ្រង់សម្ដែងសូម្បីដោយបទទាំងពួងនេះ ។

ឥឡូវនេះ ទ្រង់ប្រាថ្នានឹងសម្ដែងវចីវិញ្ញត្តិនោះ ដោយសភាវៈ ដោយអាការៈ ៣ យ៉ាង ដោយអំណាចនៃបទទាំងឡាយមានវិញ្ញត្តិជាដើម នៃសេចក្ដីដែលពោលទុកក្នុងគ្រាក្រោយ ព្រោះប្រកបដោយវាចានោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **“យា តាយ វាចាយ វិញ្ញត្តិ** = សម្ដែងឱ្យដឹងបំណងដោយវាចានោះណា” ។ ពាក្យនោះមានអត្ថងាយស្រួលទាំងអស់ ព្រោះមានន័យតាមដែលពោលទុកហើយក្នុងខាងក្រោយនោះឯង ។

ឥឡូវនេះ ដើម្បីមិនឱ្យវង្វេងក្នុងចិត្តដែលញ៉ាំងវិញ្ញត្តិឱ្យតាំងឡើង គប្បីជ្រាបបកិណ្ណកធម៌នេះ គឺចិត្ត ៣២ ដួង,ចិត្ត ២៦ ដួង, ចិត្ត ១៩ ដួង, ចិត្ត ១៦ ដួង ជាទីបំផុត ។ ពិតមែន ចិត្ត ៣២ ដួង រមែងញ៉ាំងពហិរូបឱ្យតាំងឡើង, រមែងឧបត្ថម្ភឥរិយាបថ,រមែងញ៉ាំងវិញ្ញត្តិសូម្បីទាំង ២ ឱ្យកើតឡើង ។ ចិត្ត ២៦ ដួង រមែងញ៉ាំងវិញ្ញត្តិនោះឯងមិនឱ្យកើតឡើង, រមែងធ្វើទាំង ២ ក្រៅនេះ។ ចិត្ត ១៩ ដួង រមែងញ៉ាំងរូបនោះឯងឱ្យតាំងឡើង, តែមិនធ្វើ ២ យ៉ាងក្រៅនេះទេ ។ ចិត្ត ១៦ ដួង មិនធ្វើនាទីសូម្បីត្រឹមតែម្យ៉ាង ក្នុង ៣ យ៉ាងនោះ (ឱ្យតាំងឡើង ឱ្យឧបត្ថម្ភ ឱ្យកើតវិញ្ញត្តិ) ឡើយ។

ក្នុងបកិណ្ណកធម៌ពួកនោះ ពាក្យថា **“ចិត្ត ៣២”** គឺចិត្តដែលពោលទុកក្នុងពេលមុននោះឯង គឺកាមាវចរកុសល ៨, អកុសល ១២, កិរិយាចិត្ត ១០, អភិញ្ញាចិត្តរបស់ព្រះសេក្ខៈ និងបុថុជ្ជន ១ ព្រមទាំងអភិញ្ញាចិត្តរបស់ព្រះខីណាស្រពទាំងឡាយ ១ ។

ពាក្យថា **“ចិត្ត ២៦”** គឺរូបាវចរកុសលចិត្ត ៥, រូបាវចរកិរិយាចិត្ត ៥, អរូបាវចរកុសលចិត្ត ៤, អរូបាវចរកិរិយាចិត្ត ៤, មគ្គចិត្ត ៤ និងផលចិត្ត ៤ ។

ពាក្យថា **“ចិត្ត ១៩”** គឺកាមាវចរកុសលវិបាក ១១, អកុសលវិបាក ២, កិរិយាមនោធាតុ ១ និងរូបាវចរវិបាកចិត្ត ៥ ។

ពាក្យថា **“ចិត្ត ១៦”** គឺទ្វិបញ្ចវិញ្ញាណចិត្ត ១០, បដិសន្ធិចិត្តរបស់សត្វទាំងអស់ ១, ចុតិចិត្តរបស់ព្រះខីណាស្រព ១ និងអរូបាវចរវិបាកចិត្ត ៤ ។ ចិត្តទាំង ១៦ នេះ រមែងមិនធ្វើឱ្យរូបកើត, ឧបត្ថម្ភ និងវិញ្ញត្តិសូម្បីត្រឹមតែម្យ៉ាងណាឡើយ, សូម្បីចិត្តដែលកើតក្នុងអរូបដទៃទៀតច្រើន ក៏មិនធ្វើរូបឱ្យកើតឡើងបាន ព្រោះមិនមានឱកាស; ក៏ចិត្តពួកណា រមែងញ៉ាំងកាយវិញ្ញត្តិ ឱ្យតាំងឡើង, ចិត្តនោះឯង រមែងញ៉ាំងវចីវិញ្ញត្តិឱ្យតាំងឡើងដែរ ៕

## អដ្ឋកថាអាកាសធាតុនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **អាកាសធាតុ** ដូចតទៅ ៖

សភាវៈដែលឈ្មោះថា **អាកាស** ព្រោះអត្ថថា ដែលនរណា១ រមែងភ្ជួរមិនបាន ធ្វើឱ្យជាស្នាមមិនបាន គឺថាមិនអាចដើម្បីនឹងភ្ជួរ ឬដើម្បីនឹងកាត់ ឬថា ដើម្បីនឹងធ្វើឱ្យបែក; អាកាសនោះឯងហៅថា **អាកាសគតំ** (ដល់ការរាប់ថាជា អាកាស) ដូចពាក្យថា "**ខេឡគតំ** = ដល់ការរាប់ថាជាទឹកមាត់" ជាដើម ។ ម្យ៉ាងទៀត ពាក្យថា "**អាកាស**" ឈ្មោះថា **អាកាសគតំ** ព្រោះសត្វដល់ហើយ ។ ដែលឈ្មោះថា **អឃំ** (វាលស្រឡះ) ព្រោះដែលអ្វី១ រមែងមិនប៉ះខ្ទប់, គឺមិនមានអ្វីពាល់ត្រូវបាន ។ **អឃៈ**នេះឯងហៅថា **អឃគតំ** ។ ឈ្មោះថា **ឆិទ្ទំ** (ប្រហោងធ្លុង) ព្រោះអត្ថថា ជាប្រហោង; **វិវរោ**នេះឯង ឈ្មោះថា **ឆិទ្ទគតំ** ។

ពាក្យថា "**អសម្ផុដ្ឋំ ចតូហិ មហាភូតេហិ** = ដែលមហាភូតរូប ៤ មិនពាល់ត្រូវហើយ" ព្រះមានជោគព្រាស់ទុកដល់អាកាសល្ហល្ហេវ ដែលមហាភូតរូបទាំងនេះមិនពាល់ត្រូវហើយ ។ តែកាលបើពោលដោយលក្ខណៈជាដើមគឺ ៖

**រូបបរិច្ឆេទលក្ខណា** អាកាសធាតុមានការកំណត់ទុកនូវរូបជាលក្ខណៈ

**អាកាសធាតុរូបបរិយន្តប្បកាសនរសា** មានការប្រកាសទីបំផុតនៃរូប របស់អាកាសធាតុជារស ។

**រូបបរិយាទបច្ចុបដ្ឋានា** មានព្រំដែនរបស់រូបជាបច្ចុប្បដ្ឋាន ។

**អសម្ផុដ្ឋភាវឆិទ្ទវិវរភាវបច្ចុបដ្ឋានា វា** ឬមានភាវៈដែលមហាភូតរូបពាល់ត្រូវមិនបាន មានភាវៈដែលភូតរូបឃាំងទុក និងមានភាវៈដែលជា

ប្របហោងល្អល្ហេវជាបច្ចុប្បដ្ឋាន ។

**បរិច្ឆិន្នរូបបទដ្ឋានា** មានរូបដែលកំណត់ទុកជាបទដ្ឋាន ។

កាលបើរូបទាំងឡាយដែលអាកាសណាកំណត់ទុកហើយ រូបនេះក៏មានខាងលើ ខាងក្រោម និងខាងទទឹងដោយអាកាសធាតុនោះដែរ ។

ខាងមុខអំពីនេះ គប្បីជ្រាបនិទ្ទេសនៃធម៌ទាំងឡាយមាន **រូបលហុតា** ជាដើម ដោយន័យដែលពោលទុកក្នុងធម៌ទាំងឡាយ មាន **ចិត្តលហុតា**ជាដើមនោះឯង; តែក្នុងទីនេះ ពោលដោយលក្ខណៈជាដើមថា ៖

**អទន្ធតាលក្ខណា រូបស្ស លហុតា** លហុតារូប មានការមិនយឺត ជាលក្ខណៈ ។

**រូបានំ គរុភាវវិនោទនរសា** មានការបន្ទោបង់នូវភាពធ្ងន់នៃរូបជារស

**លហុបរិវត្តិតាបច្ចុប្បដ្ឋានា** មានការផ្លាស់ប្តូរយ៉ាងរហ័សជាផល

**លហុរូបបទដ្ឋានា** មានរូបស្រាលជាបទដ្ឋាន ។

**អថទ្ធតាលក្ខណា រូបស្ស មុទុតា** មុទុតារូបមានការមិនរឹងជាលក្ខណៈ

**រូបានំ ថទ្ធភាវវិនោទនរសា** មានការបន្ទោបង់នូវភាពរឹងនៃរូបជារស

**សព្វកិរិយាសុ អវិរោធិតាបច្ចុប្បដ្ឋានា** មានភាពមិនជាសត្រូវនិងគ្នា ក្នុងទង្វើទាំងពួងជាបច្ចុប្បដ្ឋាន ។

**មុទុរូបបទដ្ឋានា** មានរូបដែលទន់ជាហេតុជិត ។

**សរីរកិរិយានុកុលកម្មញ្ញភាវលក្ខណា រូបស្ស កម្មញ្ញតា** កម្មញ្ញតារូប មានភាពគួរដល់ការងារដោយសមគួរដល់ទង្វើនៃសរីរៈជាលក្ខណៈ ។

**អកម្មញ្ញភាវវិនោទនរសា** មានការបន្ទោបង់នូវភាវៈមិនគួរដល់ការងារជារស ។

**អទុព្វលភាវបច្ចុប្បដ្ឋានា** មានសេចក្តីមិនទុព្វលភាពជាបច្ចុប្បដ្ឋាន

**កម្មញ្ញរូបបទដ្ឋានា** មានរូបដែលគួរដល់ការងារជាហេតុជិត ។

ក៏វិការរូបទាំង ៣ នេះ មិនលះនូវគ្នានឹងគ្នាឡើយ; កាលបើមានសេចក្តីយ៉ាងនោះ បណ្ឌិតគប្បីជ្រាបសេចក្តីផ្សេងគ្នានៃរូបទាំង ៣ នោះ យ៉ាងនេះថា ៖

ភាវៈដែលស្រាល គឺការមិនយឺតយ៉ាវនៃរូបទាំងឡាយ មានអាការៈប្រព្រឹត្តទៅបានរហ័ស ដូចមនុស្សមិនមានរោគ មានសមុដ្ឋានកើតពីបច្ច័យដែលជាបដិបក្សចំពោះធាតុកម្រើកដែលធ្វើឱ្យរូបណាយឺតយ៉ាវ, វិការរូបនោះឈ្មោះថា **លហុតារូប** ។ ភាវៈដែលរូបទាំងឡាយ មានការទន់ដូចស្បែកដែលចាក់ទុកល្អហើយ មានអាការៈធ្វើឱ្យទន់ប្រព្រឹត្តទៅតាមអំណាច ក្នុងទង្វើ (ការងារ) ទាំងពួងបានផ្សេងៗ គ្នា មានសមុដ្ឋានកើតពីបច្ច័យ ដែលជាបដិបក្សចំពោះធាតុកម្រើក ធ្វើឱ្យរូបឯណារឹង, វិការរូបនោះ ឈ្មោះថា **មុទុតារូប**, តែសេចក្តីដែលរូបទាំងឡាយគួរដល់ការងារ ដូចមាសដែលលត់ទុកល្អហើយ មានអាការៈស្របតាមក្នុងទង្វើរបស់សរីរៈ មានសមុដ្ឋានកើតពីបច្ច័យ ដែលជាបដិបក្សចំពោះធាតុកម្រើក ដែល

ធ្វើឱ្យរូបមិនស្របតាមទង្វើក្នុងសរីរៈឯណា, វិការរូបនោះ ឈ្មោះថា **កម្មញ្ញតារូប** ។

ម្យ៉ាងទៀត សូម្បីវិការរូបទាំង ៣ នោះ រមែងអាចដើម្បីធ្វើការងារបាន ក៏មិនមែន, រូបដែលកើតពីអាហារជាដើម (គឺកើតពីចិត្ត និងឧតុ) ប៉ុណ្ណោះ រមែងធ្វើការបាន ។ ដោយហេតុនោះឯង ទើបពួកព្រះយោគីពោលនឹងគ្នាថា "ថ្ងៃនេះពួកយើងបានអាហារជាទីសប្បាយ, កាយរបស់យើងទើបស្រាលទន់ គួរដល់ការងារ; ថ្ងៃនេះពួកយើងបានឧតុសប្បាយ, ថ្ងៃនេះចិត្តរបស់ពួកយើងស្ងប់, កាយរបស់ពួកយើងស្រាលទន់គួរដល់ការងារ" ៕

## អដ្ឋកថាឧបចយៈ និងសន្តតិនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ឧបចយៈ** និង**សន្តតិ** ដូចតទៅ ៖

បទថា "**អាយតនានំ** = អាយតនៈទាំងឡាយ" បានដល់ រូបាយតនៈទាំង ១០ កន្លះ (គឺ ១០ និងកន្លះ); បទថា "**អាចយោ** = ការប្រមូលផ្តុំ" បានដល់ការកើតឡើង ។ បទថា "**សោ រូបស្ស ឧបចយោ** = នោះជាការកើតនៃរូប" បានដល់ ការកើត ការប្រមូលផ្តុំនៃអាយតនៈដែលកើតឡើងហើយញយៗ ចំណែកណា, ចំណែកនោះឯង ឈ្មោះថា ការកើត ការប្រមូលផ្តុំនៃរូប, អធិប្បាយថា រីកចម្រើនឡើង ។ ការកើត ការប្រមូលផ្តុំនៃរូបចំណែកណា, **ចំណែកនោះជាសន្តតិ** (ការបន្ត) របស់រូប, ព្រោះហេតុដូច្នោះ ការចម្រើនរបស់រូបទាំងឡាយដែលប្រមូល

ផ្ដុំហើយ ដោយអាការៈយ៉ាងនេះចំណែកណា, ក្នុងពេលរូបប្រព្រឹត្តទៅក្រៃលែងជាងនោះ ការចម្រើននោះ ឈ្មោះថា សន្តតិរបស់រូប, គឺការប្រព្រឹត្តទៅរបស់រូប ។ ដូចយ៉ាងថា កាលបុគ្គលជីករណ្ដៅជិតឆ្នេរស្ទឹង កាលប្រមូលផ្ដុំកើតឡើង ដូចពេលដែលទឹកហូរទៅកាន់រណ្ដៅ, ការកើតឡើងចម្រើនហើយ ដូចពេលដែលទឹកពេញរណ្ដៅ, គប្បីជ្រាបថា សន្តតិប្រព្រឹត្តទៅដូចពេលដែលទឹកហូរជន់ទៅដូច្នោះ ។

*សួរថា* ដោយនិទ្ទេស ពាក្យថា **"យោ អាយតនានំ អាចយោ"** ជាដើមនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកយ៉ាងណា ? ឆ្លើយថា ព្រះអង្គត្រាស់សេចក្ដីផ្ដើមកើតដោយអាយតនៈ, ត្រាស់អាយតនៈដោយការផ្ដើមកើត ជាការត្រាស់សេចក្ដីផ្ដើមកើត និងត្រាស់អាយតនៈនោះឯងទុកហើយ ។

*សួរថា* កាលបើដូច្នោះ តើព្រះអង្គត្រាស់ទុកដូចម្ដេច ?

ឆ្លើយថា ព្រះអង្គត្រាស់ទុកដោយសេចក្ដីផ្ដើមកើត ការប្រមូលផ្ដុំ ការកើត ការចម្រើនរបស់សន្តតិរូបទាំង ៤ ។

ពិតមែន កាលពោលដោយអត្ថ សូម្បីរូបទាំង ២ នេះ (ឧបចយៈ និងសន្តតិ) ជាឈ្មោះរបស់រូបដែលកើតប៉ុណ្ណោះ; តែកាលពោលដោយសេចក្ដីផ្សេងគ្នា ដោយអាការៈ និងដោយអំណាចនៃវេនេយ្យសត្វ ទើបព្រះមានព្រះភាគជាម្ចាស់ ទ្រង់ធ្វើឧទ្ទេស និងនិទ្ទេសដោយពាក្យថា **"ឧបចយោ សន្តតិ"** , តែព្រោះក្នុងឧទ្ទេសនេះ មិនមានសេចក្ដីផ្សេងគ្នាដោយអត្ថ ព្រោះហេតុដូច្នោះ ទើបត្រាស់ទុកក្នុងនិទ្ទេស

ថា “**យោ អាយតនានំ អាចយោ, សោ រូបស្ស ឧបចយោ, យោ រូបស្ស ឧបចយោ, សោ រូបស្ស សន្តតិ** = ការប្រមូលផ្តុំនៃអាយតនៈទាំងឡាយណា, ការប្រមូលផ្តុំនៃអាយតនៈទាំងឡាយនោះ ជាការកើតឡើងនៃរូប; ការកើតឡើង នៃរូបណា, ការកើតឡើងនៃរូបនោះ ជាការបន្តនៃរូប” ដូច្នេះ ។

មួយទៀត ព្រោះសូម្បីរូបទាំង ២ (ឧបចយៈ និងសន្តតិ) នោះ ជាឈ្មោះរបស់រូបដែលកើតជាមួយគ្នា, ព្រោះហេតុដូច្នោះ និទ្ទេសនេះ បណ្ឌិតគប្បីជ្រាប (លក្ខណាទិចតុក្កៈរបស់រូបទាំង ២ នោះ) ថា៖

**អាចយលក្ខណោ រូបស្ស ឧបចយោ** ឧបចយរូបមានការផ្តើមកើតជាលក្ខណៈ ។

**បុព្វន្តតោ រូបានំ ឧម្មុជ្ជាបនរសោ** មានការញ៉ាំងរូបទាំងឡាយឱ្យកើត ដូចខន្ធដែលជាចំណែកខាងដើមជារស ។

**និយ្យាតនបច្ចុប្បដ្ឋានោ បរិបុណ្ណភាវបច្ចុប្បដ្ឋានោ វា** មានការប្រគល់ឱ្យជាបច្ចុប្បដ្ឋាន ឬមានភាពបរិបូរណ៍ជាបច្ចុប្បដ្ឋាន ។

**ឧបចិតរូបបទដ្ឋានោ** មានរូបដែលកើតហើយ (រូបដែលដល់ឧប្បាទ-ខណៈ) ជាបទដ្ឋាន។

**បវត្តិលក្ខណោ រូបស្ស សន្តតិ** សន្តតិរូបមានការប្រព្រឹត្តទៅ (គឺទៅ

ដោយអំណាចនៃការបន្ត) ជាលក្ខណៈ ។

**អនុប្បពន្ធនរសា** មានការបន្តគ្នាជាលំដាប់ (គឺការបន្តដោយអំណាចនៃរូបខាងដើម និងខាងចុង) ជារស ។

**អនុប្បច្ឆេទបច្ចុប្បដ្ឋានា** មានការមិនដាច់អំពីគ្នា (អំពីរូបខាងដើម និងខាងចុង) ជាបច្ចុប្បដ្ឋាន ។

**អនុប្បពន្ធរូបបទដ្ឋានា** មានរូបដែលបន្តជាប់គ្នាជាបទដ្ឋាន ៕

## អដ្ឋកថាជរតានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ជរតា** ដូចតទៅ ៖

ដែលឈ្មោះថា **ជរា** ដោយអំណាចនៃរូបដែលចាស់ ។ ក្នុងនិទ្ទេសនៃជរានេះ មានការពង្រីកសភាវៈថា អាការៈនៃការគ្រាំគ្រា ឈ្មោះថា **ជរា** = សេចក្តីគ្រាំគ្រា ។ អាការៈទាំង ៣ មានពាក្យថា “ធ្មេញបាក់” ជាដើម មានការពង្រីកកិច្ច គឺកន្លងកាល កន្លងវ័យទៅមែនពិត, អាការៈ ២ ខាងចុង ជាការពង្រីកសេចក្តីតាមប្រក្រតី (ប្រព្រឹត្តទៅតាមធម្មជាតិ) ។

ពិតមែន ដោយបទថា **“ជរា”** នេះ ព្រះអង្គទ្រង់សម្តែងជរានេះ ដោយសភាវៈ, ព្រោះហេតុនោះ ពាក្យថា **“ជរា”** នេះ ទើបជាការអធិប្បាយសភាវៈ

របស់ជរានោះ ។ ដោយបទថា “**ខិរណតា**” នេះ ទ្រង់សម្ដែងដោយអាការៈ, ព្រោះហេតុដូច្នោះ ពាក្យថា “**ខិរណតា**” នេះ ទើបជាការអធិប្បាយអាការៈរបស់រូបដែលមានភាពគ្រាំគ្រានោះ ។ ដោយបទថា “កាលមានធ្មេញបាក់” នេះ ទ្រង់សម្ដែងដោយកិច្ច គឺធ្វើភារៈនៃធ្មេញ និងក្រចកបាក់ ដោយការកន្លងវ័យ ។ ដោយបទថា “**បាលិច្ចំ** = កាលមានសក់ស្កូវ” នេះ ទ្រង់សម្ដែងដោយកិច្ច គឺកាលដែលសក់ និងរោមទាំងឡាយស្កូវ ។ ដោយបទថា “មានស្បែកជ្រួញ” នេះ ទ្រង់សម្ដែងដោយកិច្ច គឺធ្វើសាច់ឱ្យស្វិតហើយធ្វើស្បែកឱ្យជ្រីវជ្រួញ ព្រោះហេតុដូច្នោះ បទទាំង ៣ មានធ្មេញបាក់ជាដើមនេះ ជាការពង្រីកសេចក្ដីដល់កិច្ចដែលកន្លងកាលកន្លងវ័យនៃរូបនោះ ។ ដោយបទទាំង ៣ នោះ ព្រះអង្គទ្រង់សម្ដែង **បាកដជរា** គឺការចាស់ដែលប្រាកដដោយអំណាចនៃការឃើញវិការរូបនេះ ។

ដូចយ៉ាងថា ផ្លូវដែលទឹកហូរទៅ ឬខ្យល់ផាត់ទៅ រមែងប្រាកដដោយការទម្លាយស្មៅ និងដើមឈើជាដើម ឬថាផ្លូវដែលភ្លើងឆេះរលីងធេងទៅ រមែងប្រាកដ, ផ្លូវមានទឹកជាដើមកន្លងទៅនោះនៅប្រាកដ, តែទឹកជាដើមមិនបានប្រាកដឱ្យឃើញ, សេចក្ដីនេះ តើយ៉ាងណា, ផ្លូវដែលជរាកន្លងទៅហើយ ដោយអំណាចនៃសេចក្ដីបែកបាក់ក្នុងអវយវៈ មានធ្មេញបាក់ជាដើម រមែងប្រាកដ, ព្រោះបុគ្គលសូម្បីធ្មេចភ្នែកមើល ក៏ដឹងបាន, តែសភាវៈមានធ្មេញបាក់ជាដើម ធ្មេចភ្នែកមើលដឹងមិនបាន, ជរាក៏ដឹងមិនបានដែរ; ព្រោះថា ជរា ចក្ខុវិញ្ញាណដឹងមិនបានឡើយ ។

ក៏ដោយប្រភេទនៃបទទាំងនេះថា **"ការថយអាយុ ការចាស់ក្លានៃឥន្ទ្រិយទាំងឡាយ"** ព្រះមានព្រះភាគទ្រង់សម្ដែងការចាស់ដោយប្រក្រតី ការអស់ទៅនៃអាយុ ដោយសម្គាល់ដល់ការចាស់ជុំវិញរបស់ឥន្ទ្រិយ មានចក្ខុន្ទ្រិយជាដើមជាក់-ច្បាស់ហើយ ដោយកន្លងកាល កន្លងវ័យមែនពិត, ដោយហេតុនោះ គប្បីជ្រាបពីរប្រការក្រោយនេះថា ជានិទ្ទេសដោយប្រក្រតីនៃជរតានោះ ។ ក្នុងអាការៈទាំង ២ នោះ ព្រោះអាយុរបស់បុគ្គលអ្នកដល់សេចក្ដីចាស់ហើយរមែងថយចុះ ព្រោះហេតុដូច្នោះ ទើបត្រាស់ជរាដោយសំដៅដល់ផលថា **"ជរា អាយុនោ សន្ធានិ** = ជរាគឺសេចក្ដីថយនៃអាយុ" ដូច្នេះ, ម្យ៉ាងទៀត ព្រោះពេលដែលមនុស្សនៅក្មេងឥន្ទ្រិយទាំងឡាយ មានចក្ខុន្ទ្រិយជាដើមស្រស់ថ្លា អាចទទួលអារម្មណ៍សូម្បីល្អិតរបស់ខ្លួនបាន ដោយងាយមែនពិត, តែកាលដល់ការជរាហើយ ឥន្ទ្រិយទាំងឡាយមានចក្ខុន្ទ្រិយជាដើម ក៏ទ្រុឌទ្រោមញ៉រទទ្រើក មិនរហ័សរហួន មិនអាចនឹងទទួលអារម្មណ៍សូម្បីគ្រោតគ្រាតរបស់ខ្លួនបាន ព្រោះហេតុដូច្នោះ ទើបត្រាស់ជរាដោយផលូបចារន័យថា "ការទ្រុឌទ្រោមនៃឥន្ទ្រិយទាំងឡាយ" ដូច្នេះមែនពិត ៕

## សម្ដែងអំពីជរា ២ យ៉ាង

ក៏ជរានេះឯង ទ្រង់លើកឡើងសម្ដែងទុកយ៉ាងនេះថា ជរាសូម្បីទាំងអស់មាន ២ យ៉ាងគឺ **បាកដជរា** = ជរាប្រាកដ, **បដិច្ឆន្នជរា** = ជរាបិទបាំង ។

បណ្តាជរា ២ ពួកនោះ ជរាក្នុងរូបធម៌ទាំងឡាយ ឈ្មោះថា **បាកដជរា** ព្រោះសម្តែងសេចក្តីបែកបាក់ជាដើម ក្នុងអវយវៈមានធ្មេញបាក់ជាដើម, តែជរាក្នុងអរូបធម៌ទាំងឡាយ ឈ្មោះថា **បដិច្ឆន្នជរា** ព្រោះមិនសម្តែងវិការៈប្លែកទេ ។

ម្យ៉ាងទៀត នៅមានជរា ២ យ៉ាងទៀតគឺ **អវីចិជរា** = ជរាមិនមានការញ៉ាំរ, **សវីចិជរា** = ជរាមានការញ៉ាំរ ។

ក្នុងជរា ២ យ៉ាងនោះ គប្បីជ្រាបថា ជរាដែលឈ្មោះថា **អវីចិជរា** ព្រោះផ្សេងគ្នានៃវណ្ណៈជាដើមខាងក្នុងចន្លោះៗ ជាជរាដែលដឹងបានលំបាក ដូចជរារបស់កែវមណី មាស ប្រាក់ កែវប្រវាឡ ព្រះចន្ទ ព្រះអាទិត្យជាដើម ដូចជរារបស់សត្វមានជីវិតទាំងឡាយក្នុងពេលជាមន្ទទសកៈជាដើម និងដូចជាជរារបស់វត្ថុមិនមានជីវិតទាំងឡាយ ក្នុងពេលដែលមានផ្កា មានផ្លែ និងពន្លកជាដើម, បានដល់ **និរន្តរជរា** ។ ចំណែកជរាដែលឈ្មោះថា **សវីចិជរា** ព្រោះសេចក្តីផ្សេងគ្នានៃវណ្ណៈជាដើម ខាងក្នុងចន្លោះៗ ក្នុងវត្ថុពួកដទៃតាមដែលពោលហើយ ក្រៅអំពីនោះជារបស់ដឹងបានដោយងាយ ។ ៕

**សម្តែងអំពីលក្ខណាទិចតុក្កៈរបស់ជរតារូប គប្បីជ្រាបថា ៖**

**រូបបរិបាកលក្ខណា រូបស្ស ជរតា** ជរតារូបមានការទ្រុឌទ្រោមនៃរូបជាលក្ខណៈ ។

**ឧបនយរសា** មានការបង្អោនចូលទៅជិតសេចក្តីស្លាប់ជារស

**សភាវានបគមេមបិ នវភាវា បគមបច្ចុប្បដ្ឋានា** មានសេចក្តីប្រាស ចាក របស់ថ្មីសូម្បីនៅមិនទាន់ប្រាសចាកភាវៈរបស់ខ្លួនជាបច្ចុប្បដ្ឋាន ។

**ទិហិបុរាណភាវោ ទិយ បរិបច្ចមានរូបបទដ្ឋានា** មានរូបដែល ទ្រុឌទ្រោម ដូចស្រូវចាស់ជាបទដ្ឋាន ៕

## អដ្ឋកថាអនិច្ចតានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **អនិច្ចតារូប** ដូចតទៅ ៖

រូបដែលឈ្មោះថា **ខយោ** (ការអស់ទៅ) ដោយអំណាចនៃការដល់ សេចក្តីអស់ទៅ, ដែលឈ្មោះថា **វយោ** (ការថយចុះទៅ) ដោយអំណាចនៃការ ចូលដល់សេចក្តីថយចុះ, ដែលឈ្មោះថា **ភេទោ** (ការបែកទៅ) ដោយអំណាច នៃ សេចក្តីបែកធ្លាយ ។

ម្យ៉ាងទៀត រូបដែលឈ្មោះថា **ខយោ** ព្រោះអត្ថថា ជាទីអស់ទៅ, ដែល ឈ្មោះថា **វយោ** ព្រោះអត្ថថា ជាទីថយចុះទៅ, ដែលឈ្មោះថា **ភេទោ** ព្រោះ អត្ថថា ជាទីបែកធ្លាយទៅ, ព្រោះរូបដល់អាការៈនោះហើយ រមែងអស់ទៅ រមែង ថយចុះទៅ និងរមែងបែកធ្លាយទៅ, ការបែកធ្លាយនោះឯង ហៅថា **បរិភេទ** (សេចក្តីបែកធ្លាយទៅ) ព្រោះទ្រង់បន្ថែមបទដោយឧបសគ្គៈ ។

សភាវៈដែលឈ្មោះថា **អនិច្ចំ** ព្រោះអត្ថថា មិនទៀង គឺមានហើយ ឈ្មោះថា មិនមានវិញ, ភាវៈនៃអនិច្ចំនោះ ឈ្មោះថា **អនិច្ចតា** (ភាពមិនទៀង) ឈ្មោះថា **អន្តរធានំ** ព្រោះអត្ថថា ជាទីអន្តរធាន (វិនាស), ពិតមែន រូបដល់មរណៈហើយ រមែងអន្តរធាន, គឺរមែងដល់នូវភាពមិនឃើញ, រូបប៉ុណ្ណោះ ដល់នូវភាព មិនឃើញតែម្យ៉ាងក៏ទេ, សូម្បីបញ្ចខន្ធទាំងអស់ក៏អន្តរធានទៅដែរ, ព្រោះហេតុ ដូច្នោះ រូបនេះឯង គប្បីជ្រាបថា ជាលក្ខណៈមិនទៀងនៃខន្ធទាំង ៥, ក៏ការ ពោលដោយលក្ខណៈជាដើមគប្បីជ្រាបថា៖

**បរិភេទលក្ខណា រូបស្ស អនិច្ចតា** អនិច្ចតារូបមានការបែកធ្លាយទៅជាលក្ខណៈ ។

**សំសីទនរសា** មានការលិចចុះ ជារស

**ខយវយបច្ចុប្បដ្ឋានា** មានការអស់ទៅ សូន្យទៅ ជាបច្ចុប្បដ្ឋាន

**បរិភិជ្ជមានរូបបទដ្ឋានា** មានរូបដែលកំពុងបែកធ្លាយទៅជាបទដ្ឋាន៕

## សម្តែងអំពីជាតិ ជរា មរណៈ ដូចបច្ចាមិត្រ ៣ នាក់

ព្រះមានព្រះភាគជាម្ចាស់ទ្រង់កាន់យកជាតិ (ការកើត) ជរា (ការចាស់) សម្តែងទុកក្នុងគ្រាក្រោយហើយ, តែក្នុងទីនេះ ទ្រង់កាន់យកមរណៈ (ការស្លាប់);

ធម៌ទាំង ៣ នេះ ប្រព្រឹត្តទៅដូចជាបច្ចាមិត្រអ្នកលើកដាវឡើងប្រហារនូវសត្វទាំង-ឡាយនោះ ។ ដូចយ៉ាងថា បច្ចាមិត្រ ៣ នាក់ត្រាច់ស្វែងរកឱកាស (ទោស) ប្រទូស្តរ៉ាយបុរស; បណ្តាបច្ចាមិត្រ ៣ នាក់នោះ អ្នកទី ១ និយាយយ៉ាងនេះថា “ការនាំបុរសនេះចេញហើយចូលទៅកាន់ព្រៃក្រាស់ ជាភារៈរបស់យើង” ដូច្នេះ, អ្នកទី ២ និយាយថា “ក្នុងវេលាដែលបុរសនោះដល់ព្រៃក្រាស់ហើយ ការវាយឱ្យដួលចុះលើផែនដី គឺជាភារៈរបស់យើង” , អ្នកទី ៣ និយាយថា “ចាប់ផ្តើមអំពីវេលាដែលបុរសនោះដួលចុះលើផែនដីហើយ ក៏យកដាវកាត់ក្បាល គឺជាភារៈរបស់យើង” យ៉ាងណា, ធម៌ពួកនេះ មានជាតិជាដើមមានសភាពដូច្នោះ ក៏យ៉ាងនោះដែរ, **ជាតិ** ប្រព្រឹត្តិទៅដូចជាបច្ចាមិត្រ អ្នកចេញបញ្ជាឱ្យចូលទៅកាន់ព្រៃក្រាស់ ព្រោះឱ្យសត្វកើតក្នុងទីនោះៗ ។ **ជរា** ដូចជាបច្ចាមិត្រវាយបុរស អ្នកចូលទៅកាន់ព្រៃក្រាស់ហើយ ឱ្យដួលចុះលើផែនដី ព្រោះធ្វើខន្ធដែលកើតឡើងហើយ ឱ្យខ្សោយកម្លាំង ឱ្យអាស្រ័យអ្នកដទៃ ឱ្យឈានទៅកាន់គ្រែដេក ។ **មរណៈ** ដូចជាបច្ចាមិត្រ អ្នកយកដាវកាត់ក្បាលរបស់អ្នកដួលចុះលើផែនដី ព្រោះញ៉ាំងខន្ធទាំងឡាយដែលដល់ជរាហើយ ឱ្យដល់ការអស់ជីវិតទៅដូច្នោះដែរ ៕

## អដ្ឋកថាកពឡិង្ការាហារនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **កពឡិង្ការាហារ** ដូចតទៅ ៖

អាហារដែលឈ្មោះថា **ភពធិក្ខារ** ព្រោះត្រូវធ្វើឱ្យជាដុំ (បាយ) ឈ្មោះថា **អាហារ** ព្រោះអត្ថថា រមែងត្រូវគេទំពាសុី អធិប្បាយថា បុគ្គលធ្វើជាដុំបាយហើយរមែងទំពាសុី ។ ម្យ៉ាងទៀត ឈ្មោះថា **អាហារ** ព្រោះអត្ថថា រមែងនាំមកនូវរូប ។

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់លើកឈ្មោះឡើងសម្ដែងដោយអំណាចនៃវត្ថុយ៉ាងនេះហើយ ដើម្បីនឹងទ្រង់សម្ដែងអាហារនោះឯង ដោយអំណាចនៃវត្ថុទៀត ទើបត្រាស់ពាក្យមានជាអាទិ៍ថា **“ឱទនោ កុម្មាសោ** = បាយនំស្រស់” ; ពិតមែន អាហារ ១២ យ៉ាងមានបាយជាដើម មានទឹកអំពៅជាទីបំផុត ជាវត្ថុនៃអាហារដែលទ្រង់ប្រាថ្នាយកក្នុងទីនេះ ។ អាហារមានឫសឈើ និងផ្លែឈើជាដើម ដែលមិនបានត្រាស់ទុកក្នុងព្រះបាលី ក៏រួមចូល**ក្នុងយេវាបនកធម៌ដែរ** ។

ឥឡូវនេះ ដើម្បីនឹងសម្ដែងអាហារមានឫសឈើ និងផ្លែឈើជាដើមដែលគួរដល់សត្វទាំងឡាយគប្បីធ្វើនោះ ទើបត្រាស់ពាក្យថា **“យម្ហិ យម្ហិ ជនបទេ** = ក្នុងជនបទណា។” ជាដើម ។ ក្នុងព្រះបាលីនោះ អាហារដែលឈ្មោះថា **មុខាសិយំ** (ដែលជារបស់ដាក់ក្នុងមាត់) ព្រោះអត្ថថា គប្បីទំពាសុី គឺគប្បីបរិភោគតាមមាត់ ។ ដែលឈ្មោះថា **ទន្តវិខាទនំ** (របស់ទំពា) ព្រោះអត្ថថា ដែលសត្វគប្បីទំពាដោយធ្មេញ ។ ដែលឈ្មោះថា **គលជ្ឈោហរណីយំ** (របស់ទំពា) ព្រោះអត្ថថា ដែលសត្វគប្បីលេបចូលតាមបំពង់ក ។

ឥឡូវនេះ ទ្រង់ប្រាថ្នាដើម្បីនឹងសម្ដែងអាហារនោះដោយអំណាចនៃកិច្ច

ទើបត្រាស់ពាក្យថា **"កុច្ឆិវិត្ថម្ភនំ** = ជារបស់ឆ្អែតពោះ" ជាដើម ។ ពិតមែន អាហារមានឫសឈើ និងផ្លែឈើជាដើមនោះ ឬមានបាយ និងនំស្រស់ជាដើម ដែលសត្វលេបចូលទៅហើយ រមែងឆ្អែតពោះ, នេះជាកិច្ចរបស់អាហារនោះ ។

បទថា **"យាយ ឱជាយ សត្តា យាបេន្តិ** = សត្វទាំងឡាយចិញ្ចឹមជីវិតដោយឱជាណា" មានពាក្យអធិប្បាយថា ព្រះមានព្រះភាគជាម្ចាស់នោះ ទ្រង់សម្តែងអាហារដែលជាវត្ថុដោយបទសព្វគ្រប់ក្នុងពេលមុនហើយ ។ ឥឡូវនេះ ទ្រង់ប្រាថ្នាដើម្បីសម្តែងឱជាប៉ុណ្ណោះ ដែលសម្រេច (កើតឡើង) ហើយ ទើបត្រាស់ពាក្យថា **"យាយ ឱជាយ សត្តា យាបេន្តិ"** នេះទុក ។

***សួរថា*** ក៏បណ្តាអាហារដែលជាវត្ថុ និងឱជាពួកនោះ កិច្ចរបស់វត្ថុតើយ៉ាងណា? កិច្ចរបស់ឱជា តើដូចម្តេច ? ឆ្លើយថា វត្ថុ និងឱជាពួកនោះ មានការបំបាត់បង់នូវអន្តរាយ និងការរក្សារាងកាយជាកិច្ច ។ ពិតមែន អាហារដែលជាវត្ថុ រមែងនាំអន្តរាយចេញ, តែមិនអាចដើម្បីរក្សារាងកាយបាន; អាហារដែលជាឱជា រមែងរក្សារាងកាយបាន, តែមិនអាចនាំអន្តរាយចេញទៅបាន សូម្បីអាហារទាំង ២ រួមចូលគ្នាហើយ រមែងអាចដើម្បីរក្សា និងនាំអន្តរាយចេញទៅបាន ។

***សួរថា*** ក៏អ្វីទៅ ឈ្មោះថា អន្តរាយ ?

ឆ្លើយថា តេជោធាតុដែលកើតអំពីកម្ម ។

ពិតមែន កាលវត្ថុមានបាយជាដើម មិនមានខាងក្នុងពោះ តេជោធាតុដែល

កើតអំពីកម្មតាំងឡើងហើយ ចាប់រំអិលក្រពះអាហារ, រមែងញ៉ាំងបុគ្គលឱ្យនិយាយថា "ខ្ញុំហេវហើយ, ចូរឱ្យអាហារមកដល់ខ្ញុំ" ដូច្នេះ ក្នុងពេលដែលស៊ីអាហារហើយ តេជោធាតុដែលកើតអំពីកម្មនោះ ក៏លះរំអិលក្រពះអាហារចេញទៅចាប់វត្ថុ (ដែលជាអាហារ), ពេលនោះ សត្វក៏មានចិត្តស្ងប់ ។

ដូចយ៉ាងថា **ស្រមោលអារក្សទឹក** (អារក្សទឹកចាប់សត្វដែលចូលទៅកាន់ស្រមោល) ចាប់សត្វដែលចូលទៅកាន់ស្រមោល យកច្រវាក់ទិព្វរបស់យក្សចងទុកហើយ ឱ្យត្រេកត្រអាលក្នុងទីនៅរបស់ខ្លួន ក្នុងពេលឃ្លាន ក៏មកខាំស៊ីត្រង់ក្បាល, សត្វនោះរមែងស្រែកព្រោះត្រូវអារក្សទឹកនោះខាំស៊ី, ពួកមនុស្សស្ដាប់សំឡេងស្រែកនោះ ក៏នាំគ្នាមកត្រង់ទីនោះៗ ដោយសម្គាល់ថា "ក្នុងទីនេះមានសត្វអ្នកបានទទួលទុក្ខ" ដូច្នេះ ស្រមោលអារក្សទឹកនោះ ក៏ចាប់មនុស្សដែលមកហើយៗ ទំពាស៊ីយ៉ាងសប្បាយចិត្តក្នុងទីនៅរបស់ខ្លួនយ៉ាងណា, ពាក្យឧបមេយ្យ ជាគ្រឿងប្រៀបធៀបនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះចុះ ។

ក៏តេជោធាតុដែលកើតអំពីកម្ម ប្រៀបដូចស្រមោលអារក្សទឹក, រំអិលក្រពះអាហារ ប្រៀបដូចសត្វដែលត្រូវស្រមោលអារក្សទឹកយកច្រវាក់ទិព្វចងទុក, វត្ថុមានបាយជាដើម ប្រៀបដូចមនុស្សដែលមកទៀត, ការដែលតេជោធាតុកើតអំពីកម្មលះវត្ថុទៅ ហើយកាន់យករំអិលក្រពះអាហារ ប្រៀបដូចស្រមោលអារក្សទឹកចុះមកខាំត្រង់ក្បាល, ពេលដែលប្រាប់ថា "សូមលោកឱ្យអាហារ" ដូច្នេះ

ប្រៀបដូចពេលស្រែករបស់សត្វដែលត្រូវអារក្សទឹកខាំក្បាល,កាលតែដោធាតុដែលកើតអំពីកម្មលះក្រពះអាហារ ទៅចាប់យកវត្ថុ សត្វទាំងឡាយក៏មានចិត្តស្ងប់ប្រៀបដូចពេលស្រមោលអារក្សទឹកចាប់ពួកមនុស្សដែលមកហើយៗ ដោយសញ្ញានោះ ទំពាស៊ីយ៉ាងសប្បាយចិត្តក្នុងទីនៅរបស់ខ្លួន ៕

## សម្តែងអំពីអាហារគ្រោតគ្រាត និងល្អិត

បណ្តាអាហារពួកនោះ ក្នុងវត្ថុគ្រោតគ្រាតមានឱជាតិច, ក្នុងវត្ថុល្អិតមានឱជាច្រើន, ពិតណាស់ មនុស្សស៊ីអាហារមានស្មៅគែលលកជាដើម តែមួយរំពេចប៉ុណ្ណោះ ក៏ឃ្លាន, មនុស្សផឹកទឹកដោះថ្លាជាដើម សូម្បីតាំងនៅរហូតមួយថ្ងៃ ក៏មិនចង់បរិភោគបាយដែរ; មួយទៀត ក្នុងខនេះ គប្បីជ្រាបសេចក្តីគ្រោតគ្រាត និងល្អិត ដោយការអាស្រ័យប្រៀបធៀបគ្នា ។

ពិតមែន ការប្រៀបធៀបអាហាររបស់ពួកក្រពើហើយ អាហាររបស់ពួកសត្វក្ងោកក៏ល្អិត ។ បានឮថា ពួកក្រពើលេបថ្មចូលទៅ, ឯថ្មនោះដល់ពោះពួកវាហើយ រមែងរលាយទៅ; ពួកសត្វក្ងោករមែងស៊ីសត្វមានពស់ និងខ្ជួយជាដើម; តែប្រៀបធៀបអាហាររបស់ពួកសត្វក្ងោកហើយ អាហាររបស់ឆ្កែព្រៃល្អិតជាង; បានឮថា ពួកឆ្កែព្រៃទាំងនោះស៊ីស្បែង និងឆ្អឹងសត្វដែលចោលទុកដល់ ៣ ឆ្នាំបាន, ក៏ស្បែង និងឆ្អឹងសត្វទាំងនោះ គ្រាន់តែផ្សើមដោយទឹកមាត់ឆ្កែព្រៃពួកនោះក៏ផុយ

ដូចមើមដំឡូង; សូម្បីប្រៀបធៀបអាហាររបស់ពួកឆ្កែព្រៃនោះហើយ អាហាររបស់ពួកដំរីក៏ល្អិតជាង, ព្រោះពួកដំរីនោះ រមែងស៊ីមែកឈើផ្សេងៗ; អាហាររបស់ពួកគោព្រៃ ខ្ទីង និងម្រឹគជាដើម ល្អិតជាងអាហាររបស់ពួកដំរី ។ បានឮថា ពួកគោព្រៃ ខ្ទីង និងពួកម្រឹគទាំងនោះទំពាស៊ីស្លឹកឈើផ្សេងៗ ជាដើមដែលមិនរឹង; អាហាររបស់ពួកគោស្រុកល្អិតជាងអាហាររបស់សត្វ សូម្បីមានគោព្រៃជាដើមនោះ, ពួកគោស្រុក រមែងទំពាស៊ីស្មៅស្រស់ និងស្មៅស្ងួត; អាហាររបស់ពួកទន្សាយល្អិតជាងអាហាររបស់ពួកគោនោះៗ; អាហាររបស់ពួកបក្សីល្អិតជាងអាហាររបស់ពួកទន្សាយ; អាហាររបស់ពួកជន អ្នកនៅក្នុងបច្ចន្តប្រទេស ល្អិតជាងអាហាររបស់ពួកបក្សី; អាហាររបស់ពួកអ្នកស្រុក (អ្នកធំក្នុងស្រុក) ល្អិតជាងអាហាររបស់ពួកអ្នកបច្ចន្ត-ប្រទេស; អាហាររបស់ព្រះរាជា និងរាជមហាអាមាត្យល្អិតជាងអាហាររបស់ពួកអ្នកស្រុក (មេស្រុក); អាហាររបស់ព្រះបាទចក្រពត្តិល្អិតជាងអាហារ សូម្បីរបស់ព្រះរាជា និងរាជមហាអាមាត្យទាំងនោះ; អាហាររបស់ពួកភុម្មទេវតា ល្អិតជាងអាហាររបស់ព្រះបាទចក្រពត្តិ; អាហាររបស់ពួកចាតុម្មហារាជិកា ល្អិតជាងអាហាររបស់ពួកភុម្មទេវតា ។ ដោយអាការៈយ៉ាងនេះ គប្បីឱ្យពិស្តារទៅរហូតដល់អាហាររបស់ពួកទេវបរនិម្មិតវសវត្តី; ក៏អាហាររបស់ទេវបរនិម្មិតវសវត្តីទាំងនោះដល់ការសម្រេចថា **ល្អិតជាទីបំផុត** ៕

## សម្តែងអំពីលក្ខណាទិចតុក្កៈ

**ឱជាលក្ខណោ កពឡីការោ អាហារោ** កពឡីការាហារដែលបណ្ឌិតគប្បីជ្រាបថា មានឱជាជាលក្ខណៈ ។

**រូបាហរណរសោ** មានការនាំមកនូវរូបជាកិច្ច

**ឧបត្ថម្ភនបច្ចុបដ្ឋានោ** មានការឧបត្ថម្ភជាផល

**កពឡី កត្វា អាហរិតព្វវត្ថុបទដ្ឋានោ** មានវត្ថុដែលបុគ្គលធ្វើជាដុំបាយហើយទំពាស៊ីជាបទដ្ឋាន ៕

## អដ្ឋកថានោឧបាទានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **នោឧបាទា** ដូចតទៅ ៖

រូបដែលឈ្មោះថា **នោឧបាទា** ព្រោះអត្ថថា នោឧបាទារូបនេះ រមែងមិនអាស្រ័យ ដូចឧបាទាយរូបរមែងអាស្រ័យមហាភូតរូបប៉ុណ្ណោះ មិនអាស្រ័យរូបដទៃទេ ។ ដែលឈ្មោះថា **ផោដ្ឋព្វៈ** ព្រោះអត្ថថា ដែលកាយគប្បីពាល់ត្រូវ ។ អធិប្បាយថា ពាល់ត្រូវហើយទើបដឹង ។ រូបនោះជាផោដ្ឋព្វៈផង ជាអាយតនៈផង ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **ផោដ្ឋព្វាយតនៈ**; ក៏រូបនោះជាអាបោផង ជាធាតុផង ដោយអត្ថថា មិនមែនសត្វ និងជាសភាវៈដែលសូន្យទទេ ព្រោះហេតុនោះ ទើប

ឈ្មោះថា **អាបោធាតុ** ៕

## អដ្ឋកថាផោដ្ឋព្វាយតននិទ្ទេស

ឥឡូវនេះ ដើម្បីទ្រង់សម្តែងចែករូបទាំង ៣ ដែលកាយពាល់ត្រូវហើយគប្បីដឹងបាននោះ ទើបត្រាស់ថា "រូបដែលហៅថា ផោដ្ឋព្វាយតនៈនោះ គឺអ្វី ? គឺបឋវីធាតុ" ជាដើម ។

បណ្តាធាតុពួកនោះ **បឋវីធាតុមានលក្ខណាទិចតុក្កៈដូច្នេះ** ៖

**កក្ខឡត្តលក្ខណា** បឋវីធាតុមានភាពរឹង ជាលក្ខណៈ

**បតិដ្ឋានរសា** មានការតាំងមាំ ជាកិច្ច

**សម្បដិច្ឆន្នបច្ចុប្បដ្ឋានា** មានការទទួលរង ជាផល ៕

**តេជោធាតុមានលក្ខណាទិចតុក្កៈដូច្នេះ** ៖

**ឧណ្ហត្តលក្ខណា** តេជោធាតុមានភាពក្តៅជាលក្ខណៈ

**បរិបាចនរសា** មានការធ្វើឱ្យឆ្អិន (រលួយ) ជារស

**មទ្ទវានុប្បាទានបច្ចុប្បដ្ឋានា** មានការធ្វើឱ្យខ្សោយជាបច្ចុប្បដ្ឋាន ៕

**វាយោធាតុមានលក្ខណាទិចតុក្កៈដូច្នេះ** ៖

**ថិត្ថម្ភនលក្ខណា** វាយោធាតុមានការតឹងធូរជាលក្ខណៈ

**សមុទីរណរសា** មានការកម្រើកជារស

**អភិនីហារបច្ចុបដ្ឋានា** មានការបង្អោនទៅជាបច្ចុប្បដ្ឋាន។

ចំណែកអាបោធាតុវិញ៖

**បគ្ឃរណលក្ខណា** មានការហូរទៅជាលក្ខណៈ

**ឧបព្រូហនរសា** មានការកើតឡើងជារស

**សង្គហបច្ចុបដ្ឋានា** មានការសង្គ្រោះ (រួបរួម)[២៩] ទុកជាបច្ចុប្បដ្ឋាន ។

ក៏ក្នុងធាតុទាំង ៤ នោះ ធាតុមួយៗ គប្បីជ្រាបថា មានធាតុទាំង ៣ ដែលសល់ជាបទដ្ឋាន (**សេសត្តយបទដ្ឋានា**) ។

បទថា "**កក្ខឡំ** =រឹង" គឺមិនទន់។ បទថា "**មុទុកំ** = ទន់" គឺមិនរឹង ។ បទថា "**សណ្ហំ** = ល្អិត" គឺម៉ដ្ឋ ។ បទថា "**ផរុស** = គគ្រើម" គឺរដិបរដុប ។ បទថា "**សុខសម្ផស្សំ** = មានសម្ផស្សជាសុខ" បានដល់ មានសុខវេទនាជាបច្ច័យ គឺមានផោដ្ឋព្វៈដែលគួរប្រាថ្នា ។ បទថា "**ទុក្ខសម្ផស្សំ** = មានសម្ផស្សជាទុក្ខ"

[២៩] វិសុទ្ធិ. ២ (សមាធិនិទ្ទេស) ។

បានដល់ មានទុក្ខវេទនាជាបច្ច័យ គឺផោដ្ឋព្វៈដែលមិនគួរប្រាថ្នា ។ បទថា "**គរុកំ** = ធ្ងន់ គឺពេញទៅដោយភារៈ ។ បទថា "**លហុកំ** = ស្រាល" គឺស្រាលព្រមទាំងមិនមានភារៈធ្ងន់ ។

ក៏បណ្ដាធាតុទាំងនោះ បឋវីធាតុប៉ុណ្ណោះ ទ្រង់ចែកដោយបទទាំងឡាយថា "រឹង ទន់ ល្អិត គគ្រាត ធ្ងន់ ស្រាល" ។ សូម្បីក្នុងព្រះសូត្រថា "កាលណា កាយនេះនៅប្រកបដោយអាយុ, នៅប្រកបដោយចំហាយធំ (ភ្លើងធាតុ), នៅប្រកបដោយវិញ្ញាណ, កាលនោះ កាយនេះក៏ស្រាលជាង ទន់ជាង គួរដល់ការងារជាង" [៣០] ដូច្នេះ ត្រាស់សំដៅដល់បឋវីធាតុដែលស្រាល និងទន់ប៉ុណ្ណោះ ។

តែដោយពីរបទនេះថា "មានសម្ផស្សជាសុខ មានសម្ផស្សជាទុក្ខ" ត្រាស់ចែកមហាភូតរូប ៣; ព្រោះថា បឋវីធាតុ មានសម្ផស្សជាសុខខ្លះ មានសម្ផស្សជាទុក្ខខ្លះ; តេជោធាតុ និងវាយោធាតុ ក៏ត្រាស់ដូចបឋវីធាតុ ។ បណ្ដាធាតុទាំង ៣ នោះ បឋវីធាតុមានសម្ផស្សជាសុខ គឺថា កាលក្មេងជំទង់ អ្នកមានបាតដៃទន់ច្របាច់ជើង បុគ្គលនោះរមែងសប្បាយចិត្ត រមែងធ្វើអាការៈដែលនឹងឱ្យនិយាយថា "ច្របាច់ចុះអ្នកៗ" ដូច្នេះ ។ តេជោធាតុ មានសម្ផស្សជាសុខ កាលរដូវរងា គេត្រូវការនាំយកគ្រឿងផ្យូងភ្លើងមកហើយ ឱ្យរាងកាយកក់ក្ដៅ គេក៏សប្បាយចិត្ត រមែងធ្វើ

---

[៣០] ទី. ម. ។

អាការៈដែលនឹងឱ្យនិយាយថា “អ្នកអាំងចុះៗ” ។ **វាយោធាតុ** មានសម្ផស្សជាសុខ កាលរដូវក្តៅ ភិក្ខុកំលោះអ្នកដល់ព្រមដោយវត្តបក់ផ្លិត រមែងឱ្យសប្បាយចិត្ត រមែងធ្វើអាការៈដែលអាចឱ្យនិយាយថា “បក់ចុះអ្នកៗ” ។

តែក្មេងកំលោះមានដៃរឹងច្របាច់ជើងទាំងពីរ រមែងហាក់ដូចជាវេលាដែលឆ្អឹងទាំងឡាយនឹងបាក់ទៅ, សូម្បីគេក៏ត្រូវពោលបញ្ហាដោយនិយាយថា “អ្នកចូរចេញទៅ” ដូច្នេះ; កាលរដូវក្តៅមានមនុស្សនាំយកគ្រឿងធ្យូងភ្លើងមកឱ្យគេ ក៏នឹងត្រូវនិយាយថា “អ្នកចូរនាំវាចេញទៅវិញ” ។ កាលរដូវរងាមានមនុស្សនាំយកផ្លិតមកបក់ឱ្យ ក៏នឹងត្រូវពោលថា “ចូរចេញទៅ កុំមកបក់ឱ្យយើងអី” ដូច្នេះ គប្បីជ្រាបសេចក្តីដែលធាតុទាំង ៣ នោះ មានសម្ផស្សជាសុខ និងជាទុក្ខ ដោយប្រការដូច្នេះ ។ ក៏វារៈ ១៣ ប្រដាប់ដោយន័យ ៤ យ៉ាង តាមដែលត្រាស់ទុកដោយន័យថា “**ផោដ្ឋព្វៈណាឃើញមិនបាន, តែពាល់បាន**” ជាដើម គប្បីជ្រាបដោយន័យដែលពោលទុកក្នុងរូបាយតនៈជាដើម ខាងក្រោយនុ៎ះចុះ ។

***សួរថា*** ក៏មហាភូតរូប ៣ ទាំងនោះ មកកាន់គន្លងព្រមគ្នាតែម្តងឬ, ឬថាមិនមកព្រមគ្នាទេ ?

ឆ្លើយថា មកព្រមគ្នា ។

***សួរថា*** មហាភូតរូប ៣ មកហើយយ៉ាងនេះ ពាល់ត្រូវកាយបសាទឬទេ ?

ឆ្លើយថា រមែងពាល់ត្រូវ ។

***សួរថា*** កាយវិញ្ញាណធ្វើមហាភូតរូប ៣ ទាំងនេះ ឱ្យជាអារម្មណ៍ព្រមគ្នាហើយកើតឡើង ឬមិនកើតឡើងទេ ?

ឆ្លើយថា កាយវិញ្ញាណមិនកើតឡើងទេ ។

***សួរថា*** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះការដែលកាយវិញ្ញាណធ្វើមហាភូតរូប ៣ ឱ្យជាអារម្មណ៍ រមែងមានដោយអំណាចនៃការនឹកគិតដល់ ឬដោយអំណាចនៃធាតុដែលមានច្រើន ។

បណ្តា (អំណាច)ទាំង ២ នោះ ពោលដោយការនឹកដល់មុន, ពិតមែន កាលមនុស្សយកបាយដាក់ក្នុងបាត្ររហូតពេញនាំមកហើយ ក៏ច្បិចគ្រាប់បាយមួយគ្រាប់មកសាកល្បងមើលថា “ រឹង ឬទន់” ក្នុងបាយមួយគ្រាប់នោះ រមែងមានទាំងតេជោធាតុ មានទាំងវាយោធាតុ ក៏ពិតមែនហើយ, ប៉ុន្តែថា គេក៏រមែងនឹកដល់បឋវីធាតុប៉ុណ្ណោះ; ការលូកដៃចុះក្នុងទឹកក្តៅសាកល្បងមើលក្នុងទឹកក្តៅនោះ រមែងមានទាំងបឋវីធាតុ មានទាំងវាយោធាតុ ក៏ពិតមែនហើយ, ប៉ុន្តែថា គេក៏រមែងនឹកដល់តេជោធាតុប៉ុណ្ណោះ ។ ក្នុងរដូវក្តៅ គេបើកបង្អួចហើយឋិតនៅឱ្យខ្យល់បក់មកប៉ះសរីរៈ កាលបើខ្យល់ល្ហើយៗ បក់មក **ក្នុងខ្យល់ល្ហើយៗ ដែលបក់មកនោះ** រមែងមានទាំងបឋវីធាតុ មានទាំងតេជោធាតុ ក៏ពិតមែនហើយ, ប៉ុន្តែថា គេក៏នឹកដល់វាយោធាតុប៉ុណ្ណោះ; កាយវិញ្ញាណធាតុ ឈ្មោះថា រមែងធ្វើមហាភូតរូបទាំង

៣ ឱ្យជាអារម្មណ៍ **ដោយអំណាចនៃការនឹកដល់** មានប្រការដូច្នេះ ។

ចំណែកបុគ្គលណាភ្លាត់ជួលចុះក្តី, យកក្បាលទង្គិចដើមឈើក្តី, កំពុងបរិភោគអាហារខាំចំដុំក្រួសក្តី, ក្នុងការភ្លាត់ជួលចុះជាដើមនោះ រមែងមានទាំងតេជោធាតុ ទាំងវាយោធាតុ, តែបុគ្គលនោះរមែងធ្វើចំពោះតែបឋវីធាតុប៉ុណ្ណោះ ឱ្យជាអារម្មណ៍ ដោយអំណាចនៃធាតុដែលមានច្រើន; កាលបុគ្គលជាន់ភ្លើងក្តី **ក្នុងភ្លើងនោះ** ក៏រមែងមានទាំងបឋវីធាតុ ទាំងវាយោធាតុ ក៏ពិតមែនហើយ, ប៉ុន្តែថា គេក៏ធ្វើចំពោះតេជោធាតុប៉ុណ្ណោះ ឱ្យជាអារម្មណ៍ដោយអំណាចនៃធាតុដែលមានច្រើន; កាលខ្យល់ខ្លាំង បក់មកប៉ះស្លឹកត្រចៀក ហាក់នឹងធ្វើឱ្យត្រចៀកថ្លង់ **ក្នុងខ្យល់ខ្លាំងនោះ** រមែងមានទាំងបឋវីធាតុ មានទាំងតេជោធាតុ ក៏ពិតមែនហើយ, ប៉ុន្តែ គេក៏ធ្វើចំពោះធាតុខ្យល់ប៉ុណ្ណោះឱ្យជាអារម្មណ៍ ដោយអំណាចនៃធាតុដែលមានច្រើន ។

បុគ្គលធ្វើនូវធាតុយ៉ាងណាមួយឱ្យជាអារម្មណ៍ សូម្បីកាយវិញ្ញាណ ក៏មិនកើតឡើងព្រមគ្នា, កាលបុគ្គលត្រូវម្ជុលទាំងដុំមុតហើយ កាយត្រូវម្ជុលទាំងនោះពាល់ត្រូវព្រមគ្នា, តែក្នុងទីណាៗ កាយបសាទមានច្រើន, ក្នុងទីនោះៗ កាយវិញ្ញាណរមែងកើតឡើង; សូម្បីក្នុងទីណាៗមានការប៉ះពាល់ ខ្ទាំងខ្ទប់ដ៏មានកម្លាំង, ក្នុងទីនោះៗ កាយវិញ្ញាណរមែងកើតឡើងមុន ។

កាលយកស្លាបមាន់លាបដំបៅ សរសៃស្លាបមាន់តែមួយសរសៃ រមែងពាល់

ត្រូវកាយបសាទ; ក៏ក្នុងទីណា។ កាយបសាទមានច្រើន, ក្នុងទីនោះ។ ឯង កាយ-វិញ្ញាណរមែងកើតឡើង; បុគ្គលរមែងធ្វើធាតុទាំង ៣ ឱ្យជាអារម្មណ៍ ដោយអំណាច**នៃធាតុដែលមានច្រើន** យ៉ាងនេះ, កាយវិញ្ញាណឈ្មោះថា រមែងកើតដោយអំណាចនៃធាតុដែលមានច្រើននោះឯង ។

**សួរថា** ចុះចិត្តឈានទៅអំពីអារម្មណ៍បានយ៉ាងណា ?

ឆ្លើយថា ឈានទៅដោយអាការៈ ២ យ៉ាង គឺ **ដោយអធ្យាស្រ័យ** (ការប្រាថ្នា) ឬ **ដោយអារម្មណ៍មានកម្លាំងខ្លាំង** ។

ពិតមែន ក៏ពេលដែលមានការឆ្លង (បូជា) ព្រះវិហារជាដើម មនុស្សអ្នកទៅដោយតាំងចិត្តថា "យើងនឹងសំពះព្រះចេតិយ នឹងសំពះព្រះបដិមានោះ, យើងនឹងមើលបោត្ថកម្ម (ការធ្វើសៀវភៅ) និងចិត្តកម្ម (ការគូររូបភាព)" ដូច្នេះសំពះ ឬឃើញវត្ថុមួយហើយក៏តាំងចិត្ត ដើម្បីត្រូវការសំពះខ្លះ ដើម្បីត្រូវការឃើញវត្ថុក្រៅនេះខ្លះ ហើយក៏ទៅដើម្បីសំពះខ្លះ ដើម្បីមើលខ្លះតែម្តង; យ៉ាងនេះ ចិត្តឈ្មោះថា ឈានទៅអំពីអារម្មណ៍ដោយអធ្យាស្រ័យ គឺសេចក្តីប្រាថ្នា ។ តែកាលឈរមើលព្រះមហាចេតិយ ដែលមានចំណែកប្រៀបដូចកំពូលនៃភ្នំកៃលាស [*], លុះពេលក្រោយមក កាលភ្លេងតន្ត្រីទាំងពួងលេងឡើង ទើបលះរូបារម្មណ៍ ឈានឡើងកាន់សទ្ទារម្មណ៍, កាលបុគ្គលនាំផ្កាឈើមានក្លិនដែលចូលចិត្ត ឬរបស់ក្រអូប

---

[*] ក្លាយមកពីសំព្ទដើមថា **កេលាស** ។

មក ក៏លះសទ្ទារម្មណ៍ ឈានឡើងកាន់គន្ធារម្មណ៍; យ៉ាងនេះ ឈ្មោះថា ឈានទៅដោយ**អារម្មណ៍ដែលមានកម្លាំងខ្លាំង** ៕

## អដ្ឋកថាអាបោធាតុនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **អាបោធាតុ** ដូចតទៅ ÷

បទថា "**អាបោ** = ការជ្រាបទឹកចូល" ជាការសម្ដែងសភាវៈអាបោនោះឯង ហៅថា **អាបោគតំ** = ធម្មជាតិដែលទឹកជ្រាបចូល; **សិនេហោ** (ការស្អិត) ដោយអំណាចនៃសេចក្ដីស្អិតនោះឯង ហៅថា **សិនេហគតំ** = ធម្មជាតិដែលស្អិត ។

បទថា "**ពន្ធនត្តំ រូបស្ស** = ធម្មជាតិជាគ្រឿងពឹងពាក់រូប" បានដល់ធម្មជាតិជាគ្រឿងប្រកបភូតរូបមានបឋវីជាដើម ។ ពិតមែន អាបោធាតុឃុំឃាំងវត្ថុទាំងឡាយមានដុំដែកជាដើមទុកហើយ រមែងធ្វើឱ្យជាប់គ្នា, ធម្មជាតិទាំងឡាយមានដុំដែកជាដើមនោះ ឈ្មោះថា **ជាប់គ្នា** ព្រោះសភាវៈនៃអាបោធាតុនោះ ជាគ្រឿងឃុំឃាំងទុក; សូម្បីផ្ទាំងថ្ម ភ្នំ ដើមត្នោត ពន្លកឈើ ភ្លុកដំរី និងស្នែងគោជាដើម ក៏មានន័យយ៉ាងនេះដែរ ។ ក៏អាបោធាតុប៉ុណ្ណោះឃុំឃាំងវត្ថុទាំងអស់នោះ ធ្វើឱ្យជាប់គ្នា, ធម្មជាតិពួកនោះ ឈ្មោះថា ជាធម្មជាតិជាប់គ្នា ក៏ព្រោះត្រូវអាបោធាតុឃុំឃាំងទុក ។

*សួរថា* ក៏បឋវីធាតុពាល់ត្រូវធាតុដ៏សេស (មានអាបោធាតុជាដើម) ហើយក៏ជាទីតាំងអាស្រ័យ ឬមិនពាល់ត្រូវក៏ជាទីអាស្រ័យបាន ?, ម្យ៉ាងទៀត អាបោធាតុកាលពឹងពាក់ធាតុទាំង ៣ ដ៏សេសពាល់ត្រូវហើយរមែងពឹងពាក់ ឬថាមិនពាល់ត្រូវហើយក៏ពឹងពាក់បាន ? ឆ្លើយថា ខាងដើមបឋវីធាតុមិនពាល់ត្រូវនឹងអាបោធាតុ ក៏ជាទីអាស្រ័យបាន, តែសម្រាប់តេជោធាតុ និងវាយោធាតុវិញ បឋវីធាតុពាល់ត្រូវទើបជាទីអាស្រ័យបាន; ចំណែកអាបោធាតុវិញមិនពាល់ត្រូវ សូម្បីបឋវីធាតុតេជោធាតុ និងវាយោធាតុ ក៏រមែងពឹងពាក់បាន; បើថា អាបោធាតុពាល់ត្រូវហើយគប្បីពឹងពាក់គ្នាបានសោត អាបោធាតុនោះ ក៏គប្បីឈ្មោះថា ផោដ្ឋព្វាយតនៈ ។

សូម្បីក្នុងការដែលតេជោធាតុ និងវាយោធាតុធ្វើកិច្ចរបស់ខ្លួនៗ ក្នុងធាតុដ៏សេស ក៏ន័យនេះដែរ ។ ពិតមែន តេជោធាតុពាល់ត្រូវបឋវីធាតុហើយ ក៏ញុំាងបឋវីឱ្យឆេះ, ចំណែកបឋវីធាតុនោះ មិនមែនជារបស់ក្តៅទេ រមែងត្រូវឆេះបាន; បើថា បឋវីធាតុ គប្បីជារបស់ក្តៅត្រូវឆេះរោលសោត, បឋវីធាតុក៏គប្បីមានភាពក្តៅជាលក្ខណៈ; មួយទៀត តេជោធាតុនោះ មិនបានពាល់ត្រូវអាបោធាតុ ក៏ធ្វើឱ្យអាបោធាតុនោះ ក្តៅបាន, សូម្បីអាបោធាតុនោះកាលក្តៅ ក៏មិនមែនជាសភាវៈក្តៅហើយដុតទេ; បើថា អាបោធាតុនោះ ជាតួសភាវៈនៃកម្តៅហើយគប្បីដុតសោត, អាបោធាតុនោះ ក៏គប្បីឈ្មោះថា មានភាពក្តៅជាលក្ខណៈ; មួយទៀត តេជោធាតុនោះ ពាល់ត្រូវវាយោធាតុនោះឯង ទើបឆេះរោលបាន, សូម្បីវាយោធាតុនោះ កាល

ត្រូវឆេះរោល ក៏មិនមែនជាតួកម្ដៅហើយឆេះរោលទេ; បើវាយោធាតុជាតួសភាវៈនៃកម្ដៅហើយ ឆេះរោលសោត, វាយោធាតុនោះ ក៏គប្បីឈ្មោះថា មានភាពក្ដៅជាលក្ខណៈ ។

វាយោធាតុពាល់ត្រូវបឋវីធាតុហើយរមែងរឹងថែស (គឺពង្រីកខ្លួនចេញ); ពាល់ត្រូវតេជោធាតុក៏ធ្វើឱ្យរឹងថែសដែរ, តែថាវាយោធាតុនោះ សូម្បីមិនពាល់ត្រូវអាបោធាតុក៏ដោយ ក៏រមែងធ្វើឱ្យអាបោធាតុរឹងថែសបានដែរ ។

**សួរថា** កាលបុគ្គលរំងាស់ទឹកអំពៅធ្វើជាស្ករ អាបោធាតុនឹងជាវត្ថុរឹង ឬមិនរឹង?

ឆ្លើយថា មិនជារបស់រឹងទេ; ព្រោះអាបោធាតុនោះ មានការហូរចេញ (ឬជ្រាប) ជាលក្ខណៈ, បឋវីធាតុមានការរឹងជាលក្ខណៈ, តែថាអាបោធាតុ មានបរិមាណទាប (តូច) ក៏នឹងប្រព្រឹត្តទៅតាមបឋវីធាតុដែលច្រើនក្រៃលែង; ពិតមែនអាបោធាតុនោះ រមែងលះភាវៈដែលតាំងនៅដោយអាការៈជារស (ទឹក) បាន, តែមិនលះលក្ខណៈឡើយ; សូម្បីការរំលាយស្ករអំពៅ បឋវីធាតុរមែងមិនរលាយ; ព្រោះបឋវីមានភាពរឹងជាលក្ខណៈ, អាបោធាតុមានការហូរចេញជាលក្ខណៈ ។

តែថាបឋវីធាតុមានបរិមាណទាប ក៏នឹងកើតការប្រព្រឹត្តទៅតាមអាបោធាតុដែលមានបរិមាណខ្ពស់, បឋវីធាតុនោះរមែងលះភាវៈដែលតាំងនៅដោយអាការៈជាដុំបាន, តែមិនលះលក្ខណៈរបស់ខ្លួន; ព្រោះថា មហាភូតរូបទាំង ៤ រមែងដល់សេចក្ដីប្រែប្រួលប្រព្រឹត្តិទៅប៉ុណ្ណោះ, ដែលឈ្មោះថា សេចក្ដីប្រែប្រួលរបស់លក្ខណៈ

មិនមានទេ; ភាពមិនមាននៃសេចក្ដីប្រែប្រួលដោយលក្ខណៈនោះ ទ្រង់សម្ដែងទុក **ដោយអដ្ឋានបរិកប្បសូត្រ** ។

ខនេះសមដូចព្រះតម្រាស់ដែលត្រាស់ទុកថា “ម្នាលអានន្ទ ក៏មហាភូតរូប គឺបឋវីធាតុ អាបោធាតុ តេជោធាតុ និងវាយោធាតុ គប្បីប្រែជាដទៃទៅបាន, តែព្រះអរិយសាវ័កអ្នកប្រកបដោយសេចក្ដីជ្រះថ្លា ដែលមិនញាប់ញ័រក្នុងព្រះពុទ្ធជាម្ចាស់នឹងប្រែជាដទៃវិញ ខនេះមិនគប្បីមានឡើយ”[៣១] , ក៏ក្នុង**អដ្ឋានបរិកប្បសូត្រ**នេះ មានអធិប្បាយថា “ម្នាលអានន្ទ បឋវីធាតុដែលមានភាពរឹងជាលក្ខណៈ នឹងប្ដូរទៅជាអាបោធាតុ ដែលមានការហូរចេញជាលក្ខណៈបាន, តែព្រះអរិយសាវ័ក ឈ្មោះថា ប្ដូរជាយ៉ាងដទៃមិនបានទេ” ; ការកំណត់អដ្ឋានៈ (ហេតុដែលប្រព្រឹត្តទៅមិនបាន) មានមកហើយក្នុងព្រះបាលីនេះ ដោយប្រការដូច្នេះ ៕

## អដ្ឋកថាឧបាទិន្នាទិនិទ្ទេស

ខាងមុខអំពីនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ**ឧបាទិន្នករូប**ជាដើមដូចតទៅ ៖

សេចក្ដីនៃឧបាទិន្នករូបជាដើម គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងមាតិកានោះឯង; អាយតនៈទាំងឡាយមានចក្ខាយតនៈជាដើម ក៏ខ្ញុំឱ្យពិស្ដារហើយខាងក្រោយដែរ, តែខ្ញុំនឹងពោលចំពោះសេចក្ដីដែលផ្សេងគ្នាក្នុងទីនោះៗ ប៉ុណ្ណោះ ។

---

[៣១] អំ. តិក. ។

ក្នុងនិទ្ទេសនៃឧបាទិន្នករូបមុន រូបទាំងឡាយដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ហៅចក្ខាយតនៈជាដើម ព្រោះជារូបមានចិត្តគ្រប់គ្រងតែម្យ៉ាង; តែព្រោះរូបាយតនៈជាដើមមានចិត្តគ្រប់គ្រងក៏មាន, មិនមានចិត្តគ្រប់គ្រងក៏មាន, ព្រោះហេតុដូច្នោះ រូបាយតនៈជាដើមនោះ ទើបព្រះអង្គទ្រង់សម្តែងដោយសង្ខេបថា "**យំ យំ វា បន** = ឬសូម្បីរូបដទៃណា១" ហើយគប្បីឱ្យពិស្តារដោយន័យមានជាអាទិ៍ថា "**កម្មស្ស កតត្តា រូបាយតនំ** = រូបាយតនៈដែលកម្មតាក់តែងឡើង" ទៀត; សេចក្តីក្នុង**យេវាបនកធម៌**ទាំងអស់ គប្បីជ្រាបដោយឧបាយនេះចុះ ។

**សួរថា** ក៏ព្រោះហេតុអ្វី បានជានៅក្នុងនិទ្ទេសសូម្បីទាំង ២ គឺ **កម្មស្ស កតត្តា** = រូបដែលកម្មតាក់តែងឡើង និង **ន កម្មស្ស កតត្តា** = រូបដែលកម្មមិន បានតាក់តែងឡើង, ព្រះអង្គទ្រង់មិនបានកាន់យកជរតារូប និងអនិច្ចតារូបទេ, ទ្រង់ កាន់យកក្នុងនិទ្ទេសទាំងឡាយនៃអនុបាទិន្នករូបជាដើមប៉ុណ្ណោះ ?

ឆ្លើយថា ព្រោះក្នុងបទថា "**ន កម្មស្ស កតត្តា** = រូបដែលកម្មមិនបានតាក់តែងឡើង" នេះ ព្រះអង្គទ្រង់រូបរួមរូបដែលមានសមុដ្ឋានកើតអំពីបច្ច័យដទៃក្រៅអំពីកម្មសិន, តែក្នុងបទថា "**កម្មស្ស កតត្តា** = រូបដែលកម្មតាក់តែងឡើង" នេះ ទ្រង់រូបរួមរូបដែលមានសមុដ្ឋានកើតអំពីកម្មតែម្យ៉ាង, រូបទាំង ២ គឺជរតារូប និងអនិច្ចតារូបពួកនេះមិនបានកើតអំពីកម្ម, មិនបានកើតអំពីបច្ច័យយ៉ាង

ដទៃ ដែលញុំាងរូបឱ្យកើតឡើងទេ, ព្រោះហេតុដូច្នោះ ទើបព្រះអង្គទ្រង់មិនកាន់យក ។ ក៏ការមិនកើតឡើងនៃជរតារូប និងអនិច្ចតារូប ដោយកម្មប្បច្ច័យជាដើមនោះ នឹងជាក់ច្បាស់ខាងមុខ ។ មួយទៀត ក្នុងពាក្យខាងដើមថា "**អនុបាទិន្នំ** = រូបដែលមិនមានចិត្តគ្រប់គ្រង" ទ្រង់បដិសេធសភាវៈនៃរូប មានសមុដ្ឋានកើតពីកម្មជាដើម, ទ្រង់មិនអនុញ្ញាតសភាវៈនៃរូបនោះ មានបច្ច័យដទៃជាសមុដ្ឋាន ដោយសព្ទថា **អនុបាទិន្នៈ**ជាដើមតែម្យ៉ាងទេ; ព្រោះហេតុដូច្នោះ ក្នុងនិទ្ទេសនៃអនុបាទិន្នករូបជាដើមនោះ បណ្ឌិតគប្បីជ្រាបថា រូបទាំង ២ ព្រះអង្គទ្រង់កាន់យកហើយដូច្នេះឯង ៕

# អដ្ឋកថាចិត្តសមុដ្ឋាននិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ចិត្តសមុដ្ឋាន** ដូចតទៅ ៖

រូបទាំងពីរនេះ គឺកាយវិញ្ញត្តិ និងវចីវិញ្ញត្តិ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា រមែងប្រាកដព្រោះអាស្រ័យភូតរូប មានចិត្តជាសមុដ្ឋានតែម្យ៉ាង, តែកាលពោលដោយបរមត្ថហើយ រូបទាំង ២ ដែលអាស្រ័យភូតរូបនោះ មិនមែនជាភូតរូបទេ, តែជារូបមានចិត្តជាសមុដ្ឋានដែលមានភូតរូបនោះឯង, ព្រោះសភាវៈនៃរូបពួកនោះ អាស្រ័យចិត្តហើយទើបតាំងឡើង សូម្បីរូបទាំង ២ នេះ ក៏ឈ្មោះថា មានចិត្ត

ជាសមុដ្ឋាន ដូចជរា និងមរណៈរបស់រូបដែលមិនទៀង ក៏ឈ្មោះថា មិនទៀង ។

សូម្បីក្នុងនិទ្ទេសនៃ**ចិត្តសហភូ** ក៏ន័យនេះដែរ; រូបទាំង ២ (កាយវិញ្ញត្តិ និងវចីវិញ្ញត្តិដែលជាសហភូ) នេះប៉ុណ្ណោះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុក ព្រោះរូបទាំង ២ នោះ ប្រាកដបានរហូតវេលាដែលចិត្តនៅប្រាកដ, តែរូបទាំង ២ នេះ មិនបានកើតព្រមជាមួយចិត្ត ដូចភូតរូប និងដូចសម្បយុត្តធម៌មានចេតនាជាដើមឡើយ ។

សូម្បីក្នុងនិទ្ទេសនៃចិត្តានុបរិវត្តិ ក៏ន័យនេះឯង ។ ក៏រូបទាំង ២ (កាយវិញ្ញត្តិ និងវចីវិញ្ញត្តិ) នេះត្រាស់ហៅថា "ចិត្តានុបរិវត្តិ" ព្រោះរូបទាំង ២ នេះ ប្រាកដបានរហូតវេលាដែលចិត្តនៅប្រាកដដូច្នោះ ។

បទថា "**ឱឡារិកំ** = រូបគ្រោតគ្រាត" បានដល់ រូបដែលឈ្មោះថា **គ្រោតគ្រាត** ព្រោះជាវត្ថុដែលគប្បីកាន់យកដោយអំណាចនៃការពាល់ត្រូវ ព្រោះមានទាំងវត្ថុ និងអារម្មណ៍ ។ គប្បីជ្រាប**រូបល្អិត**ដោយសភាពផ្ទុយគ្នា ជាមួយរូបគ្រោតគ្រាតដែលបានពោលមកហើយ ។

បទថា "**ទូរេ** = រូបឆ្ងាយ" បានដល់ សូម្បីរូបតាំងនៅក្នុងទីជិត ក៏ឈ្មោះថា រូប ឆ្ងាយដោយសភាវៈដែលដឹងបានដោយលំបាក ព្រោះកាន់យកមិនបានដោយអំណាចនៃការពាល់ត្រូវ ចំណែករូបក្រៅនេះ សូម្បីតាំងនៅឆ្ងាយក៏ឈ្មោះថា **នៅជិត** ដោយសភាវៈដែលដឹងបានងាយ ព្រោះគប្បីកាន់យកបានដោយអំណាចនៃការពាល់ត្រូវ ៕

## និទ្ទេសនៃចក្ខាយតនៈជាដើម

គប្បីជ្រាបដោយពិស្ដារតាមន័យដែលពោលទុកខាងក្រោយនុ៎ះចុះ; ក្នុងការសង្គ្រោះរូបពួក ២ មានខចែកផ្សេងគ្នាត្រឹមតែប៉ុណ្ណេះ; ការសង្គ្រោះរូប ពួក ៣ មានសេចក្ដីងាយស្រួលទាំងអស់ ៕

## អដ្ឋកថាចតុក្កនិទ្ទេស

ក្នុងបទខាងចុងនៃការសង្គ្រោះរូបទាំង ៤ ព្រះមានព្រះភាគជាម្ចាស់មិនធ្វើពាក្យសួរទុកតាំងអំពីដើម ព្រោះមិនមានសេចក្ដីប្លែកផ្សេងគ្នានៃបទខាងចុង មានពាក្យថា រូបដែលឃើញបានជាដើម, តែបានត្រាស់ពាក្យមានជាអាទិ៍ថា "រូបដែលឃើញបាន គឺរូបាយតនៈ រូបដែលស្ដាប់បាន គឺសទ្ទាយតនៈ" ។

បណ្ដារូបមានរូបាយតនៈជាដើមនោះ រូបាយតនៈ ឈ្មោះថា **ទិដ្ឋំ** (រូបដែលឃើញបាន) ព្រោះអត្ថថា ដែលចក្ខុអាចសំឡឹងមើលឃើញ, សទ្ទាយតនៈ ឈ្មោះថា **សុតំ** (រូបដែលស្ដាប់បាន) ព្រោះអត្ថថា ដែលសោតៈ (ត្រចៀក) អាចស្ដាប់សំឡេងហើយដឹងបាន ។ ពួក ៣ នៃអាយតនៈមានគន្ធាយតនៈជាដើម ឈ្មោះថា **មុតំ** (រូបដែលដឹងបាន) ដោយអត្ថថា ដែលឃាន ជិវ្ហា និងកាយ គប្បីដឹងដោយការទទួលអារម្មណ៍ដែលដល់ហើយ ។ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា រូបដែលឈ្មោះថា **មុតំ** ព្រោះហេតុដែលពាល់ត្រូវហើយ ទើបកើតវិញ្ញាណដូច្នេះក៏មាន ។ ចំណែករូប

ទាំងអស់វិញ ឈ្មោះថា **ទិញ្ញាតំ** (រូបដែលដឹងច្បាស់) ដោយចិត្ត ព្រោះអត្ថថា ដែលមននោវិញ្ញាណគប្បីដឹង ៕

## អដ្ឋកថាបញ្ចកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃការសង្គ្រោះរូបពួក ៥ ដូចតទៅ ៖

បទថា "**កក្ខឡំ** = ធម្មជាតិដែលរឹង" គឺរឹងប៉ឹង ភាពរឹងប៉ឹងនោះ ហៅថា ធម្មជាតិដែលរឹងប៉ឹង, អធិប្បាយថា ធម្មជាតិដែលគ្រោតគ្រាត ។ ភាពរឹង ភាវៈដែលរឹងសូម្បីទាំង ២ ក្រៅនេះ ក៏ជាការអធិប្បាយសភាវៈនោះឯង ។

បទថា "**អជ្ឈត្តំ** = ខាងក្នុង" បានដល់ ជាខាងក្នុងខ្លួន ។

បទថា "**ពហិទ្ធា វា** = ឬខាងក្រៅក៏ដោយចុះ" បានដល់ ជាខាងក្រៅខ្លួន ។

បទថា "**ឧបាទិន្នំ** = ជាឧបាទិន្នកៈ" បានដល់មានកម្មជាសមុដ្ឋានប៉ុណ្ណោះ[៣២] ។

ពាក្យថា "**ឧបាទិន្នំ**" នេះ ទ្រង់កាន់យករូបដែលតាំងនៅក្នុងសរីរៈដោយមិនប្លែកគ្នា; ពិតមែន រូបដែលតាំងនៅក្នុងសរីរៈ នឹងជាឧបាទិន្នកៈក៏ដោយ ជាអនុបាទិន្នកៈក៏ដោយ ឈ្មោះថា **ឧបាទិន្នកៈ**ប៉ុណ្ណោះ ដោយអំណាចនៃរូបដែលតណ្ហានិងទិដ្ឋិប្រកាន់ហើយនោះឯង ។

---

[៣២] ច្បាប់ភូមាថា មិនមែនមានកម្មជាសមុដ្ឋានតែម្យ៉ាងប៉ុណ្ណោះទេ ។

បទថា **“តេជោគតំ** = ធម្មជាតិដែលក្តៅ” បានដល់ សភាវៈដែលនៅក្នុងតេជោធាតុទាំងអស់ ដែលមានភាពក្តៅជាលក្ខណៈ, ម្យ៉ាងទៀត តេជោធាតុនោះឯងទៅកាន់ភាវៈដែលក្តៅ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **តេជោគតំ** ។

បទថា **“ឧស្មា** = មានសេចក្តីក្តៅឧណ្ហៗ” បានដល់ អាការៈដែលក្តៅឧណ្ហៗ។

បទថា **“ឧស្មាគតំ** = ធម្មជាតិដែលក្តៅឧណ្ហ” បានដល់ ធម្មជាតិដែលដល់ភាវៈក្តៅឧណ្ហ, ពាក្យនេះជាឈ្មោះរបស់អាការៈដែលក្តៅឧណ្ហៗ ។

បទថា **“ឧសុមំ** = សេចក្តីក្តៅខ្លាំង” បានដល់ ការប្រគល់កម្តៅឧណ្ហៗដែលមានកម្លាំង; ការប្រគល់កម្តៅឧណ្ហៗនោះឯង ដល់ភាវៈដែលក្តៅធំ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **ឧសុមគតំ** = ធម្មជាតិដែលក្តៅធំ ។

រូបដែលឈ្មោះថា **ឰរយា** (ការបក់ទៅមក) ដោយអំណាចនៃធម្មជាតិដែលបក់ទៅមក; **វាយោ**នោះឯងឈ្មោះថា **ឰរយាគតំ** (ធម្មជាតិដែលបក់ទៅមក) ព្រោះដល់ភាវៈដែលបក់ទៅមកបាន ។

បទថា **“ថម្ភិតត្តំ** = ធម្មជាតិជាគ្រឿងគាំទ្រ” បានដល់ សេចក្តីម៉ដ្ឋចត់តានតឹងរបស់រូប ដូចសេចក្តីម៉ដ្ឋចត់តានតឹងដែលពេញដោយខ្យល់ មានមែក និងសំបកឧប្បលជាដើម ៕

# អដ្ឋកថានិក្ខេបកណ្ឌ

ព្រះមានព្រះភាគទ្រង់មិនបានធ្វើបុច្ឆាទុក តាំងអំពីខាងដើមឡើយ ព្រោះមិនមានសេចក្ដីប្លែកផ្សេងគ្នានៃបទខាងចុង (គឺរូបដែលដឹងបានដោយមនោវិញ្ញាណ) នៃការសង្គ្រោះរូប ៣ ពួក ដែលមានការសង្គ្រោះរូបពួក ៦ ជាដើម, តែទ្រង់ធ្វើពាក្យអធិប្បាយទុក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃការសង្គ្រោះរូបពួក ៦ ជាដើមនោះ រូបដែលឈ្មោះថា ចក្ខុវិញ្ញាណគប្បីដឹង ព្រោះអត្ថថា ដែលចក្ខុវិញ្ញាណអាចដើម្បីនឹងដឹង ។ល។ រូបដែលឈ្មោះថា មនោវិញ្ញាណគប្បីដឹង ព្រោះអត្ថថា ដែលមនោវិញ្ញាណអាចដើម្បីនឹងដឹងបាន ។ រូបដែលឈ្មោះថា មនោធាតុគប្បីដឹង ព្រោះអត្ថថា ដែលមនោធាតុ ៣ យ៉ាង អាចដើម្បីនឹងដឹងបាន ។

ក្នុងបទថា “**សព្វំ រូបំ** = រូបទាំងអស់” នេះ ព្រោះសូម្បីត្រឹមតែរូបមួយដែលមនោវិញ្ញាណធាតុ មិនគប្បីដឹងបានមិនមាន, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា “**សព្វំ រូបំ**” ដូច្នេះ ។ **ពិតមែន ន័យក្នុងឋានៈដែលគួរគប្បីអធិប្បាយដល់ព្រះអភិធម្មហើយ ឈ្មោះថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់មិនធ្វើទុក រមែងមិនមានឡើយ** ។ ដោយន័យនេះ ក៏ឈ្មោះថា ឋានៈដែលគួរដើម្បីណែនាំ ព្រោះសេចក្ដីមិនមានសូម្បីតែរូបម្យ៉ាង ដែលមនោវិញ្ញាណមិនគប្បីដឹងបាន, ព្រោះហេតុដូច្នោះ កាលនឹងទ្រង់ធ្វើន័យ (ខណែនាំ) ទុក ទើបត្រាស់ថា “**សព្វំ រូបំ**” ។

បទថា **"សុខសម្ផស្សា** = មានសម្ផស្សជាសុខ" គឺបានដល់ មានសុខ-វេទនាជាបច្ច័យ ។ បទថា **"ទុក្ខសម្ផស្សា** = មានសម្ផស្សជាទុក្ខ" គឺបានដល់ មានទុក្ខវេទនាជាបច្ច័យ ។ សូម្បីក្នុងពាក្យថា មានសម្ផស្សជាសុខជាដើមនេះ ព្រះអង្គទ្រង់ប្រទានន័យនេះទុក ព្រោះសភាវៈនៃផោដ្ឋព្វារម្មណ៍មានសភាវៈជាទុក្ខ និងជាសុខ ។

តែថាក្នុងនិទ្ទេសនៃរូបពួក ៩ ទ្រង់មិនប្រទានន័យទុក ព្រោះកាលរូបដែលមិនមែនជាឥន្ទ្រិយមាន, ក្នុងរូបពួក ១០ ទ្រង់ប្រទានន័យទុក ព្រោះការដែលរូបនោះៗ ឯងជាសប្បដិឃៈ (ប៉ះខ្ទប់បាន) និងអប្បដិឃៈ (ប៉ះខ្ទប់មិនបាន); ក្នុងរូបពួក ១១ ទ្រង់ចែកអាយតនៈទុក ១១ កន្លះ, បណ្ឌិតគប្បីជ្រាបនិទ្ទេស-វារៈនៃអាយតនៈពួកនោះៗ ដោយពិស្ដារតាមន័យដែលពោលទុកក្នុងខាងក្រោយចុះ ។

ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្ដីងាយស្រួលមែនពិត ៕

## សម្ដែងអំពីបកិណ្ណកកថា

ក៏ដើម្បីការមិនច្រឡំក្នុងរូបពួកនោះ បណ្ឌិតគប្បីជ្រាបបកិណ្ណកៈពួកនោះ គឺ

-**សមោធាន** ប្រមូលមក

-**សមុដ្ឋាន** ហេតុឱ្យកើតឡើង

-**បរិនិប្ផន្នៈ** គឺរូប ។

បណ្តាបកិណ្ណកៈពួកនោះ ខថា **“សមោធាន”** សេចក្តីថា រូបទាំងអស់តែម្តង ពោលដោយសមោធាន គឺការប្រមូលមករាប់បាន ២៥ រូប គឺ ចក្ខាយតនៈ, សោតាយតនៈ, ឃានាយតនៈ, ជិវ្ហាយតនៈ, កាយាយតនៈ, រូបាយតនៈ, សទ្ទាយតនៈ, គន្ធាយតនៈ, រសាយតនៈ, ឥត្ថិន្ទ្រិយ, បុរិសិន្ទ្រិយ, ជីវិតិន្ទ្រិយ, កាយវិញ្ញត្តិ, វចីវិញ្ញត្តិ, អាកាសធាតុ, រូបលហុតា, រូបមុទុតា, រូបកម្មញ្ញតា, រូបឧបចយៈ, រូបសន្តតិ, រូបជរតា, រូបអនិច្ចតា, កពឡិង្ការាហារ, ផោដ្ឋព្វាយតនៈ និងអាបោធាតុ; **រូប ២៥** នេះ រួមជាមួយរូប គឺហទយវត្ថុ គប្បីជ្រាបថា **មាន ២៦**, ឈ្មោះថា មិនមានរូបដទៃអំពីនេះទេ។ តែអាចារ្យពួកខ្លះមានវាទៈថា មិទ្ធៈជារូប ទើបពោលថា “ឈ្មោះថា មានមិទ្ធរូប” អាចារ្យទាំងនោះ គប្បីត្រូវសកវាទ្យាចារ្យពោលថា “លោកជាមុនីឥសីសម្ពុទ្ធមែន, នីវរណៈរបស់លោកមិនមានឡើយ” [៣៣] ដូច្នេះជាដើម គប្បីបដិសេធថា “រូបដែលឈ្មោះថា មិទ្ធរូបមិនមានទេ” ។ អាចារ្យមួយពួកទៀតពោលថា “រូបទាំង ២៦ នោះជាមួយពលរូប ក៏ជារូប ២៧, រួមជាមួយសម្ភវរូប ក៏ជារូប ២៨, រួមជាមួយជាតិរូប ក៏ជារូប ២៩, រួមជាមួយរោគរូប ក៏ជារូប ៣០” សូម្បីអាចារ្យនោះ ក៏គប្បីឱ្យសម្តែងសេចក្តីមិនមាននៃរូបទាំងនោះទុកមួយផ្នែកហើយទើបបដិសេធ ។

ពិតមែន ព្រះអង្គទ្រង់កាន់យកពលរូបនោះឯង ដោយវាយោធាតុដែលទ្រង់

---

[៣៣] ខុ. សុ.។

កាន់យកហើយ, ឈ្មោះថា ពលរូបដទៃវមែងមិនមាន ។ ទ្រង់កាន់យកសម្ភវរូបដោយអាបោធាតុ, ទ្រង់កាន់យកជាតិរូបដោយឧបចយៈ និងសន្តតិ, ទ្រង់កាន់យករោគរូបដោយជរតារូប និងអនិច្ចតារូបដែលកាន់យកហើយ, ក៏ឈ្មោះថា រោគរូបដទៃរមែងមិនមាន, សូម្បីអាពាធមានរោគត្រចៀកជាដើមណា, អាពាធនោះ ក៏ត្រឹមតែជាធាតុតាំងឡើងដោយបច្ច័យដែលមិនសមគ្នាប៉ុណ្ណោះ, ឈ្មោះថា រោគរូបដទៃអំពីនោះមិនមានទេ ព្រោះហេតុដូច្នោះ កាលពោលដោយការប្រមូលមករួមគ្នាហើយ ក៏មានរូបត្រឹមតែ ២៦ ប៉ុណ្ណោះ ៕

# សម្តែងអំពីសមុដ្ឋានរបស់រូប

ខថា **សមុដ្ឋាន** សេចក្តីថា រូបប៉ុន្មាន មានសមុដ្ឋានប៉ុន្មាន ?

រូប ១០ មានសមុដ្ឋាន ១, រូប ១ មានសមុដ្ឋាន ២, រូប ៣ មានសមុដ្ឋាន ៣, រូប ៩ មានសមុដ្ឋាន ៤, រូប ២ មិនតាំងឡើងអំពីសមុដ្ឋានអ្វីឡើយ; បណ្តារូបទាំងនោះ រូប ១០ ឈ្មោះថា មានសមុដ្ឋាន ១ គឺរូបទាំង ៨ នេះ បានដល់ ចក្ខុបសាទ ។ ល ។ ជីវិតិន្ទ្រិយ តាំងឡើងអំពីកម្មតែម្យ៉ាង ដោយចំណែកមួយ ។

រូប ២ គឺកាយវិញ្ញត្តិ និងវចីវិញ្ញត្តិ តាំងឡើងអំពីចិត្តតែម្យ៉ាង; រូប ១ ឈ្មោះថា **មានសមុដ្ឋាន ២** គឺសទ្ទរូបតាំងឡើងអំពីឧតុ និងចិត្ត។ ក្នុងសទ្ទរូបនោះ សំឡេងដែលកើតឡើងពីវត្ថុមិនមានវិញ្ញាណ តាំងឡើងពីឧតុ, សំឡេងដែលកើតឡើងពីវត្ថុ

ដែលមានវិញ្ញាណតាំងឡើងពីចិត្ត ។ ចំណែកវិការរូប ៣ មានលហុតារូបជាដើម ឈ្មោះថា មានសមុដ្ឋាន ៣ គឺរមែងតាំងឡើងពីឧតុ, ចិត្ត និងអាហារ ។ រូប ៩ ដ៏សេស រមែងតាំងឡើងពីសមុដ្ឋាន ៤ គឺ ឧតុ, ចិត្ត, អាហារ និងកម្ម ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **រូប ៩ មានសមុដ្ឋាន ៤** ។

ចំណែកជរតារូប និងអនិច្ចតារូប រមែងមិនតាំងឡើងពីសមុដ្ឋានទាំង ៤ នោះ សូម្បីសមុដ្ឋានតែមួយ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **រូប ២ មិនតាំងឡើងអំពីសមុដ្ឋានអ្វីឡើយ** ។

**សួរថា** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះរូបទាំង ២ នេះមិនកើតឡើង ។

**សួរថា** ព្រោះហេតុអ្វីរូបទាំង ២ នេះមិនកើតឡើង ?

ឆ្លើយថា ព្រោះរូបដែលកើតហើយ ក៏ត្រូវចាស់ និងបែកធ្លាយទៅ ។

ពិតណាស់ រូប ឬអរូបឱ្យតែកើតឡើងហើយ ក៏ត្រូវតែបែកធ្លាយ ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីព្រមទទួលពាក្យដូចពោលនេះយ៉ាងពិតប្រាកដ; ព្រោះថា រូប ឬអរូបកើតឡើងហើយឈ្មោះថា មិនអស់ទៅ នៅប្រាកដមិនដែលមានទេ; តែដរាបណារូបនៅមិនបែកធ្លាយ ភាពចាស់ទ្រុឌទ្រោមរបស់រូបនោះ ក៏នៅតែប្រាកដដរាបនោះ ព្រោះហេតុនោះ សេចក្តីនេះ ទើបសម្រេចថា រូបកើតឡើងហើយត្រូវតែចាស់ និងបែកធ្លាយទៅ ។ ក៏ប្រសិនបើរូបទាំង ២ នេះ គប្បីកើតសោត, សូម្បីរូបទាំង ២ នេះ គប្បី

ចាស់ និងបែកធ្លាយទៅ; ឯសេចក្ដីចាស់របស់រូបក៏រមែងមិនចាស់, ឬសេចក្ដីបែកធ្លាយរបស់រូប ក៏រមែងមិនបែកធ្លាយទៅ ព្រោះហេតុដូច្នោះ រូបទាំង ២ នេះ ទើបឈ្មោះថាមិនកើត ព្រោះរូបកើតឡើងហើយ ក៏ត្រូវតែចាស់ និងបែកធ្លាយ ។

ក្នុងខនេះ បើមានអ្នកតវ៉ាឡើងដោយពាក្យថា "ឧបចយរូប និងសន្តតិរូប" ក្នុងនិទ្ទេសទាំងឡាយថា "រូបដែលកម្មតាក់តែងឡើង" ជាដើម រមែងជាពាក្យធានាថា "ជាតិរូបរមែងកើត" ដូច្នេះ យ៉ាងណា, សូម្បីរូបដែលចាស់ហើយ ក៏ចូរចាស់ទៅចុះ សូម្បីរូបដែលបែកធ្លាយទៅហើយ ក៏ចូរបែកធ្លាយទៅចុះ យ៉ាងនោះដែរ ។

ក្នុងសេចក្ដីនោះ លោកមិនបានព្រមទទួលថា ជាតិរូបរមែងកើត, តែធម៌ឯណារមែងកើតឡើងដោយកម្មជាដើម លោកព្រមទទួលវោហារនៃការកើតឡើងរបស់ធម៌នោះដោយមានជាតិជាបច្ច័យ ដោយការកើតឡើងនៃធម៌ទាំងនោះ ។ តែកាលបើពោលដោយបរមត្ថ ជាតិរូបរមែងមិនកើត, ព្រោះជាតិរូបកាលបើកើតក៏គ្រាន់តែជាការកើតប៉ុណ្ណោះ គឺមិនឱ្យឈ្មោះថាកើតឡើងទេ ។

ក្នុងខនេះ បើគប្បីមានអ្នកចោទថា "ជាតិរូបជាការកើតឡើងរបស់ធម៌ឯណារមែងបានវោហារថា ជាបច្ច័យដល់ធម៌ទាំងនោះ និងវោហារថា ការកើតឡើងរបស់ធម៌ទាំងនោះ យ៉ាងណានោះឯង, ម្យ៉ាងទៀត ការចាស់ និងការបែកធ្លាយរបស់ធម៌ឯណាតែងមាន សូម្បីភាពចាស់ និងភាពបែកធ្លាយ ចូរបានវោហារថាជាបច្ច័យដល់ធម៌ទាំងនោះ និងការកើតឡើងនៃធម៌ទាំងនោះ យ៉ាងណា, សូម្បីរូបទាំង ២ នេះ

ក៏នឹងគប្បីពោលបានថា មានកម្មជាដើមជាសមុដ្ឋានយ៉ាងនោះឯង”[៣៤] ដូច្នេះឬ ?

សេចក្ដីនេះឆ្លើយថា ភាពចាស់ និងភាពបែកធ្លាយនឹងមានវោហារយ៉ាងនោះ មិនបានឡើយ ។

*សួរថា* ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះការមិនមានក្នុងខណៈនៃអានុភាពរបស់ជនកប្បច្ច័យ ។

ពិតមែនហើយ អានុភាពនៃជនកប្បច្ច័យទាំងឡាយ មានក្នុងឧប្បាទខណៈនៃធម៌ដែលខ្លួនគប្បីឱ្យកើតឡើងប៉ុណ្ណោះ, មិនលើសពីនោះទៅទេ; ឯក្នុងខណៈនៃធម៌ដែលជនកប្បច្ច័យទាំងនោះឱ្យកើតឡើង ជាតិកាលបើប្រាកដរមែងបានវោហារថាជាបច្ច័យដល់ធម៌ទាំងនោះ និងវោហារថា ជាការកើតរបស់ធម៌ទាំងនោះ ព្រោះការមាននៅព្រមក្នុងខណៈនោះ; រូប (ឧបចយៈ និងសន្តតិ) ទាំងពីរ ក្រៅពីនេះ មិនមានក្នុងខណៈនោះទេ, និងគប្បីពោលថា កើតនៅក្នុងខណៈនោះ ក៏មិនបានឡើយ ។

បើសិននឹងចោទទៅទៀតថា “សូម្បីរូបទាំងពីរនេះ ក៏នៅតែឈ្មោះថា កើតដែរ ព្រោះមានបាលីមកថា ‘ ម្នាលភិក្ខុទាំងឡាយ ជរា និងមរណៈជាវត្ថុមិនទៀង ជាសង្ខតៈ (ដែលបច្ច័យប្រជុំតាក់តែងហើយ) ជាធម៌អាស្រ័យហេតុទើបកើតឡើង”[៣៥] ដូច្នេះ ?

ឆ្លើយថា មិនមែនដូច្នោះទេ, ព្រោះព្រះបាលីសម្ដែងទុកដោយបរិយាយ;

---

[៣៤] សំ. និ. ។

[៣៥] សំ. និ. ។

ពិតណាស់ ក្នុងព្រះបាលីនោះព្រះអង្គត្រាស់ថា ជរា និងមរណៈនោះ ជាធម៌អាស្រ័យហេតុហើយកើតឡើងដូច្នោះដោយបរិយាយ ព្រោះធម៌ទាំងឡាយ ដែលអាស្រ័យហេតុហើយកើតឡើងជាជរា និងមរណៈ ។

ប្រសិនបើនឹងមានពាក្យចោទទៀតថា "សូម្បីរូបទាំង ៣ នោះ ក៏រមែងមិនមាន ដូចស្នែងទន្សាយព្រោះមិនកើតឡើង, ឬមានដូច្នោះ ក៏ជារបស់ទៀងដូចព្រះនិព្វានពិត ?"

ឆ្លើយថា មិនមែនដូច្នោះទេ ព្រោះនៅមានសេចក្តីប្រព្រឹត្តទៅជាប់ដោយនិស្សយប្បច្ច័យដែរ; ព្រោះថា កាលបើនិស្សយប្បច្ច័យមានបឋវីជាដើម ធម្មជាតិទាំង ៣ មានការកើតជាដើម ក៏រមែងប្រាកដ, ព្រោះហេតុដូច្នោះ នឹងថាមិនមែន ក៏មិនបានដែរ; មួយទៀត កាលបើមិនមាននិស្សយប្បច្ច័យទាំងនោះ ក៏នឹងមិនប្រាកដ, ព្រោះហេតុដូច្នោះ នឹងថាទៀង ក៏មិនបានដើម្បីនឹងទ្រង់បដិសេធសូម្បីសេចក្តីប្រកាន់មាំនេះទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ជរា និងមរណៈជារបស់មិនទៀង ដែលបច្ច័យប្រជុំតាក់តែងហើយ ជាធម៌អាស្រ័យហេតុហើយ ទើបកើតឡើង"[៣៦] ដូច្នេះ; ដោយន័យមានជាអាទិ៍យ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា រូបទាំង ២ (ឧបចយរូប និងសន្តតិរូប) មិនតាំងឡើងពីសមុដ្ឋានអ្វីៗ ឡើយ ។ម្យ៉ាងវិញទៀត ក្នុងខថា **"សមុដ្ឋានំ"** នេះ គប្បីជ្រាបសេចក្តីយ៉ាងដទៃ តពីមាតិកានេះ របស់សេចក្តីនោះថា ៖

---

[៣៦] សំ. និ. ។

**កម្មជំ** រូបកើតពីកម្ម

**កម្មប្បច្ចយំ** រូបមានកម្មជាបច្ច័យ

**កម្មប្បច្ចយឧតុសមុដ្ឋានំ** រូបមានឧតុជាសមុដ្ឋានកើតពីកម្មជាបច្ច័យ

**អាហារសមុដ្ឋានំ** រូបមានអាហារជាសមុដ្ឋាន

**អាហារប្បច្ចយំ** រូបមានអាហារជាបច្ច័យ

**អាហារប្បច្ចយឧតុសមុដ្ឋានំ** រូបមានឧតុជាសមុដ្ឋាន កើតពីអាហារជាបច្ច័យ ។

**ឧតុសមុដ្ឋានំ** រូបមានឧតុជាសមុដ្ឋាន

**ឧតុប្បច្ចយំ** រូបមានឧតុជាបច្ច័យ

**ឧតុប្បច្ចយឧតុសមុដ្ឋានំ** រូបមានឧតុជាសមុដ្ឋាន កើតពីឧតុជាបច្ច័យ

**ចិត្តសមុដ្ឋានំ** រូបមានចិត្តជាសមុដ្ឋាន

**ចិត្តប្បច្ចយំ** រូបមានចិត្តជាបច្ច័យ

**ចិត្តប្បច្ចយឧតុសមុដ្ឋានំ** រូបមានឧតុជាសមុដ្ឋានកើតពីចិត្តជាបច្ច័យ ។

បណ្តាសមុដ្ឋាននៃរូបទាំង ៤ នោះ រូប ៨ យ៉ាង មានចក្ខុបសាទជាដើម រួមនឹងហទយវត្ថុឈ្មោះថា **កម្មជៈ** = កើតពីកម្ម; រូបមានជាអាទិ៍យ៉ាងនេះ គឺសក់ ពុកចង្កា ភ្លុកដំរី រោមកន្ទុយសេះ រោមកន្ទុយចាមរី ឈ្មោះថា **កម្មប្បច្ច័យ** = មានកម្មជាបច្ច័យ; រូបមានជាអាទិ៍យ៉ាងនេះថា ចក្ករតនៈ ឧទ្យាន និងវិមានរបស់ពួកទេវតា

ឈ្មោះថា **កម្មប្បច្ចយឧតុសមុដ្ឋាន** = រូបមានឧតុជាសមុដ្ឋានកើតពីកម្មជាបច្ច័យ ។

សុទ្ធដ្ឋករូបតាំងឡើងពីអាហារឈ្មោះថា **អាហារសមុដ្ឋាន** = មានអាហារជាសមុដ្ឋាន; កពឡីការាហារជាបច្ច័យសូម្បីដល់រូបសន្តតិទាំងពីរ គឺអាហារសមុដ្ឋាន និងឧបាទិន្នករូបជាបច្ច័យឱ្យកើតអាហារសមុដ្ឋាន និងអនុបាលកម្មជរូប, ព្រោះហេតុដូច្នោះ កម្មជរូបដែលមានអាហារអនុបាលទុកនេះ ឈ្មោះថា **អាហារប្បច្ច័យ** = មានអាហារជាបច្ច័យ; បុគ្គលសេពវិសភាគាហារហើយដើរទៅកណ្ដាលថ្ងៃ រមែងកើតរោគឃ្លង់ខ្មៅជាដើម, នេះឈ្មោះថា **អាហារប្បច្ចយឧតុសមុដ្ឋាន** = រូបមានឧតុជាសមុដ្ឋានកើតពីអាហារជាបច្ច័យ; សុទ្ធដ្ឋករូបតាំងឡើងពីឧតុឈ្មោះថា **ឧតុ-សមុដ្ឋាន** = មានឧតុជាសមុដ្ឋាន; សូម្បីឧតុក្នុងសុទ្ធដ្ឋកៈនោះក៏ញ៉ាំងរូប ៨ យ៉ាងដទៃឱ្យតាំងឡើង, នេះឈ្មោះថា **ឧតុប្បច្ច័យ** = មានឧតុជាបច្ច័យ; សូម្បីឧតុក្នុងរូប ៨ យ៉ាងដទៃទៀត រមែងញ៉ាំងរូប ៨ យ៉ាងដទៃទៀតឱ្យតាំងឡើង នេះឈ្មោះថា **ឧតុប្បច្ចយឧតុសមុដ្ឋាន** = រូបមានឧតុជាសមុដ្ឋាន មានឧតុជាបច្ច័យ; ដោយប្រការដូច្នេះ ឧតុរមែងអាចដើម្បីបន្តសន្តតិរូប ៣ ប៉ុណ្ណោះ, ហួសពីនេះទៅ ឧតុមិនអាចបន្តបានឡើយ;សេចក្ដីនេះ សមគួរសម្ដែងសូម្បីដោយអនុបាទិន្នករូបដូច**ពលាហកោ** (មេឃ) ឈ្មោះថា មានឧតុជាសមុដ្ឋាន; ព្រោះមានឧតុជាដំណក់ភ្លៀង ឈ្មោះថា មានឧតុជាបច្ច័យ, កាលបើភ្លៀងធ្លាក់ហើយ ពូជទាំងឡាយរមែងដុះឡើង ផែនដីរមែងផ្សាយក្លិន, ភ្នំប្រាកដជាពណ៌ខៀវ, ទឹកសមុទ្រ (ទន្លេ) រមែងច្រើនឡើង

ដោយអាការៈយ៉ាងនេះ ក៏ឈ្មោះថា **ឧតុបច្ចយឧតុសមុដ្ឋាន** = រូបមានឧតុ ជាសមុដ្ឋានកើតពីឧតុជាបច្ច័យ ។

សុទ្ធដ្ឋករូបតាំងឡើងពីចិត្តឈ្មោះថា **ចិត្តសមុដ្ឋាន** = រូបមានចិត្តជាសមុដ្ឋាន; ពាក្យថា "ធម៌ទាំងឡាយ គឺចិត្ត និងចេតសិកដែលកើតខាងក្រោយ ជាបច្ច័យដល់កាយនេះ ដែលកើតមុន ដោយអំណាចនៃបច្ឆាជាតប្បច្ច័យ" [៣៧] នេះឈ្មោះថា **ចិត្តប្បច្ច័យ** = រូបមានចិត្តជាបច្ច័យ ។ ពាក្យដែលលោកពោលទុកថា "វិមែងសម្ដែងរូបដំរីខ្លះ, សម្ដែងរូបសេះខ្លះ, រូបរថខ្លះ, រូបក្បួនទ័ពផ្សេងៗខ្លះ ក្នុងអាកាស គឺកណ្ដាលវាល" [៣៨] នេះ ឈ្មោះថា **ចិត្តប្បច្ចយឧតុសមុដ្ឋាន** = រូបមានឧតុជាសមុដ្ឋានកើតពីចិត្តជាបច្ច័យ ។

ខថា **"បរិនិប្ផន្នំ"** បានដល់ (រូបកើតពីកម្ម) ១៥ រូប ឈ្មោះថា បរិនិប្ផន្នរូប,រូបមិនបានកើតពីកម្ម ១០ រូប ឈ្មោះថា អបរិនិប្ផន្នៈ; អធិប្បាយថា បើរូបធម៌ដែលជាអបរិនិប្ផន្នៈ (រូបដែលមិនកើតពីកម្ម), រូបទាំងនោះ ក៏ឈ្មោះថា **អសង្ខតរូប** = រូបដែលកម្មមិនតាក់តែងឡើង; តែកាយវិការរបស់រូបទាំងនោះៗ ឯង ឈ្មោះថា **កាយវិញ្ញត្តិ**, វចីវិការរបស់រូបទាំងនោះៗ ឯង ឈ្មោះថា **វចីវិញ្ញត្តិ** ។ វាលស្រឡះ ឈ្មោះថា **អាកាសធាតុ**, ភាពស្រាលនៃរូបឈ្មោះថា **លហុតា**, ភាពទន់នៃ

---

[៣៧] អភិ. ។

[៣៨] ខុ.បដិ. ។

រូប ឈ្មោះថា **មុទុតា** ។ ភាពគួរដល់ការងាររបស់រូបឈ្មោះថា **កម្មញ្ញតា**, ការកើតឡើងនៃរូប ឈ្មោះថា **ឧបចយៈ**, ការប្រព្រឹត្តទៅនៃរូប ឈ្មោះថា **សន្តតិ** ។ អាការៈ គឺការចាស់របស់រូបឈ្មោះថា **ជិរតា**, អាការៈដែលរូបមានហើយ ត្រឡប់ជាមិនមានវិញ ឈ្មោះថា **អនិច្ចតា** ។ រូបទាំងអស់ដូចពោលមកនេះ ជាអបរិនិប្ផន្នៈ (មិនកើតពីកម្ម), ជាសង្ខតៈ (មានបច្ច័យតាក់តែង) ទាំងអស់មែនពិត ។%

**ចប់បកិណ្ណកកថា**

**ពណ៌នារូបកណ្ឌក្នុងអដ្ឋសាលិនី**

**នៃអដ្ឋកថាធម្មសង្គហៈចប់តែប៉ុណ្ណេះ**

# អធិប្បាយសញ្ញោជនគុច្ឆកៈ

## សម្តែងអំពីមាននិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងមាននិទ្ទេសនៃ **សញ្ញោជនគោច្ឆកៈ** ដូចតទៅ ៖

បទថា “**សេយ្យោហមស្មីតិ មានោ** = ការប្រកាន់តួខ្លួនថា យើងជាបុគ្គលប្រសើរជាងគេ” បានដល់ មានះដែលកើតឡើងយ៉ាងនេះថា “យើងល្អជាងគេ” ដោយសេចក្ដីថា ខ្ពស់បំផុត ។ បទថា “**សទិសោហមស្មីតិ មានោ** = ការប្រកាន់តួខ្លួនថា យើងស្មើគេ” បានដល់ មានះដែលកើតឡើងយ៉ាងនេះថា “យើងស្មើនឹងគេ” ដោយសេចក្ដីសម្គាល់ថា ស្មើៗ គ្នា ។ បទថា “**ហីនោហមស្មីតិ មានោ** = ការប្រកាន់តួខ្លួនថា យើងអាក្រក់ជាងគេ” បានដល់ មានះដែលកើតឡើងយ៉ាងនេះថា “យើងអាក្រក់ជាងគេ” ដោយសេចក្ដីសម្គាល់ថា អន់ជាងគេ ។ មានះទាំង ៣ នេះ គឺមានះថា ល្អជាងគេ, មានះថា ស្មើនឹងគេ, មានះថា អន់ជាងគេ រមែងកើតដល់ជន ៣ ចំពូក ដោយប្រការដូច្នេះ ។

ដ្បិតថា មានះ ៣ គឺមានសេចក្ដីសម្គាល់ខ្លួនថា យើងល្អជាងគេ, ស្មើនឹងគេ, អាក្រក់ជាងគេ រមែងកើតដល់មនុស្សដែលល្អជាងគេខ្លះ, ដល់មនុស្សដែលស្មើនឹងគេខ្លះ, ដល់មនុស្សដែលអាក្រក់ជាងគេខ្លះ ។

បណ្ដាមានះទាំង ៣ នោះ សូម្បីមានះថា យើងល្អជាងគេ របស់បុគ្គលអ្នកល្អជាងគេ ជាមានះតាមសេចក្ដីពិត ។ មានះ ២ ក្រៅនេះ មិនមែនជាមានះតាមសេចក្ដីពិតទេ ។ មានះថា យើងស្មើនឹងគេ របស់បុគ្គលអ្នកស្មើគេ ។ ល ។ មានះ

ថា យើងអាក្រក់ជាងគេ របស់បុគ្គលអ្នកអាក្រក់ជាងគេ ជាមានះតាមសេចក្ដីពិត; មានះ ២ ក្រៅនេះ មិនមែនជាមានះតាមសេចក្ដីពិតឡើយ ។

ដោយពាក្យដែលពោលមកនេះ ត្រាស់ទុកយ៉ាងណា ?

ត្រាស់ទុកថា មានះ ៣ រមែងកើតដល់បុគ្គលម្នាក់បាន ។

តែក្នុង**មាននិទ្ទេស** សេចក្ដីទីមួយក្នុង**ខុទ្ទកវិភង្គ**[៧៩] ត្រាស់ថា មានះមួយ រមែងកើតដល់ជនទាំង ៣; ដែលឈ្មោះថា មានះ (ការប្រកាន់ខ្លួន) ដោយអំណាចនៃការធ្វើសេចក្ដីប្រកាន់ខ្លួន ។

បទថា "**មញ្ញនា មញ្ញិតត្តំ** = កិរិយាប្រកាន់ខ្លួន ការប្រកាន់ខ្លួន" នេះ ជាការចង្អុលដល់អាការៈ និងភាវៈ; ដែលឈ្មោះថា **ឧណ្ណតិ** (ការលើកខ្លួន) ដោយសេចក្ដីសម្គាល់ថា ស្ញើចសរសើរ ។ ដែលឈ្មោះថា **ឧណ្ណាមោ** (ការលើកតម្កើងខ្លួន) ព្រោះអត្ថថា មានះរមែងញ៉ាំងបុគ្គលអ្នកកើតមានះឱ្យអណ្ដែតឡើង គឺលើកតាំងឡើង ។ ដែលឈ្មោះថា **ធជោ** (ដូចទង់ជ័យ) ដោយសេចក្ដីសម្គាល់ថា លើកតម្កើងខ្លួនឡើង។ ដែលឈ្មោះថា **សម្បគ្គាហោ** (ការលើកចិត្តឡើង) ព្រោះអត្ថថា រមែងផ្គងចិត្ត ដោយសេចក្ដីសម្គាល់ថា ការលើកឡើង ។ បណ្ដាទង់ទាំងឡាយ ទង់ច្រើនដែលលើកឡើងខ្ពស់ ត្រាស់ថា "**កេតុ** = ទង់" ព្រោះថា មានះកាលកើតញយៗ ព្រោះអាស្រ័យមានះតៗ មក ក៏ដូចជាទង់ ព្រោះអត្ថថា លើកឡើងទុកខ្ពស់ ព្រោះ

---

[៧៩] អភិ. ។

ហេតុដូច្នោះ ទើបហៅថា ដូចទង់ ។ ចិត្តណារមែងត្រូវការមានះដូចទង់ ព្រោះហេតុដូច្នោះ ចិត្តនោះ ទើបឈ្មោះថា **កេតុកម្យំ** = ប្រាថ្នាដូចទង់, ភាវៈនៃកេតុកម្យៈនោះ ឈ្មោះថា **កេតុកម្យតា** = សភាពនៃចិត្តត្រូវការដូចទង់; ក៏សភាពនៃចិត្តត្រូវការដូចទង់នោះ ជារបស់ចិត្ត, មិនមែនជារបស់អត្តា; ដោយហេតុនោះ ទើបត្រាស់ថា "**កេតុកម្យតា ចិត្តស្ស** = ភាវៈនៃចិត្តត្រូវការដូចទង់" ; អធិប្បាយថា ចិត្តសម្បយុត្តដោយមានះ រមែងប្រាថ្នាដូចទង់ និងភាវៈនៃចិត្តនោះ ឈ្មោះថា **កេតុ-កម្យតា** គឺមានះដែលរាប់ដូចជាទង់ ៕ ៕

## សម្តែងអំពីឥស្សានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ឥស្សា** ដូចតទៅ ៖

ពាក្យថា "**យា បរលាភសក្ការគរុការមានន‌វន្ទនបូជនាទីសុ ឥស្សា** = ការច្រណែនក្នុងលាភសក្ការៈ ការធ្វើសេចក្តីគោរព រាប់អាន សំពះ និងការបូជារបស់បុគ្គលដទៃជាដើម យ៉ាងណា" សេចក្តីថា ឥស្សាណាដែលមានក្នុងខណៈខឹងចងគំនុំក្នុងសម្បត្តិរបស់អ្នកដទៃក្នុងវត្ថុទាំងឡាយ មានលាភជាដើមរបស់ពួកជនដទៃនោះថា "លាភជាដើមទាំងឡាយនោះ នឹងមានប្រយោជន៍អ្វីដោយបុគ្គលនោះ"។

ក្នុងព្រះបាលីនោះ បទថា “**លាភោ** = លាភ” បានដល់ ការបានចំពោះនូវបច្ច័យ ៤ មានចីវរជាដើម; ដ្បិតថា បុគ្គលអ្នកឥស្សា រមែងខឹងចងគំនុំចំពោះលាភរបស់បុគ្គលដទៃនោះ មិនប្រាថ្នាថា “ប្រយោជន៍អ្វីដោយលាភនេះដល់បុគ្គលនេះ”។

បទថា “**សក្ការោ** = សក្ការៈ” បានដល់ ការបានបច្ច័យទាំងនោះឯង ដែលល្អដែលបុគ្គលធ្វើល្អហើយ ។ បទថា “**គរុការោ** = ការធ្វើសេចក្តីគោរព” បានដល់កិរិយាដែលលើកតម្កើង គឺការធ្វើឱ្យជាភារៈ ។ បទថា “**មាននំ** = ការរាប់អាន” បានដល់ ការធ្វើឱ្យជាទីស្រឡាញ់ដោយចិត្ត ។ បទថា “**វន្ទនំ** = ការថ្វាយបង្គំ” បានដល់ ការថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ បទថា “**បូជនា** = ការបូជា” បានដល់ ការបូជាដោយរបស់ក្រអូប និងផ្កាឈើជាដើម ។ ដែលឈ្មោះថា **ឥស្សា** (ការច្រណែន) ដោយអំណាចនៃកិរិយាមិនចង់ឱ្យមនុស្សដទៃបានល្អ; អាការៈមិនចង់ឱ្យមនុស្សដទៃបានល្អ ឈ្មោះថា **ឥស្សាយនា** = កិរិយាឥស្សា, ភាវៈដែលមិនចង់ឱ្យមនុស្សដទៃបានល្អ ឈ្មោះថា **ឥស្សាយិតត្តំ** = ភាពឥស្សា ។ ការជំទាស់គ្នាជាដើម ជាពាក្យវេវចនៈរបស់ឥស្សា ។ បណ្ឌិតគប្បីជ្រាបលក្ខណៈនៃការខឹងរបស់ឥស្សានេះ ដោយបុគ្គលអ្នកគ្រប់គ្រងផ្ទះខ្លួន អ្នកមិនគ្រប់គ្រងផ្ទះខ្លួន ៕

## សម្ដែងអំពីលក្ខណៈឥស្សា ២ យ៉ាង

ដ្បិតថា ឃរាវាសខ្លះ អាស្រ័យសេចក្ដីព្យាយាមធ្វើដូចបុរស (កិច្ចដែលបុរសគប្បីធ្វើ) របស់ខ្លួនដោយអាជីវៈយ៉ាងណានីមួយក្នុងការងារទាំងឡាយ មានការធ្វើស្រែ និងលក់ដូរជាដើម រមែងបានយានពាហនៈ ឬរតនៈដែលល្អ; មនុស្សម្នាក់ទៀត មានសេចក្ដីប្រាថ្នាឱ្យបុគ្គលនោះសូន្យចាកលាភ មិនត្រេកអរដោយការបានលាភរបស់បុគ្គលនោះ, គិតតែថា "កាលណាហ្ន៎ មនុស្សនេះនឹងអស់អំពីសម្បត្តិនេះ ជាមនុស្សកំព្រាត្រាច់ទៅ" ដូច្នេះ កាលបុគ្គលម្នាក់នោះ សូន្យចាកសម្បត្តិនោះដោយហេតុម្យ៉ាង ក៏ពេញចិត្ត ។

សូម្បីបព្វជិតមួយរូបអ្នកមានចិត្តឥស្សា ឃើញបព្វជិតមួយរូបដទៃទៀតដល់ព្រមដោយការបានបច្ច័យជាដើមដែលកើតឡើង ព្រោះអាស្រ័យសុត្តបរិយត្តិជាដើមរបស់ខ្លួន ក៏គិតថា "កាលណាហ្ន៎ លោករូបនេះសូន្យពីលាភទាំងនេះ" ជាដើម កាលណាឃើញភិក្ខុរូបនោះសូន្យដោយហេតុម្យ៉ាង, កាលនោះក៏មានចិត្តត្រេកអរ; បណ្ឌិតគប្បីជ្រាបថា ឥស្សាមានការច្រណែនសម្បត្តិរបស់បុគ្គលដទៃ ជាលក្ខណៈដោយប្រការដូច្នេះ ៕

## សម្តែងអំពីមច្ឆរិយនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុង **មច្ឆរិយនិទ្ទេស** ដូចតទៅ ៖

គប្បីសម្តែងមច្ឆរិយៈ (សេចក្តីកំណាញ់) ដោយវត្ថុ ទើបត្រាស់ពាក្យមានជាអាទិ៍ថា "**បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ** = សេចក្តីកំណាញ់ ៥ គឺកំណាញ់អាវាស" ។ ក្នុងមច្ឆរិយៈទាំងនោះ សេចក្តីកំណាញ់ក្នុងអាវាស ឈ្មោះថា **អាវាស-មច្ឆរិយំ** ។ សូម្បីបទដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ អារាមទាំងអស់ក្តី បរិវេណនៃអារាមក្តី បន្ទប់តូចក្តី ទីស្នាក់ក្នុងវេលាយប់ជាដើមក្តី ឈ្មោះថា **អាវាស** ។ ពួកភិក្ខុដែលនៅក្នុងអាវាសរមែងនៅយ៉ាងសប្បាយ, រមែងបានបច្ច័យទាំងឡាយ; ភិក្ខុមួយរូបអ្នកកំណាញ់ រមែងមិនប្រាថ្នាឱ្យភិក្ខុអ្នកដល់ព្រមដោយវត្ត អ្នកមានសីលជាទីស្រឡាញ់មកក្នុងទីលំនៅនោះទេ; សូម្បីមកហើយក៏គិតថា "ភិក្ខុនេះចូរទៅដោយរហ័សចុះ" ដូច្នេះ នេះឈ្មោះថា **អាវាសមច្ឆរិយៈ** (សេចក្តីកំណាញ់អាវាស), តែភិក្ខុអ្នកមិនប្រាថ្នាឱ្យការទៅក្នុងទីនោះដល់ពួកអ្នកបង្កជម្លោះជាដើម មិនឈ្មោះថា អាវាសមច្ឆរិយៈ (នេះជាសេចក្តីកំណាញ់ទី ១) ។

បទថា "**កុលំ** = ត្រកូល" បានដល់ ត្រកូលឧបដ្ឋាកខ្លះ, ត្រកូលញាតិខ្លះ; កាលភិក្ខុមិនប្រាថ្នាឱ្យភិក្ខុដទៃចូលកាន់ត្រកូលនោះ រមែងជាកុលមច្ឆរិយៈ (កំណាញ់ត្រកូល) តែភិក្ខុមិនប្រាថ្នាឱ្យបុគ្គលលាមកចូលទៅកាន់ត្រកូលនោះ មិនឈ្មោះថាមច្ឆរិយៈ, ព្រោះមនុស្សលាមកនោះ រមែងបដិបត្តិដើម្បីទម្លាយសេចក្តីជ្រះថ្លារបស់

ត្រកូលទាំងនោះ, តែភិក្ខុអ្នកអាចរក្សាសេចក្ដីជ្រះថ្លាទុកបាន មិនប្រាថ្នាឱ្យភិក្ខុនោះចូលទៅក្នុងត្រកូលនោះ ទើបឈ្មោះថា មច្ឆរិយៈ (នេះជាសេចក្ដីកំណាញ់ទី ២) ។

បទថា "**លាភោ** = លាភ" បានដល់ ការបានបច្ច័យ ៤, កាលភិក្ខុអ្នកមានសីលរូបដទៃបាននូវបច្ច័យ ៤ នោះឯង ភិក្ខុអ្នកកំណាញ់គិតថា "សូមកុំបាន" ដូច្នេះ រមែងជាលាភមច្ឆរិយៈ (កំណាញ់លាភ), តែភិក្ខុណាញុំាងសទ្ធាទេយ្យ (របស់ដែលគេប្រគេនដោយសទ្ធា) ឱ្យធ្លាក់ចុះក្ដី, រមែងធ្វើបច្ច័យដែលបានមកឱ្យវិនាស ដោយអំណាចនៃការមិនបរិភោគ ឬបរិភោគមិនល្អជាដើមក្ដី, មិនឱ្យសូម្បីវត្ថុដែលនឹងដល់ការផ្អូមរលួយដល់ភិក្ខុដទៃក្ដី, ភិក្ខុអ្នកកំណាញ់ឃើញភិក្ខុនោះហើយគិតថា "បើភិក្ខុរូបនេះមិនបានបច្ច័យនេះ, ភិក្ខុដទៃដែលមានសីលគប្បីបាន, គប្បីបរិភោគ" ដូច្នេះ មិនឈ្មោះថា មច្ឆរិយៈទេ (នេះជាសេចក្ដីកំណាញ់ទី ៣) ។

សរីរវណ្ណៈ (សម្បុរនៃសរីរៈ) ក្ដី គុណវណ្ណៈ (ការសរសើរគុណ គឺសេចក្ដីល្អ) ក្ដី ឈ្មោះថា **វណ្ណោ**; ក្នុងវណ្ណៈទាំងពីរនោះ បុគ្គលអ្នកកំណាញ់សរីរវណ្ណៈ កាលមានមនុស្សនិយាយថា "បុគ្គលដទៃគួរជ្រះថ្លា មានរូបស្អាត" ដូច្នេះ មិនប្រាថ្នានឹងពោលដល់បុគ្គលនោះ ។ បុគ្គលអ្នកកំណាញ់គុណវណ្ណៈ (ការសរសើរគុណគឺសេចក្ដីល្អ) រមែងមិនប្រាថ្នានឹងពោលគុណសេចក្ដីល្អរបស់អ្នកដទៃដោយសីល ដោយធុតង្គ ដោយបដិបទា និងដោយអាចារៈ (នេះជាវណ្ណមច្ឆរិយៈទី ៤) ។

បទថា " **ធម្មោ** = ធម៌" បានដល់ បរិយត្តិធម៌ និងបដិវេធធម៌, ក្នុងធម៌ទាំងពីរនោះ ព្រះអរិយៈទាំងឡាយ រមែងមិនកំណាញ់បដិវេធធម៌ទេ, រមែងប្រាថ្នាការចាក់ធ្លុះដល់លោក ព្រមទាំងទេវលោក ក្នុងធម៌ដែលខ្លួនចាក់ធ្លុះហើយ, គឺរមែងប្រាថ្នាថា "សូមសត្វដទៃចូរដឹងការចាក់ធ្លុះធម៌នោះ" ដូច្នេះ, ក៏ឈ្មោះថា ធម្មមច្ឆរិយៈ (សេចក្តីកំណាញ់ធម៌) រមែងមានក្នុងតន្តិធម៌* (ធម៌ដែលជាគម្ពីរ) ប៉ុណ្ណោះ, បុគ្គលអ្នកប្រកបដោយតន្តិធម៌នោះ រមែងដឹងគម្ពីរដែលអាថ៌កំបាំង ឬកថាមគ្គយ៉ាងណា; មិនប្រាថ្នានឹងឱ្យមនុស្សដទៃដឹងគម្ពីរ ឬកថាមគ្គនោះ; តែថា ភិក្ខុណាគិតសញ្ជឹងដល់បុគ្គល ឬគិតសញ្ជឹងដល់ធម៌ ដោយការអនុគ្រោះ (ឧបត្ថម្ភ) ធម៌ មិនឱ្យការអនុគ្រោះឧបត្ថម្ភបុគ្គល, ភិក្ខុនេះ មិនឈ្មោះថា ធម្មមច្ឆរិយៈ។

ក្នុងខនេះ បុគ្គលខ្លះ ជាមនុស្សឡេះឡោះ គឺពេលខ្លះជាសមណៈ, ពេលខ្លះជាព្រាហ្មណ៍, ពេលខ្លះជាគ្រហស្ថ; ក៏ភិក្ខុណាមិនឱ្យដោយគិតថា "បុគ្គលនេះ នឹងទម្លាយតន្តិធម៌ដែលល្អិតសុខុម ជាធម៌ដ៏ក្រៃលែង ជាប្រពៃណីតតគ្នាមកឱ្យច្របូកច្របល់" ដូច្នេះ **ភិក្ខុនេះគិតសញ្ជឹងដល់បុគ្គលហើយ ឈ្មោះថា រមែងមិនឱ្យព្រោះត្រកងធម៌ទុក**, ចំណែកភិក្ខុណារមែងមិនឱ្យដោយគិតថា "ធម៌នេះ ល្អិតសុខុម, បើបុគ្គលនេះនឹងរៀនយក, នឹងព្យាករណ៍អរហត្តផល នឹងសម្តែងខ្លួនឱ្យដល់សេចក្តីវិនាស" , **ភិក្ខុនេះគិតសញ្ជឹងធម៌ហើយឈ្មោះថា រមែងមិនឱ្យដោយ**

---

* តន្តិធម៌ គឺធម៌ និងវិន័យ។

**ការត្រកងបុគ្គល,** តែបុគ្គលណារមែងមិនឱ្យដោយគិតថា “បើបុគ្គលនេះ រៀនធម៌នេះ នឹងអាចទម្លាយលទ្ធិ (សម័យ) របស់ពួកយើង” ដូច្នេះ, បុគ្គលនេះ ឈ្មោះថា ជាអ្នកកំណាញ់ធម៌ (នេះជាធម្មមច្ឆរិយៈទី ៥) ។

បណ្តាមច្ឆរិយៈទាំង ៥ នេះ **ពោលដោយអាវាសមច្ឆរិយៈមុន,** បុគ្គលកើតជាយក្ស ឬជាប្រេតហើយនឹងយកក្បាលទូលសំរាម ជារបស់ដែលនៅសល់នោះឯងដើរទៅ ។ **ពោលដោយកុលមច្ឆរិយៈ** កាលត្រកូលនោះធ្វើទាន និងរាប់អានបុគ្គលដទៃ កាលគេឃើញក៏គិតថា “ត្រកូលរបស់យើងនេះបែកហើយហ្ន៎” ដូច្នេះ លោហិតនឹងហូរចេញអំពីមាត់ខ្លះ មានការឆ្អល់ពោះខ្លះ, ពោះវៀនធំទាំងឡាយ ក៏នឹងដាច់ជាកំណាត់តូច កំណាត់ធំចេញមកខ្លះ ។ **ពោលដោយលាភមច្ឆរិយៈ** កំណាញ់ក្នុងលាភជារបស់សង្ឃ ឬគណៈ ឬថាបុគ្គល ក៏បរិភោគគ្រឿងប្រើប្រាស់របស់បុគ្គល រមែងកើតជាយក្ស ឬប្រេត ឬក៏ពស់វែកធំ ។ **ពោលដោយសរីរវណ្ណ-គុណមច្ឆរិយៈ** និង **បរិយត្តិធម្មមច្ឆរិយៈ** បុគ្គលរមែងសរសើរវណ្ណៈរបស់ខ្លួន, មិនសរសើរវណ្ណៈរបស់អ្នកដទៃ កាលនឹងពោលទោសនោះៗ ដោយពាក្យថា “នេះវណ្ណៈអ្វី ?” កាលមិនឱ្យបរិយត្តិអ្វីដល់នរណាៗ រមែងជាអ្នកមានពណ៌អាក្រក់ និងជាអ្នកល្ងង់ខ្លៅ ។

ម្យ៉ាងទៀត បុគ្គលរមែងត្រូវភ្លើងឆេះក្នុងខ្ទះលោហៈ ដោយសេចក្តីកំណាញ់អាវាស, រមែងជាអ្នកមានលាភតិច ដោយសេចក្តីកំណាញ់ត្រកូល, រមែងកើតក្នុង

**គូថនរក** ដោយសេចក្ដីកំណាញ់លាភ, បុគ្គលកាលកើតគ្រប់ៗ ភព រមែងមិនមានវណ្ណៈល្អ ដោយការកំណាញ់វណ្ណៈ, រមែងកើតក្នុង**កុក្កុលនរក** ដោយការកំណាញ់ធម៌ ។

ដែលឈ្មោះថា **មច្ឆេរំ** (សេចក្ដីកំណាញ់) ដោយអំណាចនៃការឃើញដល់ខ្លួន, អាការៈនៃសេចក្ដីកំណាញ់ឈ្មោះថា **មច្ឆរាយនា** (កិរិយាកំណាញ់), ភាវៈនៃចិត្តដែលត្រូវសេចក្ដីកំណាញ់ឱ្យប្រព្រឹត្តទៅ ហើយព្រមព្រៀងដោយសេចក្ដីកំណាញ់ឈ្មោះថា **មច្ឆរាយិតត្តំ** (សេចក្ដីកំណាញ់), បុគ្គលដែលឈ្មោះថា **វិវិច្ឆោ** (អ្នកហួងហែង) ព្រោះអត្ថថា ប្រាថ្នាសម្បត្តិទាំងអស់របស់ខ្លួន មិនឱ្យសាបសូន្យទៅដោយគិតថា "សូមសម្បត្តិទាំងពួង ចូរមានដល់យើងប៉ុណ្ណោះ, ចូរកុំមានដល់មនុស្សដទៃ" ; ភាវៈនៃបុគ្គលអ្នកហួងហែង ឈ្មោះថា **វេវិច្ឆំ** (ការហួងហែង), ពាក្យថា "ការហួងហែង" នេះ ជាឈ្មោះរបស់សេចក្ដីកំណាញ់យ៉ាងអន់ ។

បុគ្គលអ្នកមិនអើពើត្រាស់ថា **កទរិយោ** (អ្នកឃើញតួខ្លួន),ភាវៈនៃបុគ្គលអ្នកឃើញដល់តួខ្លួននោះហៅថា **កទរិយំ** (ការស្វិតស្វាញ) ពាក្យថា "ការស្វិតស្វាញ" នេះ ជាឈ្មោះរបស់សេចក្ដីកំណាញ់យ៉ាងខ្លាំងក្លា, ព្រោះបុគ្គលអ្នកប្រកបដោយសេចក្ដីកំណាញ់នោះ រមែងហាមសូម្បីបុគ្គលដទៃ ដែលឱ្យដល់បុគ្គលដទៃ, សេចក្ដីនេះសមដូចព្រះបាលីដែលត្រាស់ទុកក្នុង **សំយុត្តនិកាយសគាថវគ្គ** ថា ៖

**"កទរិយោ បាបសំកប្បោ មិច្ឆាទិដ្ឋិ អនាទរោ**
**ទទមានំ និវារេតិ យាចមានានំ ភោជនំ**

បុគ្គលអ្នកស្និតស្នាល មានសេចក្តីត្រិះរិះអាក្រក់ ជាមិច្ឆាទិដ្ឋិ មិនមានសេចក្តីអើពើ រមែងហាមមនុស្សដែលកំពុងឱ្យភោជនាហារដល់មនុស្សទាំងឡាយដែលសុំ”[៨០] ។

បុគ្គលណាឃើញស្មូមយាចកទាំងឡាយហើយ ឱ្យចិត្តបញ្ឈប់នៅ គឺឱ្យចិត្តរួញរានៅដោយសេចក្តីស្និតស្នាល ព្រោះហេតុនោះ បុគ្គលនោះទើបឈ្មោះថា **កដុ-កញ្ចុកោ** (អ្នកមិនអើពើ), ភាពជាអ្នកមិនអើពើនោះ ឈ្មោះថា **កដុកញ្ចុកតា** = ការមិនអើពើ ។

នំយមួយទៀត បុគ្គលអ្នកមានវែកក្នុងដៃត្រាស់ហៅថា **កដុកញ្ចុកតា**, ក៏បុគ្គលកាលនឹងកាន់យកបាយអំពីឆ្នាំងដែលពេញមាត់ឆ្នាំង រមែងកាន់យកដោយចុងវែកដែលច្បិចគ្រប់ចំណែក ក៏មិនអាចដើម្បីកាន់យកឱ្យពេញ យ៉ាងណា, ចិត្តរបស់បុគ្គលអ្នកកំណាញ់ក៏យ៉ាងនោះដែរ, រមែងចង្អៀតចង្អល់ សូម្បីកាយក៏ចង្អៀតចង្អល់រួញរា រមែងមិនលូកឱ្យដើម្បីជនដទៃ ព្រោះហេតុដូច្នោះ សេចក្តីកំណាញ់ទើបត្រាស់ហៅថា **កដុកញ្ចុកតា** = ភាពជាមនុស្សមានចិត្តចង្អៀតចង្អល់ដូចវែកដួសបាយ ។

បទថា **“អគ្គហិតត្តំ ចិត្តស្ស** = ភាពមិនអើពើនៃចិត្ត” បានដល់ ការដែលចិត្តកាន់យកទុក ដោយប្រការដែលមិនសណ្តូក (លា) ទៅ ដោយអាការៈ មានការឱ្យទានជាដើម ក្នុងការធ្វើឧបការៈដល់ជនដទៃ ។ ក៏ព្រោះមនុស្សកំណាញ់

---

[៨០] សំ. ស. ។

រមែងមិនប្រាថ្នានឹងឱ្យវត្ថុដែលខ្លួនមានដល់ជនដទៃ, ចង់នឹងទទួលតែរបស់មនុស្សដទៃ, ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្ដីកំណាញ់នោះ មានការលាក់សម្បត្តិរបស់ខ្លួនជាលក្ខណៈ ឬសេចក្ដីកំណាញ់នោះ មានការកាន់យកសម្បត្តិរបស់មនុស្សដទៃជាលក្ខណៈ ដោយអំណាចនៃការប្រព្រឹត្តទៅថា "ភាពអស្ចារ្យនេះ ចូរមានដល់យើងតែម្នាក់ប៉ុណ្ណោះ, កុំមានដល់មនុស្សដទៃឡើយ" ។ ពាក្យដ៏សេស ក្នុងគោច្ឆក្កៈនេះ មានសេចក្ដីងាយស្រួលមែនពិត ។

ក៏សំយោជនៈទាំងនេះ គួរនាំមកសម្ដែងដោយលំដាប់នៃកិលេសខ្លះ, ដោយលំដាប់នៃមគ្គខ្លះ, **ពោលដោយលំដាប់នៃកិលេស** អនាគាមិមគ្គរមែងប្រហារនូវកាមរាគសំយោជនៈ និងបដិឃសំយោជនៈ, អរហត្តមគ្គរមែងប្រហារនូវមានសំ-យោជនៈ, សោតាបត្តិមគ្គរមែងប្រហារនូវទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ, អរហត្តមគ្គ រមែងប្រហារនូវភវរាគសំយោជនៈ, សោតាបត្តិមគ្គរមែងប្រហារនូវឥស្សាមច្ឆរិយៈ, អរហត្តមគ្គរមែងប្រហារនូវអវិជ្ជា ។ **ពោលដោយលំដាប់នៃមគ្គ** សោតាបត្តិមគ្គ រមែងប្រហារនូវទិដ្ឋិវិចិកិច្ឆា សីលព្វតបរាមាសៈ ឥស្សា និងមច្ឆរិយៈ, អនាគាមិមគ្គរមែងប្រហារនូវកាមរាគៈ និងបដិឃៈ, អរហត្តមគ្គរមែងប្រហារនូវមានះ ភវរាគៈ និងអវិជ្ជាដូច្នេះឯង ៕

## សម្តែងអំពីគណ្ឋគោច្ឆកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **គណ្ឋគោច្ឆកៈ** ដូចតទៅ ៖

សភាវធម៌ដែលឈ្មោះថា កាយគណ្ឋៈ ព្រោះអត្ថថា រមែងចងនាមកាយ គឺរមែងញ៉ាំងនាមកាយឱ្យបន្តទៅក្នុងវដ្តៈដោយអំណាចនៃការបដិសន្ធិ ។ កាយគណ្ឋៈណា ដែលបដិសេធសូម្បីពាក្យរបស់ព្រះសព្វញ្ញុពុទ្ធ រមែងប្រកាន់មាំដោយអាការៈយ៉ាងនេះថា “លោកទៀង, នេះប៉ុណ្ណោះពិត, យ៉ាងដទៃគ្មានប្រយោជន៍ (ជាមោឃៈ)” ព្រោះហេតុដូច្នោះ កាយគណ្ឋៈនោះ ទើបឈ្មោះថា **ឥទំសច្ចាភិនិវេសៈ**; ក៏ព្រោះមានសេចក្តីផ្សេងគ្នានៃអភិជ្ឈា និងកាមរាគៈ, ព្រោះហេតុដូច្នោះ ក្នុងការចែកបទអភិជ្ឈាកាយគណ្ឋៈ ទើបមិនត្រាស់ថា “កាមច្ឆន្ទៈ (សេចក្តីពេញចិត្តក្នុងកាម) កាមរាគៈ (តម្រេកក្នុងកាម) ក្នុងកាមទាំងឡាយ យ៉ាងណា” ដូច្នេះ ទើបត្រាស់ពាក្យថា “រាគៈ (តម្រេក), សារាគៈ (តម្រេកខ្លាំង) ណា” ជាដើម; ដោយពុទ្ធវចនៈនេះ ពាក្យណា ដែលពោលទុកខាងក្រោយថា “ឆន្ទរាគៈ (តម្រេកដោយអំណាចនៃការពេញចិត្ត) ក្នុងវិមានទាំងឡាយ មានវិមានរបស់ពួកព្រហ្មជាដើម **មិនជាកាមាសវៈទេ**, សំឡឹងដល់គណ្ឋៈហើយ អភិជ្ឈាក៏ឈ្មោះថា កាយគណ្ឋៈ (អភិជ្ឈាកាយគណ្ឋៈ)” , ពាក្យនោះ បណ្ឌិតគប្បីជ្រាបថា ខ្ញុំពោលទុកល្អហើយ ។ សូម្បីកិលេសគោច្ឆកៈខាងមុខ ក៏មានន័យដូចគ្នានេះដែរ ។

ពាក្យថា “**ឋវេចត្វា សីលព្វតបរាមាសំ** = វៀរសីលព្វតបរាមាសៈ” នេះ សេចក្ដីថា ព្រោះសីលព្វតបរាមាសៈមិនប្រកាន់ដោយអាការៈមានជាអាទិ៍ថា “នេះប៉ុណ្ណោះពិត” , តែរមែងប្រកាន់យ៉ាងនេះថា “មានសេចក្ដីបរិសុទ្ធបានដោយសីល” ជាដើម ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគជាម្ចាស់កាលទ្រង់ជំទាស់សីលព្វតបរាមាសៈដែលជាមិច្ឆាទិដ្ឋិនោះ ទើបត្រាស់ថា “**វៀរលែង**” ដូច្នេះ ៕៚

## អធិប្បាយនីវរណគោច្ឆកៈ

## សម្ដែងអំពីថីនមិទ្ធនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងថីនមិទ្ធនិទ្ទេសនៃ **នីវរណគោច្ឆកៈ** ដូចតទៅ ៖

បទថា “**ចិត្តស្ស អកល្យតា** = ការមិនប្រកបនៃចិត្ត” គឺភាវៈនៃមនុស្សឈឺ ។ ដ្បិតមនុស្សឈឺត្រាស់ហៅថា **អកល្យកោ** = អ្នកមានសុខភាពមិនល្អ; សូម្បីក្នុងវិន័យក៏ពោលទុកថា “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាច” ដូច្នេះ ។

បទថា “**អកម្មញ្ញតា** = ភាពមិនគួរដល់ការងារ” បានដល់ អាការៈនៃសេចក្ដីមិនគួរដល់ការងារ គឺសេចក្ដីឈឺនៃចិត្ត ។ បទថា “**ឱលីយនា** = ការអស់សង្ឃឹម” បានដល់ អាការៈដែលនឿយណាយ ។ ដ្បិតថា ចិត្តដែលញ៉ាំងឥរិយាបថឱ្យកើតឡើង កាលមិនអាចដើម្បីឱ្យឥរិយាបថតាំងនៅ រមែងអស់សង្ឃឹម ដូចសត្វប្រចៀវតូចព្យួរនៅលើដើមឈើ រមែងនឿយណាយនូវផ្ទាំងទឹកផឹកដែលព្យួរ

ទុកត្រង់សសរខឿនដូច្នោះ; ព្រះមានព្រះភាគត្រាស់ថា “ការអស់សង្ឃឹម” ដូច្នេះ ទ្រង់សំដៅដល់អាការៈនោះរបស់ចិត្តនោះ ។ បទទី ២ (**សល្លីយនា** = ការឱនថយ) ទ្រង់ផ្ដើមដោយអំណាចនៃបទជាឧបសគ្គៈ ។

បទថា “**លីនំ** = ចិត្តរួញរា” បានដល់ រួញចូលហើយ ព្រោះមិនលាចេញទៅ ។ បទទាំង ២ ក្រៅនេះ (**លីយនា លីយិតត្តំ** = អាការៈដែលរួញរា ភាវៈដែលរួញរា) ជាបទសម្ដែងដល់អាការៈ និងភាវៈរបស់ចិត្តនោះ ។

បទថា “**ថីនំ** = ការងងុយងោកងក់” សេចក្ដីថា ដែលឈ្មោះថា ថីនៈ ដោយសេចក្ដីជាដុំ ព្រោះមិនផ្សាយទៅ ដូចដុំទឹកដោះថ្លា ។ បទថា “**ថីយនា** = អាការៈដែលងងុយងោកងក់” ជាការសម្ដែងអាការៈរបស់ចិត្ត; ភាវៈនៃអាការៈដែលចិត្តងងុយងោកងក់ហើយ ឈ្មោះថា **ថីយិតត្តំ** = ភាពងងុយងោកងក់, អធិប្បាយថា សភាពនៃចិត្តជាធម្មជាតិរឹងត្អឹង ដោយអំណាចនៃការមិនផ្សាយចេញទៅនោះឯង ។

បទថា “**កាយស្ស** = នៃកាយ” បានដល់ នាមកាយ គឺខន្ធ ៣ ។

បទថា “**អកល្យតា អកម្មញ្ញតា** = ការមិនសមប្រកបនៃនាមកាយ ភាពមិនគួរដល់ការងារនៃនាមកាយ” មានន័យដូចបានពោលទុកខាងក្រោយនោះឯង ។ ដែលឈ្មោះថា **ឱនាះហោ** (ការគ្របដណ្ដប់) ព្រោះអត្ថថា រមែងគ្របដណ្ដប់កាយដូចដុំពពកគ្របដណ្ដប់អាកាសដូច្នោះ; ការគ្របដណ្ដប់ដោយចំណែកទាំងអស់ ឈ្មោះ

ថា **បរិយោនាហោ** = ការហ៊ុំព័ទ្ធ ។ ដែលឈ្មោះថា **អន្តោសមោរោធោ** (ការបិទបាំងទុកខាងក្នុង) ព្រោះអត្ថថា រមែងបិទបាំងទុកខាងក្នុង; ឧទាហរណ៍ថា នគរដែលគេបិទបាំងហើយ ពួកមនុស្សរមែងមិនបានចេញទៅខាងក្រៅ យ៉ាងណា, ធម៌ទាំងឡាយដែលមិទ្ធៈ (ការងោកងក់) បិទទុកហើយ រមែងមិនបានដើម្បីការផ្សាយចេញទៅដូច្នោះដែរ; ព្រោះហេតុនោះ ទើបត្រាស់ថា "**អន្តោសមោរោធោ** = ការបិទបាំងទុកខាងក្នុង" ដូច្នេះ ។ ដែលឈ្មោះថា **មិទ្ធំ** (ការងងុយងោកងក់) ដោយអត្ថថា រមែងកម្ចាត់; អធិប្បាយថា រមែងបៀតបៀនដោយភាពមិនគួរដល់ការងារ ។ ដែលឈ្មោះថា **សោប្បំ** (ការស្លាបងងុយដេក) ព្រោះអត្ថថា ជាហេតុឱ្យលក់ ។ ដែលឈ្មោះថា **បចលាយិកា** (អាការៈដែលស្លាបងងុយដេក) ព្រោះអត្ថថា រមែងធ្វើឱ្យត្របកភ្នែកជាដើមទន់ចុះ ។

បទថា "**សុបនា សុបិតត្តំ** = កិរិយាស្លាបងងុយដេក" ជាបទដែលសម្តែងអាការៈ និងភាវៈរបស់ចិត្តនោះ; តែបទថា **ការស្លាបងងុយដេក** ខាងមុខរបស់បទទាំងនោះ យ៉ាងណា, ហេតុក្នុងការពោលដដែលរបស់បទនោះ ខ្ញុំបានពោលទុកហើយទាំងអស់ ។

បទថា "**ឥទំ វុច្ចតិ ថីនមិទ្ធំ នីវរណំ** = ថីនមិទ្ធៈនេះ ហៅថា ថីនមិទ្ធ-នីវរណៈ" គឺរួមថីនៈ និងមិទ្ធៈនេះចូលជាមួយគ្នាផង ហៅថា ថីនមិទ្ធនីវរណៈ ដោយអត្ថថា ឃាត់ឃាំង ។ ថីនមិទ្ធនីវរណៈណារមែងកើតក្នុងវេលាមុន ឬក្រោយការ

លក់ ដល់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយដោយច្រើន, ថីនមិទ្ធនីវរណៈនោះ អរហត្តមគ្គកាត់ផ្តាច់ហើយ; តែការឈានកន្លងចុះកាន់ភវង្គ របស់ព្រះខីណាស្រព ទាំងឡាយ រមែងមានទុព្វលភាពនៃករជកាយ (កាយកើតអំពីធូលី), កាលភវង្គ នោះមិនលាយដោយអារម្មណ៍ដទៃហើយប្រព្រឹត្តទៅ ព្រះខីណាស្រពទាំងនោះរមែង លក់នោះ ឈ្មោះថា ចិត្តលក់រមែងមានដល់ព្រះខីណាស្រពទាំងនោះ; ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “ម្នាលអគ្គិវេស្សនៈ ក៏យើងរមែងដឹងចំពោះ ខាង ចុងខែនៃរដូវក្តៅ យើងត្រឡប់អំពីបិណ្ឌបាត ក្នុងកាលខាងក្រោយភត្ត ក្រាល សង្ឃាដី ៤ ជាន់ ហើយជាអ្នកមាន**សតិសម្បជញ្ញៈ** ឈានចុះកាន់ការលក់ ដោយ ចំហៀងខាងស្តាំ”[៨១] ៕

## សម្តែងអំពីមិទ្ធៈមិនមែនអកុសល

ក៏ការដែលករជកាយនឿយហត់ (ទុព្វល) នេះ មានសភាពដូច្នេះ មិនមែន ភារៈដែលមគ្គគប្បីសម្លាប់ទេ, សភាពនៃកាយទុព្វលនេះ រមែងបានទាំងក្នុងរូបដែល មានចិត្តគ្រប់គ្រង និងក្នុងរូបដែលមិនមានចិត្តគ្រប់គ្រង; កាលនឹងបានក្នុងរូបដែល មានចិត្តគ្រប់គ្រង រមែងបានក្នុងវេលាដែលព្រះខីណាស្រពដើរផ្លូវឆ្ងាយ ឬធ្វើការ យ៉ាងណានីមួយហើយនឿយហត់ រមែងបានក្នុងកាលមានសភាពបែបនេះ; កាល

---

[៨១] ម. មូ. ។

បើបានក្នុងរូបដែលមិនមានចិត្តគ្រប់គ្រង រមែងបានក្នុងស្លឹកឈើ ផ្កាឈើទាំងឡាយ; ដ្បិតថា ស្លឹករបស់ដើមឈើប្រភេទខ្លះ រមែងលាចេញទៅដោយពន្លឺថ្ងៃ, ក្នុងវេលារាត្រីរមែងក្តោប; ផ្កាបទុមជាដើមរមែងរីកដោយពន្លឺព្រះអាទិត្យ, តែក្នុងវេលារាត្រីរមែងក្តោប; ក៏មិទ្ធៈនេះរមែងមានដល់ព្រះខីណាស្រពទាំងឡាយ ព្រោះសភាពនៃមិទ្ធៈនោះ មិនមែនជាអកុសលដូច្នេះឯង ។

ក្នុងអធិការនៃមិទ្ធៈនោះ បើមានអ្នកសង្ស័យថា “មិទ្ធៈមិនមែនអកុសលទេ; ព្រោះហេតុអ្វី ? ព្រោះមិទ្ធៈជារូប; ក៏រូបជាអព្យាកតៈ, ឯមិទ្ធៈក៏ជារូប, ដោយហេតុនោះ ក្នុងអធិការនេះ ទើបព្រះមានព្រះភាគត្រាស់ធ្វើ**កាយ**សព្ទថា ‘ការមិនសមប្រកបនៃនាមកាយ ភាពមិនគួរដល់ការងារនៃនាមកាយ” ដូច្នេះ ។

សេចក្តីនេះ គប្បីឆ្លើយថា ប្រសិនបើមិទ្ធៈនេះជារូបដោយត្រឹមតែពាក្យដែលត្រាស់ថា “**កាយស្ស** = នៃកាយ” ប៉ុណ្ណោះសោត, ធម៌ទាំងឡាយ សូម្បីមានកាយបស្សទ្ធិជាដើម ក៏គប្បីទៅជារូបទាំងអស់; សូម្បីការសោយសុខ និងការធ្វើឱ្យច្បាស់នូវបរមត្ថសច្ចៈដែលត្រាស់ទុកថា “សោយសុខដោយកាយ[៨២]; ធ្វើឱ្យច្បាស់នូវបរមត្ថសច្ចៈដោយកាយ”[៨៣] ដូច្នេះ ក៏គប្បីជារូបប៉ុណ្ណោះ; ព្រោះហេតុដូច្នោះ មិនគួរនិយាយថា មិទ្ធៈនេះជារូបទេ។

---

[៨២] ម. ម. /អំ. ចតុក្ក.។

[៨៣] អភិ. / ទី. សី.។

*សួរថា* ក៏ក្នុងអធិការនេះ នាមកាយឈ្មោះថា កាយ; កាលបើដូច្នោះ ព្រោះហេតុអ្វីទើបត្រាស់ថា "**សោប្បំ បចលាយិកា** = ការស្វាបងងុយ ការងោកងក់" ដូច្នេះទៅវិញ ?; ព្រោះថា នាមកាយ រមែងមិនស្វាបងងុយដេក, រមែងមិនងោកងក់ទេ ។

ឆ្លើយថា ព្រោះការស្វាបងងុយដេក និងការងោកងក់នោះ ជាផលរបស់មិទ្ធៈនោះ ដូចភេទជាដើមជាផលរបស់ឥត្ថិន្ទ្រិយដូច្នោះដែរ; ដូចយ៉ាងថា រូបរាងសណ្ឋានមានភេទជាដើមទាំងនេះ គឺភេទស្ត្រី និមិត្តស្ត្រី មាយាស្ត្រី កិរិយារបស់ស្ត្រី ទ្រង់ត្រាស់ទុក ព្រោះជាផលរបស់ឥន្ទ្រិយ យ៉ាងណា, ការស្វាបងងុយដេកជាដើម ក៏ត្រាស់ទុក ព្រោះជាផលសូម្បីរបស់មិទ្ធៈ ពោលគឺការឈឺនៃនាមកាយនោះដូច្នេះ ។ ព្រោះថា កាលបើមិទ្ធៈមាន ការស្វាបងងុយដេកជាដើមនោះក៏មាន ព្រោះហេតុដូច្នោះ ទើបត្រាស់មិទ្ធៈសូម្បីជាអរូប (នាម) ដោយផលូបចារន័យ (បំណងដល់ផល) ថា "ការស្វាបងងុយដេក ការងោកងក់ កិរិយាស្វាបងងុយដេក ភាពនៃការដេកលក់" ដូច្នេះ ។ ម្យ៉ាង សូម្បីដោយវចនត្ថៈ (ការសម្គាល់របស់ពាក្យ) ថា ដែលឈ្មោះថា **បចលាយិកា** (ការងោកងុយ) ព្រោះអត្ថថា រមែងធ្វើឱ្យត្របកភ្នែក ជាដើមទន់ចុះ ដូច្នោះ ក៏ឱ្យសម្រេចសេចក្ដីសម្គាល់នេះដូចគ្នា, ព្រោះហេតុដូច្នោះ មិទ្ធៈ ទើបមិនមែនជារូប ។ ម្យ៉ាងទៀត ភាវៈនៃមិទ្ធៈនោះ ជាអរូប ក៏ព្រះអង្គទ្រង់សម្ដែងដោយសេច-

ក្តីគ្របដណ្តប់ជាដើមដូច្នេះនោះឯង; ព្រោះថា រូបនឹងជាការគ្របដណ្តប់ ហ៊ុំព័ទ្ធបិទបាំងទុកខាងក្នុងនូវនាមកាយមិនបានទេ ។

បើមានសួរទៀតថា ក៏មិទ្ធៈនេះជារូបដោយហេតុ (មានការគ្របដណ្តប់ជាដើម) នេះឯង ពិតមែនឬ?; ព្រោះអរូប (នាម) រមែងគ្របដណ្តប់ ហ៊ុំព័ទ្ធ បិទបាំងទុកខាងក្នុងនូវអ្វីៗ មិនបានឡើយ ។

ខនេះឆ្លើយថា បើយ៉ាងនោះ សូម្បីការឃាំងឃាត់កុសលធម៌ ក៏មិនគប្បីមាន; ព្រោះហេតុដូច្នោះ គប្បីជ្រាបសូម្បីភាវៈនៃមិទ្ធៈនេះ ជាការគ្របដណ្តប់ជាដើម ដោយអត្ថមានការគ្របដណ្តប់ជាដើម ដូចអរូបធម៌មានកាមច្ឆន្ទៈជាដើម ដែលឈ្មោះថា **នីវរណៈ** ដោយអត្ថថា ឃាត់ឃាំងដូច្នោះ ។

ម្យ៉ាងវិញទៀត លោកសួរថា មិទ្ធៈនេះឈ្មោះថា ជាអរូប ព្រោះព្រះបាលីថា “លះនីវរណៈ ៥ ព្រោះធ្វើចិត្តឱ្យសៅហ្មង បន្ថយបញ្ញា”[៨៤] ដូច្នេះ ព្រោះថា រូបធ្វើចិត្តឱ្យសៅហ្មងមិនបានទេ, បន្ថយបញ្ញាក៏មិនបានដែរ; ព្រោះហេតុអ្វី ទើបមិនបាន...; ពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ មាន

[៨៤] ទី. សី. / សំ. ម. ។

[៨៥] អំ. ចតុក្ក. ។

[៨៦] ទី. សី. ។

សមណព្រាហ្មណ៍ពួកខ្លះ ផឹកសុរាមេរ័យ; មិនលះការផឹកសុរាមេរ័យ; ម្នាលភិក្ខុទាំងឡាយ នេះជាឧបក្កិលេស (គ្រឿងសៅហ្មង) របស់សមណព្រាហ្មណ៍ទីមួយ”[៨៥] ដូច្នេះ មានពិតមែនឬ ?

ខម្យ៉ាងទៀត ក៏បានត្រាស់ទុកថា “ម្នាលគហបតីបុត្រ ទោសក្នុងការប្រកបរឿយៗ ក្នុងឋានៈជាទីតាំងនៃការប្រកបសេចក្តីប្រមាទ គឺការផឹកសុរា និងមេរ័យដែលគប្បីឃើញក្នុងបច្ចុប្បន្នមាន ៦ យ៉ាង គឺអស់ទ្រព្យ ១, បង្កការឈ្លោះវិវាទ ១, ជាប្រភព (ហេតុ) កើតនៃរោគ ១, ធ្វើឱ្យវិនាសនូវកេរ្តិ៍ឈ្មោះ ១, ធ្វើមិនឱ្យដឹងការខ្មាស់ (បើកកេរ្តិ៍ខ្មាស់) ១, បន្ថយបញ្ញា ១ រួមជាទី ៦ [៨៦] ។ សូម្បីក្នុងព្រះបាលី រមែងជាវត្ថុដែលចូលចិត្តបានមែនពិត ព្រោះប្រចក្សច្បាស់ហើយ, ក៏ព្រោះហេតុតែទឹកស្រវឹងចូលដល់ពោះ ចិត្តរមែងសៅហ្មង, បញ្ញារមែងទុព្វល; ព្រោះហេតុដូច្នោះ សូម្បីមិទ្ធៈក៏ប្រៀបដូចទឹកស្រវឹង គប្បីធ្វើចិត្តឱ្យសៅហ្មង បន្ថយបញ្ញាពិតមែនឬ ?

ឆ្លើយថា មិនគួរឃើញយ៉ាងនោះទេ ព្រោះទ្រង់សម្តែងដល់សេចក្តីជាបច្ច័យ; ដ្បិតថា បើទឹកស្រវឹងគប្បីជាសង្កិលេស (ធ្វើចិត្តឱ្យសៅហ្មង) សោត សង្កិលេសនោះក៏គប្បីមកកាន់និទ្ទេស ក្នុងនិទ្ទេសនៃឧបក្កិលេសទាំងឡាយ មានជាអាទិ៍យ៉ាងនេះថា “ភិក្ខុនោះឯងលះនីវរណៈទាំង ៥ នេះ ធ្វើចិត្តឱ្យសៅហ្មង”[៨៧] ដូច្នេះ, ឬថា

---

[៨៧] ម. មូ. ។

“ម្នាលភិក្ខុទាំងឡាយ ឧបក្កិលេសរបស់ចិត្តទាំង ៥ នេះ យ៉ាងនេះឯង, ជាគ្រឿងធ្វើចិត្តឱ្យសៅហ្មង, ជាគ្រឿងធ្វើចិត្តឱ្យអន់ចុះ, មិនឱ្យគួរដល់ការងារ, មិនឱ្យបរិសុទ្ធផូរផង់,មិនឱ្យតាំងមាំដោយប្រពៃ, មិនឱ្យដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ ។ ធម៌ជាគ្រឿងសៅហ្មង ៥ យ៉ាង តើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទៈជាឧបក្កិលេសរបស់ចិត្ត” [៨៨], ឬថា “ម្នាលភិក្ខុទាំងឡាយ ក៏ឧបក្កិលេសរបស់ចិត្តតើដូចម្ដេច ? អភិជ្ឈាវិសមលោភៈជាឧបក្កិលេសរបស់ចិត្ត” [៨៩] ; ក៏ព្រោះកាលទឹកស្រវឹងនោះដែលបុគ្គលផឹកហើយ កិលេសទាំងឡាយរមែងធ្វើចិត្តឱ្យសៅហ្មង, ព្រោះហេតុដូច្នោះ ទឹកស្រវឹងនោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដោយសម្ដែងចង្អុលដល់បច្ច័យ ព្រោះសេចក្ដីដែលទឹកស្រវឹងទាំងនោះជាបច្ច័យដល់ឧបក្កិលេស ។ ចំណែកមិទ្ធៈជាសង្កិលេសនៃចិត្តដោយខ្លួនឯង និងបន្ថយបញ្ញា ព្រោះហេតុដូច្នោះ **មិទ្ធៈ** គឺជាអរូបប៉ុណ្ណោះ ។

នៅមានសេចក្ដីខ្លះ ដូចដែលនឹងគប្បីពោលឱ្យក្រៃលែងជាងនេះ ៖

ដោយការពោលដល់សម្បយោគ; ដ្បិតព្រះមានព្រះភាគត្រាស់ថា “ថីនមិទ្ធនីវរណៈជានីវរណៈ និងសម្បយុត្តដោយនីវរណៈ ដោយអវិជ្ជានីវរណៈ” [៩០] ,

---

[៨៨] សំ. ម.។

[៨៩] ម. មូ.។

[៩០] អភិ./៧៩ ។

ព្រោះហេតុដូច្នោះ ទើបមិទ្ធៈនេះមិនមែនជារូបទេ ព្រោះត្រាស់ដល់ការសម្បយោគ; ព្រោះរូបនឹងរាប់បញ្ចូលដោយធម៌ ដែលសម្បយុត្តដោយគ្នានឹងគ្នាមិនបានឡើយ ។

សូម្បីកាលបើដូច្នេះ អាចារ្យអ្នកពោលដល់មិទ្ធៈ ក៏នឹងគប្បីសួរថា “ពាក្យនេះ ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃធម៌ដែលរកបាន; ដូចយ៉ាងព្រះតម្រាស់ដែលត្រាស់ដោយអំណាចនៃការប្រកបសេចក្ដី តាមដែលបានយ៉ាងនេះថា ទាំងគ្រុំ និងខ្យងហោង ទាំងដុំក្រួស និងក្បឿង ទាំងហ្វូងត្រីត្រាច់ទៅខ្លះ តាំងនៅខ្លះ’ [៩១] , សេចក្ដីពិត ដុំក្រួស និងក្បឿងតាំងនៅតែម្យ៉ាង មិនត្រាច់ទៅទេ, ពីរយ៉ាងទៀតក្រៅនេះ រមែងត្រាច់ទៅខ្លះ រមែងតាំងនៅខ្លះ សេចក្ដីនេះយ៉ាងណា; សូម្បីក្នុងនីវរណធម៌ ក៏យ៉ាងនោះដែរ មិទ្ធៈជានីវរណៈម្យ៉ាង, មិនសម្បយុត្តដោយកុសលទេ; ថីនៈជានីវរណៈផង ជាធម៌សម្បយុត្តផង ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថីនមិទ្ធៈទាំងអស់រួមគ្នា ដោយអំណាចនៃធម៌ដែលបានថា ‘ជានីវរណៈ និងសម្បយុត្តដោយនីវរណៈ’ ; តែមិទ្ធៈជានីវរណៈតែម្យ៉ាង មិនសម្បយុត្តនឹងកុសល ដូចដុំក្រួស និងក្បឿងតាំងនៅតែម្យ៉ាង មិនត្រាច់ទៅដូច្នោះទេ; ព្រោះហេតុនោះ ទើបមិទ្ធៈជារូបប៉ុណ្ណោះ” ។

---

[៩១] ទី. សី. / ម. មូ. ។

ឆ្លើយថា លោកមិនគួរឃើញដូច្នេះ ព្រោះមិទ្ធៈមិនសម្រេចភាពជារូបបានឡើយ; ពាក្យថា ដុំក្រួស និងគ្រឿងរមែងមិនត្រាច់ទៅដូច្នេះ សូម្បីវៀរចាកព្រះសូត្រ ក៏ចូលចិត្តបាន; ព្រោះហេតុដូច្នេះ សេចក្ដីដែលអាចរកបាន ក្នុងព្រះសូត្រនេះចូរលើកទុកសិនចុះ, តែពាក្យដែលពោលថា មិទ្ធៈនោះជារូបបានដោយសូត្រនេះនេះមិនគួរចូលចិត្តបានឡើយ; នរណាៗ មិនអាចដើម្បីឱ្យមិទ្ធៈជារូបនោះ ដោយសូត្រនេះទេ ព្រោះហេតុនោះ មិទ្ធៈនេះ មិនបានត្រាស់ដោយអំណាចនៃសេចក្ដីតាមដែលបាន ព្រោះមិទ្ធៈមិនសម្រេចភាពជារូប ព្រោះហេតុនោះ ទើបមិទ្ធៈជាអរូបប៉ុណ្ណោះ ។

ពាក្យដែលគួរនឹងពោលឱ្យក្រៃលែងឡើងទៅ ជាងពាក្យដែលពោលហើយ ក៏ព្រោះព្រះបាលីថា "**ចត្តត្តា** = ព្រោះលះហើយ" ជាដើម; ពិតមែនហើយ ក្នុង**វិភង្គបករណ៍** ព្រះមានព្រះភាគត្រាស់ពាក្យមានជាអាទិ៍ថា "**ព្រោះលះហើយ** យ៉ាងនេះថា ភិក្ខុឈ្មោះថា មានថីនមិទ្ធៈទៅប្រាសហើយ" ដូច្នេះ ព្រោះលះហើយ ព្រោះខ្ជាក់ហើយ ព្រោះបញ្ជូនហើយ ព្រោះលះចោលហើយ ព្រោះលះបង់ហើយ នូវថីនមិទ្ធៈនោះ; ដោយហេតុនោះ ទើបត្រាស់ថា "អ្នកមានថីនមិទ្ធៈទៅប្រាសហើយ" [៩២] និងថា "ភិក្ខុធ្វើចិត្តឱ្យម៉ដ្ឋចត់ ឱ្យម៉ដ្ឋចត់វិសេស ឱ្យបរិសុទ្ធ ឱ្យរបេះផុត ឱ្យផុតវិសេស ឱ្យដោះចេញអំពីថីនមិទ្ធៈនេះ" ; ដោយហេតុនោះ ទើប

---

[៩២] អភិ. ។

ត្រាស់ហៅថា "ធ្វើចិត្តឱ្យបរិសុទ្ធអំពីថីនមិទ្ធៈ" [៩៣], ចំណែករូបព្រះអង្គមិនបាន ត្រាស់យ៉ាងនេះទេ; ព្រោះហេតុនោះឯង ទើបមិទ្ធៈជាអរូបប៉ុណ្ណោះ ។

អាចារ្យអ្នកពោលមិទ្ធៈរំពឹកញែកថា "លោកមិនគួរពោលដោយសភាពនៃ ថីនមិទ្ធៈមិនកើតអំពីចិត្តទេ; ពិតមែន មិទ្ធៈមាន ៣ យ៉ាង គឺកើតអំពីចិត្ត ១, កើត អំពីឧតុ ១ និងកើតអំពីអាហារ ១ ។ បណ្ដាមិទ្ធៈទាំង ៣ នោះ មិទ្ធៈណាកើតអំពី ចិត្តក្នុងវិភង្គនៃមិទ្ធៈនោះ ទើបព្រះមានព្រះភាគត្រាស់ថា ការមិនមានពីឈានចិត្ត ទាំងឡាយ; ព្រោះហេតុដូច្នោះ ទើបមិទ្ធៈមិនសម្រេចជាអរូប ដោយហេតុនោះ ទើបមិទ្ធៈជារូបប៉ុណ្ណោះ" ។

ឆ្លើយថា សេចក្ដីនេះមិនគួរយល់ឃើញមិទ្ធៈជារូបបានឡើយ; ដ្បិតពេលដែល មិទ្ធៈសម្រេចទៅជារូប នរណាៗ ក៏អាចបានពាក្យនិយាយនោះថា ការមិនកើតនៃមិទ្ធៈ ដែលកើតអំពីចិត្ត ទើបព្រះមានព្រះភាគត្រាស់ទុកហើយក្នុងវិភង្គនោះ និងភាពដែល មានមិទ្ធៈជារូបនោះមួយ រមែងមិនគួរឡើយ; ព្រោះហេតុដូច្នោះ ទើបមិទ្ធៈជា អរូបប៉ុណ្ណោះ ។

ពាក្យដែលគប្បីពោលឱ្យក្រៃលែងទៅ ដោយពោលដល់ការលះ (ប្រហារ) រមែងមាន, ដ្បិតថា ព្រះមានព្រះភាគត្រាស់ការលះសូម្បីមិទ្ធៈទុកក្នុងព្រះបាលី ទាំងឡាយមានជាអាទិ៍ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះធម៌ ៦ ប្រការបានហើយ

---

[៩៣] អភិ. ។

ក៏អាចចូលបឋមជ្ឈានបាន; ធម៌ ៦ ប្រការនោះ តើដូចម្តេចខ្លះ ? គឺកាមច្ឆន្ទៈ ១, ព្យាបាទៈ ១, ថីនមិទ្ធៈ ១, ឧទ្ធច្ចៈ ១, កុក្កុច្ចៈ ១ និងវិចិកិច្ឆា ១; ក៏ទោសក្នុងកាមទាំងឡាយនោះឯង ឈ្មោះថា បុគ្គលនោះឃើញល្អហើយដោយសម្មប្បញ្ញៈ” និងថា “ភិក្ខុលះនីវរណៈទាំង ៥ នេះហើយនឹងដឹងប្រយោជន៍ខ្លួនខ្លះ ប្រយោជន៍អ្នកដទៃខ្លះ ដោយបញ្ញាដ៏មានកម្លាំង” , ចំណែករូបបុគ្គលមិនគប្បីលះទេ; ដូចយ៉ាងដែលត្រាស់ទុកថា “រូបក្ខន្ធដែលបុគ្គលគប្បីដឹងក្រៃលែង គប្បីកំណត់ដឹង មិនគប្បីលះ មិនគប្បីចម្រើន មិនគប្បីធ្វើឱ្យជាក់ច្បាស់ឡើយ” ; ទើបមិទ្ធៈជាអរូបប៉ុណ្ណោះ ព្រោះពោលដល់ការលះមិទ្ធៈនេះឯង ។

អាចារ្យអ្នកពោលមិទ្ធៈជំទាស់ថា លោកមិនគួរពោលយ៉ាងនេះទេ ព្រោះព្រះតម្រាស់ព្រះអង្គត្រាស់ការលះនូវរូបក៏មាន; ព្រោះថា ព្រះមានព្រះភាគត្រាស់ការលះនូវរូបនោះឯង ក្នុងព្រះបាលីនេះថា “ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់ពួកអ្នកទេ, ពួកអ្នកចូរលះនូវរូបនោះចេញ” [៩៤] ព្រោះហេតុដូច្នោះ ពាក្យថា **មិទ្ធៈជាអរូប**នេះ មិនត្រឹមត្រូវឡើយ ។

អាចារ្យអ្នកចង្អុលបង្ហាញពោលថា លោកមិនគួរឃើញយ៉ាងនោះទេ ព្រោះព្រះតម្រាស់នោះជាប្រការដទៃ; ដ្បិតក្នុងព្រះសូត្រនោះ ព្រះមានព្រះភាគត្រាស់

---

[៩៤] អំ. ឆក្ក.។

ការលះរូបដោយអំណាចនៃការលះតម្រេក ដោយអំណាចនៃសេចក្តីពេញចិត្តយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ ការកម្ចាត់ឆន្ទរាគៈ (តម្រេកដោយអំណាចនៃសេចក្តីពេញចិត្ត) ក្នុងរូបណា ការកម្ចាត់នោះ ជាការលះក្នុងរូបនោះ"[៩៥] ដូច្នេះទើបមិទ្ធៈមិនមែនជារូប, ព្រោះត្រាស់ទុកដោយប្រការដទៃថា "ពាក្យថា រូប ត្រាស់ថាជាធម៌គួរលះ ដូចការលះធម៌ ៦ យ៉ាង លះនីវរណៈ ៥ យ៉ាងមិនបាន" ; ព្រោះហេតុដូច្នោះ ព្រះសូត្រណាដែលត្រាស់ទុកមានជាអាទិ៍ថា "ភិក្ខុលះនីវរណៈទាំង ៥ នេះ ដែលធ្វើចិត្តឱ្យសៅហ្មង"[៩៦] ដូច្នេះ បណ្ឌិតគប្បីជ្រាបថា មិទ្ធៈជាអរូបប៉ុណ្ណោះ ដោយព្រះសូត្រទាំងនេះផង ដោយព្រះសូត្រដទៃផង ។

ពិតយ៉ាងនោះមែន ព្រះមានព្រះភាគត្រាស់ព្រះសូត្រមិនមែនតិចទេ ដែលបំភ្លឺសេចក្តីនៃមិទ្ធៈនោះជាអរូបប៉ុណ្ណោះ មានជាអាទិ៍យ៉ាងនេះថា **"ម្នាលភិក្ខុទាំង-ឡាយ នីវរណៈជាគ្រឿងឃាំងឃាត់ គ្របសង្កត់ចិត្ត បន្ថយបញ្ញាទាំង ៥ ប្រការនេះ; ៥ ប្រការ តើដូចម្តេច ?** ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទៈ ។ល ។

---

[៩៥] ម. មូ.។

[៩៦] សំ. ម.។

ថីនមិទ្ធៈជានីវរណៈ គ្រឿងជំពាក់ ឃាត់ឃាំង គ្របដណ្តប់ចិត្ត បន្ថយបញ្ញា" [១១៥] និងថា "ម្នាលភិក្ខុទាំងឡាយ ថីនមិទ្ធៈ ជានីវរណៈធ្វើឱ្យងងឹត មិនធ្វើចក្ខុ មិនធ្វើញាណ រំលត់បញ្ញា ជាអ្នកពិឃាត មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន" [១១៦] និងថា "ម្នាលព្រាហ្មណ៍ សេចក្តីនេះ ក៏យ៉ាងនោះដែរ សម័យណាបុគ្គលត្រូវថីនមិទ្ធៈគ្របសង្កត់ចិត្ត ត្រូវថីនមិទ្ធៈរួបរឹតចិត្តហើយ" [១១៧], និងថា "ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុ មនសិការដោយឧបាយមិនត្រូវទំនង កាមច្ឆន្ទៈដែលនៅមិនកើតឡើង រមែងកើតឡើង ។ល។ ថីនមិទ្ធៈដែលនៅមិនកើតឡើង រមែងកើតឡើង" [១១៨] និងថា "ម្នាលភិក្ខុទាំងឡាយ កងនៃអកុសលសុទ្ធៗ នេះ គឺជានីវរណៈ ៥ [១១៩], ក៏ព្រោះមិទ្ធៈនេះ ជាអរូប ព្រោះហេតុដូច្នោះ ទើបកើតឡើងសូម្បីក្នុងអរូបធម៌ ។ ដ្បិតពាក្យនេះ ត្រាស់ទុកក្នុង**បដ្ឋានមហាបករណ៍**ថា "ធម៌ គឺនីវរណៈ អាស្រ័យធម៌ គឺនីវរណៈហើយ ទើបកើតឡើង មិនមែនអាស្រ័យបុរេជាតប្បច្ច័យហើយទើបកើត

---

[១១៥] សំ. មូ.។

[១១៦] ម. មូ.។

[១១៧] អភិ.។

[១១៨] អភិ.។

[១១៩] អភិ.។

ឡើងទេ” [១២០] , ពុទ្ធវចនៈទាំងអស់ ក្នុងវិភង្គនៃព្រះតម្រាស់នេះថា “អាស្រ័យកាមច្ឆន្ទនីវរណៈ ក្នុងសេចក្តីជាអរូប រមែងកើតថីនមិទ្ធៈ ឧទ្ធច្ចៈ និងអវិជ្ជា-នីវរណៈ” [១២១] ដូច្នេះ ឱ្យពិស្តារ, ព្រោះហេតុដូច្នោះ ក្នុងអធិការនេះ គប្បីមានសេចក្តីចូលចិត្តថា “មិទ្ធៈជាអរូបប៉ុណ្ណោះ” ។៚

## សម្តែងអំពីកុក្កុច្ចនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **កុក្កុច្ចៈ** ដូចតទៅ ៖

បទថា “**អកប្បិយេ កប្បិយសញ្ញិតា** = សេចក្តីសម្គាល់ថាគួរ ក្នុងរបស់មិនគួរ” ជាដើម ត្រាស់ទុកដើម្បីសម្តែងកុក្កុច្ចៈដោយមូល; ដ្បិតថា ក្នុងការឈានកន្លងដែលធ្វើហើយ ដោយមានសេចក្តីសម្គាល់យ៉ាងនេះ កាលភិក្ខុមានសតិរឭក និងដឹងច្បាស់ដល់វត្ថុ និងអជ្ឈាចារដែលសម្រេចហើយទៀត ក៏នៅក្តៅក្រហាយរឿយៗយ៉ាងនេះថា “យើងធ្វើកម្មអាក្រក់ហើយ” ដូច្នេះ ទើបកុក្កុច្ចៈនេះកើតឡើងដោយអំណាចនៃការតាមក្តៅក្រហាយខាងក្រោយទៀត, ដោយហេតុនោះ ដើម្បីទ្រង់

---

[១២០] អភិ.។

[១២១] អភិ.។

សម្តែងកុក្កុច្ចៈនោះដោយមូល ទើបត្រាស់ពាក្យមានជាអាទិ៍ថា “អកប្បិយេ កប្បិយសញ្ញិតា” ។

ក្នុងព្រះពុទ្ធវចនៈនោះ អធិប្បាយថា ភិក្ខុមានសេចក្តីសម្គាល់ថា គួរ ទើបឆាន់អាហារដែលមិនគួរ, មានសេចក្តីសម្គាល់ថា សាច់គួរ ទើបឆាន់សាច់ដែលមិនគួរ គឺរមែងឆាន់សាច់ខ្លាឃ្មុំ ដោយសម្គាល់ថា “ជាសាច់ជ្រូក” ឬរមែងឆាន់សាច់ខ្លាដំបង ដោយសម្គាល់ថា “ជាសាច់ប្រើស” កាលបើពេលកន្លងទៅហើយ សម្គាល់ថា មិនទាន់កន្លង, ហាមភត្តហើយសម្គាល់ថា មិនបានហាមភត្ត កាលធូលីដែលនៅមិនបានទទួលប្រគេនក៏ធ្លាក់ចូលទៅក្នុងបាត្រ រមែងឆាន់ដោយសម្គាល់ថា ទទួលប្រគេនហើយ យ៉ាងនេះ ឈ្មោះថា ធ្វើការកន្លង ដោយសេចក្តីសម្គាល់ថា “គួរក្នុងរបស់ដែលមិនគួរ” ។ ភិក្ខុកាលឆាន់សាច់ជ្រូកដោយសម្គាល់ថា ជាសាច់ខ្លាឃ្មុំ និងឆាន់អាហារក្នុងពេល ដោយសម្គាល់ថា ក្រៅពេល ឈ្មោះថា ធ្វើការកន្លង ដោយសេចក្តីសម្គាល់ក្នុងរបស់ដែលគួរ ថាមិនគួរ ។

ម្យ៉ាងទៀត វត្ថុខ្លះមិនមានទោស ភិក្ខុធ្វើសេចក្តីសម្គាល់ថា មានទោស និងដែលមានទោស ធ្វើសេចក្តីសម្គាល់ថា មិនមានទោស ឈ្មោះថា ធ្វើការកន្លងដោយសេចក្តីសម្គាល់ក្នុងវត្ថុដែលមិនមានទោសថា មានទោស ដោយសេចក្តីសម្គាល់ក្នុងវត្ថុដែលមានទោសថា មិនមានទោស ។ ក៏ព្រោះកុក្កុច្ចៈនេះរមែងកើតឡើង ព្រោះការកន្លងដែលធ្វើហើយ ដោយសេចក្តីសម្គាល់ថា មានទោសក្នុងរបស់ដែលមិនមាន

ទោសយ៉ាងនេះថា "កម្មដែលល្អយើងនៅមិនទាន់បានធ្វើហ្ន៎, កុសលយើងមិនបានធ្វើ, គ្រឿងការពាររបស់មនុស្សភ័យនៅមិនទាន់បានធ្វើហ្ន៎, បាបយើងធ្វើហើយហ្ន៎, សេចក្ដីគ្រោតគ្រាតអាក្រក់យើងធ្វើហើយ, សេចក្ដីកាចសាហាវយើងធ្វើហើយ" ; ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគកាលនឹងទ្រង់អនុញ្ញាតវត្ថុសូម្បីដទៃ ដល់ភិក្ខុអ្នកមានកុក្កុច្ចៈនោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា "សម្គាល់ ។ល។ ដែលមានលក្ខណៈបែបនេះឯង"។ ក្នុងអធិការនេះ បទថា "**កុក្កុច្ចៈ**" មានអត្ថងាយមែនពិត។ អាការៈនៃហេតុក្ដៅក្រហាយ ឈ្មោះថា **កុក្កុច្ចាយនា** = កិរិយាក្ដៅក្រហាយ; ភាវៈនៃធម៌ដែលកុក្កុច្ចៈឱ្យប្រព្រឹត្តទៅហើយ ឈ្មោះថា **កុក្កុច្ចាយិតត្តំ** = ភាពក្ដៅក្រហាយ ។

ក្នុងពាក្យថា "**ចេតសោ វិប្បដិសារោ** = សេចក្ដីក្ដៅក្រហាយចិត្ត" នេះ សេចក្ដីថា ការបញ្ចេញមុខចំពោះកម្មដែលធ្វើហើយ និងនៅមិនទាន់ធ្វើ ឬចេញមុខចំពោះវត្ថុដែលមានទោស និងមិនមានទោស ឈ្មោះថា **វិប្បដិសារៈ** = សេចក្ដីក្ដៅក្រហាយ; ក៏ព្រោះវិប្បដិសារៈនោះ រមែងធ្វើបាបដែលធ្វើហើយឱ្យជាកម្មដែលនៅមិនទាន់បានធ្វើ, ឬរមែងមិនធ្វើសេចក្ដីល្អដែលនៅមិនទាន់បានធ្វើ ឱ្យជាការដែលខ្លួនធ្វើហើយ, ព្រោះហេតុដូច្នោះ ការរឭកត្រឡប់សារឡើងវិញទៅខុសចាករូប ឬជាវត្ថុដែលគួររង្កៀស ព្រោះហេតុនោះ ទើបឈ្មោះថា **វិប្បដិសារៈ** ។ មួយទៀត ដើម្បីឱ្យដឹងថា វិប្បដិសារៈនោះជារបស់ចិត្ត មិនមែនសត្វ ទើបត្រាស់ថា "**ចេតសោ វិប្បដិសារោ** = សេចក្ដីក្ដៅក្រហាយរបស់ចិត្ត" ។ សេចក្ដីនេះ ជាការអធិ-

ប្បាយសភាវៈរបស់កុក្កុច្ចៈនោះ ។ ក៏កុក្កុច្ចៈកាលកើតឡើង រមែងកើតឡើងដើម្បីឱ្យចិត្តដំអក់នៅ ដូចចុងដែកស្រួចគូសលើភាជនៈសំរឹទ្ធិនោះឯង, ព្រោះហេតុដូច្នោះទើបត្រាស់ថា **"មនោវិលេខោ** = ការគូសចំណាំចិត្ត" សេចក្ដីនេះ ជាការអធិប្បាយកិច្ច (នាទី) របស់កុក្កុច្ចៈនោះ ។ ចំណែកកុក្កុច្ចៈ (សេចក្ដីរង្កៀស) ណាដែលត្រាស់ទុកក្នុងព្រះវិន័យថា **"គ្រានោះឯង ព្រះសារីបុត្ររង្កៀសថា ការនៅឆាន់អាហារក្នុងរោងឆាន់ជាប្រចាំ ព្រះមានព្រះភាគទ្រង់ហាមឃាត់ទុក ព្រោះហេតុដូច្នោះ ទើបមិនព្រមទទួល"**[១២២] កុក្កុច្ចៈ (ការរង្កៀស) នោះ មិនជានីវរណៈឡើយ ។ ព្រោះព្រះអរហន្តមិនមានសេចក្ដីក្ដៅក្រហាយខាងក្រោយថា "វត្ថុនោះយើងធ្វើខុសហើយ" ដូច្នេះទេ; ក៏ឈ្មោះថា កុក្កុច្ចៈក្នុងព្រះវិន័យ ពោលគឺការពិចារណានេះថា "វត្ថុនេះគួរ វត្ថុនេះមិនគួរ" ដូច្នេះ ជានីវរណបដិរូបកៈ = ស្រដៀងនឹងនីវរណៈដែរ ៕ ៕

## សម្ដែងអំពីធម៌ជានីវរណៈ និង សម្បយុត្តធម៌

ក្នុងនិទ្ទេសនៃបទថា **"កតមេ ធម្មា នីវរណា ចេវ នីវរណសម្បយុត្តា ច** = ធម៌ជានីវរណៈ និងសម្បយុត្តដោយនីវរណៈ តើដូចម្ដេច ?" ព្រះមានព្រះភាគមិនបានត្រាស់វែកញែកថា **"ថីនមិទ្ធៈជានីវរណៈ និង សម្បយុត្តដោយ**

---

[១២២] វិនយ.។

**នីវរណៈ ដោយអវិជ្ជានីវរណៈ** ថីនមិទ្ធៈមិនបានវៀរនូវគ្នានឹងគ្នាទេ” ។ តែព្រោះកាលឧទ្ធច្ចៈនៅមាន កុក្កុច្ចៈក៏មិនមាន, សូម្បីឧទ្ធច្ចៈវៀរចាកកុក្កុច្ចៈ ក៏កើតបាន, ព្រោះហេតុដូច្នោះ ទើបត្រាស់វែកញែកឧទ្ធច្ចៈនោះ ។

មួយទៀត ក៏នីវរណៈណា មិនដល់ការប្រកបចូលនឹងនីវរណៈណា, គប្បីជ្រាបថា នីវរណៈនោះព្រះអង្គទ្រង់មិនបានប្រកបទុក; ក៏នីវរណៈទាំងនេះ គួរដើម្បីនាំមកពោលតាមលំដាប់នៃកិលេសខ្លះ, តាមលំដាប់នៃមគ្គខ្លះ; **ពោលដោយលំដាប់នៃកិលេស** អនាគាមិមគ្គរមែងលះនូវកាមច្ឆន្ទនីវរណៈ និងព្យាបាទនីវរណៈ;អរហត្តមគ្គរមែងលះនូវថីនមិទ្ធនីវរណៈ និងឧទ្ធច្ចនីវរណៈ; សោតាបត្តិមគ្គរមែងលះនូវកុក្កុច្ចនីវរណៈ និងវិចិកិច្ឆានីវរណៈ, អរហត្តមគ្គរមែងលះនូវអវិជ្ជានីវរណៈ; **ពោលដោយលំដាប់នៃមគ្គ** កុក្កុច្ចៈ និងវិចិកិច្ឆា រមែងលះបានដោយសោតាបត្តិមគ្គ, កាមច្ឆន្ទៈ និងព្យាបាទៈរមែងលះបានដោយអនាគាមិមគ្គ, ថីនមិទ្ធៈ ឧទ្ធច្ចៈ និងអវិជ្ជារមែងលះបានដោយអរហត្តមគ្គ ។

**ក្នុងបរាមាសគោច្ឆកៈ** បទថា “*តេ ធម្មេ ឋបេត្វា* = វៀរបរាមាសធម៌ទាំងនោះចេញ” គឺព្រះអង្គធ្វើឱ្យជាពហុវចនៈ ដោយស្មើនឹងពាក្យសួរ ៕

## សម្តែងអំពីឧបាទានគោច្ឆកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ឧបាទាន** ដូច្នេះ ៖

ដែលឈ្មោះថា **កាមុបាទាន** ព្រោះអត្ថថា រមែងប្រកាន់ទុកនូវកាម ពោល គឺវត្ថុ, កាមនោះផង ឧបាទាននោះផង ព្រោះហេតុដូច្នោះឯង ទើបឈ្មោះថា **កាមុ-បាទាន** ។ បទថា **"ឧបាទានំ** = ឧបាទាន" ប្រែថា សេចក្តីប្រកាន់មាំ, ព្រោះ **ឧបសព្ទ** ក្នុងពាក្យនេះមានអត្ថថា **មាំ** ដូចក្នុងពាក្យទាំងឡាយមាន **ឧបាយាសៈ** = ការចង្អៀតចង្អល់, **ឧបកដ្ឋៈ** = ជិតដល់ហើយ [*] ជាដើម ។

**ទិដ្ឋុបាទាន** ឬដែលឈ្មោះថា **ទិដ្ឋុបាទាន** ព្រោះអត្ថថា រមែងប្រកាន់មាំនូវទិដ្ឋិ ។ ព្រោះទិដ្ឋិក្រោយ រមែងប្រកាន់ទិដ្ឋិមុន ដូចក្នុងប្រយោគមានជាដើមថា **"សស្សតោ អត្តា ច លោកោ ច** = អត្តា និងលោកទៀង" [១២៣] ។ មួយទៀត ដែលឈ្មោះថា **"សីលព្វតុបាទាន** ព្រោះអត្ថថា រមែងប្រកាន់មាំនូវសីលវ័ត។ សីល-វ័តផង ឧបាទាននោះផង ព្រោះហេតុដូច្នោះឯង ទើបឈ្មោះថា **សីលព្វតុបាទាន** ។ ពិតមែន ពាក្យថា **គោសីល** និង **គោវត្ត** ជាដើម ជាឧបាទានខ្លួនឯងមែនពិត ព្រោះប្រកាន់មាំថា "សេចក្តីបរិសុទ្ធរមែងមានដោយសីលវ័តយ៉ាងនេះ" ។ មួយទៀត ឈ្មោះថា **វាទៈ** ព្រោះអត្ថថា ជាហេតុពោល ។ ដែលឈ្មោះថា **ឧបាទាន** ព្រោះអត្ថថា ជាហេតុប្រកាន់មាំ, រមែងពោល ឬប្រកាន់អ្វី ? រមែងពោល ឬ

---

[*] ឧបាយាសៈ <ឧប + អាយាសៈ (ឧប = មាំ, អាយាសៈ = លំបាក); ឧបកដ្ឋៈ <ឧប + កដ្ឋៈ (ឧប = ដល់ហើយ, កដ្ឋៈ = ជិត) ។

[១២៣] ទី. សី. ១៤ ។

ប្រកាន់នូវខ្លួន; ការពោល និងការប្រកាន់មាំនូវអត្តារបស់ខ្លួន ឈ្មោះថា **អត្តវាទុ-បាទាន** ។ម្យ៉ាងទៀត ហេតុត្រឹមតែវាទៈថា ជាអត្តាតែម្យ៉ាង ឈ្មោះថា **អត្តវាទុ-បាទាន** ព្រោះអត្ថថា ជាហេតុប្រកាន់មាំនូវខ្លួន ៕៚

## សម្ដែងអំពីកាមុបាទាននិទ្ទេស

សូម្បីក្នុងពាក្យថា "**យោ កាមេសុ កាមច្ឆន្ទោ** = សេចក្ដីពេញចិត្ត គឺសេចក្ដីប្រាថ្នាក្នុងកាមទាំងឡាយចំណែកណា" នេះ វត្ថុកាម និងកិលេសកាមទាំង-ឡាយ ទ្រង់មានបំណងយកកាមទាំងឡាយដោយមិនសល់ឡើយ; ព្រោះហេតុដូច្នោះ ការពេញចិត្ត គឺសេចក្ដីប្រាថ្នាក្នុងវត្ថុកាម ឈ្មោះថា **កាមុបាទាន** ក្នុងអធិការនេះ; ព្រោះហេតុដូច្នោះ កាមុបាទាននោះ ទើបសម្រេច (ដល់បុថុជ្ជនជាដើម) សូម្បីដល់ព្រះអនាគាមី; តែកាមរាគៈដែលជាវត្ថុរបស់កាមគុណ ៥ រមែងមិនមានដល់ព្រះអនាគាមីនោះឡើយ ៕ ៕

## សម្ដែងអំពីទិដ្ឋុបាទាននិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ទិដ្ឋុបាទាន** ដូចតទៅ ៖

បទថា "**នត្ថិ ទិន្នំ** = ទានដែលឱ្យហើយមិនមានផល" សេចក្ដីថា គេរមែងដឹងថា "ឈ្មោះថា ទានដែលបុគ្គលឱ្យហើយនឹងមាន, គឺនរណា១ អាចដើម្បីឱ្យនូវ

អ្វីៗ ដល់នរណាៗ ក៏បាន”, តែរមែងប្រកាន់ថា “ផលវិបាករបស់ទានមិនមានទេ”។

បទថា “**នត្ថិ យិដ្ឋំ** = ការបូជាមិនមានផល” សេចក្តីថា ការបូជាធំ (**មហាយោគោ**) ត្រាស់ហៅថា **យិដ្ឋំ** (ការបូជា), គឺរមែងដឹងថា “ការបូជានោះ នរណាៗ អាចបូជាបាន”, តែរមែងប្រកាន់ថា “ផលវិបាករបស់ការបូជាមិនមានទេ” ។ បទថា “**នត្ថិ ហុតំ** = ការបួងសួងមិនមាន” សេចក្តីថា កិរិយាបូជានឹងនាំរបស់មកឱ្យដើម្បីមង្គល, បុគ្គលរមែងដឹងកិរិយាទាំងនោះថា “នរណាៗ ក៏អាចធ្វើបានដែរ”, តែគេរមែងប្រកាន់ថា ផលវិបាករបស់កិរិយាមង្គល (បូជា) នោះ មិនមានផលឡើយ ។

ក្នុងបទថា “**នត្ថិ សុកដទុក្កដានំ** = ផលវិបាករបស់កម្មល្អ កម្មអាក្រក់ដែលបុគ្គលធ្វើហើយមិនមាន” នេះ កុសលកម្មបថ ១០ ឈ្មោះថា កម្មដែលបុគ្គលធ្វើល្អហើយ, អកុសលកម្មបថ ១០ ឈ្មោះថា កម្មដែលបុគ្គលធ្វើអាក្រក់ហើយ ។ បុគ្គលរមែងដឹងដល់សេចក្តីដែលកម្មល្អ កម្មអាក្រក់នោះនឹងមាន, តែរមែងប្រកាន់ថា “ផលវិបាកមិនមាន” ។

បទថា “**នត្ថិ អយំ លោកោ** = លោកនេះមិនមាន” សេចក្តីថា បុគ្គលរមែងប្រកាន់លោកដោយគិតថា “បុគ្គលអ្នកតាំងនៅក្នុងលោកដទៃ របស់បុគ្គលអ្នកធ្វើកម្មល្អ កម្មអាក្រក់នោះមិនមាន” ។ បទថា “**នត្ថិ បរលោកោ** = លោក

ដទៃមិនមាន" បានដល់ បុគ្គលរមែងប្រកាន់ថា "បុគ្គលមាននៅក្នុងលោកនេះ, តែមិនមានក្នុងលោកដទៃឡើយ" ។

បទថា "**នត្ថិ មាតា នត្ថិ បិតា** = មាតាមិនមាន បិតាមិនមាន" សេចក្ដីថា គេរមែងដឹងនូវភាវៈនៃមាតាបិតាមាន, តែគេប្រកាន់ថា "ផលវិបាកអ្វីៗ ដោយការធ្វើឧបការៈក្នុងមាតាបិតានោះមិនមានឡើយ" ។

បទថា "**នត្ថិ សត្តា ឱបបាតិកា** = ឱបបាតិកសត្វមិនមាន" គឺគេប្រកាន់ថា "សត្វដែលចុតិ និងបដិសន្ធិមិនមាន" ។

បទថា "**សម្មគ្គតា សម្មាបដិបន្នា** = អ្នកបដិបត្តិល្អ អ្នកបដិបត្តិប្រពៃ" សេចក្ដីថា គេរមែងប្រកាន់ថា "សមណៈ និងព្រាហ្មណ៍អ្នកតាំងនៅក្នុងធម៌ អ្នកដើរទៅកាន់អនុលោមប្បដិបទាមិនមានក្នុងលោកទេ" ។

បទថា "**យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ** = សមណព្រាហ្មណ៍ដែលធ្វើឱ្យច្បាស់នូវលោកនេះ និងលោកដទៃដោយបញ្ញាដ៏ក្រៃលែងដោយខ្លួនឯង ហើយប្រកាសឱ្យអ្នកដទៃដឹងបាន មិនមានក្នុងលោក" សេចក្ដីថា រមែងប្រកាន់ថា "ឈ្មោះថា សព្វញ្ញុពុទ្ធអ្នកអាចដឹងលោកនេះ និងលោកដទៃដោយបញ្ញាដែលវិសេសក្រៃលែងដោយខ្លួនឯងប៉ុណ្ណោះមិនមាន" ។ ក៏ឧបាទាននេះ គួរដើម្បីនាំមកដោយលំដាប់នៃកិលេសខ្លះ ដោយលំដាប់នៃមគ្គខ្លះ ។

**ពោលដោយលំដាប់នៃកិលេស** មគ្គទាំង ៤ រមែងប្រហារនូវកាមុបាទាន,

សោតាបត្តិមគ្គរមែងប្រហារនូវឧបាទាន ៣ ដ៏សេស ។ **ពោលដោយលំដាប់នៃមគ្គ** សោតាបត្តិមគ្គរមែងប្រហារនូវទិដ្ឋុបាទានជាដើម, មគ្គទាំង ៤ រមែងប្រហារនូវកាមុបាទាន ៗ ។

## សម្តែងអំពីកិលេសគោច្ឆកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង **កិលេសគោច្ឆកៈ** ដូចតទៅ ៖

កិលេសប៉ុណ្ណោះ ឈ្មោះថា **កិលេសវត្ថុ**; ម្យ៉ាងទៀត ដែលឈ្មោះថា **វត្ថុ** ព្រោះអត្ថថា ជាទីនៅរបស់សត្វអ្នកមានអាសវៈដែលមិនទាន់អស់ ព្រោះភាវៈនៃសត្វពួកនោះ តាំងនៅក្នុងកិលេសមានលោភៈជាដើម; ដែលឈ្មោះថា **កិលេសវត្ថុ** ព្រោះអត្ថថា កិលេសពួកនោះផង ជាវត្ថុរបស់សត្វអ្នកតាំងនៅក្នុងកិលេសពួកនោះផង ។ ក៏ព្រោះសូម្បីកិលេសទាំងឡាយ កាលកើតឡើងដោយសេចក្តីជាអនន្តរ-ប្បច្ច័យជាដើម ឈ្មោះថា រមែងនៅក្នុងកិលេសដែលជាបច្ច័យនេះ, ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **កិលេសវត្ថុ** សូម្បីដោយអត្ថថា ជាវត្ថុ (ទីនៅ) របស់កិលេសទាំងឡាយ ។

ក៏លោភៈនេះថា "**តត្ថ កតមោ លោភោ, យោ រាគោ សារាគោ** = បណ្តាកិលេសទាំង ១០ នោះ លោភៈតើដូចម្តេច ? តម្រេក តម្រេកខ្លាំង" ទ្រង់ពង្រីកចេញទាំងរយបទក្នុងឋានៈទាំង ៣ គឺ ហេតុគោច្ឆកៈ, គណ្ឋគោច្ឆកៈ និងក្នុង

កិលេសគោច្ឆកៈនេះ ។ ទ្រង់អធិប្បាយទុកក្នុងអាសវគោច្ឆកៈ, សញ្ញោជនគោច្ឆកៈ, ឱឃគោច្ឆកៈ, យោគគោច្ឆកៈ, នីវរណគោច្ឆកៈ និងឧបាទានគោច្ឆកៈ ដោយបទទាំងឡាយប្រាំបី៧ បទ ។ លោភៈនេះឯង បណ្ឌិតគប្បីជ្រាបថា ទ្រង់កាន់យកដោយនិប្បទេស (សម្ដែងដោយមិនសល់) ក្នុងឋានៈដែលរៀបរាប់ទុកជាងរយបទខ្លះ, ក្នុងឋានៈដែលរៀបរាប់ទុកជាគោច្ឆកៈ ៨ បទខ្លះ; ក្នុងគោច្ឆកៈទាំងនោះ តណ្ហាដែលតាំងនៅដោយចំណែកតែមួយនោះឯងក្នុងហេតុគោច្ឆកៈ, គណ្ឋគោច្ឆកៈ, នីវរណគោច្ឆកៈ, ឧបាទានគោច្ឆកៈ និងកិលេសគោច្ឆកៈ គប្បីសម្លាប់ដោយមគ្គទាំង ៤ ។ តណ្ហាដែលជាចំណែកទាំង ២ តាំងនៅក្នុងអាសវគោច្ឆកៈ, សញ្ញោជនគោច្ឆកៈ, ឱឃគោច្ឆកៈ និងយោគគោច្ឆកៈ ក៏គប្បីសម្លាប់ដោយមគ្គទាំង ៤ ដែរ ។ តណ្ហាដែលជាចំណែកទាំង ២ នោះ តើដូចម្ដេច ? គឺអាសវគោច្ឆកៈ ជាកាមាសវៈ និងភវាសវៈ, ក្នុងសញ្ញោជនគោច្ឆកៈ បានដល់ កាមរាគសញ្ញោជនៈ និងភវរាគសញ្ញោជនៈ, ក្នុងឱឃៈ បានដល់ កាមោឃៈ និងភវោឃៈ, ក្នុងយោគៈ បានដល់ កាមយោគៈ និងភវយោគៈ; ក៏កិលេសវត្ថុពួកនេះ គួរនាំមកដោយលំដាប់នៃកិលេសខ្លះ ដោយលំដាប់នៃមគ្គខ្លះ ។

**ពោលដោយលំដាប់នៃកិលេស** មគ្គទាំង ៤ រមែងប្រហារនូវលោភៈ,

អនាគាមិមគ្គរមែងប្រហារនូវទោសៈ, អរហត្តមគ្គរមែងប្រហារនូវមោហៈ និងមានះ, សោតាបត្តិមគ្គរមែងប្រហារនូវទិដ្ឋិ និងវិចិកិច្ឆា, អរហត្តមគ្គរមែងប្រហារនូវថីនៈ ជាដើម ។

**ពោលដោយលំដាប់នៃមគ្គ** សោតាបត្តិមគ្គរមែងប្រហារនូវទិដ្ឋិ និង វិចិកិច្ឆា, អនាគាមិមគ្គរមែងប្រហារនូវទោសៈ, អរហត្តមគ្គរមែងប្រហារនូវកិលេស ៧ ដ៏សេស ៕ ៕

## សម្ដែងអំពីកាមាវចរនិទ្ទេសក្នុងបិដ្ឋិទុកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **កាមាវចរ** ដូចតទៅ ៖

បទថា **“ហេដ្ឋតោ** = ខាងក្រោម” បានដល់ ចំណែកខាងក្រោម ។

បទថា **“អវីចិនិរយំ** = អវីចិនរក” មានការសម្គាល់ថា ដែលឈ្មោះថា អវីចិ ព្រោះអត្ថថា ក្នុងនរកនេះមិនមានចន្លោះនៃអណ្ដាតភ្លើងទាំងឡាយ ឬមិនមានចន្លោះនៃទុក្ខវេទនារបស់សត្វទាំងឡាយ, ដែលមានឈ្មោះថា និរយៈ (នរក) ព្រោះអត្ថថា ក្នុងទីនោះ មិនមានសេចក្ដីចម្រើន ពោលគឺសេចក្ដីសុខ, មួយវិញទៀត ឈ្មោះថា **នរក** ដោយអត្ថថា មិនមានសេចក្ដីត្រេកអរខ្លះ មិនមានសេចក្ដីពេញចិត្តខ្លះ ។

បទថា **“បរិយន្តំ ករិត្វា** = ធ្វើឱ្យមានទីបំផុត” បានដល់ ធ្វើនរក ពោល គឺអវីចិនេះឱ្យមានទីបំផុត ។ បទថា **“ឧបរិតោ** = ខាងខ្ពស់” បានដល់ ចំណែកខាងលើ ។ បទថា **“បរនិម្មិតវសវត្តិទេវេ** = ទេពបរនិម្មិតវសវត្តី” សេចក្តីថា ទេពមានវោហារដែលបានហើយយ៉ាងនេះ ព្រោះញ៉ាំងអំណាចឱ្យប្រព្រឹត្តទៅក្នុងសេចក្តីប្រាថ្នា (កាម) ទាំងឡាយដែលទេពដទៃនិម្មិតឱ្យ ។

បទថា **“អន្តោ ករិត្វា** = ធ្វើឱ្យនៅខាងក្នុង” បានដល់ ឃាំងទុកខាងក្នុង ។

បទថា **“យំ ឯតស្មឹ អន្តរេ** = ក្នុងភូមិនេះចំណែកណា” បានដល់ ឱកាសនេះចំណែកណា ។ ក៏ព្រោះហេតុដែលធម៌សូម្បីពួកដទៃ រមែងត្រាច់ទៅក្នុងចន្លោះភូមិនេះដោយការកើតក្នុងភូមិណាៗ ក្នុងកាលខ្លះ គ្រាខ្លះ, ព្រោះហេតុដូច្នោះ ទ្រង់ដើម្បីមិនរួបរួមធម៌នោះដោយបទនេះថា **“ឯត្ថាវចរា** = ការត្រាច់ទៅក្នុងភូមិនោះ” ទើបត្រាស់ពាក្យថា **“អវចរា** = ត្រាច់ទៅ” ដោយពាក្យនោះ ធម៌ណារមែងត្រាច់ទៅធ្លាក់ចុះខាងក្នុងចន្លោះភូមិនេះ ដោយកន្លែងកើតនៅគ្រប់ទី គ្រប់កាល, គឺរមែងត្រាច់ទៅក្នុងចំណែកខាងក្រោម ដោយភូតរូប និងឧបាទាយរូប ក៏ប្រព្រឹត្តទៅខាងក្រោមរបស់អវីចិនរក, ទើបទ្រង់ធ្វើការរួបរួមធម៌ពួកនោះទុក; ព្រោះថា ធម៌ពួកនោះធ្លាក់ចុះហើយត្រាច់ទៅ គឺត្រាច់ចុះទៅក្នុងចំណែកខាងក្រោមនោះឯង ព្រោះហេតុនោះ ទើបត្រាស់ហៅថា **អវចរា** ។ ពិតមែន ព្រោះធម៌ពួកនេះ ត្រាច់ទៅក្នុងភូមិនេះ រមែងត្រាច់ទៅសូម្បីក្នុងភូមិដទៃ, តែមិនរាប់បញ្ចូលក្នុងភូមិដទៃនោះទេ;

ព្រោះហេតុដូច្នោះ ទើបទ្រង់ធ្វើការកំណត់ធម៌ពួកនោះ ដែលត្រាច់ទៅសូម្បីក្នុងភូមិដទៃ ដោយបទនេះថា **"ឯត្ថ បរិយាបន្នា** = រាប់បញ្ចូលក្នុងភូមិនោះ" ; កាលនឹងសម្តែងធម៌ពួកនោះ ដែលជាធម៌រាប់បញ្ចូលក្នុងភូមិនេះ ដោយសេចក្តីជារាសី (គំនរ) ដោយសេចក្តីសោះសូន្យ ដោយសេចក្តីជាបច្ច័យ និងជាសភាវៈ ទើបត្រាស់ពាក្យថា **"ខន្ធ"** ជាដើម ៕

## សម្តែងអំពីរូបាវចរធម្មនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ ***រូបាវចរធម៌*** ដូចតទៅ ៖

បទថា **"ព្រហ្មលោកំ** = ព្រហ្មលោក" បានដល់ ស្ថានទីនៅនៃព្រហ្ម ពោលគឺបឋមជ្ឈានភូមិ ។ ពាក្យដ៏សេសក្នុងនិទ្ទេសនេះ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងនិទ្ទេសនៃកាមាវចរនោះឯង ។ ក្នុងបទមានជាអាទិ៍ថា **"សមាបន្នស្ស វា** = របស់អ្នកចូលសមាបត្តិ" គប្បីជ្រាបថា ត្រាស់កុសលជ្ឈានដោយបទទី ១, ត្រាស់វិបាកជ្ឈានដោយបទទី ២, ត្រាស់កិរិយាឈានដោយបទទី ៣ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃអរូបាវចរធម៌ ដូចតទៅ ៖

បទថា **"អាកាសានញ្ចាយតនូបគេ** = អ្នកចូលដល់អាកាសានញ្ចាយតន-ភូមិ" បានដល់ អ្នកចូលដល់ភព ពោលគឺ **អាកាសានញ្ចាយតនៈ** ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដែរ ។ ពាក្យដ៏សេសក្នុងនិទ្ទេសនេះ គប្បីជ្រាបដោយន័យដែលពោលទុកហើយក្នុងគ្រាក្រោយនុ៎ះចុះ ៕ ៕

## សម្ដែងអំពីសរណទុកនិទ្ទេស (ទី ១៨)

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **សរណទុកៈ** ដូចតទៅ ៖

បណ្ដាអកុសលមូល ៣ អកុសលមូល គឺមោហៈណា, មោហៈនោះសម្បយុត្ត ដោយលោភៈ គប្បីជ្រាបថា **ជាសរណៈ** (កើតព្រមជាមួយកិលេស ជាហេតុឱ្យសត្វស្រែកយំ) ដោយលោភៈ, មោហៈដែលសម្បយុត្តដោយទោសៈ ជាសរណៈដោយទោសៈ; តែមោហៈដែលសម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈ **ជាសរណៈ** ដែលជាកិលេសតាំងនៅក្នុងឋានតែមួយ និងការប្រហារដោយកិលេសជាហេតុឱ្យសត្វស្រែកយំ គឺរាគៈដែលសម្បយុត្តដោយទិដ្ឋិ និងកិលេស គឺរូបរាគៈ អរូបរាគៈ ៕

## សម្ដែងអំពីវិជ្ជូបមទុកនិទ្ទេស

និទ្ទេសបទទាំងឡាយនៃសុត្តន្តិកទុកៈទាំងនោះ ដោយច្រើនមានអត្ថងាយស្រួលទាំងអស់មែនពិត ។ ព្រោះសុត្តន្តិកៈទាំងឡាយ ខ្ញុំបានចែកសម្ដែងដោយសេចក្ដីក្នុងមាតិកាកថាហើយ និងព្រោះសូម្បីនិទ្ទេសនៃបទទាំងនោះ ចូលចិត្តបានដោយងាយ មានន័យដែលបានពោលហើយខាងក្រោយនោះឯង ។ តែក្នុងទីនេះ ខ្ញុំនឹងសម្ដែងសេចក្ដីដែលផ្សេងគ្នាដូចតទៅ ៖

គប្បីជ្រាបវិនិច្ឆ័យក្នុងវិជ្ជូបមទុកៈជាមុនសិន បានឮថា បុរសអ្នកមានចក្ខុដើរផ្លូវទៅ ក្នុងវេលារាត្រីមានមេឃងងឹត, ផ្លូវរមែងមិនប្រាកដដល់បុរសនោះ ព្រោះ

ភាពងងឹត, ចេញផ្លេកបន្ទោរហើយកម្ចាត់ងងឹតចេញទៅ, ពេលនោះ ផ្លូវក៏ប្រាកដ ដល់គេ ព្រោះភាពងងឹតប្រាសចាកហើយ; គេទើបដើរផ្លូវតទៅ, សូម្បីគ្រាទីពីរ ភាពងងឹតក៏រមែងគ្របដណ្តប់ទៀត, ទើបផ្លូវមិនប្រាកដដល់គេ, ចេញផ្លេកបន្ទោរ ហើយ កម្ចាត់ភាពងងឹតនោះបាត់, កាលប្រាសចាកភាពងងឹតហើយ ផ្លូវក៏ប្រាកដ, ទើបគេដើរទៅកាន់ផ្លូវនោះ, គ្រាទីបីភាពងងឹតបានគ្របដណ្តប់ហើយ ផ្លូវក៏មិន ប្រាកដ, ចេញផ្លេកបន្ទោរហើយកម្ចាត់ភាពងងឹតតទៅ ។ បណ្តាសេចក្តីឧបមា ទាំងនោះ ការផ្តើមវិបស្សនារបស់អរិយសាវ័ក ដើម្បីប្រយោជន៍ពន្លុះនូវសោតា-បត្តិមគ្គ ដូចការដើរផ្លូវរបស់បុរសអ្នកមានចក្ខុក្នុងវេលាដែលងងឹត, ភាពងងឹតបិទ បាំងសច្ចៈ ដូចវេលាដែលផ្លូវមិនប្រាកដក្នុងភាពងងឹត, វេលាដែលពន្លឺភ្លឺ គឺសោតា-បត្តិមគ្គកើតឡើង កម្ចាត់សេចក្តីងងឹតដែលបិទបាំងសច្ចៈ ដូចវេលាដែលចេញផ្លេក បន្ទោរឡើងកម្ចាត់ភាពងងឹតចេញ, វេលាដែលសច្ចៈ ៤ ប្រាកដដល់សោតាបត្តិមគ្គ ដូចវេលាដែលផ្លូវប្រាកដក្នុងការប្រាសចាកភាពងងឹត, ក៏ការប្រាកដរបស់ផ្លូវ ក៏គឺ ការប្រាកដរបស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គសមង្គីនោះឯង ។

ការផ្តើមវិបស្សនារបស់បុគ្គល ដើម្បីប្រយោជន៍ពន្លុះសកទាគាមិមគ្គ ដូចការ ដើរទៅគ្រាទីពីរ, សេចក្តីងងឹតបិទបាំងសច្ចៈ ដូចវេលាដែលផ្លូវមិនប្រាកដក្នុងភាព ងងឹត, វេលាដែលពន្លឺភ្លឺ គឺសកទាគាមិមគ្គកើតឡើងកម្ចាត់សេចក្តីងងឹតដែលបិទបាំងសច្ចៈ ដូចវេលាចេញផ្លេកបន្ទោរគ្រាទីពីរកម្ចាត់ភាពងងឹត, វេលាដែលសច្ចៈ ៤ ប្រាកដ

ដល់សកទាគាមិមគ្គ ដូចវេលាដែលផ្លូវប្រាកដក្នុងការប្រាសចាកភាពងងឹត, ក៏ការប្រាកដរបស់ផ្លូវ ក៏គឺការប្រាកដរបស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គនោះឯង ។

ការផ្ដើមវិបស្សនាដើម្បីពន្លុះអនាគាមិមគ្គ ដូចបុគ្គលដើរផ្លូវគ្រាទីបី, សេចក្ដីងងឹតដែលបិទបាំងសច្ចៈ ដូចផ្លូវមិនប្រាកដក្នុងវេលាងងឹត, វេលាដែលពន្លឺភ្លឺ គឺអនាគាមិមគ្គកើតឡើងកម្ចាត់ភាពងងឹតដែលបិទបាំងសច្ចៈ ដូចវេលាដែលចេញផ្លេកបន្ទោរកម្ចាត់សេចក្ដីងងឹតគ្រាទីបី, វេលាដែលសច្ចៈ ៤ ប្រាកដដល់អនាគាមិមគ្គ ដូចវេលាដែលផ្លូវប្រាកដក្នុងការប្រាសចាកភាពងងឹត, ក៏ការប្រាកដរបស់ផ្លូវ ក៏គឺការប្រាកដរបស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គនោះឯង ។

ម្យ៉ាងទៀត ផ្ទាំងថ្ម ឬកែវមណី ឈ្មោះថា មិនបែកទៅដោយវជិរៈ* (រន្ទះបាញ់) រមែងមិនមានឡើយ; វជិរៈធ្លាក់ទៅក្នុងទីណាៗ, ទីនោះរមែងជាការត្រូវកម្ចាត់ហើយមែនពិត; វជិរៈកាលបក់បោកទៅ រមែងបក់បោកទៅ មិនឱ្យនៅសល់អ្វីឡើយ; ឈ្មោះថា ផ្លូវដែលវជិរៈឆ្លងទៅហើយ នឹងមិនជាវត្ថុប្រាកដទៀតទេ; ឈ្មោះថា **កិលេស** ដែលអរហត្តមគ្គមិនប្រហារហើយ ក៏រមែងមិនមានយ៉ាងនោះដែរ; សូម្បីអរហត្តមគ្គរមែងកម្ចាត់កិលេសទាំងអស់ គឺការញុំាងកិលេសឱ្យអស់ទៅរមែងឱ្យអស់ទៅ មិនឱ្យសេសសល់ ដូចវជិរៈកម្ចាត់ហើយដូច្នោះដែរ ។ ដែលឈ្មោះ

---

* វជិរៈ ជាឈ្មោះរបស់រន្ទះបាញ់ក៏មាន ជាឈ្មោះរបស់អាវុធនៃព្រះឥន្ទក៏មាន ។

ថា ការត្រឡប់កើតទៀតរបស់កិលេស ដែលអរហត្តមគ្គប្រហារហើយ រមែងមិនមាន ដូចផ្លូវដែលវជិរៈឆ្លងទៅហើយ មិនត្រឡប់ជាវត្ថុប្រាកដទៀតដូច្នោះដែរ ។ ៕

## សម្តែងអំពីពាលទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ពាលទុកៈ** ដូចតទៅ ៖

អហិរិកៈ និងអនោត្តប្បៈប្រាកដហើយក្នុងពាលជនទាំងឡាយ ។

ម្យ៉ាងទៀត អហិរិកៈ និងអនោត្តប្បៈទាំងនោះនៅជាមូលនៃពាលធម៌ដែលនៅសល់; ព្រោះថា មនុស្សអហិរិកៈ និងអនោត្តប្បៈ ឈ្មោះថា មិនធ្វើអកុសលអ្វីៗរមែងមិនមានទេ, ព្រោះហេតុដូច្នោះ ធម៌ទាំង ២ នេះ ទើបត្រាស់វែកញែកទុកជាមុនមែនពិត ។ សូម្បីធម៌ដែលជាចំណែកស (សុក្កធម៌) ក៏មានន័យដូចគ្នានេះដែរ, ក្នុងកណ្ហទុកៈក៏ដូចគ្នាដែរ ។ ៕

## សម្តែងអំពីតបនីយទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **តបនីយទុកៈ** ដូចតទៅ ៖

បណ្ឌិតគប្បីជ្រាប **តបនីយធម៌** (ធម៌ដែលរោលក្តៅ) ព្រោះហេតុដែលធ្វើ និងព្រោះហេតុដែលមិនធ្វើ; ដ្បិតថា កាយទុច្ចរិតជាដើមរមែងឱ្យរោលក្តៅព្រោះ

ហេតុដែលធ្វើ, កាយសុចរិតជាដើមរមែងរោលក្តៅ ព្រោះហេតុដែលមិនធ្វើ; ពិតយ៉ាងនោះមែន បុគ្គលរមែងក្តៅក្រហាយថា "កាយទុច្ចរិតយើងធ្វើទុកហើយ" , និងរមែងក្តៅក្រហាយថា "កាយសុចរិតយើងមិនបានធ្វើទុកទេ" ; រមែងក្តៅក្រហាយថា "វចីទុច្ចរិតយើងធ្វើទុកហើយ" ។ល ។ រមែងក្តៅក្រហាយថា មនោសុចរិតយើងមិនបានធ្វើទុកទេ"[១២៤] ។ សូម្បីក្នុង**អតបនីយធម៌** (ធម៌ដែលមិនរោលក្តៅ) ក៏ន័យនេះដែរ ។

ដ្បិតបុគ្គលអ្នកធ្វើសេចក្តីល្អ រមែងមិនក្តៅក្រហាយថា "កាយសុចរិត យើងធ្វើទុកហើយ" ដូច្នេះទេ, រមែងមិនក្តៅក្រហាយថា "កាយទុច្ចរិត យើងមិនបានធ្វើទុកហើយ" ; រមែងមិនក្តៅក្រហាយថា "វចីសុចរិតយើងធ្វើទុក" ។ល ។ មិនក្តៅក្រហាយថា "មនោទុច្ចរិតយើងមិនបានធ្វើទុកទេ"[១២៥] ៕

## សម្តែងអំពីអធិវចនទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **អធិវចនទុកៈ** ដូចតទៅ ៖

---

[១២៤] អំ. ឯកក. ។

[១២៥] អំ. ឯកក. ។

បទថា **"យេ តេសំ តេសំ ធម្មានំ** = ធម៌នោះៗ យ៉ាងណា" បានដល់ទ្រង់រូបរួមយកធម៌ទាំងអស់ ។ ដែលឈ្មោះថា **សង្ខា** (ការពោលឆ្លើយ) ព្រោះដែលគេប្រាប់, គឺរមែងសន្ទនាគ្នា; រមែងសន្ទនាគ្នាយ៉ាងណា ? រមែងសន្ទនាគ្នាដោយអាការៈច្រើនប្រការយ៉ាងនេះថា "យើង, របស់យើង; មនុស្សដទៃ, របស់មនុស្សដទៃ; ជាសត្វ, ជាភាវៈ, ជាបុរស, ជាបុគ្គល, ជានរៈ, ជាមាណព, ឈ្មោះថាតិស្សៈ, ឈ្មោះថា ទត្តា, គ្រែ, តាំង, ពូក, ខ្នើយ, វិហារ, បរិវេណ, ទ្វារ, បង្អួច" ; ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **សង្ខា** = ការពោលឆ្លើយ ។

ដែលឈ្មោះថា **សមញ្ញា** (ការកំណត់ដឹង) ព្រោះអត្ថថា រមែងដឹងដោយប្រពៃ ។ រមែងដឹងដោយប្រពៃយ៉ាងណា ? រមែងដឹងដោយប្រពៃថា "យើង, របស់យើង, ។ល ។ ទ្វារ, បង្អួច" ; ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **សមញ្ញា** ព្រោះអត្ថថា រមែងដឹងដោយប្រពៃ ។ ដែលឈ្មោះថា **បញ្ញត្តិ** ព្រោះអត្ថថា ដែលគេតែងតាំង ។ ដែលឈ្មោះថា **វោហារ** ព្រោះអត្ថថា ដែលគេនិយមនិយាយ; រមែងនិយមនិយាយយ៉ាងណា ? រមែងនិយមនិយាយថា "យើង, របស់យើង ។ល ។ ទ្វារ, បង្អួច" ; ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **វោហារ** ។

បទថា **"នាមំ** = នាម" បានដល់ នាម ៤ យ៉ាង គឺ

**១-សាមញ្ញនាម** នាមទូទៅ

**២-គុណនាម** នាមដោយគុណ

៣-**កិត្តិនាម** នាមដោយការលើកតម្កើង

៤-**ឱប្បាតិកនាម** នាមតាមដែលកើតឡើងឯង ។

បណ្ដានាម ៤ យ៉ាងនោះ នាមរបស់ព្រះរាជាថា "**មហាសម្មតិ**" ដូច្នេះ ព្រោះមហាជនក្នុងគ្រាបឋមកប្បប្រជុំគ្នាតាំងទុក ឈ្មោះថា **សាមញ្ញនាម**; ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្ដែងទុកថា "ម្នាលវាសេដ្ឋៈ អក្សរដំបូងថា **មហាសម្មតិ**' កើតឡើង ព្រោះមហាជនសន្មតិឡើងព្រមគ្នានោះឯង" ។ នាមដែលមានមកហើយ ដោយគុណយ៉ាងនេះថា "ព្រះធម្មកថិកអ្នកទ្រទ្រង់បង្សុកូលចីវរ ព្រះវិន័យធរអ្នកទ្រទ្រង់ព្រះត្រៃបិដក អ្នកមានសទ្ធា អ្នកជ្រះថ្លាហើយ" ដូច្នេះ ឈ្មោះ ថា **គុណនាម** ។

សូម្បីព្រះនាមរបស់ព្រះតថាគត មានច្រើនរយ មានជាអាទិ៍ថា "**ភគវា អរហំ សម្មាសម្ពុទ្ធោ**" ក៏ឈ្មោះថា **គុណនាម** ដូចគ្នា; ដោយហេតុនោះ ទើបលោកបោរាណាចារ្យពោលថា ៖

**"អសង្ខេយ្យានិ នាមានិ សគុណេន មហេសិនោ**
**គុណេ នាមមុទ្ធេយ្យំ អបិ នាម សហស្សតោ**

ព្រះពុទ្ធជាម្ចាស់ទ្រង់ស្វែងរកគុណដ៏ធំ មានព្រះនាមដោយព្រះគុណរបស់ព្រះអង្គរាប់មិនអស់ បណ្ឌិតគប្បីលើកយកមកសម្ដែងនូវព្រះនាម ដោយព្រះគុណឡើងសូម្បីជាពាន់ៗ" ។

ចំណែកនាមណា ដែលពួកញាតិទាំងឡាយឈរនៅក្នុងទីជិតធ្វើសក្ការៈដល់ព្រះទក្ខិណេយ្យបុគ្គលទាំងឡាយ នាំគ្នាគិតកំណត់ហើយក្នុងថ្ងៃដែលតាំងឈ្មោះរបស់ក្មេងអ្នកកើតច្រើនត្រកូលធ្វើការតាំងឈ្មោះថា "ក្មេងនេះ ឈ្មោះឯណោះ" ជាដើម នាមនេះ ឈ្មោះថា **កិត្តិនាម** ។

ម្យ៉ាងទៀត បញ្ញត្តិដំបូងរមែងធ្លាក់ទៅក្នុងបញ្ញត្តិក្រោយ, វោហារដំបូងរមែងធ្លាក់ទៅក្នុងវោហារក្រោយ; តើដូចម្ដេច ? ដូចព្រះចន្ទសូម្បីក្នុងកប្បមុនឈ្មោះថា ព្រះចន្ទនោះឯង, សូម្បីក្នុងបច្ចុប្បន្ន ក៏ហៅថា ព្រះចន្ទដូចគ្នា; ព្រះអាទិត្យ សមុទ្រ បឋវី បព្វតៈ (ភ្នំ) ក្នុងកប្បមុន ឈ្មោះថា បព្វតៈ (ភ្នំ) មែនពិត; សូម្បីក្នុងបច្ចុប្បន្ន ក៏ហៅថា បព្វតៈ (ភ្នំ) នោះឯង, នេះឈ្មោះថា **ឱប្បាតិកនាម** ។ សូម្បីទាំង ៤ យ៉ាងនេះ ក៏គង់ជានាមដូចគ្នានោះឯង ។

បទថា "**នាមកម្មំ** = នាមកម្ម" គឺការឱ្យឈ្មោះ ។

បទថា "**នាមធេយ្យំ** = នាមធេយ្យៈ" គឺការតាំងឈ្មោះ ។

បទថា "**និរុត្តិ** = ការចេញឈ្មោះ" បានដល់ ការហៅឈ្មោះ ។

បទថា "**ព្យញ្ជនំ** = ការបញ្ជាក់ឈ្មោះ" បានដល់ ការប្រកាសឈ្មោះ; ក៏ព្រោះការបញ្ជាក់ឈ្មោះនេះ រមែងប្រាកដដល់សេចក្ដីសម្គាល់ដូច្នេះ ទើបត្រាស់ទុកយ៉ាងនោះ ។

បទថា "**អភិលាបោ** = ការហៅឈ្មោះ" បានដល់ ឈ្មោះដែលហៅនោះឯង ។

បទថា **“សព្វេវ ធម្មា អធិវចនបថា** = ធម៌ទាំងអស់នោះឯង ឈ្មោះថា **អធិវចនបថធម៌”** បានដល់ ឈ្មោះថា ធម៌ដែលជាវិថីរបស់ធម៌ ដែលជាឈ្មោះមិនមាន មិនបានឡើយ; ធម៌មួយរមែងរួមចូលក្នុងធម៌ទាំងអស់, ធម៌ទាំងអស់ក៏ប្រជុំចុះក្នុងធម៌មួយ; សេចក្តីនេះតើយ៉ាងណា ? គឺថា ធម៌មួយ បានដល់នាមប្បញ្ញត្តិនេះ, ធម៌នោះរមែងប្រមូលចូលក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់; គឺសត្វក្តី, សង្ខារក្តី ឈ្មោះថា ផុតទៅអំពីឈ្មោះមិនមានទេ ។ សូម្បីដើមឈើក្នុងព្រៃក្រាស់ និងភ្នំជាដើម ក៏នៅជាភារៈ (ពាក្យនិយាយ) របស់អ្នកស្រុកជនបទដែរ; ព្រោះថា អ្នកស្រុកជនបទទាំងនោះ ត្រូវគេសួរថា “ដើមឈើឈ្មោះអ្វី ?” ដូច្នេះ ។ ក៏នឹងប្រាប់ឈ្មោះដែលខ្លួនដឹងថា “ដើមឈើនោះជាដើមគគីរ” ជាដើម; ពួកគេមិនដឹងនូវឈ្មោះដើមឈើណា, ក៏នឹងនិយាយថា “ដើមឈើនោះ មិនមានឈ្មោះ” ជាដើម, សូម្បីពាក្យថា ដើមឈើមិនមានឈ្មោះនោះ ក៏ជានាមធេយ្យៈ (ការតាំងឈ្មោះ) របស់ដើមឈើនោះឯង ។ សូម្បីត្រី និងអណ្តើកជាដើមក្នុងសមុទ្រ ក៏មានន័យដូចគ្នានេះដែរ ។ ពីរទុកៈក្រៅនេះ (គឺនិរុត្តិទុកៈ និងបញ្ញត្តិទុកៈ) មានសេចក្តីដូចទុកៈនេះដែរ ៕

## សម្តែងអំពីនាមរូបទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **នាមរូបទុក:** ដូចតទៅ ៖

ដែលឈ្មោះថា **នាម** ដោយអត្ថថា ជានាមករណៈ (ការឱ្យឈ្មោះ) ដោយអត្ថថា ការបង្អោនឱ្យទៅកាន់អារម្មណ៍ និងដោយអត្ថថា ការញ៉ាំងអារម្មណ៍ឱ្យបង្អោនចុះក្នុងខ្លួន ។ បណ្តាអត្ថទាំង ៣ នោះ ខន្ធ ៤ ឈ្មោះថា **នាម** ដោយអត្ថថា **ការឱ្យឈ្មោះ**; ដូចយ៉ាងព្រះនាមថា **"មហាសម្មតិ"** ជាឈ្មោះរបស់ព្រះបាទមហាសម្មតិអង្គនោះ ព្រោះមហាជនលើកតម្កើងហើយយ៉ាងណា, ឬថា មាតា និងបិតាតាំងឈ្មោះដល់បុត្រ យ៉ាងនេះថា "កូននេះ ចូរឈ្មោះថា **តិស្ស:**, កូននេះចូរឈ្មោះថា **បុស្ស:** យ៉ាងណា, ឬថា **នាម** ដែលមកដោយគុណថា "ព្រះធម្មកថិក ព្រះវិន័យធរ" ដូច្នេះ យ៉ាងណា, ឈ្មោះរបស់ខន្ធ ៤ មានវេទនាជាដើម មិនមែនយ៉ាងនោះទេ ព្រោះខន្ធ ៤ មានវេទនាជាដើម ការធ្វើឈ្មោះរបស់ខ្លួនហើយកើតឡើង ក៏ដូចជាមហាប្រឹថពីជាដើមដែរ, កាលវេទនាជាដើមទាំងនោះ កើតឡើងហើយ ឈ្មោះរបស់ខន្ធមានវេទនាជាដើម ក៏រមែងកើតឡើងដែរ; ដ្បិតនរណាៗ នឹងនិយាយដល់វេទនាដែលកើតឡើងហើយថា "អ្នកឈ្មោះថា វេទនា" ដូច្នេះ មិនមានទេ ។ ឯកិច្ច គឺនាទីដែលតាំងឈ្មោះរបស់វេទនានោះ ក៏មិនមាន ។ កាលប្រឹថពីកើតឡើងហើយ កិច្ចដែលនឹងតាំងឈ្មោះថា "អ្នកចូរឈ្មោះថា ប្រឹថពី" ដូច្នេះ មិនមានឡើយ; កាលចក្រវាឡ ភ្នំសិនេរុ ដួងចន្ទ ដួងអាទិត្យ ដួងនក្ខត្តឫក្សកើតឡើង

ហើយ កិច្ចដែលនឹងតាំងឈ្មោះថា “អ្នកចូរឈ្មោះថា ចក្រវាឡ, អ្នកចូរឈ្មោះថា ភ្នំសិនេរុ, អ្នកចូរ ឈ្មោះថា ដួងចន្ទ, អ្នកចូរឈ្មោះថា ដួងអាទិត្យ, អ្នកចូរឈ្មោះថា ដួងនក្ខត្តប្ញក្ស = ផ្កាយ” ដូច្នេះ មិនបានមានទេ, នាមកើតឡើងហើយនោះឯង រមែងធ្លាក់ចុះក្នុងឧប្បាតិកបញ្ញត្តិ (បានឈ្មោះតាមសភាពដែលកើតឡើង) យ៉ាងណា; កាលវេទនា កើតឡើងហើយ ក៏ដូច្នោះដែរ កិច្ចដែលនឹងតាំងឈ្មោះថា “អ្នកចូរឈ្មោះថា វេទនា” ដូច្នេះ មិនបាន កាលវេទនានោះ កើតឡើងហើយ ឈ្មោះថា **វេទនា** ក៏រមែងកើតឡើងនោះឯង, រមែងធ្លាក់ចុះក្នុងឧប្បាតិកបញ្ញត្តិ; សូម្បីក្នុងខន្ធមានសញ្ញាជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ដ្បិតវេទនា ក៏ឈ្មោះថា វេទនានោះឯង; សញ្ញា ក៏ឈ្មោះថា សញ្ញា; សង្ខារ ក៏ឈ្មោះថា សង្ខារ និងវិញ្ញាណ ក៏ឈ្មោះថា វិញ្ញាណដូចគ្នា; សូម្បីក្នុងអតីតៈ; សូម្បីក្នុងអនាគត; សូម្បីក្នុងបច្ចុប្បន្ន ។ តែព្រះនិព្វាន ក៏ឈ្មោះថា ព្រះនិព្វាននោះឯង សូម្បីក្នុងកាលគ្រប់កាល ព្រោះហេតុដូច្នោះ ខន្ធ ៤ ទើបឈ្មោះថា **នាម** ដោយអត្ថថា សភាវៈធ្វើឈ្មោះ ។

ចំណែកក្នុងសេចក្ដីថា **ការបង្អោនទៅកាន់អារម្មណ៍** នេះ ខន្ធ ៤ ឈ្មោះថា នាម; ដ្បិតថា ខន្ធទាំង ៤ នោះ បង្អោនទៅចំពោះអារម្មណ៍; សូម្បីនាមទាំងអស់ ឈ្មោះថា **នាម** ដោយអត្ថថា **បង្អោនទៅ**, ព្រោះខន្ធ ៤ រមែងញ៉ាំងគ្នានឹងគ្នាឱ្យបង្អោនទៅក្នុងអារម្មណ៍, ព្រះនិព្វានរមែងញ៉ាំងធម៌មិនមានទោស ឱ្យបង្អោនទៅ

ក្នុងខ្លួន ព្រោះជាអារម្មណាធិបតិប្បច្ច័យ ។

**ក្នុងនិទ្ទេសនៃអវិជ្ជានុក:** ព្រះមានព្រះភាគទ្រង់កំណត់អវិជ្ជា និងភវតណ្ហា ដើម្បីសម្តែងការកើតឡើងហើយប្រព្រឹត្តទៅរបស់វដ្តមូល ។

**ក្នុងនិទ្ទេសនៃភវទិដ្ឋិ** បទថា "**ភវិស្សតិ អត្តា ច លោកោ ច** = អត្តា និងលោកនឹងកើតមាន" បានដល់ សស្សតទិដ្ឋិដែលប្រកាន់ខន្ធបញ្ចកៈថា "ជាអត្តា និងលោក" ហើយប្រកាន់ទុកដោយអាការៈដែលប្រកាន់ថា "ខន្ធបញ្ចកៈនោះនឹងកើតមាន" ។ ទិដ្ឋិទី ២ គឺឧច្ឆេទទិដ្ឋិដែលប្រកាន់យកដោយអាការៈថា "ខន្ធបញ្ចកៈនោះ នឹងមិនកើតមាន" ។

**ក្នុងនិទ្ទេសនៃបុព្វន្តានុទិដ្ឋិនុក:** បទថា "**បុព្វន្តំ អារព្ភ** = ប្រារព្ធចំណែកអតីតៈ" បានដល់ ធ្វើចំណែកអតីតៈឱ្យជាអារម្មណ៍, ទ្រង់កាន់យកបុព្វន្តានុទិដ្ឋិ ១៨ ដែលមានមកក្នុងព្រហ្មជាលសូត្រ ដោយបទថា "**បុព្វន្តំ អារព្ភ**" នេះ ។

បទថា "**អបរន្តំ អារព្ភ** = ប្រារព្ធចំណែកអនាគត" បានដល់ ធ្វើចំណែកអនាគតឱ្យជាអារម្មណ៍ហើយកាន់យកអបរន្តានុទិដ្ឋិ ៤៤ ដែលមានមកហើយក្នុងព្រហ្មជាលសូត្រនោះឯង ដោយបទថា **អបរន្តំ អារព្ភ** នេះ ។

**ក្នុងនិទ្ទេសនៃទោវចស្សតា** បទថា "**សហធម្មិកេ វុច្ចមានេ** = កាលត្រូវពោលដោយសហធម៌" សេចក្តីថា ព្រះមានព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទណាឈ្មោះថា **សហធម្មិក**, ភិក្ខុកាលត្រូវគេចង្អុលប្រាប់វត្ថុក្នុងសិក្ខាបទនោះ ដាក់

អាបត្តិហើយពោលថា “លោកត្រូវអាបត្តិឈ្មោះនេះ, និមន្តលោកសម្តែងអាបត្តិ, និមន្តលោកចេញចាកអាបត្តិ, និមន្តលោកធ្វើឱ្យជាក់ច្បាស់នូវអាបត្តិ” ។

ក្នុងបទថា **“ទោវចស្សាយំ** = កិរិយារបស់អ្នកប្រដៅលំបាក” ជាដើម កម្មរបស់អ្នកប្រដៅលំបាក ដែលត្រូវដាស់តឿនយ៉ាងនេះ ដោយបាតុកម្មតបខ្លះ ដោយមិនព្រមទទួលឱវាទដោយគោរពខ្លះ ឈ្មោះថា **ទោវចស្សាយំ**; កិរិយារបស់អ្នកប្រដៅលំបាកនោះឯង ត្រាស់ហៅថា **“ទោវចស្សំ** = ភាពជាអ្នកប្រដៅលំបាក” ដូច្នេះ ក៏មាន ។ ភាវៈរបស់អ្នកប្រដៅលំបាកនោះ ឈ្មោះថា **ទោវ-ចស្សិយំ**; ពាក្យក្រៅអំពីនេះ មានពាក្យថា **ភាពរឹងទទឹងជាដើម** ជាពាក្យវេវចនៈរបស់ភាពជាអ្នកប្រដៅលំបាកនោះឯង ។

បទថា **“វិប្បដិកូលគាហិតា** = ភាពរឹងទទឹង” បានដល់ សេចក្តីប្រកាន់ដោយមិនស្របតាម; បុគ្គលឈ្មោះថា **វិបច្ចនីកសាតោ** (ពេញចិត្តខាងជំទាស់) ព្រោះអត្ថថា មានសេចក្តីត្រេកអរដោយការជំទាស់ ពោលគឺកាន់ខាងរឹងទទឹង ។ ពាក្យនេះជាឈ្មោះរបស់បុគ្គលអ្នកបានសេចក្តីសុខ ដោយពេញចិត្តថា “យើងបានធ្វើឱ្យគេគ្មានសំឡេង ដោយពាក្យដែលសំខាន់ត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ” ។ ភាវៈរបស់បុគ្គលអ្នកពេញចិត្តក្នុងផ្លូវរឹងទទឹងនោះ ឈ្មោះថា **វិបច្ចនីកសាតតា** = សេចក្តីពេញចិត្តផ្លូវរឹងទទឹង; ភាវៈរបស់មនុស្សអ្នកមិនអើពើ ដោយអំណាចនៃការមិនទទួលយកឱវាទ ឈ្មោះថា **អនាទរិយំ** = សេចក្តីមិនអើពើ; ពាក្យក្រៅពីនេះ មាន

ភាវៈនៃអ្នកមិនអើពើជាដើម ជាវេវចនៈរបស់សេចក្ដីមិនអើពើនោះឯង; ម្យ៉ាងទៀត អាការៈមិនអើពើ ឈ្មោះថា **អនាទរតា** * = ភាពជាអ្នកមិនអើពើ ។

ភាវៈមិនគោរព ដែលកើតឡើងដោយការមិននៅក្នុងអំណាចអប់រំរបស់គ្រូ ឈ្មោះថា **អគារវតា** = សេចក្ដីមិនគោរព ។ ភាវៈដែលមិនព្រមជឿស្ដាប់ ដែលកើតឡើង ដោយការមិននៅក្នុងអំណាចនៃការអប់រំ របស់បុគ្គលអ្នកមានសេចក្ដីចម្រើន (រៀមច្បង) ឈ្មោះថា **អប្បដិស្សវតា** = ការមិនទទួលស្ដាប់ ។

បទថា "**អយំ វុច្ចតិ** = នេះហៅថា" សេចក្ដីថា កិរិយានេះ គឺឃើញបែបនេះ ហៅថា **ទោវចស្សតា** = កិរិយារបស់អ្នកប្រដៅលំបាក ។

ក៏**ទោវចស្សតា**នេះ ពោលដោយសេចក្ដី បានដល់ ខន្ធ ៤ ដែលប្រព្រឹត្តទៅដោយអាការៈនោះ, ឬថា បានដល់ សង្ខារក្ខន្ធតែម្យ៉ាង ។ សូម្បីក្នុង**បាបមិត្តតា**ជាដើម ក៏មានន័យដូចគ្នានេះដែរ; ដ្បិតថា **ទោវចស្សតា** និង **បាបមិត្តតា**ជាដើម ឈ្មោះថាជាចេតសិកធម៌មួយចំណែក ក៏រមែងមិនមាន ។

ដែលឈ្មោះថា **អសទ្ធា** (មនុស្សមិនមានសទ្ធា) ព្រោះអត្ថថា សទ្ធារបស់បុគ្គលទាំងនោះមិនមាន, អធិប្បាយថា គេរមែងមិនជឿវត្ថុទាំងឡាយ មានព្រះពុទ្ធជាដើម ។ បទថា "**ទុស្សីលា** = មិនមានសីល" បានដល់ ដែលឈ្មោះថា កំហុសរបស់សីលមិនមានទេ គឺមនុស្សតើ ដែលមិនមានសីលនោះ ។ បទថា "**អប្បស្សុតា** =

---

* ច្បាប់ខ្លះថា អនាទិរិតា ។

មានសុតៈតិច” គឺវៀរចាកការសិក្សា ។

ដែលឈ្មោះថា **មច្ឆរិនោ** (មានសេចក្តីកំណាញ់) ព្រោះអត្ថថា មានសេចក្តីកំណាញ់ ៥ យ៉ាង ។ ដែលឈ្មោះថា **ទុប្បញ្ញា** = មានបញ្ញាថោកទាប ព្រោះអត្ថថា គ្មានបញ្ញា ។ ឈ្មោះថា **សេវនា** (ការសេព) ដោយអំណាចនៃការគប់រក ។ ការសេពដែលមានកម្លាំង ឈ្មោះថា **និសេវនា** = ការសេពគប់រកជាគ្នា ។ ការសេពដោយប្រការទាំងពួង ឈ្មោះថា **សំសេវនា** = ការសេពគប់ដោយល្អ ។ម្យ៉ាងទៀត ទ្រង់ផ្តើមបទដោយអំណាចនៃឧបសគ្គៈហើយ ត្រាស់សេវនៈសូម្បីទាំង ៣ បទ ឱ្យមកតែមួយបទ ។

បទថា “**ភជនា** = ការគប់” បានដល់ ការចូលទៅជិត ។

បទថា “**សម្ភជនា** = ការគប់រក” បានដល់ ការគប់ដោយចំណែកទាំងពួង ឈ្មោះថា ការគប់រក ។ ម្យ៉ាងទៀត ត្រាស់បន្ថែមបទដោយអំណាចនៃឧបសគ្គៈ ។ បទថា “**ភត្តិ** = សេចក្តីភក្តី” បានដល់ ការភក្តីយ៉ាងពិតប្រាកដ ។ បទថា “**សម្ភត្តិ** = ចងមេត្រីដោយភក្តីភាព” បានដល់ ការមានភក្តីភាពដោយចំណែកទាំងពួង ។ ម្យ៉ាងវិញទៀត ទ្រង់ផ្តើមបទដោយឧបសគ្គៈ ហើយត្រាស់ភក្តីភាពយ៉ាងមាំទាំទាំងពីរបទ ។

បទថា “**តំសម្បវង្កតា** = ភាពជាអ្នកមានកាយ និងចិត្តទោរទន់ទៅតាមបុគ្គលនោះ” បានដល់ ភាវៈដែលទោរទន់ទៅដោយកាយ និងចិត្តក្នុងបុគ្គលទាំងនោះ,

អធិប្បាយថា ការទ្រេតទៅ ការឱនទៅ ការចេញទៅក្រៅរបស់បុគ្គលនោះ ។ សូម្បី **និទ្ទេសនៃសោវចស្សតាទុកៈ** ក៏គប្បីជ្រាបដោយន័យផ្ទុយគ្នាតាមដែលពោលមកហើយចុះ ។

**ក្នុងនិទ្ទេសនៃអាបត្តិកុសលតាទុកៈ** បទថា “**បញ្ចបិ អាបត្តិក្ខន្ធា** = អាបត្តិទាំង ៥ កង” បានដល់ អាបត្តិទាំង ៥ កងនេះ តាមនិទ្ទេសនៃមាតិកា គឺ បារាជិក, សង្ឃាទិសេស, បាចិត្តិយៈ, បាដិទេសនីយៈ និងទុក្កដ ។ បទថា “**សត្តបិ អាបត្តិក្ខន្ធា** = អាបត្តិទាំង ៧ កង” បានដល់ អាបត្តិទាំង ៧ កងនេះ តាមនិទ្ទេសនៃវិន័យ គឺបារាជិក, សង្ឃាទិសេស, ថុល្លច្ច័យ, បាចិត្តិយៈ, បាដិទេសនីយៈ, ទុក្កដ និងទុព្ភាសិត ។

បណ្ដាភាពជាអ្នកឆ្លាតក្នុងអាបត្តិទាំងនោះ បញ្ញាដែលដឹងការកំណត់អាបត្តិទាំងនោះព្រមដោយវត្ថុ ឈ្មោះថា **អាបត្តិកុសលតា** = ភាពជាអ្នកឆ្លាតក្នុងអាបត្តិ; ចំណែកបញ្ញាដែលដឹងការកំណត់ ក្នុងការចេញចាកអាបត្តិព្រមនឹងកម្មវាចា ឈ្មោះថា **អាបត្តិវុដ្ឋានកុសលតា** = ភាពជាអ្នកឆ្លាតក្នុងការចេញចាកអាបត្តិ ។

**ក្នុងនិទ្ទេសនៃសមាបត្តិកុសលតា** ដែលឈ្មោះថា **សមាបត្តិ** ព្រោះជាគុណធម៌ដែលព្រះយោគីគប្បីចូល, ចំណែកបញ្ញាដែលដឹងការកំណត់អប្បនា ព្រមទាំងបរិកម្ម ឈ្មោះថា **សមាបត្តិកុសលតា** = ភាពជាអ្នកឆ្លាតក្នុងការចូលសមាបត្តិ; ឈ្មោះថា **សមាបត្តិវុដ្ឋានកុសលតា** (ភាពជាអ្នកឆ្លាតក្នុងការចេញចាកសមាបត្តិ)

ព្រោះការតាំងចិត្តថា "កាលព្រះចន្ទ ឬព្រះអាទិត្យ ឬក៏ដួងផ្កាយគោចរមកកាន់ទីនេះហើយ យើងនឹងចេញចាកសមាបត្តិ" មាននៅដោយបញ្ញាជាគ្រឿងកំណត់ការចេញក្នុងសម័យនោះមិនខុសភ្លាត់ឡើយ ។

**ក្នុងនិទ្ទេសនៃធាតុកុសលទុកៈ** បញ្ញាដែលដឹងការកំណត់ ការរៀន ការមនសិការ ការស្ដាប់ ការទ្រទ្រង់នូវធាតុ ១៨ ឈ្មោះថា **ធាតុកុសលតា** (ភាពជាអ្នកឆ្លាតក្នុងធាតុ) បញ្ញាដែលដឹងការរៀន និងការមនសិការធាតុទាំងនោះឯង ឈ្មោះថា **មនសិការកុសលតា** = ភាពជាអ្នកឆ្លាតក្នុងមនសិការ ។

**ក្នុងនិទ្ទេសនៃអាយតនកុសលតាទុកៈ** បញ្ញាដែលដឹងការកំណត់ ការរៀន ការមនសិការ ការស្ដាប់ និងការទ្រទ្រង់នូវអាយតនៈ ១២ ឈ្មោះថា **អាយតន-កុសលតា** = ភាពជាអ្នកឆ្លាតក្នុងអាយតនៈ ។

ម្យ៉ាងទៀត បណ្ដាកុសលតាសូម្បីទាំង ៣ នេះ គឺ (ធាតុកុសលតា មន-សិការកុសលតា និងអាយតនកុសលតា) សេចក្ដីដឹងទាំងពួង គឺការរៀន ការមនសិ-ការ ការស្ដាប់ ការចូលចិត្ត ការចាក់ធ្លុះ និងការពិចារណាឃើញ រមែងសមគួរ ។ បណ្ដាការដឹងទាំង ៦ នោះ ការស្ដាប់ ការរៀន ការពិចារណាឃើញ **ជាលោកិយ**, ការចាក់ធ្លុះ **ជាលោកុត្តរ**, ការចូលចិត្ត និងការមនសិការ **ជាមិស្សកៈ** គឺជាលោកិយក៏មាន ជាលោកុត្តរក៏មាន ។

បទថា **“អវិជ្ជាបច្ចយា សង្ខារា”** ជាដើម នឹងជាក់ច្បាស់ក្នុងបដិច្ចសមុ-ប្បាទវិភង្គ ។ បញ្ញាដែលដឹងថា “ធម៌នេះជាបច្ច័យដល់ធម៌នោះ” ឈ្មោះថា **បដិច្ច-សមុប្បាទកុសលតា** = ភាពជាអ្នកឆ្លាតក្នុងបដិច្ចសមុប្បាទ ៕

## សម្តែងអំពីឋានាឋានកុសលតា

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ឋានាឋានទុកៈ** ដូចតទៅ ៖

ពាក្យទាំង ២ នេះថា **“ហេតុបច្ចយា** = ជាហេតុ ជាបច្ច័យ” ជាពាក្យវេវចនៈរបស់គ្នានឹងគ្នា ។ ដ្បិតថា ចក្ខុបសាទជាហេតុ និងជាបច្ច័យដល់ចក្ខុវិញ្ញាណដែលធ្វើរូបឱ្យជាអារម្មណ៍ហើយកើតឡើង ។ម្យ៉ាងទៀត សោតបសាទជាដើម ក៏ជាហេតុ និងជាបច្ច័យដល់សោតវិញ្ញាណជាដើម, ពូជទាំងឡាយមានពូជស្វាយជាដើម ក៏ជាហេតុ និងជាបច្ច័យដល់ផ្លែស្វាយជាដើម ។

ក្នុងន័យទី ២ គប្បីជ្រាបសេចក្តីយ៉ាងនេះថា បទថា **“យេ ធម្មា** = ធម៌ណា” ជាពាក្យសម្តែងបច្ចយធម៌ដែលជាវិសភាគៈគ្នា ។ បទថា **“យេសំ យេសំ** = ពួកណាៗ” ជាពាក្យសម្តែងដល់បច្ចយសមុប្បន្នធម៌ ដែលជាវិសភាគៈគ្នា ។ បទថា **“ន ហេតូ ន បច្ចយា** = មិនជាហេតុ មិនជាបច្ច័យ” បានដល់ ចក្ខុបសាទមិនជាហេតុ មិនជាបច្ច័យដល់សោតវិញ្ញាណដែលកើតឡើងហើយ ធ្វើសំឡេងឱ្យជាអារម្មណ៍ ។ មួយទៀត សោតបសាទជាដើម មិនជាហេតុ មិនជាបច្ច័យដល់វិញ្ញាណ

ដ៏សេស; ឯពូជស្វាយជាដើម ក៏មិនជាហេតុ មិនជាបច្ច័យដល់ការកើតឡើងនៃដើមត្នោតជាដើមដែរ ៗ៕

## សម្តែងអំពីនិទ្ទេសនៃអាជ្ជវៈ និង មទ្ទវៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **អាជ្ជវៈ** និង **មទ្ទវទុកៈ** ដូចតទៅ ៖

បទថា **“នីចចិត្តតា** = ភាពជាអ្នកបន្ទន់ចិត្ត” នេះ ជាការផ្សេងគ្នាត្រឹមតែបទប៉ុណ្ណោះ; សេចក្តីនៃពាក្យនោះថា បុគ្គលឈ្មោះថា **នីចចិត្តោ** (ចេះបន្ទន់ចិត្ត) ព្រោះអត្ថថា មានចិត្តដាក់ចុះដោយមិនមាននូវមានះ ។ ភាវៈនៃបុគ្គលអ្នកចេះដាក់ចិត្ត ឈ្មោះថា **នីចចិត្តតា** = ភាពជាអ្នកចេះបន្ទន់ចិត្ត ។ ពាក្យដ៏សេសមានមកក្នុងបទភាជនីយ៍នៃចិត្តុជុកតា និងចិត្តមុទុតាន់ុះឯង ៕

## សម្តែងអំពីខន្តិទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ខន្តិទុកៈ** ដូចតទៅ ៖

ដែលឈ្មោះថា **ខន្តិ** ដោយអំណាចនៃការអត់ធន់; អាការៈនៃសេចក្តីអត់ធន់ ឈ្មោះថា **ខមនតា** (កិរិយាដែលអត់ទ្រាំ) ដែលឈ្មោះថា **អធិវាសនតា** (ការអត់ទ្រាំ) ព្រោះអត្ថថា ជាហេតុអត់ទ្រាំ, គឺជាហេតុលើកឡើងខាងលើខ្លួនទ្រាំទ្រនៅ មិនប្រឆាំង មិនជាសត្រូវហើយតាំងនៅ ។

ភាវៈនៃការមិនកាចឈ្មោះថា **អចណ្ឌិក្កំ** = ការមិនកាច; ពាក្យពោលដែលចេញមកអាក្រក់ ព្រោះលើកឡើងរកការត្រឹមត្រូវមិនបាន, ក្នុងបទថា **អនសុរោបោ** (មិនមាត់កាច) នេះ លោកហៅថា ការមិនមានមាត់អាក្រក់ ។ ឈ្មោះថា **អនសុរោបោ** (មិនមានមាត់កាច) ព្រោះមានភាពផ្ទុយគ្នានឹងមាត់កាចនោះឯង, បានដល់ វាចាដែលនិយាយចេញមកល្អ ។ ក្នុងអធិការនេះ ទ្រង់សម្តែងដល់ហេតុ ដោយផលូបចារន័យយ៉ាងនេះចុះ ។

បទថា "**អត្តមនតា ចិត្តស្ស** = ភាពរីករាយនៃចិត្ត" បានដល់ ភាពនៃចិត្តជាចិត្តរបស់ខ្លួនដោយអំណាចនៃសោមនស្ស, អធិប្បាយថា ភាវៈនៃចិត្តជារបស់ខ្លួននោះឯង, គឺការដែលចិត្តមិនព្យាបាទហើយ ៕

## សំដែងអំពីសោរច្ចនុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **សោរច្ចនុកៈ** ដូចតទៅ ៖

បទថា "**កាយិកោ អវិតិក្កមោ** = ការមិនកន្លងល្មើសផ្លូវកាយ" បានដល់កាយសុចរិត ៣ យ៉ាង ។ បទថា "**វាចសិកោ អវិតិក្កមោ** = ការមិនកន្លងល្មើសដោយវាចា" បានដល់ វចីសុចរិត ៤ យ៉ាង ។ ដោយបទថា "**កាយិកវាចសិកោ** = ផ្លូវកាយ និងផ្លូវវាចា" នេះ ទ្រង់មានបំណងកាន់យកអាជីវមដ្ឋកសីល (សីលមានអាជីវៈជាគម្រប់ ៨) ដែលតាំងឡើងដោយកាយ និងវាចា ។ បទថា "**ឥទំ វុច្ចតិ**

**វេសារជ្ជំ** = នេះហៅថា វេសារជ្ជៈ” នេះ ត្រាស់ឈ្មោះថា វេសារជ្ជទុកៈ ព្រោះសេចក្ដីស្ងប់ស្ងាត់ដោយល្អចាកបាប ។ បទថា “**សព្ពាមិ សីលសំវរា** = សូម្បីសីលសំវរៈទាំងអស់” នេះ ព្រះភគវាត្រាស់ដើម្បីទ្រង់សម្ដែងការកាន់សីលតាមផ្លូវចិត្ត ព្រោះបុគ្គលមិនមែនប្រព្រឹត្តអនាចារតាមផ្លូវកាយ និងវាចាតែប៉ុណ្ណោះទេ សូម្បីផ្លូវចិត្ត ក៏ត្រូវប្រព្រឹត្តបានដូចគ្នាដែរ ៕៚

## សម្ដែងអំពីសាខល្យទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **សាខល្យទុកៈ** ដូចតទៅ ៖

បទថា “**អណ្ឌកា** = ជាគំនួច” បានដល់ កើតជាគំនួចដោយវាចាបរិភាស និងចំអកចំអន់ដោយទោស ដូចពកដែលកើតឡើងត្រង់ដើមឈើដែលមានទោសដូច្នោះ ។

បទថា “**កក្កសា** = ជាកាកសំណល់” បានដល់ វាចាស្អុយ គឺវាចានោះ ជាកាកសំណល់, ដូចជាដើមឈើដែលស្អុយរមែងជាកាកសំណល់ ជាកំទេចដែលហូរចេញមកដូច្នោះដែរ, វាចាដែលជាកាកសំណល់នោះ ហាក់បីដូចជាចូលទៅខ្ទាំងខ្ទប់ត្រចៀក; ដោយហេតុនោះ ទើបត្រាស់ថា “ជាកាកសំណល់” ។

បទថា “**បរកដុកា** = ក្ដៅក្រហាយចំពោះអ្នកដទៃ” បានដល់ ក្ដៅក្រហាយមិនជាទីពេញចិត្ត ឱ្យកើតទោសដល់អ្នកដទៃ ។ បទថា “**បរាភិសជ្ជនី** = ទាញអ្នកដទៃទុក” បានដល់ ដូចជាមែកឈើមានបន្លាចាក់ស្បែកពួកអ្នកដទៃ មិន

ឱ្យទៅ, សូម្បីគេប្រាថ្នានឹងទៅ ក៏ធ្វើឱ្យជាប់នៅ រមែងមិនឱ្យទៅដូច្នោះ ។

បទថា **“កោធសាមន្តា = ពន្យុះឱ្យក្រោធ”** បានដល់ វាចាជិតចំពោះសេចក្តីក្រោធ ។ បទថា **“អសមាធិសំវត្តនិកា = មិនប្រព្រឹត្តទៅដើម្បីសមាធិ”** បានដល់ មិនប្រព្រឹត្តទៅដើម្បីបានអប្បនាសមាធិ ឬឧបចារសមាធិ; ពាក្យទាំងអស់នេះ ជាវេវចនៈរបស់វាចាដែលប្រព្រឹត្តទៅមួយអន្លើដោយទោស មានប្រការដូច្នេះ ។

បទថា **“តថារូបឹ វាចំ បហាយ = លះវាចាដូច្នោះចេញ”** នេះ ត្រាស់ទុកដើម្បីសម្តែងថា វាចាទន់ភ្លន់ សូម្បីប្រព្រឹត្តទៅក្នុងចន្លោះរបស់អ្នកមិនបានលះផរុសវាចាហើយតាំងនៅ ក៏ឈ្មោះថា វាចាមិនទន់ភ្លន់នោះដែរ ។

បទថា **“នេឡា = គ្មានទោស”** អធិប្បាយថា ទោសត្រាស់ហៅថា ឯឡំ, ទោសរបស់វាចានោះមិនមាន ព្រោះហេតុដូច្នោះ វាចានោះ ទើបឈ្មោះថា **នេឡា**, អធិប្បាយថា មិនមានទោស; ដូចសីល[១២៦] (ដែលមិនមានទោស) ដែលត្រាស់ទុកក្នុងពាក្យនេះថា **“នេឡង្គោ សេតបច្ឆាទោ”**[១២៧] ជាដើម ប្រែថា រថ គឺអត្តភាពមានសីលដែលរកទោសមិនបាន មានការប្រដាប់ដោយបរិក្ខារជាដើម ។

បទថា **“កណ្ណសុខា = ស្រួលដល់ត្រចៀក”** បានដល់ សប្បាយដល់ត្រចៀក

---

[១២៦] សំ. សឡា. ។

[១២៧] ខុ. ខុ. ។

ទាំងពីរ ព្រោះជាវាចាដែលពីរោះដោយព្យញ្ជនៈ, គឺមិនធ្វើការចាក់ដោតត្រចៀកឱ្យកើតឡើងដូចការចាក់ដោយម្ជុល ។

វាចាណា មិនញុំាងសេចក្តីក្រោធឱ្យកើត រមែងញុំាងសេចក្តីស្រឡាញ់ឱ្យកើតក្នុងសរីរៈ ព្រោះជាវាចាពីរោះដោយអត្ថ ព្រោះហេតុនោះ វាចានោះទើបឈ្មោះថា **បេមនិយា** = វាចាពីរោះ ។

វាចាណា ទៅកាន់ហឫទ័យ មិនមានអ្វីរាំងស្ទះ ចូលទៅកាន់ចិត្តបានដោយងាយ ព្រោះហេតុនោះ វាចានោះទើបឈ្មោះថា **ហទយង្គមា** = វាចាគួរឱ្យចាប់ចិត្ត ។

វាចាណា ជាពាក្យមាននៅក្នុងក្រុង ព្រោះជាវាចាបរិបូរណ៍ដោយគុណ ព្រោះហេតុនោះ វាចានោះទើបឈ្មោះថា **បោរី** = វាចារបស់អ្នកក្រុង, វាចាដែលពោលហៅថា “ម្នាលកុមារីសោភា ដូចនារីអ្នកមានវឌ្ឍនធម៌ដ៏ល្អក្នុងបុរី ព្រោះហេតុនោះ សូម្បីវាចានោះក៏ឈ្មោះថា **បោរី** ដែរ, វាចានេះឯងមានដល់អ្នកទីក្រុង ព្រោះហេតុនោះ សូម្បីវាចានេះក៏ឈ្មោះថា **បោរី**; អធិប្បាយថា ជាពាក្យពេចន៍របស់អ្នកក្រុង; ពិតណាស់ ជនអ្នកទីក្រុង មានពាក្យពេចន៍ដ៏សមគួរ, រមែងហៅបុគ្គលដែលល្មមជាបិតាថា “បិតា” រមែងហៅបុគ្គលគួរជាបងប្រុស ប្អូនប្រុសថា “បងប្រុស ប្អូនប្រុស” ជាដើម ។

វាចាណា មានសភាពបែបនេះ រមែងជាទីស្រឡាញ់ពេញចិត្តដល់ជនជាច្រើន ព្រោះហេតុនោះ វាចានោះទើបឈ្មោះថា **ពហុជនកន្តា** = វាចាដែលពេញចិត្តនៃជនដ៏ច្រើន ។

វាចាណាជាទីញុំាងចិត្តឱ្យរីករាយ គឺធ្វើសេចក្ដីចម្រើននៃចិត្តដល់ជនចំនួនច្រើន ដោយភាពជាវាចាដែលចម្រើនចិត្តរបស់ជនពួកច្រើននោះឯង ហេតុនោះ វាចានោះទើបឈ្មោះថា **ពហុជនមនាបា** = ជាវាចាដែលចម្រើនចិត្តដល់ជនច្រើន ។

បទថា "**យា តត្ថ**" បានដល់ វាចាណាក្នុងបុគ្គលនោះ ។

បទថា "**សណ្ហវាចតា** = ភាពជាអ្នកមានវាចាទោរទន់" បានដល់ ភាពជាអ្នកមានវាចាស្រឡះស្រឡំ ។

បទថា "**សខិលវាចតា** = ភាពជាអ្នកមានវាចាផ្អែមល្ហែម" បានដល់ វាចាទន់ភ្លន់ ។ បទថា "**អផរុសវាចតា** = ភាពជាអ្នកមានវាចាមិនគ្រោតគ្រាត" បានដល់ វាចាមិនរឹងត្អឹង ៕

## សម្ដែងអំពីបដិសណ្ឋារទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **បដិសណ្ឋារទុកៈ** ដូចតទៅ ៖

បទថា "**អាមិសបដិសណ្ឋារោ** = អាមិសបដិសណ្ឋារៈ" បានដល់ ឱកាស (បែកបាក់សាមគ្គី) របស់ជនពួកដទៃជាមួយនឹងខ្លួន ព្រោះការមិនបានអាមិស

រមែងបិទជិតហើយដោយប្រការណា, ការក្រោកទទួលភ្ញៀវ ដោយអាមិស (បុគ្គលគប្បីបិទ) ដោយប្រការនោះ ។

បទថា **"ធម្មប្បដិសណ្ឋារោ** = ធម្មបដិសណ្ឋារៈ" បានដល់ ឱកាសរបស់ពួកជនដទៃទើនឹងខ្លួន ព្រោះការមិនបានធម៌ រមែងបិទជិតហើយដោយប្រការណា, ការក្រោកទទួលភ្ញៀវដោយធម៌ (បុគ្គលគប្បីបិទ) ដោយប្រការនោះ ។

បទថា **"បដិសណ្ឋារកោ ហោតិ** = បុគ្គលអ្នកមានបដិសណ្ឋារៈ" សេចក្ដីថា ចន្លោះរបស់លោកសន្និវាសមាន ២ ប៉ុណ្ណោះ, បុគ្គលអ្នកបដិសណ្ឋារៈ (អ្នកបិទចន្លោះ) ទាំងពីរនោះ គឺបុគ្គលអ្នកបដិសណ្ឋារៈនោះ រមែងចុកប្រហោង គឺការធ្វើជានិច្ចដោយបដិសណ្ឋារៈទាំងពីរនេះ គឺដោយអាមិសបដិសណ្ឋារៈ ឬដោយធម្មបដិសណ្ឋារៈ ។ ក្នុងអធិការនេះ គប្បីជ្រាបកថានេះ ចាប់តាំងអំពីដើម ៖

មែនពិត ភិក្ខុអ្នកធ្វើបដិសណ្ឋារៈ ឃើញអាគន្តុកភិក្ខុកំពុងមក គប្បីក្រោកឡើងទទួលបាត្រចីវរ, ប្រគេនអាសនៈ, បក់ដោយផ្លិតស្លឹកត្នោត*, លាងជើងហើយលាបប្រេង, កាលបើមានទឹកដោះថ្លា និងទឹកអំពៅ ក៏គប្បីប្រគេនឱ្យជាភេសជ្ជៈ, គប្បីអើពើសួរដោយទឹកផឹក, គប្បីចាត់ចែងទីសំណាក់អាស្រ័យ; ដោយអាការៈយ៉ាងនេះ ឈ្មោះថា អាមិសបដិសណ្ឋារៈដែលភិក្ខុត្រូវធ្វើដោយឯកទេស ។ម្យ៉ាងទៀត ក្នុងវេលាល្ងាច កាលបើភិក្ខុខ្ចីជាងមិនមកកាន់ទីបម្រើរបស់ខ្លួននោះឯង គួរ

---

* ពាក្យនេះគ្រាន់តែជាមុខន័យប៉ុណ្ណោះ (អត្ថនោមត៌) ។

ទៅកាន់សំណាក់របស់ភិក្ខុអាគន្តុកៈ គប្បីអង្គុយហើយ មិនសួរបញ្ហាដែលមិនមែនជាវិស័យ គប្បីសួរបញ្ហាក្នុងវិស័យរបស់លោក, គឺមិនសួរថា "ពួកលោកឈ្លាសនិកាយណា" ដូច្នេះទេ, គប្បីសួរថា "អាចារ្យ និងឧបជ្ឈាយ៍របស់លោក ជំនាញក្នុងគម្ពីរណា ?" ហើយសួរបញ្ហាក្នុងឋានៈល្មមសមគួរ ។ បើលោកអាចឆ្លើយ បានខនោះ ជាការល្អ; បើលោកមិនអាចឆ្លើយបាន ក៏គប្បីឆ្លើយដោយខ្លួនឯង; ដោយអាការៈយ៉ាងនេះ ឈ្មោះថា **ធម្មបដិសណ្ឋារៈ ដែលភិក្ខុត្រូវធ្វើដោយឯកទេស**។

បើលោកនៅក្នុងសំណាក់របស់ខ្លួន, គប្បីនាំលោកត្រាច់ទៅបិណ្ឌបាតជានិច្ច; បើលោកប្រាថ្នានឹងទៅ, ព្រឹកឡើងក៏គប្បីនាំលោកទៅក្នុងទិស ដែលគួរត្រាច់ទៅបិណ្ឌបាតក្នុងស្រុកមួយហើយគប្បីបញ្ជូនឱ្យត្រឡប់វិញ ។ បើពួកភិក្ខុឱ្យគេនិមន្តក្នុងទិសដទៃ ក៏គប្បីនាំភិក្ខុនោះអ្នកដែលប្រាថ្នាទៅផងចុះ, កាលបើមិនប្រាថ្នានឹងទៅដោយគិតថា "ទិសនេះមិនគួរដល់យើង" ដូច្នេះ ក៏គប្បីបញ្ជូនពួកភិក្ខុដ៏សេសឱ្យទៅហើយនាំលោកត្រាច់បិណ្ឌបាត, អាមិសដែលខ្លួនបានហើយគួរប្រគេនលោក; យ៉ាងនេះ ឈ្មោះថា **អាមិសបដិសណ្ឋារៈ** ដែលភិក្ខុត្រូវធ្វើ ។

***សួរថា*** អាមិសដែលខ្លួនបានហើយ ភិក្ខុអ្នកធ្វើបដិសណ្ឋារៈ គប្បីប្រគេនដល់នរណាមុន ?

ឆ្លើយថា គួរប្រគេនដល់ភិក្ខុអាគន្តុកៈមុន; បើភិក្ខុអ្នកអាពាធ ឬមិនទាន់មានវស្សាទេ ក៏គប្បីប្រគេនភិក្ខុសូម្បីអ្នកអាពាធជាដើមទាំងនោះមុនចុះ, គប្បី

ប្រគេនដល់អាចារ្យ និងឧបជ្ឈាយ៍, គប្បីប្រគេនដល់ភិក្ខុអ្នកចែកភណ្ឌៈ, តែភិក្ខុអ្នកបំពេញសារាណីយធម៌ គប្បីប្រគេនដល់ភិក្ខុទាំងឡាយ អ្នកមកហើយសូម្បីមួយរយដង មួយពាន់ដង ចាប់ផ្តើមពីថេរាសនៈទៅ, ចំណែកភិក្ខុអ្នកធ្វើបដិសណ្ឋារៈ គប្បីឱ្យដល់ភិក្ខុអ្នកមិនទាន់បាន; ចេញទៅស្រុកហើយឃើញភិក្ខុ ឬភិក្ខុនីជរា ឬក៏អនាថា (មិនមានទីពឹង) ក៏គប្បីប្រគេនសូម្បីដល់លោកទាំងនោះ ។ ក្នុងខនោះ មានរឿងជាឧទាហរណ៍ថា ៖

បានឮមកថា កាលបើពួកចោរប្លន់ស្រុកឈ្មោះថា **គុត្តសាលា** ក្នុងខណៈនោះ៧ ឯង ព្រះខីណាស្រពថេរីមួយរូបចេញចាកនិរោធហើយ ឱ្យភិក្ខុនីក្រមុំកាន់យកភណ្ឌៈហើយទៅកាន់ផ្លូវជាមួយនឹងមហាជន លុះដល់ទ្វារនៃស្រុក**នកុលនគរ** ក៏អង្គុយជិតគល់ឈើក្នុងវេលាថ្ងៃត្រង់, ក្នុងសម័យនោះ ព្រះមហានាគត្ថេរលោកនៅក្នុងវត្ត**កាឡវល្លិមណ្ឌប** ត្រាច់ទៅបិណ្ឌបាតក្នុងស្រុកនកុលនគរ មកឃើញព្រះថេរី ទើបសួរអើពើដោយភត្ត; ព្រះថេរីតបថា “ខ្ញុំព្រះករុណាមិនមានបាត្រទេ” ព្រះថេរៈបានឱ្យភត្ត ព្រមទាំងបាត្រថា “និមន្តនាងឆាន់ដោយបាត្រនេះ” ; ព្រះថេរីធ្វើភត្តកិច្ចស្រេច លាងបាត្រថ្វាយព្រះថេរៈហើយពោលថា “លោកម្ចាស់នឹងលំបាក ដោយភិក្ខាចារត្រឹមតែមួយថ្ងៃប៉ុណ្ណោះ, តាំងពីថ្ងៃនេះទៅ ឈ្មោះថា សេចក្តីលំបាក ដោយភិក្ខាចាររបស់លោកនឹងមិនមានឡើយ” ។ តាំងពីថ្ងៃនោះមកឈ្មោះថា បិណ្ឌបាតមានតម្លៃតិចជាងមួយកហាបណៈ មិនបានកើតឡើងដល់ព្រះ

ថេរៈឡើយ; នេះឈ្មោះថា **អាមិសបដិសណ្ឋារៈ** ។

ឯភិក្ខុនឹងធ្វើនូវបដិសណ្ឋារៈនេះ គួរតាំងនៅក្នុងចំណែកសង្គ្រោះប្រាប់កម្ម-ដ្ឋានដល់ភិក្ខុនោះ, គប្បីប្រាប់ធម៌, គប្បីកម្ចាត់សេចក្ដីសង្ស័យ, គប្បីធ្វើករណីយកិច្ចដែលកើតឡើង, គប្បីឱ្យអព្ភាន, វុដ្ឋានៈ, មានត្ត និងបរិវាស; អ្នកគួរបព្វជ្ជា ក៏គប្បីឱ្យបព្វជ្ជា, អ្នកគួរឧបសម្បទ ក៏គប្បីឱ្យឧបសម្បទ ។ ការធ្វើកម្មវាចា សូម្បីដល់ភិក្ខុនីអ្នកចង់ឧបសម្បទ ក្នុងសំណាក់របស់ខ្លួនក៏គួរ; នេះឈ្មោះថា **ធម្មបដិសណ្ឋារៈ** ។

ភិក្ខុអ្នកធ្វើបដិសណ្ឋារៈទាំងពីរ រមែងញ៉ាំងលាភដែលមិនទាន់កើតឡើង ឱ្យកើតឡើង, រមែងញ៉ាំងលាភដែលកើតឡើងហើយឱ្យមាំទាំ, រមែងរក្សាជីវិតរបស់ខ្លួនក្នុងឋានៈដែលត្រូវតស៊ូ (គឺប្រកបដោយភ័យយ៉ាងកាចសាហាវ) បាន, ដូចព្រះថេរៈ (អ្នកធ្លាក់នៅក្នុងឋានៈដែលត្រូវតស៊ូ) ប្រើដៃដែលចាប់បាត្រនោះឯង កាន់ភត្តដ៏លើស កាយបាយក្នុងបាត្រទាំងឡាយ ថ្វាយចំពោះព្រះបាទ**ចោរនាគរាជ**ដូច្នោះ * ។

ចំណែកក្នុងការញ៉ាំងលាភ ដែលនៅមិនទាន់បានឱ្យកើតឡើង បណ្ឌិតគប្បីសម្ដែងដល់រឿងការថ្វាយមហាភេសជ្ជៈ ដែលព្រះមហានាគលោកចៀសចេញពីត្រើយនេះ ទៅកាន់ត្រើយនោះ ហើយទទួលសេចក្ដីអនុគ្រោះក្នុងសំណាក់របស់ព្រះថេរៈមួយរូប បានត្រឡប់មកតាំងនៅក្នុងរាជសម្បត្តិទៀត ទ្រង់ប្រព្រឹត្តឱ្យដំណើរ

---

* បានឮថា ព្រះបាទចោរនាគរាជកាចសាហាវណាស់ ។

ការទៅក្នុងលាននៃវត្ត**សេតម្ពវិហារ** រហូតដល់អស់ព្រះជន្ម ។ ក្នុងការធ្វើលាភដែលកើតឡើងហើយឱ្យជាថាវរៈ គប្បីសម្តែងរឿងដែលពួកចោរបានទទួលបដិ-សណ្ឋារៈ ពីដៃរបស់**ព្រះទីឃភាណកអភយត្ថេរ** ហើយមិនប្លន់ លួចភណ្ឌៈក្នុងចេតិយបព៌តចុះ ៕៚

## សម្តែងអំពីឥន្ទ្រិយេសុ អគុត្តទ្វារតានុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃភាពជាអ្នកមិនសង្រួមក្នុងឥន្ទ្រិយដូចតទៅៈ

បទថា "**ចក្ខុនា រូបំ ទិស្វា** = ឃើញរូបហើយដោយចក្ខុ" បានដល់ឃើញរូបដោយចក្ខុវិញ្ញាណដែលអាចក្នុងការឃើញរូប ដែលមានវោហារបានហើយថា "**ចក្ខុ**" ដូច្នេះ ដោយអំណាចជាហេតុ ។ ក៏ព្រះបោរាណាចារ្យទាំងឡាយពោលទុកថា "ចក្ខុរមែងមិនឃើញរូប, ព្រោះចក្ខុមិនមែនចិត្ត; ចិត្តក៏ឃើញរូបមិនបាន, ព្រោះចិត្តមិនមែនចក្ខុ; តែបុគ្គលឃើញបាន ដោយចិត្តដែលមានបសាទវត្ថុ ដោយការខ្ទប់គ្នានៃទ្វារ និងអារម្មណ៍, ក៏កថានេះដូច្នេះ ឈ្មោះថា **សសម្ភារកថា** ដូចក្នុងប្រយោគមានជាអាទិ៍ថា 'គេបាញ់ដោយធ្នូ', ព្រោះហេតុដូច្នោះ ក្នុងអធិការនេះទើបមានពាក្យអធិប្បាយថា '**ឃើញរូបដោយចក្ខុវិញ្ញាណ**" ។

បទថា "**និមិត្តគ្គាហី** = អ្នកកាន់យកនិមិត្ត" បានដល់ រមែងកាន់យកនិមិត្តថា ជាស្រី ជាប្រុស ឬនិមិត្តដែលជាទីតាំងនៃកិលេស មានសេចក្តីសម្គាល់ថាល្អ

ជាដើម ដោយអំណាចនៃឆន្ទរាគៈ, មិនតាំងនៅក្នុងរូបដែលគ្រាន់តែជាការឃើញប៉ុណ្ណោះ ។

បទថា **"អនុព្យញ្ជនគ្គាហី** = ជាអ្នកកាន់យកដោយអនុព្យញ្ជនៈ" បានដល់កាន់យកកិរិយាអាការៈ ដែលផ្សេងដោយដៃជើង ការញញឹម ការសើច ការនិយាយ ការក្រឡេកមើល ការងាកមើលឆ្វេងស្តាំជាដើម ដែលបានវោហារថា "អនុព្យញ្ជនៈ" ព្រោះជាគ្រឿងប្រាកដរបស់កិលេសទាំងឡាយ **គឺព្រោះនឹងធ្វើកិលេសឱ្យប្រាកដ**។

បទថា **"យត្វាធិករណមេនំ** = ព្រោះហេតុដែលមិនសង្រួមនូវចក្ខុន្ទ្រិយណា" សេចក្តីថា ធម៌ទាំងឡាយមានអភិជ្ឈាជាដើមនេះ គប្បីគ្របសង្កត់ គឺគប្បីជាប់តាម គប្បីរួបរឹតបុគ្គល អ្នកមានចក្ខុន្ទ្រិយមិនសង្រួមនេះ ដោយទ្វារគឺ **សតិ** គឺជាអ្នកមិនមានចក្ខុទ្វារដែលបិទរាំងហើយជាប្រក្រតីនេះ ព្រោះហេតុអ្វី ? ព្រោះហេតុដែលមិនសង្រួមនូវចក្ខុន្ទ្រិយណា ។

បទថា **"តស្ស សំវរាយ ន បដិបជ្ជតិ** = មិនបដិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ" សេចក្តីថា រមែងមិនបដិបត្តិដើម្បីប្រយោជន៍ដល់ការបិទនូវចក្ខុន្ទ្រិយនោះ ដោយទ្វារ គឺសតិ, ក៏បុគ្គលយ៉ាងនេះឯង ហៅថា អ្នកមិនរក្សាចក្ខុន្ទ្រិយ, មិនសម្រេចការសង្រួមក្នុងចក្ខុន្ទ្រិយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អ្នកមិនសម្រេចការសង្រួមក្នុងចក្ខុន្ទ្រិយនោះ ថា សំវរៈក្តី អសំវរៈក្តី រមែងមិនមានក្នុងចក្ខុន្ទ្រិយ ក៏ពិតមែន, ព្រោះថា សតិ ឬការ

វង្វេងសតិរមែងកើតឡើង ព្រោះអាស្រ័យចក្ខុបសាទ ក៏មិនមែន ។ តែថាក្នុងកាលណា រូបារម្មណ៍មិនមកដល់គន្លងនៃចក្ខុ, ក្នុងកាលនោះ កាលបើភវង្គចិត្តកើតរលត់ ២ វារៈហើយ កិរិយាមនោធាតុ ក៏ញុំាងអាវជ្ជនកិច្ចឱ្យសម្រេចការកើតរលត់, លំដាប់នោះ ចក្ខុវិញ្ញាណក៏ញុំាងទស្សនកិច្ចឱ្យសម្រេចការកើតរលត់, បន្ទាប់ពីនោះ វិបាក-មនោធាតុ ក៏ញុំាងសម្បដិច្ឆន្នកិច្ចឱ្យសម្រេចការកើតរលត់, បន្ទាប់មក វិបាកា-ហេតុកមនោវិញ្ញាណធាតុ ក៏ញុំាងសន្តីរណកិច្ចឱ្យសម្រេចការកើតរលត់, បន្ទាប់មកទៀត មនោវិញ្ញាណធាតុដែលជាអហេតុកកិរិយា ក៏ញុំាងវោដ្ឋវនកិច្ចឱ្យសម្រេចការកើតរលត់, ក្រោយពីនោះមក ជវនចិត្តរមែងស្ទុះទៅ; សំវរៈក្តី អសំវរៈក្តី នឹងមាននៅសូម្បីក្នុងសម័យនៃភវង្គចិត្តនោះ ក៏មិនមែន, ឬនឹងមាននៅក្នុងសម័យនៃអាវជ្ជនចិត្តជាដើម សម័យណានីមួយក៏មិនមែន, តែក្នុងខណៈនៃជវនចិត្ត ភាពជាអ្នកទ្រុស្តសីលខ្លះ ការភ្លេចសតិខ្លះ ការមិនដឹងខ្លះ ការមិនអត់ធន់ខ្លះ ការខ្ជិលច្រអូសខ្លះ រមែងកើតឡើង, អសំវរៈរមែងមាន ។ ក៏អសំវរៈនោះយ៉ាងនេះ ទើបត្រាស់ហៅថា អសំវរៈក្នុងចក្ខុន្ទ្រិយ ។ ព្រោះហេតុអ្វី ? ព្រោះកាលបើអសំវរៈនោះកំពុងមាន សូម្បីទ្វារក៏មិនបានឃុំគ្រង សូម្បីភវង្គ វីថិចិត្ត មានអាវជ្ជនចិត្តជាដើម រមែងជាការដែលមិនបានឃុំគ្រង; ដូចជាអ្វី ? ដូចជាទ្វារទាំង ៤ ទិសរបស់ព្រះនគរដែលគេមិនបានបិទទុកដល់ខាងក្នុងផ្ទះ ស៊ុំទ្វារ និងបន្ទប់ជាដើម នឹងបិទទុកយ៉ាងល្អ ក៏ដោយ, ក៏នៅតែមិនបានរក្សាដដែល មិនបានឃុំគ្រងវត្ថុទាំងអស់ទុកខាងក្នុងព្រះនគរ

ឡើយ; ព្រោះពពួកចោរចូលទៅតាមទ្វារនគរ គប្បីធ្វើតាមប្រាថ្នាបាន យ៉ាងណា, កាលបើការទ្រុស្តសីលជាដើម កើតឡើងហើយក្នុងជវ័ន កាលបើអសំវរៈនោះកំពុងតែមាន រមែងជាការដែលមិនបានឃុំគ្រង សូម្បីទ្វារ, សូម្បីភវង្គ, សូម្បីវីថិចិត្ត មានអាវជ្ជនៈជាដើម ក៏យ៉ាងនោះដែរ ។ សូម្បីពាក្យមានជាអាទិ៍ថា "ស្តាប់សំឡេងហើយដោយសោតៈ" ដូច្នេះ ក៏ន័យនេះដែរ ។

បទថា "**យា ឥមេសំ** = ឥន្ទ្រិយទាំងនេះណា" សេចក្តីថា ការមិនឃុំគ្រងឯណា, ការមិនរក្សាឯណា, ការមិនសង្រួមឯណានៃឥន្ទ្រិយទាំង ៦ នេះ អធិប្បាយថា ការមិនឃាំង ការមិនបិទឥន្ទ្រិយទាំង ៦ នេះ ៕

## សម្តែងអំពីភោជនេ អមត្តញ្ញុតានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃភោជនេ **អមត្តញ្ញុតា** ដូចតទៅ ៖

បទថា "**ឥធេកច្ចោ** = បុគ្គលពួកខ្លះក្នុងលោកនេះ" បានដល់ បុគ្គលពួកខ្លះ ក្នុងសត្វលោកនេះ ។ បទថា "**អប្បដិសង្ខា** = មិនពិចារណា" បានដល់ មិនដឹង គឺមិនពិចារណាដោយបញ្ញាជាគ្រឿងពិចារណា ។ បទថា "**អយោនិសោ** = ដោយមិនត្រូវទំនង" បានដល់ ដោយមិនមែនជាឧបាយ ។ បទថា "**អាហារំ** = អាហារ" បានដល់ វត្ថុដែលគប្បីលេបចូលទៅ មានបាយ និងទឹកជាដើម ។ បទថា "**អាហារេតិ** = បរិភោគ" បានដល់ រមែងបរិភោគលេបចូលទៅ ។ បទថា "**ទវាយ** =

ដើម្បីនឹងលេង” ជាដើមនេះ ត្រាស់ទុកដើម្បីសម្ដែងដល់វត្ថុដែលមិនមែនជាឧបាយ; ពិតមែន បុគ្គលកាលបើបរិភោគអាហារដោយមិនមែនជាឧបាយ រមែងបរិភោគ ដើម្បីលេង ដើម្បីស្រវឹង ដើម្បីតាក់តែង * ឬដើម្បីការប្រដាប់ *, មិនឈ្មោះថា បរិភោគព្រោះអាស្រ័យឧបាយដែលជាប្រយោជន៍នេះឡើយ ។

បទថា “**យា តត្ថ អសន្តុដ្ឋិតា** = ភាពជាអ្នកមិនសន្តោស” បានដល់ កិរិយាដែលមិនពេញចិត្ត គឺការមិនចូលចិត្តក្នុងការបរិភោគអាហារ ដោយមិនមែន ជាឧបាយនោះឯង ។ បទថា “**អមត្តញ្ញុតា** = ភាពជាអ្នកមិនដឹងប្រមាណ” បានដល់ ភាពនៃខ្លួនជាអ្នកមិនដឹងនូវប្រមាណ, គឺការមិនដឹងនូវប្រមាណ ពោលគឺការពេញចិត្ត ។

បទថា “**អយំ វុច្ចតិ** = នេះហៅថា” សេចក្ដីថា ការប្រព្រឹត្តទៅ ដោយ អំណាចនៃការបរិភោគអាហារដែលមិនពិចារណា នេះឈ្មោះថា **ភោជនេ អមត្ត-ញ្ញុតា** = ភាពជាអ្នកមិនដឹងនូវប្រមាណក្នុងការបរិភោគ ៕ ៕

## សម្ដែងអំពីឥន្ទ្រិយេសុ គុត្តទ្វារតាទុកនិទ្ទេស

នឹងវិនិច្ឆ័យក្នុងនិទ្ទេសនៃការឃុំគ្រងទ្វារក្នុងឥន្ទ្រិយ ដូចតទៅ ៖

---

* បាលីថា **មណ្ឌនាយ** = ដើម្បីប្រដាប់ ។

* **វិភូសនាយ** = ដើម្បីការស្អិតស្អាង ។

បទថា “ **ចក្ខុនា** = ដោយចក្ខុ” ជាដើម គប្បីជ្រាបដោយន័យ ដែលពោលហើយនោះចុះ ។ បទថា “**ន និមិត្តគ្គាហី ហោតិ** = ជាអ្នកមិនកាន់យកនិមិត្ត” បានដល់ រមែងមិនកាន់យកនិមិត្ត មានប្រការតាមដែលបានពោលហើយដោយអំណាចនៃឆន្ទរាគៈ ។ សូម្បីបទដ៏សេស គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដែលបានពោលហើយនោះ មានប្រការដូច្នេះចុះ ។

ក៏ពាក្យដែលខ្ញុំពោលទុកខាងក្រោយថា “កាលបើភាពជាអ្នកទ្រុស្តសីលជាដើម កើតឡើងក្នុងជវនចិត្ត កាលបើអសំវរៈនោះកំពុងតែមាន សូម្បីទ្វារក៏រមែងជាការដែលមិនបានឃុំគ្រង, សូម្បីភវង្គ សូម្បីវីថិចិត្តទាំងឡាយ មានអាវជ្ជនៈជាដើម ក៏ជាការដែលមិនបានឃុំគ្រង” យ៉ាងណា, ក្នុងអធិការនេះ ក៏យ៉ាងនោះដែរ; កាលបើសីលជាដើមកើតឡើងក្នុងជវនចិត្តនោះ សូម្បីទ្វារក៏រមែងជាការដែលបានឃុំគ្រងហើយ, សូម្បីភវង្គ សូម្បីវីថិចិត្តទាំងឡាយមានអាវជ្ជនៈជាដើម ក៏រមែងជាការដែលបានឃុំគ្រងហើយ; ដូចជាអ្វី ? ដូចជាទ្វារព្រះនគរដែលបិទល្អហើយ ខាងក្នុងផ្ទះជាដើមមិនបានបិទទុក ក៏ពិតមែន, ក៏ប៉ុន្តែថា សម្ភារវត្ថុទាំងអស់ខាងក្នុងព្រះនគរ ក៏រមែងជាការដែលរក្សាល្អហើយ ឃុំគ្រងល្អហើយដែរ, ព្រោះកាលបើទ្វារព្រះនគរបិទហើយ ពួកចោរក៏រមែងចូលទៅមិនបាន យ៉ាងណា, កាលបើសីលជាដើម កើតក្នុងជវនចិត្តហើយ សូម្បីទ្វារក៏ជាការដែលបានឃុំគ្រងហើយ សូម្បីភវង្គ សូម្បីវីថិចិត្តទាំងឡាយមានអាវជ្ជនៈជាដើមក្តី ក៏រមែងជាការដែលបានឃុំគ្រង

ហើយ យ៉ាងនោះដែរ; ព្រោះហេតុដូច្នោះ សំវរៈសូម្បីកើតនៅក្នុងជវនចិត្ត ក៏ព្រះភគវាត្រាស់ថា “សំវរៈក្នុងចក្ខុន្ទ្រិយដែរ” ។

សូម្បីក្នុងបទមានជាអាទិ៍ថា បានឮសំឡេងដោយសោតៈ ក៏ន័យនេះដែរ៕

## សម្តែងអំពីភោជនេ មត្តញ្ញុតានិទ្ទេស

នឹងវិនិច្ឆ័យក្នុងនិទ្ទេសនៃភាពជាអ្នកដឹងប្រមាណ ដូចតទៅ ៖

បទថា “**បដិសង្ខា យោនិសោ អាហារំ អាហារេតិ** = ពិចារណាដោយត្រឹមត្រូវ ទើបបរិភោគអាហារ” បានដល់ ដឹងដោយបញ្ញាជាគ្រឿងពិចារណាហើយបរិភោគអាហារដោយឧបាយ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងឧបាយនោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា “**នេវ ទវាយ** = មិនមែនដើម្បីលេង” ។ ក្នុងបទទាំងនោះ បទថា “**នេវ ទវាយ**” បានដល់ មិនបរិភោគដើម្បីលេង ។ ក្នុងព្រះបាលីនោះ អ្នករាំរែក និងអ្នកលេងលោតខ្ពស់ៗ ជាដើម ឈ្មោះថា រមែងបរិភោគដើម្បីលេង ។ ព្រោះកាលបើគេបរិភោគភោជនណាហើយ ការលេង ពោលគឺការរាំច្រៀងកាព្យឃ្លោង និងការលេងសើច រមែងស្រស់បស់យ៉ាងក្រៃលែង, ជនទាំងនោះ ស្វែងរកអាហារដោយអធម៌មិនបានត្រឹមត្រូវឡើយ រមែងបរិភោគអាហារទាំងនោះ; តែភិក្ខុនេះមិនបរិភោគអាហារយ៉ាងនេះទេ ។ បទថា “**ន មទាយ** = មិនមែនដើម្បីនឹង

ស្រវឹង” បានដល់ រមែងមិនបរិភោគដើម្បីការកពូនសេចក្ដីស្រវឹងដោយមានះ និងសេចក្ដីស្រវឹង ដោយការសម្គាល់ថា ជាបុរស ។ ក្នុងខនោះ ព្រះរាជា និងមហាអាមាត្យរបស់ព្រះរាជា ឈ្មោះថា រមែងបរិភោគដើម្បីសេចក្ដីស្រវឹង; ព្រោះជនទាំងនោះ រមែងបរិភោគភោជនមានរសឆ្ងាញ់ និងប្រណីតដើម្បីសេចក្ដីកពូនការស្រវឹងដោយមានះ ស្រវឹងដោយសម្គាល់ថា ជាបុរសរបស់ខ្លួន; តែភិក្ខុនេះ មិនបរិភោគយ៉ាងនោះទេ ។

បទថា **“ន មណ្ឌនាយ** = មិនបរិភោគដើម្បីស្អិតស្អាងពណ៌សម្បុរ” សេចក្ដីថា មិនបរិភោគដើម្បីតាក់តែងសរីរៈ; ក្នុងខនោះ ស្ត្រីពេស្យា ស្ត្រីអ្នកស្រុក ស្ត្រីអ្នកក្រុងជាដើម រមែងផឹកទឹកដោះថ្លា និងទឹកអំពៅ; រមែងបរិភោគអាហារដ៏ស្និទ្ធ និងទន់ល្មើយដោយគិតថា “ការបរិភោគយ៉ាងនេះ ការតាំងនៅនៃអវយវៈរបស់យើងនឹងតាំងនៅបានយ៉ាងល្អ, ឆវិវណ្ណក្នុងសរីរៈនឹងស្រស់ថ្លា” ; តែភិក្ខុនេះ មិនបរិភោគយ៉ាងនោះទេ ។

បទថា **“ន វិភូសនាយ** = មិនបរិភោគដើម្បីស្អិតស្អាង” បានដល់ មិនបរិភោគដើម្បីស្អិតស្អាងសាច់ក្នុងសរីរៈ; ក្នុងបុគ្គលទាំងនោះ អ្នកកីឡាកាស កីឡាប្រដាល់ កីឡាចំបាប់ជាដើម រមែងញ៉ាំងសរីរៈឱ្យធំធាត់ ដោយភោជនាហារ មានត្រីនិងសាច់ជាដើមដ៏ស្និទ្ធល្អ ដោយគិតថា “ដោយការបរិភោគយ៉ាងនេះ សាច់របស់ពួកយើងនឹងធំធាត់ ដើម្បីប្រយោជន៍ដល់ការដែលនឹងធន់ចំពោះការប្រហារ” ; តែភិក្ខុ

នេះ មិនបរិភោគដើម្បីប្រយោជន៍ធ្វើសាច់ឱ្យធំធាត់ក្នុងសរីរៈយ៉ាងនោះទេ ។

បទថា "**យាវទេវ** = ត្រឹមតែ" នេះ ជាពាក្យសម្ដែងការកំណត់ប្រយោជន៍ក្នុងការបរិភោគអាហារ ។ បទថា "**ឥមស្ស កាយស្ស ឋិតិយា** = ដើម្បីឱ្យកាយនេះតាំងនៅបាន" បានដល់ រមែងបរិភោគដើម្បីឱ្យករជកាយដែលប្រកបដោយមហាភូតរូបទាំង ៤ នេះតាំងនៅបាន, សេចក្ដីនេះ ជាប្រយោជន៍ក្នុងការបរិភោគអាហារ របស់ភិក្ខុនេះ ។ បទថា "**យាបនាយ** = ដើម្បីឱ្យជីវិតិន្ទ្រិយប្រព្រឹត្តទៅ" បានដល់ រមែងបរិភោគដើម្បីប្រយោជន៍ដល់ការឱ្យជីវិតិន្ទ្រិយប្រព្រឹត្តទៅ ។ បទថា "**វិហឹសុបរតិយា** = ដើម្បីបំបាត់សេចក្ដីហេវ" បានដល់ ធម្មតាសេចក្ដីហេវកើតឡើងព្រោះការមិនបានបរិភោគជាបច្ច័យ ឈ្មោះថា **វិហឹសា** ភិក្ខុរមែងបរិភោគដើម្បីត្រូវការកម្ចាត់វិហឹសានោះ គឺដើម្បីឱ្យវិហឹសានោះស្ងប់ ។ បទថា "**ព្រហ្មចរិយានុគ្គហាយ** = ដើម្បីអនុគ្រោះព្រហ្មចរិយៈ" សេចក្ដីថា ត្រៃសិក្ខា គឺសាសនា (ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ) ទាំងអស់ ឈ្មោះថា **ព្រហ្មចរិយៈ**, ភិក្ខុនេះរមែងបរិភោគដើម្បីអនុគ្រោះព្រហ្មចរិយៈនោះ ។ បទថា "**ឥតិ**" នេះ ជាបទសម្ដែងដល់ឧបាយ, អធិប្បាយថា ដោយឧបាយនេះ ។

បទថា "**បុរាណញ្ច វេទនំ បដិហង្ខាមិ** = យើងនឹងកម្ចាត់វេទនាចាស់ចេញផង" សេចក្ដីថា វេទនាដែលកើតឡើងព្រោះការមិនបានបរិភោគអាហារជាបច្ច័យ ឈ្មោះថា វេទនាចាស់, ភិក្ខុរមែងបរិភោគអាហារដោយគិតថា "យើងនឹង

កម្ចាត់វេទនាចាស់នោះចេញ” ។

បទថា **“នវញ្ច វេទនំ ន ឧប្បាទេស្សាមិ** = នឹងមិនឱ្យវេទនាថ្មីកើតឡើងបានផង” សេចក្តីថា វេទនាដែលកើតឡើង ព្រោះការបរិភោគហួសទៅជាបច្ច័យ* ឈ្មោះថា **វេទនាថ្មី**, ភិក្ខុរមែងបរិភោគដោយគិតថា “យើងនឹងមិនឱ្យវេទនាថ្មីនោះកើតឡើង” , ម្យ៉ាងទៀត វេទនាដែលកើតឡើង ព្រោះការបរិ-ភោគហើយជាបច្ច័យ ឈ្មោះថា **វេទនាថ្មី**, ភិក្ខុរមែងបរិភោគដើម្បីមិនឱ្យកើតវេទនានោះ ដែលនៅមិនទាន់កើតឡើងនោះឯង ។

បទថា **“យាត្រា ច មេ ភវិស្សតិ** = សេចក្តីតាំងនៅនៃជីវិតនឹងមានដល់យើង” ។ បទថា **“អនវជ្ជតា ច** = សេចក្តីមិនមានទោស” នេះ បានដល់ ក្នុងការបរិភោគនេះ វត្ថុដែលមានទោសក៏មាន, វត្ថុដែលមិនមានទោសក៏មាន; ក្នុងវត្ថុពីរយ៉ាងនោះ ការស្វែងរកដែលមិនត្រឹមត្រូវតាមធម៌ ការទទួលដោយមិនត្រឹមត្រូវតាមធម៌ ការបរិភោគដោយមិនត្រឹមត្រូវតាមធម៌នេះ ឈ្មោះថា **សាវជ្ជៈ** = មានទោស ។ ការស្វែងរកដោយធម៌ ការទទួល ការពិចារណា ហើយបរិភោគដោយធម៌ នេះឈ្មោះថា **អនវជ្ជៈ** = មិនមានទោស ។

បុគ្គលពួកខ្លះ រមែងធ្វើអាហារដែលមិនមានទោសនោះឯង ឱ្យមានទោស, គឺធ្វើអាហារដែលខ្លួនបានមកដោយធម៌ហើយបរិភោគហួសប្រមាណ, លោកមិនអាច

---

* ច្បាប់ភូមាជា អតិភុត្តបច្ចយេន ។

ឱ្យអាហារនោះរលាយ រមែងលំបាកដោយការឆ្អល់ពោះ និងបន្ទោបង់ផ្ទៃជាដើម, ពួកភិក្ខុទាំងវត្តត្រូវជួយគ្នាខ្វល់ខ្វាយក្នុងការបដិបត្តិ (ថែទាំ) រាងកាយ ស្វែងរកថ្នាំជាដើម ឱ្យភិក្ខុនោះ, កាលបើត្រូវគេសួរថា "កើតរោគអ្វី?" , ពួកភិក្ខុក៏នឹងពោលថា "ភិក្ខុឯណោះហើមពោះ" ជាដើម, ភិក្ខុទាំងឡាយក៏នាំគ្នា តិះដៀលថា "លោកនេះមានប្រក្រតីយ៉ាងនេះជានិច្ចកាល, រមែងមិនដឹងនូវប្រមាណនៃពោះរបស់ខ្លួន" ; ភិក្ខុនេះ ឈ្មោះថា រមែងធ្វើអាហារដែលមិនមានទោស ឱ្យមានទោសយ៉ាងនេះ ។ ភិក្ខុរមែងមិនធ្វើយ៉ាងនោះទេ, គឺរមែងឆាន់អាហារដោយមនសិការថា "សេចក្តីមិនមានទោសនឹងមាន" ដូច្នេះ ។

សូម្បីក្នុងបទថា "**ផាសុវិហារោ ច** = និងការនៅសប្បាយដោយផាសុកភាព " នេះ សេចក្តីថា ការនៅដោយផាសុកភាពក៏មាន, ការនៅដោយមិនជាផាសុកភាពក៏មាន ៗ៕

## ព្រាហ្មណ៍ល្មោភស៊ី ៥ នាក់

ក្នុងការបរិភោគនោះ ការបរិភោគរបស់ព្រាហ្មណ៍ទាំង ៥ នាក់នេះ គឺព្រាហ្មណ៍ឈ្មោះ **អាហារហត្ថកៈ** ១, **អលំសាដកៈ** ១, **តត្ថវដ្ដកៈ** ១, **កាកមាសកៈ** ១ និងព្រាហ្មណ៍ឈ្មោះ **ភុត្តវមិតកៈ** ១ ឈ្មោះថា នៅមិនសប្បាយ ។

សេចក្តីថា បណ្តាព្រាហ្មណ៍ទាំងនោះ ព្រាហ្មណ៍ឈ្មោះថា **អាហារហត្ថកៈ**

បរិភោគច្រើនមិនអាចក្រោកឡើងតាមធម្មតារបស់ខ្លួនបាន ទើបពោលថា “ជួយទាញដៃឡើងផង” ។ ព្រាហ្មណ៍ឈ្មោះថា **អលំសាដកៈ** បរិភោគអាហារច្រើន សូម្បីនឹងក្រោកឡើងបាន, តែមិនអាចស្លៀកសំពត់បាន ព្រោះជាអ្នកមានពោះប៉ោងធំ ។ ព្រាហ្មណ៍ឈ្មោះ **តត្ថវដ្តកៈ** បរិភោគច្រើនមិនអាចក្រោកឡើងបាន រមែងវិលនៅទីនោះឯង ។ ព្រាហ្មណ៍ឈ្មោះ **កាកមាសកៈ** បរិភោគច្រើនរហូតហៀរដល់មាត់ រហូតដល់ពពួកក្អែកអាចចឹកស៊ីបាន ។ ព្រាហ្មណ៍ឈ្មោះ **ហុត្តវមិតកៈ** បរិភោគច្រើន មិនអាចដើម្បីបិទមាត់បាន រមែងក្អួតក្នុងទីនោះៗឯង ។

ភិក្ខុមិនឆាន់យ៉ាងនេះទេ រមែងឆាន់អាហារដោយគិតថា “ការនៅដោយផាសុកភាពនឹងមានដល់យើង” ។ កាលដែលផ្ទៃពោះនៅខ្វះដោយពំនូតបាយ ៤-៥ ពំនូត ឈ្មោះថា ការនៅជាផាសុកភាព; ព្រោះកាលបើភិក្ខុបរិភោគអាហារត្រឹមតែប៉ុណ្ណេះហើយឆាន់ទឹក ឥរិយាបថ ៤ រមែងប្រព្រឹត្តទៅដោយស្រួល; ព្រោះហេតុដូច្នោះ ទើបព្រះធម្មសេនាបតីពោលទុកយ៉ាងនេះថា ៖

**“ចត្តារោ បញ្ច អាលោបេ អភុត្វា ឧទកំ បិវេ**
**អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ**

ភិក្ខុមិនបរិភោគអាហារ ៤ - ៥ ពំនូតហើយ គប្បីផឹកទឹក
ជំនួស ការបរិភោគយ៉ាងនោះ សមគួរដើម្បីនៅជាផាសុកភាព
របស់ភិក្ខុអ្នកមានចិត្តប្រព្រឹត្តទៅក្នុងកម្មដ្ឋាន” ៕

## អង្គ ១២ របស់ភិក្ខុអ្នកឆាន់អាហារ

ក៏ក្នុងឋានៈនេះ គួរប្រមូលអង្គទាំងឡាយ គឺ

១-មិនបរិភោគដើម្បីលេង

២-មិនបរិភោគដើម្បីស្រវឹង

៣-មិនបរិភោគដើម្បីប្រដាប់

៤-មិនបរិភោគដើម្បីស្អិតស្អាង

៥-ដើម្បីឱ្យកាយនេះតាំងនៅ

៦-ដើម្បីឱ្យជីវិតិន្ទ្រិយប្រព្រឹត្តទៅ

៧-ដើម្បីបំបាត់សេចក្តីហេវ

៨-ដើម្បីអនុគ្រោះព្រហ្មចរិយៈ

៩-ព្រោះឧបាយនេះ យើងនឹងកម្ចាត់វេទនាចាស់

១០-មិនឱ្យវេទនាថ្មី (ឆ្អែតហួសប្រមាណ) កើតឡើងបាន

១១-ការតាំងនៅនៃជីវិតនឹងមានដល់យើង

១២-ការមិនមានទោស និងការនៅជាសុខ ។

ក្នុងការបរិភោគអាហារនេះ ជាអានិសង្សនៃការបរិភោគភោជន ។ ៕

## ព្រះមហាសិវត្ថេរចាត់អង្គទុក ៨

ចំណែកព្រះមហាសិវត្ថេរពោលថា “អង្គ ៤ ខាងដើម ឈ្មោះថា ខហាមជាអង្គ ១, គប្បីប្រមូលអង្គ ៨ ខាងចុង មកក្នុងអង្គ ៨ ខាងចុងនោះ” ដូច្នេះវិញ ៖

១-ត្រឹមតែឱ្យកាយនេះតាំងនៅ

២-ដើម្បីឱ្យជីវិតិន្ទ្រិយប្រព្រឹត្តទៅ

៣-ដើម្បីបំបាត់សេចក្ដីហេវ

៤-ដើម្បីអនុគ្រោះដល់ការប្រព្រឹត្តព្រហ្មចរិយៈ

៥-ដោយឧបាយនេះ យើងនឹងកម្ចាត់វេទនាចាស់ចេញ

៦-មិនឱ្យវេទនាថ្មីកើតឡើងបាន

៧-ការតាំងនៅនៃជីវិតនឹងមានដល់យើង

៨-សេចក្ដីមិនមានទោស ។

ក៏ការនៅជាផាសុកភាព ជាផលរបស់ការបរិភោគភោជនដូច្នេះ ។

ភិក្ខុកាលបើបរិភោគអាហារប្រកបដោយអង្គ ៨ យ៉ាងនេះ ឈ្មោះថា ជាអ្នកដឹងប្រមាណក្នុងការបរិភោគអាហារ ។

បទថា “**អយំ វុច្ចតិ** = នេះហៅថា” សេចក្ដីថា ការបរិភោគដោយការពិចារណាប្រព្រឹត្តទៅដោយអំណាចនៃការដឹងនូវប្រមាណដែលគួរស្វែងរក ការទទួល និងការបរិភោគ នេះឈ្មោះថា **ភោជនេ មត្តញ្ញុតា** = ភាពជាអ្នកដឹងនូវប្រមាណ

ក្នុងភោជន ៕

## សម្តែងអំពីមុដ្ឋស្សច្ចទុកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង **មុដ្ឋស្សច្ចទុកៈ** ដូចតទៅ ៖

បទថា “**អសតិ** = ការរឭកមិនបាន” បានដល់ នាមខន្ធ ៤ ដែលវៀរចាកសតិ ។

បទថា “**អននុស្សតិ អប្បដិស្សតិ** = ការមិនតាមរឭក ការមិនភ្ញាក់រឭក” នេះ ទ្រង់បន្ថែមបទដោយអំណាចនៃឧបសគ្គៈ ។

បទថា “**អសរណតា** = ការដែលរឭកមិនបាន” ។

បទថា “**អធារណតា** = ការមិនទ្រទ្រង់” បានដល់ មិនអាចដើម្បីទ្រទ្រង់; ព្រោះបុគ្គលអ្នកប្រកបដោយភាពមិនអាចទ្រទ្រង់នោះ សូម្បីតាំងចិត្ត ក៏មិនអាចរក្សាទុកបាន ។

ដែលឈ្មោះថា **ពិលាបនតា** (ភាពឃ្លេងឃ្លោង) ព្រោះអត្ថថា រមែងឃ្លេងឃ្លោងក្នុងអារម្មណ៍ ដូចសម្បកឃ្លោកអណ្តែតលើទឹកដូច្នោះ ។

បទថា “**បម្មុស្សនតា** = ការភ្លេចស្មារតី” បានដល់ ព្រោះមិនមានសតិ ឬភ្លេចសតិ, ព្រោះបុគ្គលអ្នកមិនមានសតិ ឬភ្លេចសតិ រមែងហាក់ដូចជាក្អែកដែលទុកដុំបាយ និងដូចជាសុនខចចកដែលទុកដុំសាច់ដូច្នោះ ៕៚

# សម្តែងអំពីភាវនាពលទុកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ភាវនាពលទុកៈ** ដូចតទៅ ៖

បទថា "**កុសលានំ ធម្មានំ** = នូវកុសលធម៌ទាំងឡាយ" **គឺពោធិបក្ខិយ-ធម៌** ។

បទថា "**ភាវនា** = ការចម្រើន" គឺការផ្តើមឡើង ។

បទថា "**អាសេវនា** = ការសេព" គឺការសេពតាំងពីដើម ។

បទថា "**ពហុលីកម្មំ** = ការធ្វើឱ្យច្រើន" គឺការធ្វើញយៗ ។

និទ្ទេសនៃសីលវិបត្តិគប្បីជ្រាបដោយន័យផ្ទុយគ្នានឹងសោវច្ចនិទ្ទេស; និទ្ទេសនៃទិដ្ឋិវិបត្តិ គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងទិដ្ឋិសម្បទា, ឯនិទ្ទេសនៃទិដ្ឋិសម្បទាគប្បីជ្រាបដោយន័យផ្ទុយគ្នានឹងនិទ្ទេសនៃទិដ្ឋុប្បាទាន ។ និទ្ទេសនៃសីលវិសុទ្ធិ ដូចនឹងនិទ្ទេសនៃសីលសម្បទា ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា ក្នុងនិទ្ទេសនៃសីលសម្បទានោះ ព្រះអង្គទ្រង់ត្រាស់បាដិមោក្ខសំវរសីលឱ្យដល់វិសុទ្ធិ, ចំណែកនិទ្ទេសនៃសីល-វិសុទ្ធិនេះ ទ្រង់ត្រាស់សីលដែលដល់សីលវិសុទ្ធិ ។

ក៏លោកិយធម៌ និងលោកុត្តរធម៌សូម្បីប្រព្រឹត្តទៅក្នុងភូមិ ៤ ព្រះភគវា ក៏ត្រាស់ទុកដោយទុកៈទាំង ៦ នេះ គឺ

១-សតិ និងសម្បជញ្ញៈ (ទុកៈទី ៣០)

២-បដិសង្ខានពលៈ និងភាវនាពលៈ (ទុកៈទី ៣១)

៣-សមថៈ និងវិបស្សនា ( ទុកៈទី ៣២)

៤-សមថនិមិត្ត និងបគ្គាហនិមិត្ត ( ទុកៈទី ៣៣)

៥-បគ្គាហៈ និងអវិក្ខេបៈ ( ទុកៈទី ៣៤)

៦-សីលសម្បទា និងទិដ្ឋិសម្បទា ( ទុកៈទី ៣៦) ៕ ៕

## សម្តែងអំពីទិដ្ឋិវិសុទ្ធិទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ទិដ្ឋិវិសុទ្ធិ** ដូចតទៅ ៖

បទថា **"កម្មស្សកតញ្ញាណំ** = ញាណជាគ្រឿងដឹងថា សត្វមានកម្មជារបស់ខ្លួន" បានដល់ បញ្ញាជាគ្រឿងដឹងថា "នេះជាកម្មរបស់ខ្លួន, នេះមិនមែនជាកម្មរបស់ខ្លួន" , បណ្តាកម្មទាំង ២ នោះ កម្មដែលខ្លួនធ្វើហើយ និងអ្នកដទៃធ្វើហើយចូរលើកទុកសិនចុះ, សូម្បីអកុសលកម្មទាំងអស់ ក៏មិនមែនជារបស់ខ្លួន; ព្រោះហេតុអ្វី ? ព្រោះទម្លាយអត្ថ ( ប្រយោជន៏) និងព្រោះឱ្យកើតអនត្ថៈ ( មិនមែនជាប្រយោជន៏); ចំណែកកុសលកម្ម ជាកម្មរបស់ខ្លួន ព្រោះទម្លាយអនត្ថៈ និងព្រោះឱ្យកើតអត្ថ; ក្នុងសេចក្តីនេះ ដូចបុរសមានទ្រព្យ មានភោគៈ ដើរផ្លូវឆ្ងាយ ក្នុងចន្លោះផ្លូវកាលបើគេប្រកាសលេងនក្ខត្តឫក្សក្នុងស្រុក ឬនិគមជាដើម ក៏មិនបានគិតថា "យើងជាអាគន្តុកៈ ( ភ្ញៀវ), គប្បីអាស្រ័យនរណាហ្ន៎ ហើយលេងនក្ខត្តឫក្ស" កាលបើលេងនក្ខត្តឫក្សដោយទំនងដែលត្រូវការ រមែងឆ្លងផ្លូវកន្តារដោយសប្បាយ

យ៉ាងណា; សត្វពួកនេះតាំងនៅក្នុងកម្មស្សកតញ្ញាណ ក៏យ៉ាងនោះដែរ ធ្វើកម្មដែលជាវដ្តគាមិនីជាច្រើន សោយសេចក្តីសុខ ដោយសុខ សម្រេចព្រះអរហត្តហើយ ហួសនឹងគណនាបាន ។

បទថា **"សច្ចានុលោមិកញ្ញាណំ** = សច្ចានុលោមិកញ្ញាណ" បានដល់វិបស្សនាញាណដែលអនុលោមតាមសច្ចៈទាំង ៤ ។

បទថា **"មគ្គសមង្គិស្ស ញាណំ, ផលសមង្គិស្ស ញាណំ** = ញាណរបស់លោកអ្នកព្រមព្រៀងដោយមគ្គ, ញាណរបស់លោកអ្នកព្រមព្រៀងដោយផល" បានដល់ មគ្គញ្ញាណ និងផលញ្ញាណនោះឯង ។

ក្នុងនិទ្ទេសនៃបទថា **"ទិដ្ឋិវិសុទ្ធិ ខោ បន** = សេចក្តីបរិសុទ្ធិនៃទិដ្ឋិ" ព្រះភគវាទ្រង់ចែកញាណ ៤ មានកម្មស្សកតញ្ញាណនោះឯង ដែលត្រាស់ទុកខាងក្រោយ ដោយបទមានជាអាទិ៍ថា **"យា បញ្ញា បជាននា** = បញ្ញា គឺកិរិយាដែលដឹងច្បាស់ឯណា" ។

ក្នុងនិទ្ទេសនៃបទថា **"យថា ទិដ្ឋិស្ស ច បធានំ** = សេចក្តីព្យាយាមនៃបុគ្គលអ្នកមានទិដ្ឋិដ៏បរិសុទ្ធ" បានដល់ សេចក្តីព្យាយាមដែលទ្រង់សម្តែងដោយបទមានជាអាទិ៍ថា **"យោ ចេតសិកោ វីរិយារម្ភោ** = ការប្រារព្ធសេចក្តីព្យាយាមតាមផ្លូវចិត្តឯណា" ក្នុងគតិដូចបញ្ញានោះដែរ; ក្នុងឋានៈដែលបញ្ញាជាលោកិយ ក៏គប្បីជ្រាបថា វីរិយៈនោះជាលោកិយ, ក្នុងឋានៈនៃលោកុត្តរបញ្ញា ក៏គប្បីជ្រាបថា

វីរិយៈជាលោកុត្តរៈ ៕ ៚

## សម្ដែងអំពីសង្វេគទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **សង្វេគទុកៈ** ដូចតទៅ ៖

បទថា **"ជាតិភយំ** = ខ្លាចជាតិ" បានដល់ ញាណដែលឃើញជាតិ (ការកើត) ដោយសេចក្ដីជាភ័យហើយតាំងនៅ ។ សូម្បីក្នុងញាណដែលឃើញជរា និងមរណៈដោយការភ័យខ្លាចជាដើម ក៏ន័យនេះដែរ ។

ដោយបទថា **"អនុប្បន្នានំ បាបកានំ** = ដើម្បីមិនឱ្យកើតឡើងនៃបាបធម៌" ជាដើម ព្រះមានព្រះភាគត្រាស់សេចក្ដីព្យាយាម ដែលជាហេតុរបស់ភិក្ខុអ្នកឃើញជាតិជាដើម ដោយការភ័យខ្លាចហើយ ប្រាថ្នាដើម្បីនឹងឱ្យរួចផុតចាកជាតិ ជរា ព្យាធិ និងមរណៈ ។ ចំណែកសេចក្ដីនៃបទភាជនីយ៍ នឹងមានច្បាស់ក្នុងអដ្ឋកថាវិភង្គ ។

## សម្ដែងអំពីអសន្តុដ្ឋតាកុសលធម្មទុកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសថា **"អសន្តុដ្ឋតា ច កុសលេសុ ធម្មេសុ** = ភាពជាអ្នកមិនឆ្អែតក្នុងកុសលធម៌ទាំងឡាយ" ដូចតទៅ ៖

បទថា **"ភិយ្យោកម្យតា** = ភាពពេញចិត្តក្រៃលែងៗ ឡើងទៅ" បានដល់សេចក្ដីពេញចិត្តយ៉ាងអស្ចារ្យ; បុគ្គលពួកខ្លះក្នុងលោកនេះ រមែងប្រគេន **បក្ខិកភត្ត**

= អាហារដែលគេឱ្យប្រចាំបក្សខ្លះ, **សលាកភត្ត** = អាហារដែលគេឱ្យដោយវិធីចាប់ស្លាកខ្លះ, **ឧបោសថិកភត្ត** = អាហារដែលគេឱ្យក្នុងថ្ងៃឧបោសថខ្លះ, **បាដិបទិក-ភត្ត** = អាហារដែលគេឱ្យក្នុងថ្ងៃ ១ រោច ឬ ១ កើតខ្លះ តាំងពីដើមម្ល៉េះ; បុគ្គលនោះជាអ្នកមិនឆ្អែតដោយការឱ្យទាននោះៗ ទើបថ្វាយ **ធុរភត្ត** = អាហារជាប្រចាំ *, **សង្ឃភត្ត** = អាហារសម្រាប់សង្ឃ, **វស្សាវសិកភត្ត** = អាហារសម្រាប់ភិក្ខុអ្នកនៅចាំវស្សាទៀត; រមែងសាងអាវាស, រមែងឱ្យសូម្បីបច្ច័យទាំង ៤ ។ គេក៏នៅតែជាអ្នកមិនឆ្អែតចិត្តសូម្បីក្នុងការឱ្យនោះៗ ទើបទទួលសរណៈទាំងឡាយ, សមាទានបញ្ចសីលថែមទៀត, គេក៏នៅតែជាអ្នកមិនឆ្អែតចិត្ត សូម្បីក្នុងការធ្វើកុសលនោះៗ ទើបបួស, លុះបួសហើយក៏រៀនពុទ្ធវចនៈ គឺព្រះត្រៃបិដក ជានិកាយមួយ និកាយពីរ រមែងញ៉ាំងសមាបត្តិ ៨ ឱ្យកើត, ចម្រើនវិបស្សនា ចាប់យកព្រះអរហត្ត, ចាប់ដើមពីការសម្រេចព្រះអរហត្តហើយ ជាអ្នកឈ្មោះថា **មហាសន្តុដ្ឋៈ** (ឆ្អែតចិត្តយ៉ាងខ្លាំង); សេចក្តីស្ងប់ចិត្តយ៉ាងអស្ចារ្យ រហូតដល់ព្រះអរហត្តយ៉ាងនេះ ឈ្មោះថា **តិរោយ្យាកម្យតា** = ការពេញចិត្តក្រៃលែងៗ ឡើងទៅ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃបទថា "**អប្បដិវានិតា ច បធានស្មឹ** =

---

* យោជនាថា **ធុរភត្ត** = អាហារដែលគេឱ្យដល់អ្នកធ្វើសេចក្តីព្យាយាម ។

ភាពជាអ្នកមិនរួញរាក្នុងការព្យាយាម” ព្រោះភិក្ខុនឿយណាយក្នុងការចម្រើនកុសលធម៌ដ៏ក្រៃលែងក្នុងសេនាសនៈដ៏ស្ងាត់ទាំងឡាយ ឈ្មោះថា ញុំាងសេចក្ដីព្យាយាមឱ្យធូរថយ, កាលបើភិក្ខុមិននឿយណាយ ឈ្មោះថា មិនញុំាងសេចក្ដីព្យាយាមឱ្យធូរថយ; ព្រោះហេតុដូច្នោះ ដើម្បីទ្រង់សម្ដែងន័យនោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា “**យា កុសលានំ ធម្មានំ** = ដើម្បីសេចក្ដីចម្រើនកុសលធម៌ឯណា” ។

ក្នុងព្រះបាលីទាំងនោះ បទថា “**សក្កច្ចកិរិយតា** = ភាពជាអ្នកធ្វើដោយគោរព” បានដល់ ភាពជាអ្នកធ្វើដោយគោរពក្នុងការធ្វើកុសលទាំងឡាយ ។

បទថា “**សាតច្ចកិរិយតា** = ភាពជាអ្នកធ្វើរឿយៗ” គឺធ្វើជាប់គ្នានោះឯង ។

បទថា “**អដ្ឋិតកិរិយតា** = ការធ្វើមិនឈប់” គឺធ្វើមិនឱ្យដាច់ ធ្វើមិនអាក់ខាន ។ បទថា “**អនោលីនវុត្តិតា** = ការប្រព្រឹត្តមិនរារែក” គឺការតម្រង់ជីវៈ មិនឱ្យរួញរា ឬសេចក្ដីប្រព្រឹត្តមិនធូរថយ ។

បទថា “**អនិក្ខិត្តឆន្ទតា** = ការមិនលះបង់ឆន្ទៈ” គឺការមិនលះបង់ ក្នុងកុសលឆន្ទៈ ។

បទថា “**អនិក្ខិត្តធុរតា** = ការមិនដាក់ធុរៈ” គឺមិនបោះបង់ធុរៈសេចក្ដីព្យាយាមក្នុងការសាងកុសល។ ៕

## សម្តែងអំពីវិជ្ជាក្នុងនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា “**បុព្វេនិវាសានុស្សតិញ្ញាណំ វិជ្ជា**” នេះ ដូចតទៅ ៖

បទថា “**បុព្វេនិវាសោ = បុព្វេនិវាស**” បានដល់ ខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន និងខន្ធដែលជាប់តគ្នា ។ ការតាមរឭកបុព្វេនិវាសបាន ឈ្មោះថា **បុព្វេនិវាសានុស្សតិ** ។ ញាណដែលសម្បយុត្តដោយបុព្វេនិវាសានុស្សតិនោះ ឈ្មោះថា **បុព្វេនិវាសានុស្សតិញ្ញាណ** ។ បុព្វេនិវាសានុស្សតិញ្ញាណនេះឯង ឈ្មោះថា **វិជ្ជា** សូម្បីព្រោះអត្ថថា រមែងកម្ចាត់សេចក្តីងងឹតដែលបិទបាំងខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន, គឺញាណនោះកម្ចាត់សេចក្តីងងឹតហើយធ្វើខន្ធទាំងនោះ ដែលខ្លួនដឹងច្បាស់ហើយឱ្យប្រាកដ ព្រោះហេតុនោះ ញាណនោះទើបឈ្មោះថា **វិជ្ជា** ដោយអត្ថថា ធ្វើខន្ធឱ្យប្រាកដ ។

បទថា “**ចុតូបបាតេ ញាណំ = ចុតូបបាតញ្ញាណ**” បានដល់ ញាណ គឺសេចក្តីដឹងក្នុងចុតិ និងឧប្បត្តិ ។ សូម្បីញាណនេះ ក៏ឈ្មោះថា **វិជ្ជា** សូម្បីដោយអត្ថថា រមែងកម្ចាត់សេចក្តីងងឹតដែលបិទបាំងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ, គឺញាណនោះកម្ចាត់សេចក្តីងងឹតហើយធ្វើចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយដែលដឹងហើយឱ្យប្រាកដ, ព្រោះហេតុដូច្នោះ ញាណនោះទើបឈ្មោះថា **វិជ្ជា** ដោយអត្ថថា ធ្វើចុតិ និងបដិសន្ធិដែលដឹងហើយឱ្យប្រាកដឡើង ។

បទថា **“អាសវានំ ខយេ ញាណំ** = អាសវក្ខយញ្ញាណ” បានដល់ញាណក្នុងសម័យអស់សព្វកិលេសទាំងឡាយ; ញាណនេះឯង ឈ្មោះថា **វិជ្ជា** ព្រោះអត្ថថា រមែងកម្ចាត់សេចក្តីងងឹតដែលបិទបាំងសច្ចៈទាំង ៤; គឺញាណនោះ កម្ចាត់សេចក្តីងងឹតហើយធ្វើសច្ចៈ ៤ ដែលដឹងហើយឱ្យប្រាកដ, ព្រោះហេតុនោះ ទើបឈ្មោះថា **វិជ្ជា** សូម្បីដោយអត្ថថា ធ្វើឱ្យច្បាស់លាស់ឡើង ។

ក្នុងខថា **“ចិត្តស្ស ច អធិមុត្តិ និព្វានញ្ច** = អធិមុត្តិនៃចិត្ត និងនិព្វាន” នេះ សមាបត្តិ ៨ ឈ្មោះថា **អធិមុត្តិនៃចិត្ត** ដោយអត្ថថា បង្អោនទៅក្នុងអារម្មណ៍ និងដោយអត្ថថា រួចផុតដោយល្អចាកធម៌ដែលជាសត្រូវទាំងឡាយ; ចំណែកញាណក្រៅនេះឈ្មោះថា **និព្វាន** ដោយអត្ថថា **វានៈ** ពោលគឺតណ្ហាមិនមានក្នុងនិព្វាននេះ, ឬនិព្វាននេះចេញទៅចាកវានៈ (តណ្ហាជាគ្រឿងចាក់ស្រេះ) នោះ ។ បណ្តាធម៌ទាំង ២ (អធិមុត្តិនៃចិត្ត និងនិព្វាន) នោះ សមាបត្តិ ៨ ត្រាស់ថា **វិមុត្តិ** ព្រោះរួចផុតហើយចាកកិលេសដែលសង្កត់ទុកបានដោយខ្លួនឯង ។ តែព្រះនិព្វានត្រាស់ថា **វិមុត្តិ** ព្រោះរួចផុតដោយចំណែកមួយចាកសព្វកិលេសទាំងឡាយ ។

បទថា **“មគ្គសមង្គិស្ស ញាណំ** = ញាណរបស់លោកអ្នកព្រមព្រៀងដោយមគ្គ” បានដល់ មគ្គញ្ញាណទាំង ៤ ។ បទថា **“ផលសមង្គិស្ស ញាណំ** = ញាណរបស់លោកអ្នកព្រមព្រៀងដោយផល” បានដល់ ផលញ្ញាណទាំង ៤ ។

បណ្តាញាណទាំងនោះ មគ្គញ្ញាណទី ១ ឈ្មោះថា **ខយេ ញាណំ** (ញាណ

ក្នុងការអស់ទៅ) ព្រោះអត្ថថា កើតឡើងហើយញ៉ាំងកិលេស ៥ យ៉ាងឱ្យអស់ទៅ ឱ្យរលត់ទៅ ឱ្យស្ងប់ ឱ្យរម្ងាប់ទៅ ។ មគ្គញ្ញាណទី ២ ញ៉ាំងកិលេស ៤ យ៉ាងឱ្យអស់ទៅ ។ មគ្គញ្ញាណទី ៣ ក៏ញ៉ាំងកិលេស ៤ យ៉ាង ឱ្យអស់ទៅដូចគ្នាដែរ ។ តែមគ្គញ្ញាណទី ៤ ឈ្មោះថា **ខយេ ញាណំ** (ខយញ្ញាណ) ព្រោះអត្ថថា រមែងកើតឡើងធ្វើកិលេស ៨ យ៉ាងឱ្យអស់ទៅ ឱ្យរលត់ទៅ ឱ្យស្ងប់ ឱ្យរម្ងាប់ទៅ ។

តែផលញ្ញាណរបស់មគ្គនោះៗ ឈ្មោះថា **អនុប្បាទេ ញាណំ** (អនុប្បាទ-ញ្ញាណ) ព្រោះអត្ថថា កើតឡើងក្នុងទីបំផុតនៃការអស់ទៅ ក្នុងទីបំផុតនៃការរលត់ទៅ ក្នុងទីបំផុតនៃការរម្ងាប់ទៅ ក្នុងទីបំផុតនៃការស្ងប់ទៅ ក្នុងទីបំផុតនៃការមិនកើតឡើង ក្នុងទីបំផុតនៃការមិនប្រព្រឹត្តទៅនៃកិលេសទាំងនោះដូច្នេះឯង ។

## ការពណ៌នានិក្ខេបកណ្ឌ

## ក្នុងអដ្ឋសាលិនី នៃអដ្ឋកថា

## ធម្មសង្គណី

## ចប់

# អដ្ឋកថាកណ្ឌ*

## អធិប្បាយសេចក្ដីនៃពួកតិកៈ

ឥឡូវនេះ ដល់លំដាប់នៃការពណ៌នាអដ្ឋកថាកណ្ឌដែលលោកតាំងទុក ក្នុងលំដាប់នៃនិក្ខេបកណ្ឌ ។ **សួរថា** ក៏កណ្ឌនេះឈ្មោះថា **អដ្ឋកថាកណ្ឌ** ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះលើកយកសេចក្ដីនៃព្រះពុទ្ធវចនៈ គឺពង្រីកសេចក្ដីនៃព្រះត្រៃបិដក ( អភិធម្មបិដក) ។

ពិតមែន សេចក្ដីផ្សេងគ្នានៃធម៌ដែលមានមកក្នុងបិដកទាំង ៣ លោកបានកំណត់វែកញែកវិចារណ៍ទុកដោយអដ្ឋកថាកណ្ឌនោះឯង មានឈ្មោះថា ជាពាក្យដែលលោកវិនិច្ឆ័យល្អហើយ ។ សូម្បីនឹងកំណត់ផ្លូវនៃន័យក្នុងព្រះអភិធម្មទាំងអស់រហូតដល់ការពង្រីកសេចក្ដីដល់បញ្ហាការប្រព្រឹត្តិទៅ នៃការរាប់ក្នុងមហាបករណ៍មិនបាន ក៏គួរនាំមកប្រៀបធៀបសេចក្ដីពីអដ្ឋកថាកណ្ឌបាន ។

**សួរថា** ក៏អដ្ឋកថាកណ្ឌនេះ កើតពីនរណា ?

ឆ្លើយថា កើតពីព្រះសារីបុត្តត្ថេរ ។

មានសេចក្ដីតំណាលថា ព្រះសារីបុត្តត្ថេរបានពោលអដ្ឋកថាកណ្ឌ ឱ្យសទ្ធិវិហារិករបស់លោកមួយរូប ដែលមិនអាចកំណត់សេចក្ដីក្នុងនិក្ខេបកណ្ឌបាន, តែអដ្ឋ-

---

* បាលី ( បិដក) ជា អត្ថុទ្ធារកណ្ឌ = កណ្ឌដែលរើសេចក្ដី ។

កថាកណ្ឌនេះ លោកពោលជំទាស់ទុកក្នុងមហាអដ្ឋកថាដូច្នេះថា ៖

“ធម្មតាព្រះអភិធម្មមិនមែនជាវិស័យរបស់ព្រះសាវ័ក, មិនមែនជាគោចររបស់ព្រះសាវ័កទេ; ព្រះអភិធម្មនេះ ជាពុទ្ធវិស័យ, ជាគោចររបស់ព្រះពុទ្ធ; តែព្រះធម្មសេនាបតីត្រូវសទ្ធិវិហារិកសួរហើយ ទើបនាំសទ្ធិវិហារិកនោះ ទៅកាន់សំណាក់ព្រះសាស្តាហើយទូលសួរចំពោះព្រះសម្មាសម្ពុទ្ធ; ទើបព្រះអង្គត្រាស់អដ្ឋកថាកណ្ឌប្រទានដល់ភិក្ខុនោះ ។ តើបានត្រាស់ប្រទានយ៉ាងណា ? គឺព្រះភគវាត្រាស់សួរថា **“កតមេ ធម្មា កុសលា** = ធម៌ជាកុសលតើដូចម្តេច ?” ។ អធិប្បាយថា អ្នកកំណត់ថា “ធម្មតាកុសលធម៌ទាំងឡាយ តើយ៉ាងណា” ; ពេលនោះ ព្រះមានជោគកាលបើទ្រង់សម្តែងធម៌មានកុសលជាដើម ដោយអំណាចនៃការពង្រីកសេចក្តីធ្វើឱ្យជាចង្កោម ជាក្រុម១[*] ប្រទានដល់ភិក្ខុអ្នកតុណ្ហីភាព (នៅស្ងៀម) នោះ ដោយន័យនេះថា **“កុសលផ្សេងដោយភូមិ ដោយន័យមានជាអាទិ៍ថា ‘ធម៌ជាកុសលតើដូចម្តេច ? កាមាវចរកុសលចិត្តកើតឡើងក្នុងសម័យណា, តថាគតសម្តែងហើយមិនមែនឬ, កុសលចិត្តសូម្បីទាំងអស់ក្នុងភូមិ ៤ នោះ សភាវៈធម៌ទាំងនេះ ឈ្មោះថា ធម៌ជាកុសល”** ។

---

* ពាក្យទាំង ៣ នេះ មានសេចក្តីដូចគ្នា (អត្ថយោជនា) ។

ក្នុងពុទ្ធវចនៈទាំងនោះ បទថា **“ចតូសុ** = ក្នុងភូមិ ៤” បានដល់ កាមាវចរភូមិ, រូបាវចរភូមិ, អរូបាវចរភូមិ និងលោកុត្តរភូមិ ។ បទថា **“កុសលំ** = កុសល” បានដល់ កុសលផ្សេងដោយកុសលមានផស្សៈជាដើម ។ បទថា **“ឥមេ ធម្មា កុសលា** = សភាវធម៌ទាំងឡាយនេះ ឈ្មោះថា ធម៌ជាកុសល” បានដល់ សូម្បីធម៌ទាំងអស់មានផស្សៈជាដើមនេះ ដែលត្រាស់ទុកក្នុងភូមិ ៤ នោះៗ ឈ្មោះថា **ធម៌ជាកុសល** ។

ក៏ព្រោះអកុសលធម៌ទាំងឡាយ មិនមានសេចក្ដីផ្សេងគ្នាដោយអំណាចនៃភូមិ ទើបត្រាស់ថា **“ទ្វាទស អកុសលចិត្តុប្បាទា** = ចិត្តុប្បាទខាងអកុសល ១២ ដួង” ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អកុសលចិត្តុប្បាទ** នោះ ដូចតទៅ ៖

ដែលឈ្មោះថា **ឧប្បាទោ** (ឧប្បាទៈ) ព្រោះអត្ថថា កើតឡើង ។

ឧប្បាទៈ គឺចិត្តនោះឯង ឈ្មោះថា **ចិត្តុប្បាទ**, ក៏ពាក្យថា ចិត្តុប្បាទនេះ ជាប្រធានរបស់ទេសនាប៉ុណ្ណោះ, ដូចយ៉ាងដែលគេពោលថា “ព្រះរាជាស្ដេចយាងមកហើយ” ដូច្នេះ រមែងជាការដែលពោលដល់ការមក សូម្បីរបស់អាមាត្យជាដើមយ៉ាងណា, កាលបើព្រះអង្គត្រាស់ថា **“ចិត្តុប្បាទ”** ដូច្នេះ សូម្បីសម្បយុត្តធម៌ទាំងឡាយ ក៏ជាការដែលត្រាស់ហើយ ដោយចិត្តុប្បាទទាំងនោះដូចគ្នាដែរ, ព្រោះ

ហេតុដូច្នោះ ដោយសព្វថាចិត្តុប្បាទក្នុងទីទាំងអស់ គប្បីជ្រាបថា ទ្រង់កាន់យកចិត្ត ព្រមទាំងសម្បយុត្តធម៌ ។

ក៏ចាប់ផ្ដើមពីនេះទៅ សេចក្ដីនៃបទដែលគប្បីចែកដោយបទតិកៈ និងទុកៈ សូម្បីទាំងអស់មានជាអាទិ៍ថា **"ចតូសុ ភូមីសុ វិបាកោ** = វិបាកក្នុងភូមិ ៤" និង នវត្តព្វធម៌ (គឺធម៌ដែលមិនគប្បីពោល) នៃវេទនាមានសុខវេទនាជាដើម ក្នុង វេទនាតិកៈជាដើម បណ្ឌិតពិចារណាព្រះបាលី និងអដ្ឋកថាខាងក្រោយហើយ ក៏គប្បី ជ្រាបបានដោយន័យ ដែលពោលហើយនោះឯង, ខ្ញុំនឹងពោលតែសេចក្ដីដែល ផ្សេងគ្នាប៉ុណ្ណោះ ៕ ៕

## សម្ដែងអំពីបរិត្តារម្មណត្តិកៈ

បណ្ដាតិកៈទាំងនោះ គប្បីជ្រាបបរិត្តារម្មណត្តិកៈជាមុនសិន ៖

ក្នុងខថា **"សព្វេ កាមាវចរស្ស វិបាកោ** = កាមាវចរវិបាកទាំងអស់" នេះ បានដល់ ទ្វិបញ្ចវិញ្ញាណ (វិញ្ញាណ ១០) ឈ្មោះថា ធម៌មានអារម្មណ៍ជាបរិត្តៈ (កាមារម្មណ៍) ព្រោះអត្ថថា អាស្រ័យចក្ខុបសាទជាដើម ហើយផ្ដើមប្រព្រឹត្តទៅ ក្នុងធម៌ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ផ្សេងដោយឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ជាដើម ដោយពិតប្រាកដ ។ ឯមនោធាតុ ២ គឺកុសលវិបាក និងអកុសលវិបាក ក៏ ឈ្មោះថា **ធម៌មានអារម្មណ៍ជាបរិត្តៈ** ព្រោះអត្ថថា អាស្រ័យដោយហទយវត្ថុ

ហើយ ប្រារព្ធអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើមនោះឯង ទើបប្រព្រឹត្តទៅក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើមដោយពិត ។

អហេតុកមនោវិញ្ញាណធាតុដែលជាកុសលវិបាក សហគតៈដោយសោមនស្ស ក៏ឈ្មោះថា **ធម៌មានអារម្មណ៍ជាបរិត្តៈ** ព្រោះអត្ថថា ប្រារព្ធអារម្មណ៍ជាកាមាវចរ ៦ មានរូបារម្មណ៍ជាដើម ហើយប្រព្រឹត្តទៅដោយសច្ចភាព គឺដោយអំណាចជាសន្តីរណៈ (កិច្ច) ក្នុងទ្វារទាំង ៥ ដោយអំណាចនៃតទារម្មណ៍ក្នុងទ្វារទាំង ៦ ។

អហេតុកមនោវិញ្ញាណធាតុដែលជាកុសលវិបាក និងអកុសលវិបាកទាំង ២ ក៏ឈ្មោះថា **ធម៌មានអារម្មណ៍ជាបរិត្តៈ** ព្រោះអត្ថថា ប្រារព្ធកាមាវចរារម្មណ៍ ៦ មានរូបជាដើមនោះឯងដោយពិត ហើយប្រព្រឹត្តទៅដោយសន្តីរណៈក្នុងបញ្ចទ្វារ ដោយអំណាចនៃតទារម្មណ៍ក្នុងទ្វារទាំង ៦; សូម្បីកាលបើប្រព្រឹត្តទៅ ដោយអំណាចនៃបដិសន្ធិ ក៏នៅតែធ្វើបរិត្តកម្ម ឬកម្មនិមិត្ត ឬក៏គតិនិមិត្តឱ្យជាអារម្មណ៍; កាលបើប្រព្រឹត្តទៅដោយអំណាចនៃចុតិក្នុងកាលជាទីបំផុត ដោយអំណាចនៃភវង្គក្នុងបវត្តិកាល ក៏ធ្វើបរិត្តារម្មណ៍នោះៗ ឯង ឱ្យជាអារម្មណ៍ ។

ឯសហេតុកកុសលវិបាកចិត្តុប្បាទ ៨ ដួង ឈ្មោះថា **ធម៌មានអារម្មណ៍ជាបរិត្តៈ** ព្រោះប្រារព្ធបរិត្តធម៌នេះឯង ឱ្យប្រព្រឹត្តទៅដោយអំណាចនៃតទារម្មណ៍ និង

ដោយអំណាចនៃបដិសន្ធិ ភវង្គ និងចុតិ តាមដែលបានពោលក្នុងអហេតុកមនោ-វិញ្ញាណធាតុ ដែលជាកុសលវិបាក និងអកុសលវិបាក ២ ដួងនោះៗ ឯង ។

កិរិយាមនោធាតុ (១) ឈ្មោះថា **ធម៌មានអារម្មណ៍ជាបរិត្តៈ** ព្រោះប្រារព្ធអារម្មណ៍មានរូបារម្មណ៍ជាដើមហើយប្រព្រឹត្តទៅក្នុងទ្វារ ៥ ។ អហេតុក-មនោវិញ្ញាណធាតុ ដែលសហគតៈដោយសោមនស្ស (១) ឈ្មោះថា **ធម៌មានអារម្មណ៍ជាបរិត្តៈ** ព្រោះប្រារព្ធធម៌មានរូបជាដើម ដែលជាកាមាវចរនោះឯងជាបច្ចុប្បន្នក្នុងទ្វារ ៦, សូម្បីជាអតីតៈ និងអនាគត នឹងធ្វើអាការៈដែលរីករាយហើយ ឱ្យប្រព្រឹត្តទៅដល់ព្រះខីណាស្រពទាំងឡាយក្នុងមនោទ្វារ ។

ចិត្តុប្បាទទាំង ២៥ នេះ ដោយអាការៈយ៉ាងនេះ គប្បីជ្រាបថា **មានអារម្មណ៍ជាបរិត្តៈ** (កាមារម្មណ៍) តែមួយចំណែកប៉ុណ្ណោះ ៕

## សម្តែងអំពីធម៌មានអារម្មណ៍ជាមហគ្គតៈជាដើម

ធម៌ គឺវិញ្ញាណញ្ចាយតនៈ និងនេវសញ្ញានាសញ្ញាយតនៈឈ្មោះថា **មានអារម្មណ៍ ជាមហគ្គតៈ** ព្រោះប្រារព្ធសមាបត្តិខាងក្រោមរបស់ខ្លួនៗ ហើយប្រព្រឹត្តទៅ ។ ធម៌ គឺមគ្គ និងផល ឈ្មោះថា **មានអារម្មណ៍ជាអប្បមាណៈ** ។

ចិត្តុប្បាទដែលជាញាណវិប្បយុត្ត ៨ គឺដែលជាកុសល ៤ ជាកិរិយា ៤ ឈ្មោះថា **ធម៌មានអារម្មណ៍ជាបរិត្តៈ** ក្នុងវេលាដែលព្រះសេក្ខបុគ្គល បុថុជ្ជន និងព្រះ

ខីណាស្រពប្រារព្ធកាមាវចរធម៌ក្នុងវេលាឱ្យទាន, ការពិចារណា, ការស្តាប់ធម៌ដោយមិនគោរពជាដើមហើយប្រព្រឹត្តទៅ, ឈ្មោះថា **មានអារម្មណ៍ជាមហគ្គតៈ** ក្នុងវេលាដែលពិចារណាធម៌មានបឋមជ្ឈានជាដើម ដែលស្ទាត់ជំនាញណាស់, ឈ្មោះថា **ជានវត្តព្វារម្មណ៍** ក្នុងការបញ្ញត្តិមានកសិណនិមិត្តជាដើម ។ ចិត្តុប្បាទដែលជាទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង ខាងអកុសល ឈ្មោះថា **មានអារម្មណ៍ជាបរិត្តៈ** ក្នុងវេលាដែលរីករាយភ្លើតភ្លើនដោយការយល់ឃើញកាមាវចរធម៌ ៥៥ ដួងថា "ជាសត្វមានអត្តា" ដូច្នេះ, ដែលឈ្មោះថា **មានអារម្មណ៍ជាមហគ្គតៈ** ក្នុងវេលាប្រារព្ធសហគតធម៌ ២៧ ដួង ហើយប្រព្រឹត្តទៅដោយអាការៈយល់ឃើញខុសនោះឯង, ឈ្មោះថា **មានអារម្មណ៍ជានវត្តព្វៈ** ក្នុងវេលាដែលប្រារព្ធបញ្ញត្តិធម៌ហើយឱ្យប្រព្រឹត្តទៅ ។ ចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្តគប្បីជ្រាបថា មានអារម្មណ៍ជា **បរិត្តៈ មហគ្គតៈ** និង **នវត្តព្វៈ** ក្នុងវេលាដែលប្រារព្ធធម៌ទាំងនោះហើយ ឱ្យប្រព្រឹត្តទៅដោយអំណាចនៃសេចក្តីរីករាយភ្លើតភ្លើនតែម្យ៉ាង ។ ឯចិត្តុប្បាទដែលជាបដិឃសម្បយុត្ត គប្បីជ្រាបថា **មានអារម្មណ៍ ជាបរិត្តៈ មហគ្គតៈ** និង **នវត្តព្វៈ** ក្នុងវេលាប្រព្រឹត្តទៅដោយអំណាចនៃទោមនស្ស ។ ចិត្តុប្បាទដែលសម្បយុត្តដោយវិចិកិច្ឆា គប្បីជ្រាបថា **មានអារម្មណ៍ជាបរិត្តៈ មហគ្គតៈ** និង **នវត្តព្វៈ** ក្នុងការប្រព្រឹត្តទៅដោយអំណាចនៃការមិនទម្លាក់ចិត្តចុះ ។ ចិត្តុប្បាទដែលសហគតៈដោយ

ឧទ្ធច្ចៈ ក៏គប្បីជ្រាបថា **មានអារម្មណ៍ជាបរិត្តៈ មហគ្គតៈ** និង **នវត្តព្វៈ** ក្នុងការប្រព្រឹត្តិទៅដោយអំណាចនៃការរវើរវាយ និងដោយអំណាចនៃការមិនស្ងប់ ។

ក៏បណ្ដាធម៌ទាំងនោះ សូម្បីតែធម៌មួយយ៉ាងរមែងមិនអាចប្រារព្ធអប្បមាណធម៌ ហើយឱ្យប្រព្រឹត្តទៅបាន; ព្រោះហេតុដូច្នោះ ធម៌ទាំងឡាយនោះឈ្មោះថា ន **អប្បមាណារម្មណា** = មានអារម្មណ៍ប្រមាណមិនបាន ។

ចិត្តុប្បាទដែលសម្បយុត្តដោយញាណ ៨ គឺខាងកុសល ៤, ខាងកិរិយា ៤ **មានអារម្មណ៍ជាបរិត្តៈ, មហគ្គតៈ** និង **នវត្តព្វៈ** ក្នុងវេលាដែលព្រះសេក្ខបុគ្គលបុថុជ្ជន និងព្រះខីណាស្រពប្រារព្ធធម៌ មានប្រការតាមដែលពោលហើយប្រព្រឹត្តទៅក្នុងការឱ្យទាន ការពិចារណា និងការស្ដាប់ធម៌ដោយគោរពជាដើម ។ ចិត្តុប្បាទដែលសម្បយុត្តដោយញាណ ៨ នោះ គប្បីជ្រាបថា **ជាធម៌មានអារម្មណ៍ប្រមាណមិនបាន** ក្នុងកាលនៃគោត្រភូ និងក្នុងការពិចារណាលោកុត្តរធម៌៕ ៕

## សម្ដែងអំពីចតុត្ថជ្ឈាន ១២ យ៉ាង

ក៏រូបាវចរចតុត្ថជ្ឈាននោះ ខាងកុសលក៏មាន, ខាងកិរិយាក៏មាននីមួយៗ ១២ យ៉ាង គឺ

-ចតុត្ថជ្ឈានដែលជាបាទក្នុងធម៌ទាំងពួង ១

-ចតុត្ថជ្ឈានប្រព្រឹត្តទៅក្នុងអាកាសកសិណ ១

-ចតុត្ថជ្ឈានប្រព្រឹត្តទៅក្នុងអាលោកកសិណ ១

-ចតុត្ថជ្ឈានប្រព្រឹត្តទៅក្នុងព្រហ្មវិហារ ១

-ចតុត្ថជ្ឈានប្រព្រឹត្តទៅក្នុងអានាបានៈ ១

-ចតុត្ថជ្ឈានប្រព្រឹត្តទៅក្នុងឥទ្ធិវិធៈ ១

-ចតុត្ថជ្ឈានប្រព្រឹត្តទៅក្នុងទិព្វសោត ១

-ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណ ១

-ចតុត្ថជ្ឈានប្រព្រឹត្តទៅក្នុងយថាកម្មូបគញ្ញាណ ១

-ចតុត្ថជ្ឈានប្រព្រឹត្តទៅក្នុងទិព្វចក្ខុញ្ញាណ ១

-ចតុត្ថជ្ឈានប្រព្រឹត្តទៅក្នុងបុព្វេនិវាសញ្ញាណ ១

-ចតុត្ថជ្ឈានប្រព្រឹត្តទៅក្នុងអនាគតំសញ្ញាណ ១ ។

បណ្តាចតុត្ថជ្ឈានទាំងនោះ ចតុត្ថជ្ឈានក្នុងកសិណ ៨ ឈ្មោះថា ចតុត្ថជ្ឈានជាបាទក្នុងធម៌ទាំងពួង, សេចក្តីថា ចតុត្ថជ្ឈានក្នុងកសិណ ៨ នោះ ជាបាទនៃវិបស្សនាខ្លះ, ជាបាទនៃអភិញ្ញាទាំងឡាយខ្លះ, ជាបាទនៃនិរោធខ្លះ, ជាបាទនៃវដ្តៈខ្លះ, ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ថា "ចតុត្ថជ្ឈានជាបាទក្នុងធម៌ទាំងពួង" ។

ចំណែកចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអាកាសកសិណ និងអាលោកកសិណ ជាបាទនៃវិបស្សនាខ្លះ, ជាបាទនៃអភិញ្ញាទាំងឡាយខ្លះ, ជាបាទនៃវដ្តៈខ្លះ, តែមិនជាបាទនៃនិរោធប៉ុណ្ណោះទេ; ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងព្រហ្មវិហារ និងអានា-

បានសមាធិ ជាបាទនៃវិបស្សនា និងជាបាទនៃវដ្តៈប៉ុណ្ណោះ, តែមិនជាបាទនៃអភិញ្ញាទាំងឡាយ និងមិនជាបាទនៃនិរោធឡើយ ។

បណ្តាចតុត្ថជ្ឈានទាំងនោះ ឈានដែលមានកសិណជាអារម្មណ៍ សូម្បីទាំង ១០ (កសិណ ១០) ឈ្មោះថា **នវត្តព្វារម្មណ៍** គឺមានអារម្មណ៍ដែលគប្បីពោលមិនបានដោយអំណាចនៃបរិត្តារម្មណ៍ជាដើម ព្រោះប្រារព្ធកសិណបញ្ញត្តិហើយប្រព្រឹត្តទៅ, ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងព្រហ្មវិហារ ក៏ឈ្មោះថា **នវត្តព្វារម្មណ៍** គឺមានអារម្មណ៍ដែលពោលមិនបាន ដោយអំណាចនៃបរិត្តារម្មណ៍ជាដើម, ព្រោះប្រារព្ធសត្តបញ្ញត្តិហើយប្រព្រឹត្តទៅ ។ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអនាបានសមាធិ ក៏ឈ្មោះថា **នវត្តព្វារម្មណ៍** គឺមានអារម្មណ៍ដែលពោលមិនបាន ដោយអំណាចនៃបរិត្តារម្មណ៍ជាដើម ព្រោះប្រារព្ធនិមិត្តហើយប្រព្រឹត្តទៅ ។

**ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងឥទ្ធិវិធៈ** រមែងមានអារម្មណ៍ជាបរិត្តៈ និងមហគ្គតៈ, តើយ៉ាងណា ? គឺថា ក្នុងកាលណា ព្រះយោគាវចរមានបំណងធ្វើកាយឱ្យអាស្រ័យចិត្តហើយមានប្រាថ្នាដើម្បីនឹងទៅ (ហោះទៅ) ដោយកាយដែលមើលមិនឃើញ ក៏ញ៉ាំងកាយឱ្យធ្លាក់ទៅដោយអំណាចនៃចិត្ត, រមែងតាំងទុក រមែងលើកកាយឡើងក្នុងមហគ្គតចិត្ត ក្នុងកាលនោះ ឥទ្ធិវិធៈនោះក៏មានអារម្មណ៍ជាបរិត្តៈ ព្រោះមានរូបកាយជាអារម្មណ៍ ព្រោះធ្វើអធិប្បាយថា មានអារម្មណ៍ដែលបានហើយដោយការប្រកប ។ **ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វសោត** មាន

**អារម្មណ៍ជាបរិត្តៈតែម្យ៉ាង** ក្នុងកាលណាព្រះយោគាវចរធ្វើចិត្តឱ្យអាស្រ័យកាយ មានបំណងនឹងទៅដោយកាយដែលមើលឃើញ ក៏ញុំាងចិត្តឱ្យធ្លាក់ទៅតាមអំណាចនៃកាយ, រមែងតាំងចិត្តដែលមានឈានជាបាទទុក គឺរមែងលើកឡើងតាំងទុកក្នុងរូបកាយ, ក្នុងកាលនោះ ឥទ្ធិវិធៈនោះ ក៏មានអារម្មណ៍ជាមហគ្គតៈ ព្រោះមានមហគ្គត-ចិត្តជាអារម្មណ៍ ដោយមានការធ្វើអធិប្បាយថា មានអារម្មណ៍ដែលបានដោយការប្រកប ។ **ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅដោយទិព្វសោត មានអារម្មណ៍ជាបរិត្តៈតែម្យ៉ាង** ព្រោះប្រារព្ធសំឡេងហើយប្រព្រឹត្តទៅ ។

**ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅដោយចេតោបរិយញ្ញាណ** មានអារម្មណ៍ជាបរិត្តៈ មហគ្គតៈ និងអប្បមាណៈ ។ យ៉ាងណា ? គឺថាក្នុងវេលាដែលដឹងចិត្ត ជាកាមាវចររបស់ជនដទៃ ចេតោបរិយញ្ញាណនោះ ក៏មានអារម្មណ៍ជាបរិត្តៈ; ក្នុងវេលាដែលដឹងរូបាវចរចិត្ត និងអរូបាវចរចិត្តរបស់ជនដទៃ **ក៏មានអារម្មណ៍ជាមហគ្គតៈ**; ក្នុងវេលាដែលដឹងមគ្គ និងផលរបស់ជនដទៃ **ក៏មានអារម្មណ៍ជាអប្បមាណៈ**; ក្នុងអធិការនេះ បុថុជ្ជន រមែងមិនដឹងចិត្តរបស់ព្រះសោតាបន្ន, សោតាបន្នរមែងមិនដឹងចិត្តរបស់សកទាគាមី, ដោយអាការៈយ៉ាងនេះ គប្បីជ្រាបរហូតដល់ព្រះអរហន្ត, តែព្រះអរហន្តរមែងដឹងចិត្តរបស់បុគ្គលទាំងអស់, ក៏អរិយ-បុគ្គលថ្នាក់ខ្ពស់ដទៃទៀត រមែងដឹងចិត្តរបស់បុគ្គលថ្នាក់ទាប គប្បីជ្រាបសេចក្តីផ្សេងគ្នាដូចពោលមកនេះ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងយថាកម្មូបគញ្ញាណ រមែងមានអារម្មណ៍ជាបរិត្តៈ ក្នុងវេលាដែលដឹងកម្មជាកាមាវចរ, មានអារម្មណ៍ជាមហគ្គតៈ ក្នុងវេលាដែលដឹងកម្មជារូបាវចរ និងអរូបាវចរ ។

**ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វចក្ខុ** មានអារម្មណ៍ជាបរិត្តៈតែម្យ៉ាង ព្រោះមានរូបជាអារម្មណ៍ ។

**ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងបុព្វេនិវាសញ្ញាណ** មានអារម្មណ៍ដែលជាបរិត្តៈ មហគ្គតៈ អប្បមាណ និងនវត្តព្វៈ ។ តើយ៉ាងណា ? គឺថា ក្នុងវេលាដែលតាមរឭកដល់ខន្ធជាកាមាវចរ បុព្វេនិវាសញ្ញាណនោះ **ក៏មានអារម្មណ៍ជាបរិត្តៈ**, ក្នុងវេលាដែលតាមរឭកដល់ខន្ធជារូបាវចរ និងជាអរូបាវចរ **ក៏មានអារម្មណ៍ជាមហគ្គតៈ**, ក្នុងវេលាដែលតាមរឭកដល់មគ្គដែលខ្លួនឯង ឬបុគ្គលដទៃចម្រើនហើយ ឬផលដែលខ្លួនឯង ឬក៏មនុស្សដទៃធ្វើឱ្យជាក់ច្បាស់ហើយក្នុងអតីតៈ **ក៏មានអារម្មណ៍ជាអប្បមាណៈ**, សូម្បីបុព្វេនិវាសញ្ញាណ ដោយការពិចារណាមគ្គផលនិព្វាន ដោយអំណាចនៃការតាមរឭកដល់ព្រះពុទ្ធ ព្រះអង្គមានវដ្តៈដែលដាច់ហើយយ៉ាងនេះថា “ព្រះសម្ពុទ្ធទាំងឡាយ ក្នុងអតីតៈចម្រើនមគ្គហើយ, ធ្វើផលឱ្យជាក់ច្បាស់ហើយ, បរិនិព្វានហើយដោយនិព្វានធាតុ” ដូច្នេះ **ក៏មានអារម្មណ៍ជាអប្បមាណៈ**, បុព្វេនិវាសញ្ញាណ **មានអារម្មណ៍ដែលមិនគប្បីពោល** (នវត្តព្វារម្មណ៍) ក្នុងវេលាដែលតាមរឭកនាម គោត្រ និងនិមិត្ត បឋវីកសិណជាដើម ដោយន័យមាន

ជាអាទិ៍ថា “ព្រះភគវាព្រះនាមថា **តិបស្សី** មានមកហើយក្នុងអតីតកាល, ព្រះនគររបស់ព្រះអង្គមាននាមថា **ពន្ធុមតី**, ព្រះរាជបិតាមានព្រះនាមថា ព្រះបាទ **ពន្ធុមរាជ**, ព្រះរាជមាតាព្រះនាមថា **ពន្ធុមតី**” ។

**សូម្បីក្នុងចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអនាគតំសញ្ញាណ ក៏ន័យនេះដែរ** ។

សេចក្ដីថា ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅ សូម្បីក្នុងអនាគតំសញ្ញាណនោះ **មានអារម្មណ៍ជាបរិត្តៈ** ក្នុងវេលាដែលដឹងថា “បុគ្គលនេះ ក្នុងអនាគតកាលនឹងកើតក្នុងកាមាវចរ” ដូច្នេះ ។ អនាគតំសញ្ញាណនោះ មានអារម្មណ៍ជាមហគ្គតៈ ក្នុងវេលាដែលដឹងថា “បុគ្គលនេះ ក្នុងអនាគតកាល នឹងកើតក្នុងរូបាវចរ ឬអរូបាវចរ”, **មានអារម្មណ៍ជាអប្បមាណៈ** ក្នុងវេលាដែលដឹងដល់បុគ្គលអ្នកមានវដ្តៈដែលដាច់ហើយថា “ក្នុងអនាគតកាលបុគ្គលនេះនឹងចម្រើនមគ្គ, នឹងធ្វើផលឱ្យជាក់ច្បាស់, នឹងបរិនិព្វានដោយនិព្វានធាតុ” ; ព្រមទាំងមានអារម្មណ៍ដែលមិនគប្បីពោល (ន-វត្តព្វារម្មណ៍) ក្នុងវេលាដែលដឹងឈ្មោះ និងគោត្រ ដោយន័យមានជាដើមថា “ក្នុងអនាគតកាល ព្រះភគវាព្រះនាមថា **មេត្តេយ្យៈ** នឹងទ្រង់ឧប្បត្តិឡើង, ព្រាហ្មណ៍នាមថា **សុព្រហ្ម** នឹងជាព្រះពុទ្ធបិតា, ព្រាហ្មណីនាមថា **ព្រហ្មវតី** នឹងជាព្រះពុទ្ធ-មាតា” ។

ចំណែកចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអរូបាវចរ និងចតុត្ថជ្ឈានក្នុងការអស់ទៅនៃអាសវៈទាំងឡាយ ខ្ញុំបានពោលទុកក្នុងព្រះបាលី ដែលមានមកហើយនុ៎ះឯង ។

អហេតុកមនោវិញ្ញាណធាតុជាកិរិយា ដែលសហគតៈដោយឧបេក្ខាជាបុរេចារិកប្រព្រឹត្តទៅខាងមុខនៃកុសលចិត្ត អកុសលចិត្ត និងកិរិយាចិត្តសូម្បីទាំងអស់នេះ ។ គប្បីជ្រាបសេចក្ដីផ្សេងគ្នានៃអារម្មណ៍របស់អហេតុកមនោវិញ្ញាណធាតុ ជាកិរិយាដែលសហគតៈដោយឧបេក្ខានោះ ដោយន័យដែលពោលទុកក្នុងកុសលចិត្ត អកុសលចិត្ត និងកិរិយាចិត្តទាំងនោះចុះ ។ តែក្នុងវេលាប្រព្រឹត្តទៅដោយអំណាចនៃវោដ្ឋព្វនៈក្នុងទ្វារ ៥ រមែងមានអារម្មណ៍ជាបរិត្តៈតែម្យ៉ាងប៉ុណ្ណោះ ។ ឈាន ៣ និងឈាន ៤ ដែលជារូបាវចរជាដើម មានអារម្មណ៍មិនគប្បីពោល (នវត្តព្វារម្មណ៍) ព្រោះប្រព្រឹត្តទៅក្នុងនវត្តព្វធម៌ (ធម៌ដែលមិនគប្បីពោល) ដោយសេចក្ដីជាបរិត្តធម៌ជាដើម ។ ព្រោះក្នុងឈាន ៣ និងឈាន ៤ នៃរូបាវចរនេះ រូបាវចរទាំងឡាយរមែងប្រព្រឹត្តទៅក្នុងបឋវីកសិណជាដើម, អាកាសានញ្ចាយតនៈ ក៏ប្រព្រឹត្តទៅក្នុងការបើកអាកាស, អាកិញ្ចញ្ញាយតនៈ ក៏ប្រព្រឹត្តទៅក្នុងការប្រាសចាកវិញ្ញាណ របស់អរូបជ្ឈានដូច្នេះឯង ៕

## សម្តែងអំពីមគ្គារម្មណត្តិកៈ

បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុង**មគ្គារម្មណត្តិកៈ** ដូចតទៅ ៖

ចិត្តុប្បាទដែលប្រកបដោយញាណ ៨ ដែលត្រាស់ទុកខាងដើម **ជាធម៌មានមគ្គជាអារម្មណ៍** ( មគ្គារម្មណ៍) ក្នុងវេលាដែលព្រះសេក្ខៈ និងអសេក្ខបុគ្គលពិចារណាមគ្គដែលខ្លួនចាក់ធ្លុះ, ដែលមិនមានហេតុ គឺមគ្គ ព្រោះមិនកើតព្រមដោយមគ្គ, តែឈ្មោះថា **មគ្គាធិបតិនោ** ( មានមគ្គជាអធិបតី) ដោយអំណាចនៃអារម្មណាធិបតី, ក្នុងកាលពិចារណានឹងធ្វើមគ្គ ដែលខ្លួនចាក់ធ្លុះហើយឱ្យមាំទាំ ក្នុងវេលាដែលធ្វើធម៌ដទៃទៀតឱ្យជាអារម្មណ៍មិនគប្បីពោលថា "មានមគ្គជាអារម្មណ៍" ដូច្នេះខ្លះ "មានមគ្គជាអធិបតី" ដូច្នេះខ្លះទេ ។ អរិយមគ្គ ៤ ជាធម៌មានហេតុ ជាមគ្គដោយចំណែកមួយ ព្រោះមានហេតុ ពោលគឺមគ្គ ឬហេតុដែលសម្បយុត្តដោយមគ្គ, តែក្នុងវេលាចម្រើនមគ្គ នឹងធ្វើវីរិយៈ ឬវីមង្សាឱ្យជាធំ ហើយកើតព្រមនឹងអធិបតី ក៏គប្បីមានមគ្គជាអធិបតី, ក្នុងវេលាដែលធ្វើឆន្ទៈ ឬចិត្តយ៉ាងណានីមួយឱ្យជាធំ ក៏មិនគប្បីពោលថា "មានមគ្គជាអធិបតី" ដូច្នេះឡើយ, ក្នុងរូបាវចរចតុត្ថជ្ឈាន ១២ យ៉ាង ចតុត្ថជ្ឈាន ៩ យ៉ាង មានចតុត្ថជ្ឈានដែលជាបាទក្នុងធម៌ទាំងពួងជាដើម មិនជាមគ្គារម្មណ៍ ( មិនមានមគ្គជាអារម្មណ៍), មិនជាមគ្គហេតុកៈ ( មិនមានហេតុគឺមគ្គ), មិនជាមគ្គាធិបតី ( មិនមានមគ្គជាអធិបតី) ។ ចំណែកចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណ, បុព្វេនិវាសញ្ញាណ និងអនាគតំសញ្ញាណ **មានមគ្គជា**

**អារម្មណ៍** ក្នុងវេលាដែលដឹងមគ្គចិត្តរបស់ព្រះអរិយៈទាំងឡាយ, តែមិនជាមគ្គ-ហេតុកៈ (មិនមានហេតុគឺមគ្គ) ព្រោះមិនកើតព្រមនឹងមគ្គ, មិនជាមគ្គាធិបតី (មិនមានមគ្គជាអធិបតី) ព្រោះមិនធ្វើមគ្គឱ្យធ្ងន់ហើយប្រព្រឹត្តទៅ ។

**សួរថា** ក៏ព្រោះហេតុអ្វី ចតុត្ថជ្ឈានទាំង ៣ នេះ ទើបមិនធ្វើមគ្គឱ្យធ្ងន់ ?

ឆ្លើយថា ព្រោះខ្លួនជាមហគ្គតៈ ។

ដូចយ៉ាងសត្វលោកទាំងអស់ ធ្វើព្រះរាជាឱ្យជាទីគោរព, ចំណែកមាតា និងបិតាមិនធ្វើការគោរព; ព្រោះមាតាបិតាទាំងនោះ ឃើញព្រះរាជាហើយ មិនក្រោកចាកអាសនៈ, មិនធ្វើអញ្ជលីជាដើម, រមែងហៅដោយន័យដែលហៅក្នុងវេលាទ្រង់នៅក្មេងនោះឯង យ៉ាងណា; សូម្បីចតុត្ថជ្ឈានទាំង ៣ ដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណជាដើម ក៏យ៉ាងនោះដែរ; រមែងមិនធ្វើមគ្គឱ្យធ្ងន់ ព្រោះភាវៈនៃខ្លួនជាមហគ្គតៈ ។

សូម្បីអហេតុកមនោវិញ្ញាណធាតុដែលជាកិរិយា (មនោទ្វារាវជ្ជនចិត្ត) ក៏ជាមគ្គារម្មណ៍ គឺមានមគ្គជាអារម្មណ៍ ព្រោះវេលាពិចារណាមគ្គរបស់ព្រះអរិយៈទាំងឡាយ ជាបុរេចារិករបស់បច្ចវេក្ខណៈ, តែមិនជាមគ្គហេតុកៈ (មិនមានហេតុនៃមគ្គ) ព្រោះមិនកើតព្រមដោយមគ្គ, មិនជាមគ្គាធិបតី (មិនមានមគ្គជាអធិបតី) ព្រោះមិនធ្វើមគ្គឱ្យធ្ងន់ហើយប្រព្រឹត្តទៅ ។

**សួរថា** ព្រោះហេតុអ្វី ទើបចិត្តនេះ មិនធ្វើមគ្គឱ្យធ្ងន់ ?

ឆ្លើយថា ព្រោះភាពនៃខ្លួនជាអហេតុកៈ ជាសភាពអន់ ជាការល្ងង់ ។ ដូចព្រះរាជាដែលប្រជារាស្ត្រទាំងពួងតែងគោរព, តែក្មេងអ្នកទទួលបម្រើ មានមនុស្សគមជាដើម ដែលរាជបរិវារមិនបានធ្វើសេចក្ដីគោរពយ៉ាងក្រៃលែងដូចជាបណ្ឌិត ព្រោះភាពនៃខ្លួនជាមនុស្សល្ងង់ យ៉ាងណា, សូម្បីចិត្តនេះ ក៏យ៉ាងនោះដែរ រមែងមិនធ្វើមគ្គឱ្យធ្ងន់ ព្រោះខ្លួនជាអហេតុកៈ ជាសភាពថោកទាប ជាសេចក្ដីល្ងង់ ។

ចិត្តុប្បាទដែលជាកុសល មិនប្រកបដោយញាណជាដើម រមែងមិនបានអារម្មណ៍ មានមគ្គារម្មណ៍ជាដើម ព្រោះមិនមានញាណ និងព្រោះមានអារម្មណ៍ជាលោកិយធម៌, គប្បីជ្រាបថា ចិត្តុប្បាទនេះរមែងជានវត្តព្វារម្មណ៍តែប៉ុណ្ណោះឯង ៕៚

## សម្ដែងអំពីអតីតារម្មណត្តិកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង **អតីតារម្មណត្តិកៈ** ដូចតទៅ ៖

ធម៌ គឺវិញ្ញាណញ្ចាយតនៈ និងនេវសញ្ញានាសញ្ញាយតនៈ **ជាធម៌មានអារម្មណ៍ ជាអតីតៈដោយចំណែកមួយប៉ុណ្ណោះ** ព្រោះប្រារព្ធកាន់យកសមាបត្តិដែលជាអតីតៈខាងដើមហើយប្រព្រឹត្តទៅ ។

បទថា **“និយោគា អនាគតារម្មណា នត្ថិ** = ធម៌ដែលមានអារម្មណ៍ ជាអនាគតដោយចំពោះមិនមាន” សេចក្ដីថា ឈ្មោះថា ចិត្តដែលមានអារម្មណ៍ចំពោះអនាគតដែលកំណត់សង្ស៊ឹមទុកមិនបាន។ ***សួរថា*** ក៏អនាគតំសញ្ញាណ មានអារម្មណ៍

ជាអនាគតដោយចំណែកមួយ, សូម្បីចិត្តដែលជាចេតោបរិយញ្ញាណ ក៏ប្រារព្ធអនាគតហើយប្រព្រឹត្តទៅមិនមែនឬ ? ឆ្លើយថា មិនមែនមិនប្រារព្ធហើយប្រព្រឹត្តទៅទេ, តែចិត្តដែលជាអនាគតំសញ្ញាណ និងចេតោបរិយញ្ញាណនេះ មានអារម្មណ៍ចំពោះតែមួយដួងមិនបាន, មានតែអារម្មណ៍ដែលជាមិស្សកៈដោយមហគ្គតចិត្តដទៃៗ ព្រោះទ្រង់សង្គ្រោះទុកដោយរូបាវចរចតុត្ថជ្ឈាន; ដោយហេតុនោះ ទើបត្រាស់ថា **“និយោគា អនាគតារម្មណា នត្ថិ** = ធម៌ដែលមានអារម្មណ៍ដោយចំពោះ មិនមានឡើយ” ។

ទ្វិបញ្ចវិញ្ញាណ (វិញ្ញាណ ១០) និងមនោធាតុ ៣ ឈ្មោះថា មានអារម្មណ៍ជាបច្ចុប្បន្ន ព្រោះប្រព្រឹត្តទៅក្នុងអារម្មណ៍ មានរូបារម្មណ៍ជាដើមដែលជាបច្ចុប្បន្ន ។

ក្នុងបទថា **“ទសចិត្តុប្បាទា** = ចិត្តុប្បាទដែលជាវិបាក ១០” នេះ បានដល់សហេតុកវិបាក ៨ ដួង ឈ្មោះថា **មានអារម្មណ៍ជាអតីតៈប៉ុណ្ណោះ** ក្នុងការដែលប្រារព្ធកម្ម ឬកម្មនិមិត្តក្នុងការចាប់បដិសន្ធិរបស់ពួកទេវតា និងមនុស្សហើយប្រព្រឹត្តទៅ; សូម្បីក្នុងវេលាជាភវង្គ និងចុតិ ក៏ន័យនេះដែរ ។

តែថាក្នុងវេលាដែលចិត្តនេះ ប្រារព្ធគតិនិមិត្តហើយចាប់បដិសន្ធិ និងក្នុងវេលាដែលភវង្គតពីបដិសន្ធិមកជាបច្ចុប្បន្នារម្មណ៍ (មានអារម្មណ៍ជាបច្ចុប្បន្ន) ក្នុងខណៈដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ ដោយអំណាចនៃតទារម្មណ៍ ក៏មានអារម្មណ៍ជាបច្ចុប្បន្នដូចគ្នា, តែព្រោះទទួលអារម្មណ៍ពីជវ័ន ដែលមានអារម្មណ៍ជាអតីតៈ អនា-

គត និងបច្ចុប្បន្នក្នុងមនោទ្វារហើយប្រព្រឹត្តទៅ ទើបមានអារម្មណ៍ជាអតីតៈ អនាគត និងបច្ចុប្បន្ន ។ សូម្បីក្នុងមនោវិញ្ញាណធាតុ ដែលសហគតៈដោយឧបេក្ខា ខាងកុសលវិបាកអហេតុកៈ ក៏មានន័យដូចគ្នានេះដែរ ។ ក្នុងអធិការនេះ មានសេចក្តីផ្សេងគ្នា យ៉ាងនេះ គឺមនោវិញ្ញាណធាតុ ដែលសហគតៈដោយឧបេក្ខាអហេតុកកុសលវិបាកនោះ ជាបដិសន្ធិរបស់មនុស្សទាំងឡាយ អ្នកខ្វាក់ពីកំណើតជាដើមក្នុងពួកមនុស្សតែម្យ៉ាង និងមានអារម្មណ៍ជាបច្ចុប្បន្នដោយអំណាចនៃការធ្វើសន្តីរណកិច្ច ក្នុងបញ្ចទ្វារ; ចំណែកមនោវិញ្ញាណធាតុ ដែលសហគតៈដោយសោមនស្សវិបាកអហេតុកៈ ជាធម៌មានអារម្មណ៍បច្ចុប្បន្ន ដោយអំណាចនៃការធ្វើសន្តីរណកិច្ច និងតទារម្មណកិច្ចក្នុងបញ្ចទ្វារ និងគប្បីជ្រាបថា មានអារម្មណ៍ដែលជាអតីតៈ អនាគត និងបច្ចុប្បន្នដោយអំណាចនៃតទារម្មណ៍ក្នុងមនោទ្វារ ដូចមនោវិញ្ញាណធាតុដែលជាសហេតុកវិបាកដូច្នោះ ។

ចំណែកអហេតុកមនោវិញ្ញាណធាតុដែលជាអកុសលវិបាក មានគតិដូចមនោវិញ្ញាណធាតុ ដែលសហគតៈដោយឧបេក្ខាអហេតុកកុសលវិបាកនោះឯង ។ តែក្នុងទីនេះមានសេចក្តីប្លែកគ្នាដូច្នេះថា អហេតុកមនោវិញ្ញាណធាតុ ខាងអកុសលវិបាកនោះ ប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ ភវង្គ និងចុតិរបស់ពួកសត្វក្នុងអបាយភូមិទាំងឡាយតែម្យ៉ាង ។ អហេតុកមនោវិញ្ញាណធាតុខាងកិរិយា សហគតៈដោយសោមនស្ស កាលបើធ្វើអាការៈរីករាយរបស់ព្រះខីណាស្រពទាំងឡាយក្នុងបញ្ចទ្វារ

ក៏ជាធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ។ ក្នុងវេលាប្រារព្ធធម៌ផ្សេងដោយអតីតៈជាដើម ក្នុងមនោទ្វារហើយប្រព្រឹត្តទៅ ដោយអំណាចនៃហសិតុប្បាទកិច្ច ក៏ជាធម៌មានអារម្មណ៍ជាអតីតៈ អនាគត និងបច្ចុប្បន្ន ៕ ៕

## សម្តែងអំពីចិត្តុប្បាទកាមាវចរកុសល ៨

គប្បីជ្រាបបទមានជាអាទិ៍ថា **កាមាវចរកុសលំ** (កាមាវចរកុសល) តទៅ ៖

**ពោលដោយកុសលជាមុន** ចិត្តុប្បាទដែលសម្បយុត្តដោយញាណ ៤ ដួង របស់ព្រះសេក្ខៈ និងបុថុជ្ជនអ្នកពិចារណាខន្ធ ធាតុ និងអាយតនៈ ដែលផ្សេងដោយអតីតៈជាដើម រមែងជាធម៌មានអារម្មណ៍ជាអតីតៈ អនាគត និងបច្ចុប្បន្ន, ក្នុងខណៈពិចារណាបញ្ញត្តិ និងព្រះនិព្វានជានវត្តព្វារម្មណ៍ គឺជាធម៌មានអារម្មណ៍មិនគប្បីពោលឡើយ ។ សូម្បីក្នុងចិត្តុប្បាទដែលជាញាណវិប្បយុត្ត ក៏ន័យនេះដែរ ។ ក្នុងអធិការនេះ ការពិចារណា មគ្គ ផល និងនិព្វាន ដោយចិត្តុប្បាទដែលជាញាណវិប្បយុត្តនោះមិនមានទេ; នេះជាការផ្សេងគ្នាតែម្យ៉ាងប៉ុណ្ណោះ ។

**ពោលដោយអកុសល** ចិត្តុប្បាទដែលជាទិដ្ឋិគតសម្បយុត្ត ៤ ជាធម៌មានអារម្មណ៍ជាអតីតៈជាដើម ក្នុងវេលាដែលចិត្តរីករាយភ្លើតភ្លើន និងមានសេចក្តីប្រកាន់ខុសនូវខន្ធ ធាតុ និងអាយតនៈ ដែលផ្សេងដោយខន្ធអតីតៈជាដើម, រមែងជាធម៌មានអារម្មណ៍មិនគប្បីពោល (នវត្តព្វារម្មណ៍) របស់បុគ្គលអ្នករីករាយភ្លើត

ភ្លើនប្រារព្ធបញ្ញត្តិ តែងប្រកាន់ថា “ជាសត្វ ជាអត្តា” ដូច្នេះ ។ សូម្បីក្នុងចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្តក៏មាននន័យដូចគ្នានេះដែរ ។ ក្នុងទីនេះ ការប្រកាន់ខុសដោយចិត្តុប្បាទ ដែលជាទិដ្ឋិវិប្បយុត្តមិនមានត្រឹមតែម្យ៉ាងប៉ុណ្ណេះទេ ។

ចិត្តុប្បាទដែលជាបដិឃសម្បយុត្ត ២ ដួង រមែងជាធម៌មានអតីតៈជាដើមជាអារម្មណ៍ ដល់បុគ្គលអ្នកទោមនស្សហើយប្រារព្ធធម៌ ដែលផ្សេងដោយអតីតខន្ធជាដើម, ជាធម៌មានអារម្មណ៍មិនគប្បីពោលដល់បុគ្គល អ្នកមានទោមនស្សហើយប្រារព្ធបញ្ញត្តិមកជាអារម្មណ៍ ។ ចិត្តុប្បាទដែលសម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈក្នុងខណៈប្រព្រឹត្តទៅក្នុងធម៌ទាំងឡាយយ៉ាងនោះឯង ដោយសេចក្តីជាធម៌ដែលចូលចិត្តមិនបាន, ឯសេចក្តីរវើរវាយ ក៏ជាធម៌មានអារម្មណ៍ជាអតីតៈ អនាគត បច្ចុប្បន្ន និងនវត្តព្វារម្មណ៍ ។

**ពោលដោយកិរិយា** សហេតុកចិត្តុប្បាទ ៨ មានគតិដូចកុសលចិត្តុប្បាទនោះដែរ; កិរិយាអហេតុកមនោវិញ្ញាណធាតុ ដែលសហគតៈដោយឧបេក្ខាក្នុងខណៈប្រព្រឹត្តទៅ ដោយអំណាចនៃការធ្វើវោដ្ឋព្វនកិច្ចក្នុងបញ្ចទ្វារ ជាធម៌មានអារម្មណ៍ជាបច្ចុប្បន្នប៉ុណ្ណោះ, ក្នុងវេលាដែលជាបុរេចារិករបស់ជវនចិត្ត ដែលមានធម៌ជាអតីតៈ អនាគត បច្ចុប្បន្នជាអារម្មណ៍ និងមានបញ្ញត្តិជាអារម្មណ៍ក្នុងមនោទ្វារ ចិត្តនេះក៏ជាធម៌មានអារម្មណ៍ជាអតីតៈ អនាគត បច្ចុប្បន្ន និងនវត្តព្វារម្មណ៍៕

## សម្តែងអំពីចិត្តុប្បាទជារូបាវចរចតុត្ថជ្ឈាន

ក្នុងចតុត្ថជ្ឈានដែលជារូបាវចរ មានប្រភេទតាមដែលពោលហើយ ចតុត្ថ-ជ្ឈានទាំង ៥ នេះ គឺចតុត្ថជ្ឈានដែលជាបាទនៃធម៌ទាំងពួង ១, ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអាកាសកសិណ ១, ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអាលោកកសិណ ១, ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងព្រហ្មវិហារ ១, ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអានាបានសមាធិ ១ ជានវត្តព្វារម្មណ៍ (ធម៌មានអារម្មណ៍មិនគប្បីពោល) មែនពិត។ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងឥទ្ធិវិធៈ ជាធម៌មានអតីតៈជាអារម្មណ៍ ព្រោះភាវៈនៃយោគាវចរបុគ្គល អ្នកញ៉ាំងចិត្តឱ្យផ្លាស់ទៅតាមអំណាចនៃការប្រារព្ធឈានចិត្តក្នុងអតីតៈជាបាទហើយឱ្យប្រព្រឹត្តទៅ, តែជាធម៌មានអារម្មណ៍ជាអនាគត ដល់យោគាវចរបុគ្គលអ្នកអធិដ្ឋានធម៌ដែលជាអនាគត ដូចព្រះមហាកស្សបត្ថេរជាដើម អធិដ្ឋានក្នុងគ្រាបញ្ចុះព្រះបរមសារីរិកធាតុ ក៏មានអារម្មណ៍ជាអនាគត ។

បានឮថា ព្រះមហាកស្សបត្ថេរ កាលបើបញ្ចុះព្រះបរមសារីរិកធាតុ បានអធិដ្ឋានថា “ក្នុងអនាគតកាលរហូតដល់ ២១៨ ឆ្នាំ សូមក្លិនក្រអូបទាំងនេះ កុំវិនាសទៅ, ផ្កាឈើទាំងឡាយកុំស្វិតស្រពោន, ប្រទីបទាំងឡាយកុំរលត់អី” [១២៨] ដូច្នេះ, វត្ថុទាំងអស់បានហាក់ដូចជាការអធិដ្ឋាននោះឯង [*] ។ ព្រះអស្សគុត្តត្ថេរ

---

[១២៨] វិសុទ្ធិ. ២ (អភិញ្ញានិទ្ទេស) ។

[*] ត្រង់ស្តូបដែលលោកបានអធិដ្ឋាននេះ មានឈ្មោះថា **អជាតស្តូប** នៅក្នុងក្រុងរាជគ្រឹះ (អត្ថនោម័ត)

ឃើញពួកភិក្ខុសង្ឃដែលឆាន់ភត្តាហារសុទ្ធ (បាយសុទ្ធ) ក្នុងសេនាសនៈរោងឆាន់ ទើបអធិដ្ឋានថា "សូមត្រពាំងទឹកចូរជារសនៃទឹកដោះជូរ ក្នុងវេលាបុរេភត្តរាល់ៗថ្ងៃ" , ទឹកដែលធ្លាក់មកក្នុងវេលាបុរេភត្ត ទើបមានរសជាទឹកដោះជូរ, ក្នុងវេលាបច្ឆាភត្ត ទឹកនោះ ក៏ក្លាយជាទឹកប្រក្រតីដូចដើមវិញ; តែក្នុងវេលាដែលព្រះយោគីបុគ្គលធ្វើកាយឱ្យអាស្រ័យចិត្ត (គឺប្រព្រឹត្តទៅរហ័សដូចចិត្ត) ហើយទៅដោយកាយដែលមើលមិនឃើញ ឬថា ក្នុងវេលាដែលធ្វើបាដិហារ្យដទៃ, ចតុត្ថជ្ឈាននោះក៏ជាធម៌ មានអារម្មណ៍ជាបច្ចុប្បន្ន ព្រោះប្រារព្ធកាយហើយប្រព្រឹត្តទៅ ។

**ចតុត្ថជ្ឈានដែលជាទិព្វសោត** ជាធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ព្រោះប្រារព្ធសំឡេងដែលកំពុងតែមាននោះហើយប្រព្រឹត្តទៅ ។ **ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណ** រមែងជាធម៌មានអារម្មណ៍ជាអតីតៈ និងជាធម៌មានអារម្មណ៍ជាអនាគតដល់បុគ្គលអ្នកដឹងចិត្តរបស់បុគ្គលដទៃក្នុងអតីតៈខាងក្នុង ៧ ថ្ងៃ និងក្នុងអនាគតខាងក្នុង ៧ ថ្ងៃ, តែក្នុងវេលាហួស ៧ ថ្ងៃហើយ ក៏មិនអាចដើម្បីនឹងដឹងចិត្តនោះបាន; ព្រោះថា នេះជាវិស័យរបស់អតីតំសញ្ញាណ និងអនាគតំសញ្ញាណ, មិនជាវិស័យរបស់ចេតោបរិយញ្ញាណទេ; តែក្នុងវេលាដែលដឹងចិត្តបច្ចុប្បន្នរបស់មនុស្សដទៃនេះ ក៏ជាធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ៕ ៕

## សម្តែងអំពីបច្ចុប្បន្នកាល ៣ យ៉ាង

ឈ្មោះថា បច្ចុប្បន្ននេះ មាន ៣ យ៉ាង គឺ

១-ខណបច្ចុប្បន្ន

២-សន្តតិបច្ចុប្បន្ន

៣-អទ្ធាបច្ចុប្បន្ន ។

បណ្តាបច្ចុប្បន្នទាំង ៣ នោះ បច្ចុប្បន្នដែលដល់ឧប្បាទខណៈ ឋិតិខណៈ និង ភង្គខណៈ ឈ្មោះថា **ខណបច្ចុប្បន្ន** ។ បច្ចុប្បន្នរាប់បញ្ចូលដោយវារៈប្រព្រឹត្តទៅជាប់តគ្នាអស់ ១ ឬ ២ វារៈ ឈ្មោះថា **សន្តតិបច្ចុប្បន្ន** ។

ក្នុងខសន្តតិបច្ចុប្បន្ននោះ កាលបើបុគ្គលអង្គុយក្នុងទីងងឹតហើយ ចេញមកកាន់ទីភ្លឺ អារម្មណ៍មិនទាន់ជាក់ច្បាស់ភ្លាមទេ, អារម្មណ៍នោះនឹងប្រាកដច្បាស់ដរាបណា, ខាងក្នុងចន្លោះនេះ គប្បីជ្រាបវារៈដែលតជាប់គ្នាអស់ ១ ឬ ២ វារៈ; កាលបើបុគ្គលត្រាច់ទៅក្នុងទីវាល (ភ្លឺ) ហើយចូលទៅកាន់បន្ទប់តូច (បន្ទប់ងងឹត) រូបារម្មណ៍ ក៏នៅមិនប្រាកដច្បាស់ភ្លាមទេ, រូបារម្មណ៍នោះ នៅមិនប្រាកដច្បាស់ដរាបណា, ខាងក្នុងចន្លោះនេះ គប្បីជ្រាបវារៈការបន្តអស់ ១ វារៈ ឬ ២ វារៈ; ក៏កាលបើបុគ្គលឈរនៅទីឆ្ងាយ សូម្បីឃើញការកម្រើកដៃរបស់ពួកជាងជ្រលក់ និងការកម្រើកដៃគោះជង់ វាយស្គរ ក៏នៅតែមិនបានឮសំឡេងភ្លាមទេ; លុះមិនទាន់ឮដរាបណា សូម្បីក្នុងចន្លោះនេះ ក៏គប្បីជ្រាបការបន្ត ១ ឬ ២ វារៈ ។ លោក

**មជ្ឈិមភាណកាចារ្យ** ពោលទុកយ៉ាងនេះសិន ។ ចំណែក**សំយុត្តភាណកាចារ្យ** ពោលដល់សន្តតិ ២ យ៉ាង គឺ រូបសន្តតិ និងអរូបសន្តតិ ហើយពោលថា “រលកទឹកដែលបុគ្គលដើរឆ្លងទឹកលុយទៅកាន់ច្រាំង នៅមិនទាន់ថ្លាឆ្វង់ដរាបណា កាលបើបុគ្គលមកពីផ្លូវឆ្ងាយ ភាពក្តៅក្នុងកាយនៅមិនស្ងប់ទៅដរាបណា នេះឈ្មោះថា រូប-សន្តតិ (ការបន្តនៃរូប), កាលបើបុគ្គលមកពីហាលថ្ងៃ ចូលទៅកាន់បន្ទប់ សេចក្តីងងឹតមិនទាន់ទៅប្រាសដរាបណា, កាលបើបុគ្គលមនសិការកម្មដ្ឋានខាងក្នុងបន្ទប់ បើកបង្អួចក្រឡេកមើលថ្ងៃ ការញាប់ញ័រ (ព្រិល) នៃភ្នែកនៅមិនស្ងប់ដរាបណា នេះក៏ឈ្មោះថា រូបសន្តតិ; វារៈនៃជវនៈ ២-៣ ឈ្មោះថា អរូបសន្តតិ (ការបន្តនៃនាម) ហើយពោលថា “សូម្បីសន្តតិទាំង ២ នេះ ឈ្មោះថា បច្ចុប្បន្ន” ។

ចំណែកបច្ចុប្បន្នដែលកំណត់ដោយភពមួយឈ្មោះថា **អទ្ធាបច្ចុប្បន្ន**, ក្នុងភទ្ទេករត្តសូត្រ ព្រះមហាកច្ចាយនត្ថេរសំដៅយកអទ្ធាបច្ចុប្បន្ន ដែលព្រះភគវាត្រាស់ទុកថា “**យោ ចាវុសោ មនោ យេ ច ធម្មា សម្បយុត្តា, ឧភយមេតំ បច្ចុប្បន្នំ តស្មឹ ចេ បច្ចុប្បន្នេ ។ បេ ។ ធម្មេសុ សំហិរតិ** = ម្នាលលោកអ្នកមានអាយុទាំងឡាយ បើបុគ្គលមានសេចក្តីដឹងខ្លួន មានវិញ្ញាណរាប់បញ្ចូលដោយឆន្ទរាគៈក្នុងមនោ និងធម៌ដែលសម្បយុត្តគ្នាទាំងពីរយ៉ាង ជាបច្ចុប្បន្ននោះ, ព្រោះសេចក្តីដឹងខ្លួនរាប់បញ្ចូលដោយឆន្ទរាគៈ, បុគ្គលទើបភ្លើតភ្លើនក្នុងមនោ និងធម៌នោះ,

កាលបើភ្លើតភ្លើន ទើបឈ្មោះថា វង្វេងវង្វាងក្នុងធម៌ដែលជាបច្ចុប្បន្ន"[១២៩] ។

ក៏ក្នុងបច្ចុប្បន្នដែលជាសន្តតិ និងអទ្ធាទាំងនេះ សន្តតិបច្ចុប្បន្នមកក្នុងអដ្ឋកថាទាំងឡាយ, អទ្ធាបច្ចុប្បន្នមកក្នុងព្រះសូត្រ ក្នុងខណបច្ចុប្បន្នជាដើមនោះ កេចិ-អាចារ្យទាំងឡាយពោលថា "ចិត្តដែលជាខណបច្ចុប្បន្ន រមែងជាអារម្មណ៍របស់ចេតោបរិយញ្ញាណ" ដូច្នេះ; ព្រោះហេតុអ្វី ? ព្រោះចិត្តរបស់លោកអ្នកមានឫទ្ធិ និងរបស់បុគ្គលដទៃកើតឡើងក្នុងឋានៈជាមួយគ្នា ។

ក៏សេចក្ដីឧបមារបស់កេចិអាចារ្យទាំងនោះ មានដូចតទៅនេះ ៖

បាច់ផ្កាដែលបុគ្គលបោះទៅក្នុងអាកាស ផ្កាមួយរមែងស៊កទងដោយទងរបស់ផ្កាឈើមួយទៀតបានមាំទាំ យ៉ាងណា, កាលបើព្រះយោគាវចរបុគ្គល ពិ-ចារណាចិត្តរបស់មហាជនដោយអំណាចជាដុំថា "យើងនឹងដឹងចិត្តរបស់មនុស្សដទៃ" ដូច្នេះ ក៏នឹងដឹងចិត្តរបស់បុគ្គលម្នាក់ដោយចិត្ត ១ ដួង ក្នុងឧប្បាទខណៈ ឬឋិតិខណៈ ឬក៏ភង្គខណៈបានពិតយ៉ាងនោះមែន; ក៏ពាក្យរបស់ពួកកេចិអាចារ្យនោះ លោកបដិសេធទុកក្នុងអដ្ឋកថាទាំងឡាយថា "មិនត្រឹមត្រូវឡើយ" ព្រោះចិត្ត ២ ដួង ដែលជាហេតុឱ្យបុគ្គលរឭកសូម្បី ១០០ ឆ្នាំ សូម្បី ១ សែនឆ្នាំ រមែងរឭកបាន និងរមែងដឹងបាន មិនមានឋានៈរួមគ្នា និងព្រោះទោសនៃការដល់ភាពជាអាវជ្ជនចិត្ត

---

[១២៩] ម. ឧ. ២២ ។

និងជវនចិត្ត មានអារម្មណ៍ផ្សេងគ្នាក្នុងឋានៈដែលមិនគួរប្រាថ្នា; ចំណែកសន្តតិ-បច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្ន គប្បីជ្រាបថា រមែងជាអារម្មណ៍ ។

បណ្តាសន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្នទាំងនោះ ពាក្យណាដែលពោលទុកក្នុងអដ្ឋកថាថា ចិត្តរបស់បុគ្គលដទៃណាក្នុងវេលាដែលបែកធ្លាយទៅ ២ - ៣ ជវន-វីថិដោយអំណាចនៃអតីតៈ និងអនាគតពីជវនវីថិបច្ចុប្បន្ន, សូម្បីចិត្តទាំងអស់នោះក៏ឈ្មោះថា **សន្តតិបច្ចុប្បន្ន**; ចំណែកអទ្ធាបច្ចុប្បន្ន គប្បីសម្តែងដោយវារៈនៃជវនដូច្នេះ ពាក្យនោះលោកពោលទុកល្អហើយ ។

ក្នុងពាក្យរបស់ព្រះអដ្ឋកថានោះ លោកសម្តែងទុកដូច្នេះ ៖

បុគ្គលអ្នកមានឫទ្ធិបំណងនឹងដឹងចិត្តរបស់បុគ្គលដទៃ រមែងនឹកដល់, ការនឹកដល់រមែងធ្វើខណបច្ចុប្បន្នឱ្យជាអារម្មណ៍ហើយ ក៏រលត់ទៅព្រមនឹងអារម្មណ៍នោះៗដែរ; តពីនោះក៏ជាជវន ៤-៥ ជវន, មានឥទ្ធិចិត្តជាដួងចុងក្រោយ, ចិត្តដ៏សេសជាកាមាវចរ, បណ្តាចិត្តទាំងអស់នោះ ចិត្តដែលរលត់ហើយនោះឯង រមែងជាអា-រម្មណ៍, ចិត្តទាំងនោះមិនមែនមានអារម្មណ៍ផ្សេងគ្នាទេ, រមែងមានអារម្មណ៍ដូចគ្នានោះឯង ព្រោះសភាពនៃចិត្តទាំងនោះ មានអារម្មណ៍ជាបច្ចុប្បន្នដោយអំណាចនៃអទ្ធាបច្ចុប្បន្ន, ក៏ឥទ្ធិចិត្តប៉ុណ្ណោះ រមែងដឹងចិត្តរបស់បុគ្គលដទៃសូម្បីក្នុងភាវៈមានអារម្មណ៍ជាមួយគ្នា, ចិត្តដទៃដឹងមិនបានទេ, ដូចចក្ខុវិញ្ញាណប៉ុណ្ណោះ រមែងឃើញរូបក្នុងចក្ខុទ្វារ, វិញ្ញាណក្រៅពីនោះ ឃើញមិនបានទេ, ព្រោះហេតុដូច្នោះ

ឥទ្ធិចិត្តនេះ ទើបជាធម៌មានអារម្មណ៍ជាបច្ចុប្បន្នដោយអំណាចនៃសន្តតិបច្ចុប្បន្ន និង អទ្ធាបច្ចុប្បន្ន មានប្រការដូច្នេះ ។

ម្យ៉ាងទៀត ក៏ព្រោះសន្តតិបច្ចុប្បន្ន រមែងប្រព្រឹត្តទៅក្នុងន័យនៃអទ្ធា-បច្ចុប្បន្ននោះឯង, ព្រោះហេតុដូច្នោះ ឥទ្ធិចិត្តនេះ បណ្ឌិតគប្បីជ្រាបថា ជាធម៌មាន អារម្មណ៍ជាបច្ចុប្បន្នដោយអំណាចនៃអទ្ធាបច្ចុប្បន្ននោះឯង ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងបុព្វេនិវាស គប្បីជ្រាបថាជាធម៌មានអារម្មណ៍ មិនគប្បីពោល (នវត្តព្វារម្មណ៍) សូម្បីការតាមរឭកដល់ឈ្មោះ និងគោត្រក្នុងការ ពិចារណាដល់និព្វាន និងនិមិត្តនោះឯង, គប្បីជ្រាបថាជាអតីតារម្មណ៍ គឺជាធម៌មាន អារម្មណ៍ជាអតីតៈនោះឯងក្នុងកាលដ៏សេស ។ សូម្បីចតុត្ថជ្ឈានដែលប្រព្រឹត្តទៅ ក្នុងយថាកម្មូបគញ្ញាណ ក៏ជាអតីតារម្មណ៍ដូចគ្នា ។

បណ្តាចតុត្ថជ្ឈានមានបុព្វេនិវាសញ្ញាណជាដើមនោះ បុព្វេនិវាសញ្ញាណ និង ចេតោបរិយញ្ញាណ ជាធម៌មានអារម្មណ៍ជាអតីតៈ ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា បណ្តាបុព្វេនិវាសញ្ញាណ និងចេតោបរិយញ្ញាណនោះ បុព្វេនិវាសញ្ញាណ ក៏ជាធម៌ មានខន្ធក្នុងអតីតៈ និងជាធម៌រាប់បញ្ចូលដោយខន្ធអ្វី ឈ្មោះថា មិនមែនជាអារម្មណ៍ ក៏មិនមែន, ព្រោះបុព្វេនិវាសញ្ញាណនោះ មានគតិស្មើដោយសព្វញ្ញុតញ្ញាណ ក្នុង ធម៌ទាំងឡាយ មានខន្ធ និងធម៌ដែលរាប់បញ្ចូលដោយខន្ធ ក្នុងអតីតៈជាអារម្មណ៍, ចំណែកចេតោបរិយញ្ញាណមានចិត្តដែលឆ្លងផុតទៅខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះ ជា

អារម្មណ៍ ព្រោះចេតោបរិយញ្ញាណនោះ រមែងមិនដឹងខន្ធដទៃ ឬធម៌ដែលរាប់បញ្ចូលដោយខន្ធ, តែដោយបរិយាយត្រាស់ថា មានមគ្គជាអារម្មណ៍ ព្រោះមានចិត្តសម្បយុត្តដោយមគ្គជាអារម្មណ៍, ចំណែកយថាកម្មូបគញ្ញាណជាមគ្គ គឺចេតនាក្នុងអតីតៈប៉ុណ្ណោះជាអារម្មណ៍ គប្បីជ្រាបសេចក្ដីផ្សេងគ្នាដូចពណ៌នាមកនេះ ។

ក្នុងឋានៈនេះ គប្បីជ្រាបន័យរបស់អដ្ឋកថា ដូចតទៅ ៖

ក៏ព្រោះត្រាស់ទុកក្នុងបដ្ឋានថា **"កុសលខន្ធជាបច្ច័យដល់ឥទ្ធិវិធិញ្ញាណ** ដល់ចេតោបរិយញ្ញាណ ដល់បុព្វេនិវាសានុស្សតិញ្ញាណ ដល់យថាកម្មូបគញ្ញាណ និងដល់អនាគតំសញ្ញាណដោយអំណាចនៃអារម្មណប្បច្ច័យ" [១៣០], ព្រោះហេតុដូច្នោះ សូម្បីខន្ធទាំង ៤ ទើបជាអារម្មណ៍របស់ចេតោបរិយញ្ញាណ និងយថាកម្មូបគញ្ញាណ សូម្បីក្នុងញាណទាំង ២ នោះ យថាកម្មូបគញ្ញាណ ក៏មានកុសល និងអកុសលនោះឯង ជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វចក្ខុ ឈ្មោះថាជាធម៌មានអារម្មណ៍ ជាបច្ចុប្បន្នតែប៉ុណ្ណោះ ព្រោះរមែងមានពណ៌ (វណ្ណៈ) ជាអារម្មណ៍ ។ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអនាគតំសញ្ញាណ ជាធម៌មានអារម្មណ៍ ជាអនាគតប៉ុណ្ណោះ; ព្រោះអនាគតំសញ្ញាណនោះ មានគតិដូចសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងឡាយដែល

---

[១៣០] អភិ. ។

មានខន្ធជាអនាគត និងធម៌ដែលរាប់បញ្ចូលដោយខន្ធក្នុងអនាគតជាអារម្មណ៍ ដូច បុព្វេនិវាសញ្ញាណ ។ បណ្តាចេតោបរិយញ្ញាណ និងអនាគតំសញ្ញាណទាំងនោះ សូម្បី ចេតោបរិយញ្ញាណ នឹងមានអារម្មណ៍ជាអនាគតក៏ពិតមែនហើយ, ក៏ប៉ុន្តែថា ចេតោ-បរិយញ្ញាណ ក៏ធ្វើចិត្តដែលកើតឡើងខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះឱ្យជាអារម្មណ៍; អនា-គតំសញ្ញាណនេះ រមែងធ្វើចិត្តដែលកើតឡើងខ្លះ ខន្ធដែលកើតឡើងខ្លះ ធម៌ដែល រាប់បញ្ចូលដោយខន្ធខ្លះ ក្នុងអនាគតទាំងសែនកប្បឱ្យជាអារម្មណ៍បាន ។

ឈាន ៣ និងឈាន ៤ ដែលជារូបាវចរជាដើម គប្បីជ្រាបថា នវត្តព្វារម្មណ៍ គឺជាធម៌មានអារម្មណ៍ គប្បីពោលមិនបានដោយចំណែកមួយ ព្រោះមិនប្រារព្ធធម៌ សូម្បីតែម្យ៉ាងក្នុងធម៌ដែលជាអតីតៈ អនាគត និងបច្ចុប្បន្នហើយឱ្យប្រព្រឹត្តទៅ ៕

## សម្តែងអំពីអជ្ឈត្តតិកៈជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ដែលជា **អជ្ឈត្តតិកៈ** ដូចតទៅ ៖

បទថា **"អនិន្ទ្រិយពទ្ធរូបញ្ច និព្វានញ្ច ពហិទ្ធា** = រូបដែលមិនជាប់ ដោយឥន្ទ្រិយ និងនិព្វានជាធម៌ខាងក្រៅ" នេះ ត្រាស់ថា ធម្មជាតិនេះ ឈ្មោះថា **ពហិទ្ធា** (ជាធម៌ខាងក្រៅ) ព្រោះមិនមានបរិយាយនៃធម៌ខាងក្នុង ដែលកើតក្នុង ខ្លួនដោយប្រការដែលថា ធម្មជាតិនេះនឹងចាត់ជាធម៌ខាងក្នុង ដោយបរិយាយណាៗ

មិនបាន, ដូចរូបដែលជាប់ដោយឥន្ទ្រិយ សូម្បីនឹងហៅថាជាធម៌ខាងក្រៅ ព្រោះមានក្នុងសន្តានរបស់បុគ្គលដទៃ ក៏រាប់ថា ជាធម៌ខាងក្នុង ព្រោះភាពនៃឥន្ទ្រិយរូបនោះ ជាធម្មជាតិជាប់ដោយសន្តានរបស់ខ្លួន មិនមែនព្រោះហេតុដែលមិនកើតត្រឹមតែខាងក្នុងខ្លួនទេ ។

ចំណែកក្នុង **អជ្ឈត្តារម្មណត្តិកៈ** ត្រាស់ថា ជាពហិទ្ធារម្មណ៍ (ធម៌មានអារម្មណ៍ជាខាងក្រៅ) ទ្រង់សម្តែងយកហេតុត្រឹមតែថា ការមិនកើតឡើងដល់ធម៌ត្រឹមតែខាងក្នុងរបស់ខ្លួន ។

ព្រះតម្រាស់ដែលត្រាស់ថា "**អាកិញ្ចញ្ញាយតនៈ** នឹងពោលថា មានអារម្មណ៍ជាខាងក្នុង ក៏មិនបាន" ជាដើម ព្រោះព្រះអង្គមិនព្រមទទួលសូម្បីនូវភាវៈដែលជាខាងក្នុង និងភាវៈដែលជាខាងក្រៅ សូម្បីទាំងខាងក្នុងទាំងខាងក្រៅនៃអារម្មណ៍របស់អាកិញ្ចញ្ញាយតនៈ ដោយហេតុត្រឹមតែការប្រាសចាកធម៌ខាងក្នុងប៉ុណ្ណោះ ។

បណ្តាធម៌មានអាកិញ្ចញ្ញាយតនៈជាដើមនេះ អាកិញ្ចញ្ញាយតនៈនេះឯងរមែងមិនជានវត្តព្វារម្មណ៍តែម្យ៉ាងទេ, សូម្បីអាវជ្ជនៈ សូម្បីឧបចារចិត្តទាំងឡាយរបស់អាកិញ្ចញ្ញាយតនៈនោះ សូម្បីចិត្តដែលពិចារណាអារម្មណ៍របស់អាកិញ្ចញ្ញាយតនៈនោះ សូម្បីអកុសលចិត្តទាំងឡាយ ដែលប្រព្រឹត្តទៅដោយអំណាចនៃសេចក្តីរីករាយជាដើម របស់អាកិញ្ចញ្ញាយតនៈទាំងអស់នោះ ក៏ជានវត្តព្វារម្មណ៍ (គឺជា

ធម៌មានអារម្មណ៍មិនគប្បីពោល) មែនពិត; ក៏ធម្មជាតិទាំងនេះ កាលបើត្រាស់ដល់អាកិញ្ចញ្ញាយតនៈហើយ ក៏ឈ្មោះថា ជាការដែលត្រាស់ហើយដូចគ្នា ព្រោះហេតុដូច្នោះទើបមិនបានត្រាស់ទុកមួយផ្នែក ។

**សួរថា** ឈ្មោះថា ការត្រាស់ហើយដូចគ្នា តើដូចម្ដេច ?

ឆ្លើយថា ក៏អាកិញ្ចញ្ញាយតនៈនេះ គប្បីមានអារម្មណ៍ដូចគ្នានឹងធម្មជាតិដែលជាបុរេចារិករបស់អាកិញ្ចញ្ញាយតនៈនោះ ដែលប្រព្រឹត្តទៅដោយអំណាចនៃធម៌មានអាវជ្ជនៈ និងឧបចារៈជាដើម, សូម្បីធម៌ទាំងអស់នោះ ក៏ត្រាស់ថា ជានវត្តព្វារម្មណ៍ គឺជាធម៌មានអារម្មណ៍មិនគប្បីពោលបាន ព្រោះក្នុង**អតីតារម្មណត្តិកៈ**ទ្រង់ធានាសភាពនៃចិត្តុប្បាទទាំងនេះ ដែលត្រាស់ទុកយ៉ាងនេះថា "កាមាវចរកុសល អកុសល កិរិយាចិត្តុប្បាទ ៩ ដួង និងចតុត្ថជ្ឈានដែលជារូបាវចរ" ដូច្នេះជានវត្តព្វារម្មណ៍ ដោយន័យមានជាអាទិ៍ថា "ធម៌ទាំងនេះ មិនគប្បីពោលថា មានអារម្មណ៍ជាអតីតៈទេ" និងព្រោះត្រាស់ដល់សភាពនៃអាកិញ្ចញ្ញាយតនៈគ្រាន់តែជានវត្តព្វារម្មណ៍ ដោយចំណែកមួយយ៉ាងនេះថា "ធម៌ទាំងនេះ គឺអាកិញ្ចញ្ញាយតនៈមគ្គ ៤ ដែលជាលោកុត្តរៈ និងសាមញ្ញផលសូម្បីទាំង ៤ មិនគប្បីពោលថា ជាអតីតារម្មណ៍ (គឺមិនគប្បីពោលថាជាធម៌មានអារម្មណ៍ជាអតីតៈ) " ដូច្នេះក៏មាន ។

ឥឡូវនេះ អាកិញ្ចញ្ញាយតនៈនោះ សូម្បីព្រះអង្គត្រាស់ទុកតែម្យ៉ាង ក្នុងអជ្ឈត្តារម្មណត្តិកៈ, តែព្រោះសេចក្ដីដែលកុសលមានកាមាវចរជាដើម ជានវត្តព្វា-

រម្មណ៍ (គឺជាធម៌មានអារម្មណ៍មិនគប្បីពោល) ទើបត្រាស់សំដៅដល់សូម្បីសេចក្ដីជាអារម្មណ៍ ដូចគ្នានឹងអាកិញ្ចញ្ញាយតនៈនោះក្នុងខាងក្រោយ, ព្រោះហេតុដូច្នោះទើបសម្ដែងសភាពនៃកុសលមានកាមាវចរជាដើមទាំងនោះ ជានវត្តព្វារម្មណ៍ សូម្បីក្នុងអជ្ឈត្តារម្មណត្តិកៈ ។ ពិតណាស់ ធម៌ណា១ នឹងជាការខ្វាស់ក្នុងសេចក្ដីដែលជាធម៌ មានកាមាវចរជាដើម ដែលជាអារម្មណ៍ដូចគ្នានឹងអាកិញ្ចញ្ញាយតនៈនោះ ជាន-វត្តព្វារម្មណ៍ កាលបើត្រាស់ដល់អាកិញ្ចញ្ញាយតនៈនេះដោយអាការៈយ៉ាងនេះហើយក៏គប្បីជ្រាបបានថា កុសលមានកាមាវចរនោះ ជាការដែលត្រាស់ទុកហើយដូចគ្នាដូច្នេះឯង ។ ពាក្យដ៏សេសក្នុងទីនេះដោយព្រះបាលីក្នុងអជ្ឈត្តារម្មណត្តិកៈ មានសេចក្ដីងាយស្រួលមែនពិត ៗ ។

## សម្ដែងអំពីការចែកអារម្មណ៍របស់ចិត្តុប្បាទ

ក៏ពោលដោយការចែកដោយអំណាចនៃអារម្មណ៍ ចិត្តុប្បាទទាំងនេះ គឺវិញ្ញាណញ្ចាយតនៈ និងនេវសញ្ញានាសញ្ញាយតនៈជា ៦ ដោយអំណាចនៃកុសលវិបាក និងកិរិយាសិន គប្បីជ្រាបថា មានអារម្មណ៍ជាខាងក្នុង (អជ្ឈត្តារម្មណ៍) ព្រោះប្រារព្ធសមាបត្តិខាងក្រោមដែលជាប់ដោយសន្តានរបស់ខ្លួនហើយប្រព្រឹត្តទៅ ។

ក៏បណ្ដាចិត្តុប្បាទទាំង ៦ នេះ អាកាសានញ្ចាយតនៈដែលជាកិរិយា រមែង

ជាអារម្មណ៍របស់វិញ្ញាណញ្ចាយតនៈ ដែលជាកិរិយាប៉ុណ្ណោះ មិនជាអារម្មណ៍របស់វិញ្ញាណញ្ចាយតនៈដែលជាកុសល និងវិបាកក្រៅនេះទេ; ព្រោះហេតុអ្វី ? ព្រោះបុគ្គលអ្នកព្រមព្រៀងដោយអាកាសានញ្ចាយតនកិរិយា មិនមានវិញ្ញាណញ្ចាយតនៈដែលជាកុសល និងវិបាកទេ ។ ក៏កុសលរមែងជាអារម្មណ៍ដល់កុសលវិបាក និងកិរិយាទាំង ៣ បាន; ព្រោះហេតុអ្វី ? ព្រោះភាពនៃបុគ្គលជាអ្នកញុំាងអាកាសានញ្ចាយតនកុសលឱ្យកើតឡើងហើយតាំងនៅ ឱ្យវិញ្ញាណញ្ចាយតនៈសូម្បីទាំង ៣ យ៉ាង កើតឡើងខ្ពស់ជាងការកើតរបស់អាកាសានញ្ចាយតនកុសលនោះ ។ ក៏វិបាករមែងមិនជាអារម្មណ៍របស់ចិត្តុប្បាទណា។ ឡើយ; ព្រោះហេតុអ្វី ? ព្រោះចិត្តក្នុងសមាបត្តិចេញចាកវិបាកហើយមិនមានអភិនីហារទេ ។ សូម្បីក្នុងការធ្វើឱ្យជាអារម្មណ៍របស់នេវសញ្ញានាសញ្ញាយតនៈ ក៏ន័យនេះដែរ ។ បណ្ឌិតគប្បីជ្រាបសភាពនៃចិត្តុប្បាទ សូម្បីទាំងអស់មានឈានទី ៣ និងទី ៤ ដែលជារូបាវចរជាដើមជាពហិទ្ធារម្មណ៍ គឺជាធម៌មានអារម្មណ៍ខាងក្រៅ ព្រោះប្រារព្ធបឋវីកសិណជាដើមដែលជាខាងក្រៅហើយ ប្រព្រឹត្តទៅដោយភាវៈជាខាងក្រៅពីធម៌ដែលជាខាងក្នុងរបស់ខ្លួន។

គប្បីជ្រាបវិនិច្ឆ័យក្នុងខថា **“សព្វេ ច កាមាវចរា កុសលាកុសលាព្យាកតា ធម្មា រូបាវចរចតុត្ថជ្ឈានំ** = កុសលធម៌ អកុសលធម៌ អព្យាកតធម៌ ដែលជាកាមាវចរទាំងអស់... រូបាវចរជ្ឈាន” នេះ ដូចតទៅ ៖

**ពោលដោយកុសល** ចិត្តុប្បាទដែលសម្បយុត្តដោយញាណ ៤ ដួង ជាធម៌មានអារម្មណ៍ខាងក្នុង (អជ្ឈត្តារម្មណ៍) ដល់អ្នកពិចារណាធម៌មានខន្ធជាដើម របស់ខ្លួន, ជាធម៌មានអារម្មណ៍ខាងក្រៅ (ពហិទ្ធារម្មណ៍) ក្នុងខណៈពិចារណាខន្ធជាដើមរបស់មនុស្សដទៃ, ឯក្នុងខណៈពិចារណាបញ្ញត្តិ និងព្រះនិព្វាន ជាធម៌មានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅ (អជ្ឈត្តពហិទ្ធារម្មណ៍) ដោយអំណាចនៃការពិចារណាធម៌ មានខន្ធជាដើមទាំងរបស់ខ្លួន និងរបស់បុគ្គលដទៃទាំងពីរនោះ ។ សូម្បីក្នុងញាណវិប្បយុត្ត ក៏ន័យនេះដែរ ។ ការពិចារណាព្រះនិព្វានរបស់កុសល ដែលជាញាណវិប្បយុត្តទាំងនោះតែម្យ៉ាងមិនមានទេ ។

**ពោលដោយអកុសល** ចិត្តុប្បាទដែលសម្បយុត្តដោយទិដ្ឋិ ៤ ដួង ជាធម៌មានអារម្មណ៍ខាងក្នុង នៅវេលាត្រេកអររីករាយ និងប្រកាន់សេចក្តីយល់ខុសក្នុងធម៌មានខន្ធជាដើមរបស់ខ្លួន, ជាធម៌មានអារម្មណ៍ខាងក្រៅ ក្នុងវេលាដែលប្រព្រឹត្តទៅយ៉ាងនោះឯងក្នុងខន្ធជាដើម និងក្នុងរូបកសិណដែលមិនទាក់ទងដោយឥន្ទ្រិយជាដើមរបស់បុគ្គលដទៃ, ជាធម៌មានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅ ដោយអំណាចនៃអារម្មណ៍ទាំងពីរនោះ; សូម្បីចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្តទាំងឡាយ ក៏មានន័យដូចគ្នានេះដែរ ។ កាលប្រកាន់សេចក្តីយល់ឃើញខុស រមែងមិនមានដល់ចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្តទាំងនោះតែម្យ៉ាងទេ ។ ចិត្តុប្បាទដែលសម្បយុត្តដោយបដិឃៈ ២ ដួង ជាធម៌មានអារម្មណ៍ខាងក្នុង ដល់បុគ្គលអ្នកមានទោមនស្សក្នុងខន្ធ

ជាដើមរបស់ខ្លួន ជាធម៌មានអារម្មណ៍ខាងក្រៅដល់បុគ្គលអ្នកមានទោមនស្ស ក្នុងខន្ធជាដើម និងក្នុងរូបបញ្ញត្តិដែលមិនទាក់ទងដល់ឥន្ទ្រិយរបស់បុគ្គលដទៃ, ជាធម៌មានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរ ។ សូម្បីចិត្តុប្បាទដែលសម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ក៏គប្បីជ្រាបថា មានសេចក្តីជាអារម្មណ៍ខាងក្នុងជាដើម ក្នុងវេលាប្រព្រឹត្តទៅដោយអំណាចនៃសេចក្តីសង្ស័យ និងការរវើរវាយក្នុងធម៌ទាំងឡាយ មានប្រការតាមដែលពោលហើយ ។

ចិត្តុប្បាទទាំង ១៣ ដូចនេះ គឺទ្វិបញ្ចវិញ្ញាណ ១០, មនោធាតុ ៣ ក្នុងវេលាដែលប្រារព្ធរូបជាដើមរបស់ខ្លួនហើយប្រព្រឹត្តទៅ ជាធម៌មានអារម្មណ៍ខាងក្នុង, ក្នុងវេលាប្រារព្ធរូបជាដើមរបស់បុគ្គលដទៃហើយប្រព្រឹត្តទៅ ជាធម៌មានអារម្មណ៍ខាងក្រៅ ជាធម៌មានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅដោយអំណាចទាំងពីរនោះ ។

អហេតុកវិបាកមនោវិញ្ញាណធាតុ ដែលសហគតៈដោយសោមនស្ស ជាធម៌មានអារម្មណ៍ខាងក្នុង ក្នុងវេលាប្រព្រឹត្តទៅហើយប្រារព្ធធម៌មានរូបជាដើម ៥ យ៉ាងរបស់ខ្លួនដោយអំណាចនៃសន្តីរណៈ និងតទារម្មណ៍ក្នុងបញ្ចទ្វារ និងក្នុងវេលាប្រព្រឹត្តទៅក្នុងកាមាវចរធម៌, សូម្បីធម៌ពួកដទៃដែលជាខាងក្នុង ដោយអំណាចនៃតទារម្មណ៍ ក្នុងមនោទ្វារនោះឯង, កាលបើប្រព្រឹត្តទៅក្នុងធម៌ទាំងឡាយពួកដទៃទៀត ក៏ជាធម៌មានអារម្មណ៍ខាងក្រៅ, ជាធម៌មានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរ ។ ក្នុងវិបាកអហេតុកមនោវិញ្ញាណធាតុដែល

សហគតៈដោយឧបេក្ខា សូម្បីទាំងពីរដួងក៏ន័យនេះដែរ; ក៏មនោវិញ្ញាណធាតុទាំងនេះ រមែងប្រព្រឹត្តទៅក្នុងកម្មជាដើម ដែលផ្សេងដោយអជ្ឈត្តធម៌ជាដើម សូម្បីដោយអំណាចនៃបដិសន្ធិ ភវង្គ និងចុតិក្នុងសុគតិភូមិប៉ុណ្ណោះ ។

មហាវិបាកចិត្ត ៨ ដួង ក៏មានគតិដូចវិបាកអហេតុកមនោវិញ្ញាណធាតុដែលសហគតៈដោយឧបេក្ខាសូម្បីទាំងពីរនោះដែរ; តែមហាវិបាកចិត្តទាំងនេះ មិនប្រព្រឹត្តទៅដោយអំណាចនៃសន្តីរណៈតែម្យ៉ាងទេ; រមែងប្រព្រឹត្តទៅក្នុងសុគតិភូមិដោយអំណាចនៃបដិសន្ធិ ភវង្គ និងចុតិរបស់សត្វទាំងនោះប៉ុណ្ណោះ អហេតុកកិរិយាដែលសហគតៈដោយសោមនស្សជាធម៌មានអារម្មណ៍ខាងក្នុង ក្នុងវេលាប្រារព្ធរូបជាដើមរបស់ខ្លួន ដោយអំណាចនៃការធ្វើអាការៈរីករាយក្នុងបញ្ចទ្វារ, ជាធម៌មានអារម្មណ៍ខាងក្នុង ហើយប្រព្រឹត្តទៅក្នុងរូបជាដើមរបស់បុគ្គលដទៃ, ជាធម៌មានអារម្មណ៍ខាងក្នុង ហើយប្រព្រឹត្តទៅដោយអំណាចនៃហសិតុប្បាទដល់ព្រះតថាគតព្រះអង្គទ្រង់ពិចារណាកិរិយា ដែលព្រះអង្គទ្រង់ធ្វើហើយក្នុងវេលាជា **ជោតិបាល-មាណព ស្តេចមឃទេវរាជ** និងកណ្ហតាបសជាដើមក្នុងមនោទ្វារ, ជាធម៌មានអារម្មណ៍ខាងក្រៅ ក្នុងវេលាប្រារព្ធការធ្វើកិរិយារបស់នាងមល្លិកាទេវី សន្តតិមហា-មាត្យ និងនាយសុមនមាលាការជាដើម ហើយប្រព្រឹត្តទៅ, ជាធម៌មានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរ ។

កិរិយាអហេតុកមនោវិញ្ញាណធាតុ ដែលសហគតៈដោយឧបេក្ខា ជាធម៌មាន

អារម្មណ៍ខាងក្នុងជាដើម ក្នុងវេលាប្រព្រឹត្តទៅក្នុងបញ្ចទ្វារដោយអំណាចនៃវោដ្ឋព្វនៈ និងក្នុងមនោទ្វារដោយអំណាចនៃអាវជ្ជនៈ; មហាកិរិយាចិត្តុប្បាទ ៨ ដួង មានគតិដូចកុសលចិត្តនោះដែរ ។ មហាកិរិយាចិត្តុប្បាទទាំងនោះ រមែងកើតឡើងដល់ព្រះខីណាស្រពតែម្យ៉ាង; ក្នុងកុសលចិត្តរមែងកើតដល់ព្រះសេក្ខៈ និងបុថុជ្ជន, ព្រោះហេតុដូច្នោះ ក្នុងខនេះ ទើបមានការធ្វើដែលផ្សេងគ្នា ដោយពាក្យមានប្រមាណប៉ុណ្ណេះ, ក្នុងរូបាវចរចតុត្ថជ្ឈានមានប្រការតាមដែលពោលហើយ ចតុត្ថជ្ឈានទាំង ៥ មានចតុត្ថជ្ឈានជាបាទក្នុងធម៌ទាំងពួងជាដើម រមែងបានឱកាសក្នុងតិកៈនេះ ។

ពិតមែន ឈានទាំង ៥ តាមដែលពោលហើយនេះ ជាពហិទ្ធារម្មណ៍ គឺជាធម៌មានអារម្មណ៍ខាងក្រៅ ព្រោះមានកសិណបញ្ញត្តិ និងនិមិត្តជាអារម្មណ៍ ។ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅនៅក្នុងឥទ្ធិវិធៈជាអជ្ឈត្តារម្មណ៍ គឺជាធម៌មានអារម្មណ៍ខាងក្នុង ព្រោះធ្វើកាយ និងចិត្តរបស់ខ្លួនឱ្យជាអារម្មណ៍ ក្នុងវេលាដែលញ៉ាំងចិត្តឱ្យធ្លាក់ទៅតាមអំណាចនៃកាយ ឬញ៉ាំងកាយឱ្យធ្លាក់ទៅតាមអំណាចនៃចិត្ត និងក្នុងវេលាដែលនិមិត្តរូបជាភេទកុមារជាដើមរបស់ខ្លួន, **មានអារម្មណ៍ខាងក្រៅ** (ពហិទ្ធារម្មណ៍) ក្នុងវេលាដែលសម្តែងរូបជាសត្វដំរី និងសេះជាដើមខាងក្រៅ, មានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅ (អជ្ឈត្តពហិទ្ធារម្មណ៍) ក្នុងវេលាដែលប្រព្រឹត្តទៅខាងក្នុង តាមកាលដែលគួរ និងក្នុងវេលាដែលប្រព្រឹត្តទៅខាងក្រៅ

តាមកាលដែលគួរ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វសោត **មានអារម្មណ៍ខាងក្នុង** (អជ្ឈត្តារម្មណ៍) ក្នុងពេលស្តាប់សំឡេងក្នុងពោះរបស់ខ្លួន, **មានអារម្មណ៍ខាងក្រៅ** (ពហិទ្ធារម្មណ៍) ក្នុងវេលាស្តាប់សំឡេងរបស់អ្នកដទៃ, **មានអារម្មណ៍ទាំងខាងក្នុង និង ខាងក្រៅ** (អជ្ឈត្តពហិទ្ធារម្មណ៍) ដោយអំណាចនៃអារម្មណ៍ទាំងពីរ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណ **មានអារម្មណ៍ខាងក្រៅ** តែម្យ៉ាង ព្រោះមានចិត្តអ្នកដទៃជាអារម្មណ៍, ក៏ការប្រើចេតោបរិយញ្ញាណនោះដឹងចិត្តរបស់ខ្លួនមិនបានឡើយ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងបុព្វេនិវាសញ្ញាណ ជាធម៌**មានអារម្មណ៍ខាងក្នុង** ក្នុងវេលាដែលតាមរឭកដល់ខន្ធរបស់ខ្លួន, ជាធម៌**មានអារម្មណ៍ខាងក្រៅ** ព្រោះតាមរឭកដល់ខន្ធរបស់មនុស្សដទៃ រូបដែលមិនជាប់ដោយឥន្ទ្រិយ និងបញ្ញត្តិទាំង ៣, ជាធម៌**មានអារម្មណ៍ទាំងខាងក្នុង** និង **ខាងក្រៅ** ដោយអំណាចនៃអារម្មណ៍ទាំងពីរ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វចក្ខុ ជាធម៌មានអារម្មណ៍ខាងក្នុង ក្នុងវេលាឃើញរូបក្នុងពោះរបស់ខ្លួនជាដើម, ជាធម៌មានអារម្មណ៍ខាងក្រៅ ក្នុងវេលាឃើញរូបដ៏សេស, ជាធម៌មានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអនាគតំសញ្ញាណ ជាធម៌មានអារម្មណ៍ខាងក្នុង ក្នុងវេលាដែលរឭកដល់ខន្ធដែលជាអនាគតរបស់ខ្លួន ជាធម៌មានអារម្មណ៍ខាងក្រៅ ក្នុងវេលារឭកដល់ខន្ធដែលជាអនាគតរបស់មនុស្សដទៃ ឬរូបដែលមិនជាប់ដោយឥន្ទ្រិយ ជាធម៌មានអារម្មណ៍ទាំងខាងក្នុង និងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរ ។

ហេតុដែលអាកិញ្ចញ្ញាយតនជ្ឈានជានវត្តព្វារម្មណ៍ គឺជាធម៌មិនគប្បីពោលខ្ញុំបានពោលទុកខាងក្រោយហើយដែរ ៕ ៕

## សម្តែងអំពីហេតុគោច្ឆកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ**ហេតុគោច្ឆកទុកៈ** ដូចតទៅ ៖

ព្រះមានជោគ លុះទ្រង់សម្តែងហេតុដោយន័យមានជាអាទិ៍ថា "**តយោ កុសលហេតូ**" ដូច្នេះ ហើយទ្រង់មានបំណងនឹងសម្តែងហេតុទាំងនោះឯង ដោយឋានៈនៃការកើតឡើងទៀត ទើបត្រាស់ព្រះតម្រាស់មានជាអាទិ៍ថា "**ចតូសុ ភូមីសុ កុសលេសុ ឧប្បជ្ជន្តិ** = កើតក្នុងកុសលទាំង ៤ ភូមិ" ។ ន័យរបស់ទេសនាសូម្បីក្នុងគោច្ឆកៈដ៏សេស បណ្ឌិតគប្បីជ្រាបដោយឧបាយនេះចុះ ។

ក្នុងនិទ្ទេសនៃ**អាសវទុកៈ**ថា "**យត្ថ ទ្វេ តយោ អាសវា ឯកតោ ឧប្បជ្ជន្តិ** = អាសវៈ ២-៣ យ៉ាង កើតរួមគ្នាក្នុងចិត្តុប្បាទណា" នេះ បណ្ឌិតគប្បី

ជ្រាបថា សេចក្តីកើតឡើងនៃអាសវៈរួមគ្នា ៣ យ៉ាង ។

បណ្តាអាសវៈទាំងនោះ កាមាសវៈរមែងកើតរួមគ្នាដោយប្រការ ២ យ៉ាង គឺកើតឡើងក្នុងទិដ្ឋិវិប្បយុត្ត ៤ ដួង រួមនឹងអវិជ្ជាសវៈ កើតឡើងក្នុងទិដ្ឋិសម្បយុត្ត ៤ ដួងព្រមទាំងទិដ្ឋាសវៈ និងអវិជ្ជាសវៈ; ចំណែកភវាសវៈ រមែងកើតរួមគ្នាតែម្យ៉ាង គឺកើតក្នុងទិដ្ឋិវិប្បយុត្ត ៤ ព្រមទាំងអវិជ្ជាសវៈ ។

ក៏ក្នុងពាក្យថា **អាសវៈ ២_៣ យ៉ាង** កើតឡើងរួមគ្នានេះ យ៉ាងណា, សូម្បីក្នុងពាក្យថា **“សញ្ញោជនៈ** ២-៣ កើតរួមគ្នាក្នុងចិត្តុប្បាទណា” នេះ ក៏យ៉ាងនោះដែរ គឺការកើតឡើងរបស់សញ្ញោជនៈទាំងឡាយរួមគ្នា មាន ១០ យ៉ាង ។

បណ្តាសញ្ញោជនៈទាំងនោះ កាមរាគសញ្ញោជនៈរមែងកើតរួមគ្នា ៤ យ៉ាង, បដិឃៈរមែងកើតរួមគ្នា ៣ យ៉ាង, មានះរមែងកើតរួមគ្នាតែម្យ៉ាង, វិចិកិច្ឆា និងភវរាគៈ ក៏កើតរួមគ្នាតែម្យ៉ាងៗ ដូចគ្នា; ខនេះតើយ៉ាងណា ? កាមរាគសញ្ញោជនៈកើតរួមគ្នា ៤ យ៉ាង គឺកើតរួមគ្នាជាមួយមានសញ្ញោជនៈ និងអវិជ្ជាសញ្ញោជនៈ១, កើតរួមគ្នាជាមួយទិដ្ឋិសញ្ញោជនៈ និងអវិជ្ជាសញ្ញោជនៈ ១, កើតរួមគ្នាជាមួយសីលព្វតបរាមាសៈ និងអវិជ្ជាសញ្ញោជនៈ ១, កើតរួមគ្នាជាមួយអវិជ្ជាសញ្ញោជនៈត្រឹមតែប៉ុណ្ណេះ ១ ។

ក៏បដិឃសញ្ញោជនៈកើតរួមគ្នា ៣ យ៉ាងនេះ គឺ

-កើតរួមគ្នាដោយឥស្សាសញ្ញោជនៈ និងអវិជ្ជាសញ្ញោជនៈ ១

-កើតរួមគ្នាដោយមច្ឆរិយសញ្ញោជនៈ និងអវិជ្ជាសញ្ញោជនៈ ១

-កើតរួមគ្នាដោយអវិជ្ជាសញ្ញោជនៈត្រឹមតែមួយប៉ុណ្ណោះ ១ ។

**មានសញ្ញោជនៈ** កើតរួមជាមួយគ្នាដោយភវរាគសញ្ញោជនៈ និងអវិជ្ជា-សញ្ញោជនៈ ។ វិចិកិច្ឆាសញ្ញោជនៈក៏យ៉ាងនេះដែរ; មែនពិត វិចិកិច្ឆាសញ្ញោជនៈនោះរមែងកើតឡើងរួមគ្នាតែម្យ៉ាង គឺរួមដោយអវិជ្ជាសញ្ញោជនៈ ។ សូម្បីក្នុងភវរាគ-សញ្ញោជនៈ ក៏ន័យនេះដែរ; សញ្ញោជនៈ ២-៣ កើតរួមគ្នាក្នុងកិលេសទាំងនេះដោយប្រការដូច្នេះ ៕ ៕

## សម្តែងអំពីនីវរណគោច្ឆកនុកៈ

ព្រះតម្រាស់ណាដែលត្រាស់ទុកក្នុងគោច្ឆកៈថា **“យត្ថ ទ្វេ តីណិ នីវរ-ណានិ ឯកតោ ឧប្បជ្ជន្តិ** = នីវរណៈ ២-៣ កើតរួមគ្នាក្នុងចិត្តុប្បាទណា” , សូម្បីក្នុងព្រះតម្រាស់នោះ បណ្ឌិតក៏គប្បីជ្រាបការកើតរួមគ្នានៃនីវរណៈទាំងឡាយមាន ៨ យ៉ាង ។

មែនពិត បណ្តានីវរណៈទាំងនោះ កាមច្ឆន្ទៈកើតរួមគ្នា ២ យ៉ាង, ព្យាបាទកើតរួមគ្នា ៤ យ៉ាង, ឧទ្ធច្ចៈកើតរួមគ្នាតែម្យ៉ាង, វិចិកិច្ឆាក៏កើតរួមគ្នាតែម្យ៉ាងដែរ; ខនេះ តើយ៉ាងណា ? គឺកាមច្ឆន្ទៈ រមែងកើតរួមគ្នា ២ យ៉ាង គឺកើតរួមគ្នាដោយឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈក្នុងអសង្ខារិកចិត្តមួយ, កើតរួមគ្នាដោយថីននីវរណៈ

មិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ ក្នុងសសង្ខារិកចិត្តមួយ ។ ក៏ពាក្យណា ដែលត្រាស់ថា "នីវរណៈកើតរួមគ្នា ២-៣" ដូច្នេះនោះ, ពាក្យនោះ ខ្ញុំពោលដោយការកំណត់ទុកខាងដើមហើយ; ព្រោះហេតុដូច្នោះ ការកើតរួមគ្នានៃនីវរណៈសូម្បីទាំង ៤ ក៏រមែងត្រឹមត្រូវមែនពិត ។

ចំណែកព្យាបាទកើតរួមគ្នា ៤ យ៉ាង គឺ

កើតរួមគ្នានឹងឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈក្នុងអសង្ខារិកចិត្ត ១ កើតរួមគ្នាដោយថីននីវរណៈ មិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ និងអវិជ្ជានីវរណៈ ក្នុងសសង្ខារិកចិត្ត ១។

កើតរួមគ្នាដោយឧទ្ធច្ចនីវរណៈ កុក្កុច្ចនីវរណៈ និងអវិជ្ជានីវរណៈ ក្នុងសសង្ខារិកចិត្ត ១ ។

កើតរួមគ្នាដោយថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈ កុក្កុច្ចនីវរណៈ និងអវិជ្ជា-នីវរណៈ ក្នុងសសង្ខារិកចិត្ត ១ ។

ចំណែកឧទ្ធច្ចនីវរណៈកើតរួមគ្នាមានតែម្យ៉ាង គឺកើតរួមដោយអវិជ្ជានីវរណៈត្រឹមតែមួយ; វិចិកិច្ឆាក៏កើតរួមគ្នាតែម្យ៉ាង គឺកើតដោយឧទ្ធច្ចនីវរណៈ និងអវិជ្ជា-នីវរណៈ៕ ៕

# សម្តែងអំពីកិលេសគោច្ឆកនុកៈ

សូម្បីព្រះតម្រាស់ឯណា ដែលត្រាស់ទុកក្នុងកិលេសគោច្ឆកៈថា **“យត្ថ ទ្វេ តយោ កិលេសា ឯកតោ ឧប្បជ្ជន្តិ** = កិលេស ២-៣ យ៉ាង កើតរួមគ្នាក្នុងចិត្តុប្បាទណា” ។ ក្នុងព្រះបាលីនោះ បណ្ឌិតគប្បីជ្រាបសេចក្ដីយ៉ាងនេះថា “កិលេស ២-៣ យ៉ាង កើតរួមគ្នាដោយកិលេសដទៃ ឬកិលេស ៣ យ៉ាង កើតរួមគ្នាដោយកិលេសដទៃ” ; ព្រោះហេតុអ្វី ? ព្រោះមានកិលេស ២ ឬ ៣ យ៉ាង កើតរួមគ្នា; ក្នុងព្រះបាលីនោះ ការកើតឡើងរួមគ្នានៃកិលេសមាន ១០ យ៉ាង ។

មែនពិត ក្នុងបណ្ដាកិលេសទាំង ១០ នោះ លោភកិលេសរមែងកើតឡើងរួមគ្នា ៦ យ៉ាង; បដិឃកិលេសកើតរួមគ្នា ២ យ៉ាង, មោហកិលេស ក៏គប្បីជ្រាបថាកើតរួមគ្នា ២ យ៉ាងដែរ ។ គប្បីជ្រាបយ៉ាងណា ? គឺលោភៈកើតរួមគ្នា ៦ យ៉ាង បានដល់កើតរួមគ្នាដោយមោហៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ក្នុងអសង្ខារិកទិដ្ឋិវិប្បយុត្តចិត្ត ១, កើតរួមគ្នាដោយមោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ ក្នុងសសង្ខារិកទិដ្ឋិវិប្បយុត្តចិត្ត ១, កើតរួមគ្នាដោយមោហៈ មានះ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ ក្នុងអសង្ខារិកចិត្តប៉ុណ្ណោះ ១, កើតរួមគ្នាដោយមោហៈ មានះ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ ក្នុងសសង្ខារិកចិត្តប៉ុណ្ណោះ ១,ម្យ៉ាងទៀត កើតរួមគ្នាដោយមោហៈ ឧទ្ធច្ចៈ ទិដ្ឋិ អហិរិកៈ និងអនោត្តប្បៈ ក្នុងអសង្ខារិកដែលសម្បយុត្តដោយទិដ្ឋិ ១, កើតរួមគ្នាដោយមោហៈ ទិដ្ឋិ ថីនៈ មិទ្ធៈ

ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ ក្នុងសសង្ខារិកចិត្ត ប្រកបដោយទិដ្ឋិ ១។

ចំណែកបដិឃៈកើតរួមគ្នា ២ យ៉ាងនេះ គឺកើតរួមគ្នាដោយមោហៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ ក្នុងអសង្ខារិកចិត្ត ១, កើតរួមគ្នាដោយមោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ ក្នុងសសង្ខារិកចិត្ត ១ ។

ចំណែកមោហៈកើតរួមគ្នា ២ យ៉ាង គឺកើតព្រមដោយវិចិកិច្ឆា ឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈ ក្នុងចិត្តដែលសម្បយុត្តដោយវិចិកិច្ឆា ១, កើតព្រមដោយឧទ្ធច្ចៈ អហិរិកៈ និងអនោត្តប្បៈក្នុងចិត្តដែលសម្បយុត្តដោយឧទ្ធច្ចៈ ១ ។ ពាក្យដ៏សេស ក្នុងទីទាំងពួង មានសេចក្ដីអណ្ដែតឡើងទាំងអស់ដែរ ៕ ៕

## អដ្ឋកថាកណ្ឌ ធម្មសង្គណី
## ឈ្មោះអដ្ឋសាលិនី
## ចប់

## និគមកថា

ក៏ដោយពាក្យមានប្រមាណប៉ុណ្ណេះ ៖

ព្រះលោកនាថ កាលនឹងទ្រង់ចែកចិត្តុប្បាទកណ្ឌ, រូបកណ្ឌ, និក្ខេប-កណ្ឌ និងអត្ថុទ្ធារកណ្ឌ ដ៏គួរឱ្យមនោរម្យ (រីករាយចិត្ត) ទើបទ្រង់សម្ដែងព្រះធម្មសង្គណីណា; កាលពណ៌នាសេចក្ដីនៃព្រះអភិធម្មសង្គណី ដែលបានទ្រង់

រូបរួមធម៌ដោយសព្វគ្រប់នៃ ព្រះអភិធម្មបិដក ដែលទ្រង់តាំងទុកហើយនោះ, ខ្ញុំបានផ្ដើមហើយ; ការពណ៌នាសេចក្ដីនេះឯង ចូលដល់ការសម្រេចហើយដោយឈ្មោះថា អដ្ឋសាលិនី ព្រោះមានសេចក្ដីមិនច្របូកច្របល់ ដោយព្រះបាលី ៣៩ ភាណវារៈ ដើម្បីសេចក្ដីតាំងនៅមាំនៃព្រះសទ្ធម្ម ។

កុសលឯណា ដែលខ្ញុំបានញ៉ាំងអត្ថវណ្ណនា ឱ្យចប់រួចស្រេចហើយនោះ, ដោយអានុភាពនៃកុសលនោះ សូមសព្វសត្វសូម្បីទាំងអស់ចូរដឹងនូវព្រះធម៌របស់ព្រះធម្មរាជា ដែលនាំមកនូវសេចក្ដីសុខ, ចូរពន្ទុះសន្តិសុខគឺព្រះនិព្វានដ៏កំពូល, មិនមានសេចក្ដីសោក, មិនមានការចង្អៀតចង្អល់ចិត្តដោយឧបដិបត្តិដ៏បរិសុទ្ធបានដោយងាយចុះ ។

សូមព្រះសទ្ធម្មតាំងនៅអស់កាលដ៏យូរ, សូមពពួកសត្វសូម្បីទាំងអស់គោរពនូវព្រះធម៌, សូមភ្លៀងធ្លាក់ត្រូវតាមរដូវកាល; ព្រះរាជាពីបុរាណទ្រទ្រង់គុណធម៌ដ៏ល្អ ទ្រង់គ្រប់គ្រងប្រជាជនដោយធម៌ឯណា, សូមព្រះរាជាបច្ចុប្បន្នទ្រង់គ្រប់គ្រងប្រជាជនដោយធម៌ ដូចជាព្រះឱរសរបស់ព្រះអង្គដែរ ។

អដ្ឋកថានៃធម្មសង្គណីឈ្មោះ **អដ្ឋសាលិនី** នេះ ដែលព្រះថេរៈអ្នកមាននាម

ដែលគ្រូទាំងឡាយតាំង* ឈ្មោះហើយថា **"ពុទ្ធឃោសៈ"** ដូច្នេះ អ្នកប្រដាប់ដោយសទ្ធា បញ្ញា និងវីរិយៈដ៏វិសុទ្ធិយ៉ាងក្រៃលែង, អ្នកញ៉ាំងពួកនៃគុណមានសីលអាចារៈ សេចក្ដីស្មោះត្រង់ និងសេចក្ដីទន់ភ្លន់ជាដើម ឱ្យតាំងឡើងហើយ, អ្នកអាចស្ទង់ (ស្ទង់) ចុះកាន់ជជះ (ការវិនិច្ឆ័យខសេចក្ដីដែលស្មុគស្មាញ) ក្នុងសេចក្ដីផ្សេងគ្នានៃលទ្ធិរបស់ខ្លួន និងរបស់មនុស្សដទៃ, អ្នកប្រកបដោយសេចក្ដីប្រតិពលដោយបញ្ញា, អ្នកមានប្រីជាញាណ (បញ្ញា) ដែលមិនទើសទាក់ក្នុងសត្ថុសាសន៍ ផ្សេងដោយបរិយត្តិ គឺព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា អ្នកជាមហាវេយ្យាករណ៍, អ្នកអធិប្បាយសេចក្ដីយ៉ាងទូលំទូលាយ, អ្នកប្រកបដោយពាក្យពេចន៍ ដ៏ពីរោះឯកដែលបញ្ចេញទៅបានយ៉ាងស្ទាត់ជំនាញ ដែលកើតពីករណសម្បត្តិ, ជាអ្នកពោលថ្នាក់ខ្ពស់ (វាគ្មិន) ដោយទាំងចង (សួរ) ទាំងស្រាយ (ឆ្លើយ), **ជាមហាកវី**, ជាអលង្ការនៃថេរវង្ស* ខាងមហាវិហារដែលជាប្រទីបនៃវង្សរបស់ព្រះថេរៈ អ្នកមានចំណេះដឹងដែលតាំងមាំល្អហើយ ក្នុងឧត្តរិមនុស្សធម៌ ប្រដាប់ដោយគុណ មានការ

---

* ក្នុងទីនេះពោលដល់នាមធេយ្យ (ការតាំងឈ្មោះ) ជារបស់ព្រះពុទ្ធឃោសាចារ្យ ដែលគ្រូទាំង-ឡាយ ដាក់ឱ្យមានដល់ទៅ ១៣ បទ ។

* ថេរវង្សសំដៅដល់ព្រះមហាកស្សបត្ថេរជាដើម និងពាក្យថា អ្នកមានការដឹងដែលតាំងមាំល្អហើយក្នុងឧត្តរិមនុស្សធម្ម ១០ ប្រដាប់ដោយគុណមានការបែកធ្លាយក្នុងអភិញ្ញា៦ ជាដើម មានបដិសម្ភិទាដែលបែកធ្លាយល្អហើយជាបរិវារ ទាំងនេះជាគុណរបស់ព្រះមហាកស្សបត្ថេរជាដើម ។

បែកធ្លាយ ក្នុងអភិញ្ញា ៦ ជាដើម, មានបដិសម្ភិទាដែលបែកធ្លាយហើយជាបរិវារ; ជាអ្នកមានសេចក្ដីដឹងវិបុល (ទូលំទូលាយ) និងបរិសុទ្ធវិសេសហើយរចនាទុក ។

អយំ អដ្ឋសាលិនី នាម ធម្មសង្គហដ្ឋកថា ៖
តាវ តិដ្ឋតុ លោកស្មឹ លោកនិដ្ឋរណេសិនំ
ទស្សេន្តី កុលបុត្តានំ នយំ បញ្ញាវិសុទ្ធិយា.
យាវ "ពុទ្ធោ"តិ នាមម្បិ សុទ្ធចិត្តស្ស តាទិនោ
លោកម្ហិ លោកជេដ្ឋស្ស បវត្តតិ មហេសិនោ

សូមអដ្ឋកថា ធម្មសង្គណី ឈ្មោះអដ្ឋសាលិនីនេះ ៖

ដែលសម្ដែងន័យរបស់បញ្ញាវិសុទ្ធិ ដល់កុលបុត្តទាំងឡាយអ្នកស្វែងរកធម៌ជាគ្រឿងរលាស់ចេញចាកលោក, ចូរតាំងនៅក្នុងលោក ដរាបដល់មានព្រះនាមថា "ពុទ្ធោ" ដូច្នេះ របស់ព្រះលោកជេដ្ឋ, ព្រះអង្គជាព្រះមហាឥសី, មានព្រះទ័យបរិសុទ្ធ, មាំទាំ នៅប្រព្រឹត្តទៅក្នុងលោកចុះ ។

**អដ្ឋសាលិនី**

**អដ្ឋកថាព្រះអភិធម្មបិដក**

**ឈ្មោះ ធម្មសង្គណី**

**បឋមភាគ ៤**

ចប់